**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**

UNIVERSITE ROYALE DE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញ ២០២៣ - ២០២៤

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ទេព និនរស្មី**

ព្រះតេជគុណ **ចន់ វិបុល**

សាស្រ្តាចារ្យណែនាំ

សាស្រ្តាចារ្យ បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

អាត្មាភាព **ចន់ ចិបុល** និងខ្ញុំបាទ **ទេព និនរស្មី** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកត្តញ្ញូតាធម៌ និងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

យើងខ្ញុំ សូមធ្វើការដឹងគុណ ចំពោះលោកអ្នកមានគុណទាំងពីរមានមាតាបិតា ដែលបានផ្តល់កំណើត ចិញ្ចឹមបីបមថ្នមរក្សា និងផ្តល់នូវសេចក្តីស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌មកដល់រូបយើងខ្ញុំ។ លោកទាំងពីរជាកត្តាចម្បងដែលជំរុញយើងខ្ញុំទាំងពីរអង្គនាក់ឱ្យមកដល់ចំណុចនេះ ការអប់រំទូន្មានរបស់លោកទាំងពីរមានគុណតម្លៃយ៉ាងជ្រាលជ្រៅមកលើរូបយើងខ្ញុំ។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម បណ្ឌិត **លុយ ចន្ណា** ដែលជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងគណៈគ្រប់គ្រងទាំងអស់ ដែលបានខិតខំ ប្រឹងប្រែង ជ្រោមជ្រែង កិច្ចការនានា និងលើកទឹកចិត្តដល់ក្រុមយើងខ្ញុំ។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ បណ្ឌិត **ឈុន ណារ៉េត** ដែលជាសាស្ត្រាចារ្យដឹកនាំកិច្ចការស្រាវជ្រាវមួយនេះ។ លោកបានផ្តល់ឱកាស និងចំណាយពេលវេលាយ៉ាងមានតម្លៃរបស់លោកដើម្បីធ្វើការចែករំលែក បង្ហាត់បង្រៀន និងណែនាំដល់យើងខ្ញុំក្នុងកិច្ចការសារណាមួយនេះ។

យើងខ្ញុំ សូមថ្លែងអំណរគុណជូនជាពិសេសចំពោះ ឯកឧត្តម **ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងមន្ត្រីនៃសាលារាជធានីភ្នំពេញទាំងអស់ ដែលបានចូលរួមសហការក្នុងការផ្តល់ព័ត៌មាន បទសម្ភាស និងចែករំលែកនូវចំណេះដឹងនានា ដែលព័ត៌មានទាំងនោះបានដើរតួយ៉ាងសំខាន់នៅក្នុងកិច្ចការនេះ។

យើងខ្ញុំ សូមថ្លែងអំណរគុណជូន ប្រជាពលរដ្ឋរួមមាននិស្សិត អាជីវករ និងប្រជាពលរដ្ឋផ្សេងៗទៀតដែលបានចាប់អារម្មណ៍ នឹងរួមចំណែកនៅក្នុងការសិក្សាស្រាវជ្រាវមួយនេះ ប្រកបដោយគុណភាព។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះ លោកគ្រូ អ្នកគ្រូ សិស្សច្បង និងមិត្តរួមថ្នាក់ដទៃទៀតដែលបានរួមចំណែកក្នុងការផ្តល់យោបល់ លើកទឹកចិត្ត និងចែករំលែកនូវបទពិសោធន៍ដល់យើងខ្ញុំ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរអង្គនាក់ សូមជូនពរលោកអ្នកមានគុណ លោកសាស្ត្រាចារ្យ គណៈគ្រប់គ្រង និងមិត្តទាំងអស់ឱ្យមានកម្លាំងពលរឹងមាំ បញ្ញាវាងវៃ សុខមាលភាពល្អបរិបូរណ៍ និងជៀសឆ្ងាយពីរោគពាធផ្សេងៗ ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខ ពល សិរីវឌ្ឍនៈចូលកើតមានកុំបីអាក់ខានឡើយ។

# អារម្ភកថា

បន្ទាប់ពីយើងខ្ញុំទទួលបានការបណ្តុះបណ្តាលរយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក យើងខ្ញុំទាំងពីរអង្គអ្នកបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលស្តីពី "**ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញ ២០២៣-២០២៤**" មកធ្វើការសិក្សាស្រាវជ្រាវ ក្រោមការដឹកនាំរបស់លោកសាស្ត្រាចារ្យ បណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំ ដើម្បីយកមកធ្វើជាសារណាបញ្ចប់ការសិក្សា និងជាឯកសារសម្រាប់ចែករំលែកដល់និស្សិត និងជនដទៃទៀតសម្រាប់យកទៅសិក្សា។

មូលហេតុចម្បងដែលជំរុញឱ្យយើងខ្ញុំទាំងពីរអង្គនាក់ជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារសម្រាប់បញ្ចប់ការសិក្សាផ្នែករដ្ឋបាលសាធារណៈនេះមានពីរសំខាន់ៗ។ ទីមួយ គឺដើម្បីបំពេញនូវចន្លោះខ្វះខាតនៃចំណេះដឹងរបស់យើងខ្ញុំទាក់ទងនឹងប្រធានបទខាងលើនេះ ដោយយើងបានយល់ឃើញពីសារៈសំខាន់នៃកិច្ចការមួយនេះនៅក្នុងអភិវឌ្ឍណ៍ប្រទេសជាតិ និងការស្វែងយល់ពីស្ថានភាពសង្គមជាក់ស្តែង។ ចំណុចទីពីរ គឺយើងចង់បង្កើតស្នាដៃមួយដែលអាចនឹងផ្តល់ផលប្រយោជន៍ដល់សិស្សានុសិស្ស និងអ្នកអានផ្សេងទៀត ដែលពួកគេអាចយកទៅប្រើប្រាស់ទៅតាមតម្រូវការ និងជាកោសិកាក្នុងការបណ្តុះគំនិតស្នេហាជាតិ។ ដូចនេះការសិក្សា និងការយល់ដឹងមួយនេះមានសារៈសំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជា និងជាពិសេសសម្រាប់និស្សិតរដ្ឋបាលសាធារណៈ។

នៅក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវកិច្ចការមួយនេះ យើងខ្ញុំទាំងពីរអង្គអ្នកបានធ្វើការចាប់ផ្តើមមូលដ្ឋាននៃការសិក្សាស្រាវជ្រាវដោយការសិក្សាស្វែងរកប្រភពឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីបង្កើតនូវចំណេះដឹងមូលដ្ឋាន ដែលឯកសារទាំងអស់នោះរួមមាន ប្រភពឯកសារលិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាល ការចុះផ្សាយនៃសារព័ត៌មានរបស់ស្ថាប័នពាក់ព័ន្ធ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។ ក្រៅពីនេះយើងខ្ញុំ ក៏បានចុះទៅធ្វើការសិក្សាស្រាវជ្រាវផ្ទាល់នៅសាលារាជធានីភ្នំពេញ ដើម្បីប្រមូលទិន្នន័យទាំងអស់នេះ គឺធ្វើក្នុងគោលបំណងឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងនៃដំណើរការរដ្ឋបាលថ្នាក់ក្រោមជាតិ។ យើងក៏បានធ្វើការស្ទង់មតិពីប្រជាពលរដ្ឋ ដែលរស់នៅក្នុងរាជធានីភ្នំពេញផងដែរ ដើម្បីស្រង់យកការយល់ដឹង និងចំណាប់អារម្មណ៍របស់ពួកគេចំពោះកិច្ចគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ។ ព័ត៌មានទាំងនេះ វានឹងឆ្លុះបញ្ចាំងអំពី ស្ថានភាពសង្គមនៅរាជធានីភ្នំពេញ រួមមានការយល់ដឹងរបស់ប្រជាពលរដ្ឋ ស្ថានភាពកិច្ចការអភិវឌ្ឍន៍ រចនាសម្ព័ន្ធ និងដំណើរការនៃកិច្ចការងាររបស់មន្ត្រី។

យើងខ្ញុំទាំងពីរអង្គនាក់សង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងក្លាយទៅជាអត្ថបទ ឬឯកសារមួយដែលមានសារៈប្រយោជន៍សម្រាប់មិត្ត និស្សិត និងបញ្ញាវន្តផ្សេងទៀត ដែលមានចំណាប់អារម្មណ៍ចង់សិក្សាស្វែងយល់បន្ថែមអំពីប្រធានបទមួយនេះ។ ក្រៅពីនេះ វាក៏អាចប្រើប្រាស់សម្រាប់ធ្វើជាមូលដ្ឋាននៃការសិក្សាស្រាវជ្រាវផ្សេងៗទៀតរបស់និស្សិត និងអាចធ្វើការសិក្សាស្រាវជ្រាវបន្តនាពេលអនាគត ដើម្បីធ្វើការប្រៀបធៀបការប្រែប្រួលរបស់ប្រទេសកម្ពុជានាពេលខាងមុខ។ យើងខ្ញុំទាំងពីរអង្គនាក់ក៏សង្ឃឹមទៀតថា ឯកសារសារណាមួយនេះ នឹងក្លាយទៅជាចំណែកមួយ ដែលជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការរីកចម្រើនកាន់តែប្រសើរឡើង។

ជាអាវសានកថា បើទោះបីជាយើងខ្ញុំបានខិតខំធ្វើការសិក្សាស្រាវជ្រាវ និងត្រួតពិនិត្យទៅលើកិច្ចការមួយនេះយ៉ាងណាក៏ដោយ ក៏ការសរសេរសារណាមួយនេះនៅតែអាចមានចំណុចខ្វះខាតកើតមានឡើង។ ដូចនេះយើងទាំងពីរអង្គអ្នក សូមធ្វើការសុំអភ័យទោសជាមុនចំពោះចំណុចខ្វះខាតទាំងនោះ ហើយយើងខ្ញុំទាំងពីរអង្គនាក់ នឹងរីករាយជានិច្ចក្នុងការទទួលយកនូវការណែនាំ និងការទិតៀន ពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិត និងអ្នកអានទាំងអស់ ដើម្បីកែលម្អសារណាមួយនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរបន្ថែមទៀត។

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ..........

**អារម្ភកថា** ..........

**បញ្ជីរាយនាមរូបភាព** .......... iv

**បញ្ជីរាយនាមក្រាហ្វិក** .......... v

**បញ្ជីរាយនាមតារាង** .......... vi

**សេចក្តីផ្តើម** .......... ១

១. លំនាំបញ្ហា .......... ១

២. ចំណោទបញ្ហា .......... ២

៣. គោលបំណងនៃការសិក្សា .......... ៤

៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សា .......... ៤

៥. សារៈសំខាន់នៃការស្រាវជ្រាវ .......... ៥

៦. វិធីសាស្ត្រស្រាវជ្រាវ .......... ៥

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ .......... ៦

**ជំពូកទី១ សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា** .......... ៩

១.១. ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា .......... ៩

១.១.១. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ .......... ១០

១.១.២. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា .......... ១៦

១.១.៣. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យរដ្ឋកម្ពុជា .......... ១៩

១.១.៤. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ .......... ២២

១.២. ប្រព័ន្ធរៀបចំ គ្រប់គ្រងរដ្ឋបាលនៅកម្ពុជា .......... ៣១

១.២.១. ប្រព័ន្ធមជ្ឈការ .......... ៣១

១.២.២. ប្រព័ន្ធវិមជ្ឈការ .......... ៣៣

១.២.៣. ប្រព័ន្ធវិសហមជ្ឈការ .......... ៣៦

១.២.៤. សហគ្គិភាពរវាងវិមជ្ឈការ និងវិសហមជ្ឈការ .......... ៣៧

១.៣. ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា .......... ៣៨

១.៣.១. ក្របខណ្ឌគតិយុត្ត .......... ៣៨

១.៣.២. មូលហេតុនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៣៩
១.៣.៣. គោលដៅនៃកំណែទម្រង់រដ្ឋបាល ........ ៤០
១.៣.៤. គំនូសប្រៀបធៀបការរៀបចំរដ្ឋបាលដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា ........ ៤០
**ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ** ........ ៤២
២.១. ទិដ្ឋភាពទូទៅរបស់រាជធានីភ្នំពេញ ........ ៤២
២.១.១. ភូមិសាស្ត្រ ........ ៤២
២.១.២. អាកាសធាតុ ........ ៤៣
២.១.៣. ផ្ទៃដី និងប្រជាជន ........ ៤៣
២.១.៤. សេដ្ឋកិច្ច ........ ៤៤
២.២. ការរៀបចំសាលារាជធានីភ្នំពេញ ........ ៤៤
២.២.១. រចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ ........ ៤៥
២.២.២. សេវាសាធារណៈ ........ ៤៧
២.២.៣. ការផ្តល់ព័ត៌មានរបស់សាលារាជធានីភ្នំពេញ ........ ៤៨
២.៣. តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់សាលារាជធានីភ្នំពេញ ........ ៤៩
២.៣.១. ក្រុមប្រឹក្សារាជធានីភ្នំពេញ ........ ៤៩
២.៣.២. គណៈអភិបាលរាជធានីភ្នំពេញ ........ ៥៥
២.៣.៣. គណៈកម្មាធិការនានារបស់សាលារាជធានីភ្នំពេញ ........ ៦៣
២.៣.៤. នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ........ ៧៤
២.៣.៥. ទីចាត់ការ និងការិយាល័យចំណុះ ........ ៧៨
២.៤. ទំនាក់ទំនងកិច្ចការនានារបស់សាលារាជធានីភ្នំពេញ ........ ១០២
២.៤.១. ទំនាក់ទំនងកិច្ចការរវាងក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី ........ ១០២
២.៤.២. ទំនាក់ទំនងកិច្ចការរវាងរដ្ឋបាលរាជធានី និងរដ្ឋបាលខណ្ឌ ........ ១០៣
២.៤.៣. ទំនាក់ទំនងកិច្ចការរវាងរដ្ឋបាលរាជធានី និងរដ្ឋបាលសង្កាត់ ........ ១០៤
២.៤.៤. ទំនាក់ទំនងកិច្ចការរវាងរដ្ឋបាលរាជធានី និងក្រសួង ស្ថាប័ននានា ........ ១០៦
**ជំពូកទី៣ សមិទ្ធផលរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០២៣-២០២៤** ........ ១០៨
៣.១. សកម្មភាពរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០២៣-២០២៤ ........ ១០៨
៣.១.១. ការគ្រប់គ្រងសេវាសាធារណៈ(សេវារដ្ឋបាល) ........ ១០៨
៣.១.២. ការគ្រប់គ្រងធនធានមនុស្ស ........ ១១០

៣.១.៣. ការគ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពសាធារណៈ ...................................................... ១១២
៣.១.៤. ការគ្រប់គ្រងរៀបចំក្រុង (រាជធានីភ្នំពេញ) ................................................................ ១១៤
៣.១.៥. ការគ្រប់គ្រងចរាចរណ៍ ................................................................................ ១១៦
៣.២. បញ្ហាប្រឈម ................................................................................................ ១១៨
៣.២.១. កត្តាប្រជាពលរដ្ឋ ................................................................................... ១១៨
៣.២.២. កត្តាធនធានមនុស្ស ................................................................................. ១២១
**ជំពូកទី៤ របកគំហើញនៃការសិក្សា** ................................................................ ១២៤
៤.១. គម្លាតអន្តរកម្មរវាងរដ្ឋបាលរាជធានីភ្នំពេញ និងប្រជាពលរដ្ឋ ......................................... ១២៤
៤.១.១. កម្រិតនៃការយល់ដឹងរបស់មន្ត្រីចំពោះប្រជាពលរដ្ឋ ......................................................១២៤
៤.១.២. កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះមន្ត្រី ..................................................... ១៣០
៤.២. ប្រសិទ្ធភាពនៃសេវាសាធារណៈ ................................................................... ១៣៥
៤.២.១. ការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈ ................................................ ១៣៦
៤.២.២. ស្ថានភាពនៃសេវាសាធារណៈតាមលក្ខខណ្ឌអន្តរកម្ម .................................................. ១៣៧
៤.៣. ការវាយតម្លៃទៅលើការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ ............................................... ១៣៩
**សេចក្តីសន្និដ្ឋាន** .......................................................................................... ១៤៤
**អនុសាសន៍** ............................................................................................... ១៤៧
**ឯកសារយោង** ............................................................................................. ១៤៩
**ឧបសម្ព័ន្ធ** ................................................................................................ ១៥៨

# បញ្ជីរាយនាមរូបភាព

**រូបភាពទី១៖** ភូមិភាគ និងតំបន់នៅសម័យកម្ពុជាប្រជាធិបតេយ្យ

**រូបភាពទី២៖** ទង់ជាតិរបស់ប្រទេសកម្ពុជានៅសម័យកាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា

**រូបភាពទី៣៖** ទង់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា(ទី២)

**រូបភាពទី៤៖** គំរូរដ្ឋបាលបែបប្រព័ន្ធមជ្ឈការ

**រូបភាពទី៥៖** គំរូរដ្ឋបាលបែបប្រព័ន្ធវិមជ្ឈការ

**រូបភាពទី៦៖** គំនូសបំព្រួញអំពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**រូបភាពទី៧៖** រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ

**រូបភាពទី៨៖** ផែនទីតម្រាយផ្លូវរត់រថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ

**រូបភាពទី៩៖** គំនូសតាងអន្តរកម្មរវាងអ្នកទទួលសេវា និងអ្នកផ្តល់សេវា

# បញ្ជីរាយនាមក្រាហ្វិក

**ក្រាហ្វិកទី១៖** សូចនាករចោរកម្ម និងអំពើហិង្សានៅកម្ពុជាពីឆ្នាំ១៩៩២រហូតមកដល់២០១២

**ក្រាហ្វិកទី២៖** ការប្រៀបធៀបរវាងអាត្រាកំណើនមន្ត្រី និងប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ

**ក្រាហ្វិកទី៣៖** លទ្ធផលការវាយតម្លៃរបស់ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញទាក់ទងនឹងសារៈសំខាន់

**ក្រាហ្វិកទី៤៖** លទ្ធផលកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងប្រព័ន្ធរដ្ឋបាល

**ក្រាហ្វិកទី៥៖** លទ្ធផលកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងផែនការ យុទ្ធសាស្ត្រ និងសកម្មភាព

**ក្រាហ្វិកទី៦៖** លទ្ធផលកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាសាធារណៈ

**ក្រាហ្វិកទី៧៖** លក្ខណៈសម្បត្តិនៃការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ(២០២៤)

# បញ្ជីរាយនាមតារាង

**តារាងទី១៖** ឈ្មោះ និងកាលបរិច្ឆេទនៃសម័យកាលរបស់កម្ពុជា

**តារាងទី២៖** លទ្ធផលជំរឿនប្រជាជនឆ្នាំ២០១៩

**តារាងទី៣៖** របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវាប្រចាំឆ្នាំ២០២៣&២០២៤(ឆមាសទី១)

**តារាងទី៤៖** ចំនួនមន្ត្រីរបស់សាលារាជធានីភ្នំពេញ

**តារាងទី៥៖** តារាងរបាយការណ៍ ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០២៣

**តារាងទី៦៖** សូចនាករនៃការពង្រឹងសន្តិសុខ សុវត្ថិភាពសាធារណៈជារួម

**តារាងទី៧៖** លទ្ធផលសមាមាត្រចំនួនប្រជាពលរដ្ឋដែលមន្ត្រីម្នាក់ត្រូវមានទំនួលខុសត្រូវ

**តារាងទី៨៖** តម្រូវការរបស់ប្រជាពលរដ្ឋ និងផែនការរបស់អាជ្ញាធរមូលដ្ឋាន

**តារាងទី៩៖** សូចនាករគោលនយោបាយភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព និងគ្មានគ្រឿងញៀន

**តារាងទី១០៖** ប្រភពព័ត៌មានផ្លូវការដែលប្រជាពលរដ្ឋភាគច្រើនបានស្គាល់

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ការគ្រប់គ្រងកិច្ចរដ្ឋបាល គឺជាកិច្ចការមួយដ៏មានសារៈសំខាន់ជាទីបំផុតនៅក្នុងសង្គមមនុស្ស ឬប្រទេសនីមួយៗ ដែលកិច្ចការនេះមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងច្បាប់ និងបទបញ្ញត្តិ។ ដោយមនុស្សគ្រប់រូបរស់នៅក្រោមការគ្រប់គ្រងរបស់រដ្ឋអំណាច សកម្មភាព និងការរស់នៅប្រចាំថ្ងៃរបស់ពួកគេក៏មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងប្រព័ន្ធរដ្ឋបាលរបស់រដ្ឋាភិបាលផងដែរ។ កិច្ចការរដ្ឋបាលមានដើមកំណើតចាប់តាំងពីពេលកកើតមានសង្គមមនុស្សមកម្ល៉េះ។ ការងាររដ្ឋបាលកើតមាននៅគ្រប់ទីកន្លែងទាំងអស់ សូម្បីតែសេវាកម្មផ្សេងៗដូចជា សុខាភិបាល ការអប់រំ សំណង់ ជំនួញ ។ល។ ក៏ត្រូវតែមានការចូលរួមពីកិច្ចការរដ្ឋបាលដែរ ទើបវាអាចប្រព្រឹត្តទៅបាន។[1]

យោងតាមអ្នកនយោបាយជនជាតិអាមេរិកម្នាក់ លោក **Woodrow Wilson** រដ្ឋបាលសាធារណៈគឺជាសកម្មភាពទាំងឡាយរបស់រដ្ឋាភិបាលក្នុងការដឹកនាំរដ្ឋ ដែលវាមានលក្ខណៈជាក់លាក់ និងជាប្រព័ន្ធនៃនីតិវិធី។[2] រដ្ឋបាលសាធារណៈ គឺជាកាតាលីករមួយយ៉ាងសំខាន់ដែលរួមចំណែកក្នុងការដឹកនាំប្រទេសដូចជា ការអភិវឌ្ឍសហគមន៍ ស្ថេរភាពនៃការអភិវឌ្ឍ ការគ្រប់គ្រងបរិស្ថាន ភាពជាអ្នកដឹកនាំ សន្តិសុខជាតិ ស្ថេរភាពសង្គម និងការគ្រប់គ្រងវិបត្តិផ្សេងៗទៀត។ អាស្រ័យហេតុនេះ ទើបគ្រប់ប្រទេសទាំងអស់នៅក្នុងពិភពលោកបានយកចិត្តទុកដាក់ និងគិតគូរយ៉ាងជិតដល់ចំពោះកិច្ចការមួយនេះ។

ក្រឡេកមកមើលប្រទេសកម្ពុជាវិញ បន្ទាប់ពីបានឆ្លងកាត់នូវភ្លើងសង្គ្រាមពីអតីតកាលជាបន្តបន្ទាប់ រដ្ឋបាលសាធារណៈតែងតែទទួលបានការកែប្រែ "**កំណែទម្រង់រដ្ឋបាលសាធារណៈ**" ជាជំហាន និងដំណាក់កាល ដើម្បីធានាឱ្យបាននូវស្ថេរភាពនៃការអភិវឌ្ឍប្រទេសជាតិ។ នៅក្នុងឆ្នាំ២០១៤ ប្រទេសកម្ពុជាបានបង្កើត **គណៈកម្មាធិការជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ(គ.ក.ស)** តាមសំណើររបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលមានបេសកកម្មផ្តួចផ្តើម រៀបចំ ដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តគោលនយោបាយ យុត្តិសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈស្របតាមគោលនយោបាយ និងការតម្រង់ទិសរបស់រាជរដ្ឋាភិបាល។[3] ក្រៅពីនេះប្រទេសកម្ពុជា ក៏បានបង្កើតច្បាប់មួយចំនួនដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង

[1] Steinar Halden. "Important of Public Administration in our Society" *Global Journal of Interdisciplinary Social Sciences,* Vol.11, No.2, 2022, p. 1.
[2] Woodrow Wilson. "The Study of Administration" *Political Science Quarterly,* Vol.2, No.2, 1887, pp. 197-222.
[3] អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ.

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងកិច្ចការងាររដ្ឋបាលនៅក្នុងប្រទេសឱ្យឈានទៅរកការអភិវឌ្ឍ។ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ហើយនឹងត្រូវគ្រប់គ្រងតាមច្បាប់រៀបចំអង្គការ។ យោងតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ភ្នំពេញគឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ដែលរាជធានីត្រូវបានបែងចែកជាខណ្ឌ និងខណ្ឌបែងចែកជាសង្កាត់។[4] ចំពោះខេត្ត ត្រូវបែងចែកជាក្រុងនិងស្រុក ហើយក្រុងបែងចែកជាសង្កាត់ និងស្រុកបែងចែកជា ឃុំនិងសង្កាត់។ ចំពោះការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រទេសកម្ពុជាប្រកាន់យកគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។[5] លើសពីនេះ នៅក្នុងចក្ខុវិស័យនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ ដែលស្ថិតនៅក្រោមការដឹកនាំរបស់**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** កម្ពុជានឹងក្លាយជាប្រទេសចំណូលខ្ពស់ និងមានសេដ្ឋកិច្ចធន់រឹងមាំនៅក្នុងឆ្នាំ២០៥០។ នៅក្នុងនោះ រដ្ឋបាលសាធារណៈត្រូវបានកំណត់ថាជាស្នូលនៃយុទ្ធសាស្ត្រដ៏សំខាន់ដែលគាំទ្រ និងជំរុញដល់ការអភិវឌ្ឍប្រទេសជាតិ។[6]

ដោយសារការសង្កេតឃើញនូវសារៈសំខាន់របស់ការគ្រប់គ្រងកិច្ចការរដ្ឋបាលនៅក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិ ក្រុមយើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី "**ការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ ២០២៣-២០២៤**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារមួយ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ និងដើម្បីស្វែងយល់ឱ្យច្បាស់បន្ថែមទៀតពីដំណើរការនៃកិច្ចការងារនេះ។

## ២. ចំណោទបញ្ហា

ខណៈពេលដែលការគ្រប់គ្រងរដ្ឋបាលនៅក្នុងប្រទេសមួយគឺជា ស្នូលនៃការអភិវឌ្ឍប្រទេសឱ្យឈានទៅរកភាពរីកចម្រើននិងប្រសើរឡើង ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋគឺជាកត្តាសំខាន់ដែលកំណត់នូវប្រសិទ្ធភាព នៃផែនការគ្រប់គ្រងនិងអភិវឌ្ឍទាំងអស់នោះ។

ការចូលរួមសហការរបស់អាជ្ញាធរមូលដ្ឋានមានសារៈសំខាន់ណាស់ក្នុងការកំណត់នូវគុណភាពសេវាសាធារណៈនិង គុណភាពនៃផែនការអភិបាលកិច្ចរបស់រដ្ឋាភិបាល។ សកម្មភាពនានារបស់អាជ្ញាធរមូលដ្ឋាន

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, "*ជំពូកទី១៣ ថ្មី៖ អំពីការគ្រប់គ្រងរដ្ឋបាល*", ១៩៩៣, មាត្រា ១៤៥ថ្មី-មាត្រា ១៤៦ថ្មី.
[5] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ, "*ជំពូកទី១៖ អំពីបទប្បញ្ញត្តិទូទៅ*", ២០០៨, មាត្រា២-មាត្រា៥.
[6] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០*, ២០២៣, ទំព័រ ៣៥-៤២.

មានឥទ្ធិពលយ៉ាងខ្លាំងចំពោះការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសង្គម នេះដោយសារអាជ្ញាធរមូលដ្ឋានមានទំនាក់ទំនងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ដែលអនុញ្ញាតឱ្យការផ្សព្វផ្សាយព័ត៌មាន និងទទួលព័ត៌មានអំពីតម្រូវការរបស់ប្រជាពលរដ្ឋមានភាពឆាប់រហ័ស។[7] អាជ្ញាធរមូលដ្ឋានអាចសន្និដ្ឋានបានថា ជាភ្នាក់ងាររបស់រដ្ឋាភិបាល ដើម្បីបម្រើប្រជាពលរដ្ឋ និងជាភ្នាក់ងាររបស់ប្រជាពលរដ្ឋ ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សេងៗឱ្យរដ្ឋាភិបាលបានដឹង។ អាស្រ័យហេតុនេះហើយទើបការចូលរួមសកម្មភាពរបស់អាជ្ញាធរមូលដ្ឋានដើរតួរយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍប្រទេស។

បើទោះបីជាសកម្មភាពរបស់អាជ្ញាធរមូលដ្ឋានគឺជាកត្តាចម្បង ដែលអនុញ្ញាតដល់ការអភិវឌ្ឍប្រទេសជាតិ ការអភិវឌ្ឍនឹងមិនអាចធ្វើទៅបាននោះទេ ប្រសិនបើគ្មានការសហការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋ។[8] ប្រជាពលរដ្ឋមានឥទ្ធិពលយ៉ាងខ្លាំងដល់ការអភិវឌ្ឍនៃប្រជាជាតិមួយ ទាំងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ដែលផ្នែកទាំងពីរនេះត្រូវបានកំណត់ដោយផ្អែកលើចំណេះដឹងរបស់ប្រជាពលរដ្ឋ។ ចំណេះដឹងរបស់ប្រជាពលរដ្ឋ ទាំងចំណេះដឹងទូទៅអំពីសង្គម ការរស់នៅប្រចាំថ្ងៃ និងចំណេះដឹងបច្ចេកទេសអំពីជំនាញ បច្ចេកទេស គឺសុទ្ធតែមានចំណែកក្នុងការកំណត់នូវផលិតភាព គុណភាព និងស្ថានភាពសង្គម។ នៅពេលដែលប្រជាពលរដ្ឋមានចំណេះដឹងមានកាន់តែច្រើន ការចូលរួមនៅក្នុងសង្គមនឹងមានការកើនឡើង មិនត្រឹមតែប៉ុណ្ណោះសេដ្ឋកិច្ច សន្តិសុខសង្គម សីលធម៌សង្គម វប្បធម៌ និងកេរ្តិ៍ឈ្មោះរបស់ប្រទេសក៏នឹងមានភាពប្រសើរឡើងដែរ។[9] ដោយមើលឃើញពីសារៈសំខាន់នៃការចូលរួមនេះហើយ រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានកំណត់ "**ការចូលរួម**" ជាគោលការណ៍ទី១នៃអភិបាលកិច្ចល្អ។[10] បន្ថែមពីនេះ ការអភិវឌ្ឍសមត្ថភាព ជំនាញ និងចំណេះដឹងរបស់ប្រជាពលរដ្ឋ ក៏ជាផ្នែកមួយនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ដើម្បីធានាឱ្យបាននូវវឌ្ឍនភាពនៃប្រជាជាតិមួយនេះ។[11]

យោងតាមលំនាំបញ្ហា និងសារៈសំខាន់នៃអន្តរកម្មរបស់តួរអង្គទាំងពីរនៅក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពប្រសើរឡើង ការសិក្សាអំពី "**ការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ ២០២៣-២០២៤**" នឹងបង្ហាញឱ្យឃើញនូវស្ថានភាពជាក់ស្តែងរបស់សង្គមកម្ពុជា នៅក្នុងដំណើរការអភិវឌ្ឍ ដែលយើងនឹងផ្តោតសំខាន់

---

[7] Ishwor Thapa. "Local Government: Concept, Roles, and Importance for Contemporary Society." *Tribhuvan University*, 2020.
[8] Carmen Morosan. *The role of the local government in promoting social and economic development*. Johns Hopkins University, 1995.
[9] Ozturk Ilhan. "The role of education in economic development: a theoretical perspective" *Journal of Rural Development and Administration*, Vol.33, No.1, 2001, pp. 39-47.
[10] ក្រសួងមហាផ្ទៃ, *អភិបាលកិច្ចល្អ (បោះពុម្ពលើកទី២)*, ២០១០, ទំព័រ ៦-៧.
[11] រាជរដ្ឋាភិបាលកម្ពុជា, *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភាសម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨*, ២០២៣, ទំព័រ ៣៤-៣៦.

ទៅលើចំណុចដូចខាងក្រោម៖

- តើសាលារាជធានីភ្នំពេញគ្រប់គ្រងដោយប្រព័ន្ធអ្វី? ហេតុអ្វី?
- តើសាលារាជធានីភ្នំពេញមានសមាសភាព និងរចនាសម្ព័ន្ធដូចម្តេច?
- តើសាលារាជធានីភ្នំពេញបានសម្រេចនូវសមិទ្ធផលអ្វីខ្លះ ដើម្បីបម្រើជាប្រយោជន៍ដល់ប្រជាពលរដ្ឋ?
- តើសាលារាជធានីភ្នំពេញបានជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ និងមាននីតិវិធីដូចម្តេច ដើម្បីដោះស្រាយបញ្ហាទាំងនោះ?
- តើផែនការ និងយុទ្ធសាស្ត្ររបស់សាលារាជធានីភ្នំពេញពិតជាបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋមែនដែរឬទេ?

## ៣. គោលបំណងនៃការសិក្សា

ដោយមើលឃើញពីសារៈសំខាន់នៃរដ្ឋបាលសាធារណៈ និងការយល់ដឹងអំពីការចូលរួមរបស់អាជ្ញាធរ និងប្រជាពលរដ្ឋនៅក្នុងផែនការអភិវឌ្ឍប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវមួយនេះ មានគោលបំណងសំខាន់ៗដូចតទៅ៖

- សិក្សាស្វែងយល់អំពីការវិវត្តនៃសង្គមកម្ពុជាពីមួយសម័យកាលទៅមួយសម័យកាល
- សិក្សាស្វែងយល់អំពីប្រព័ន្ធរដ្ឋបាលនានា ដែលមានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា
- សិក្សាស្វែងយល់អំពីទិដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ និងរចនាសម្ព័ន្ធនានា
- សិក្សាស្វែងយល់អំពីតួនាទី ទំនាក់ទំនងរវាងស្ថាប័ននឹងស្ថាប័ន និងស្ថាប័ននឹងប្រជាពលរដ្ឋ
- សិក្សាស្រាវជ្រាវអំពី សមិទ្ធផល បញ្ហាប្រឈម និងទិសដៅរបស់សាលារាជធានីភ្នំពេញ
- សិក្សាអំពីតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ
- និងដើម្បីរួមចំណែកក្នុងការចែករំលែកចំណេះដឹង និងជំរុញការអភិវឌ្ឍដល់ប្រទេសកម្ពុជា។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សា

ការសិក្សាស្រាវជ្រាវមួយនេះមានដែនកំណត់ និងវិសាលភាពចំពោះ (១)ប្រព័ន្ធនៃការគ្រប់គ្រងសង្គមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ និងសាលារដ្ឋបាលរាជធានីភ្នំពេញ (២)កម្មវិធី និងផែនការសកម្មភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជាដែលបាន និងកំពុងអភិវឌ្ឍត្រឹមឆ្នាំ២០២៤ (៣)តម្រូវការ និងការយល់ឃើញរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញនៅក្នុងឆ្នាំ២០២៤ (៤)ស្ថានភាពជាក់ស្តែងនៅក្នុងសាលារាជធានីភ្នំពេញ (៥)ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលក្រសួង និងស្ថាប័នពាក់ព័ន្ធបាន

អនុម័តគិតត្រឹមឆ្នាំ២០២៤។ ម្យ៉ាងវិញទៀត ការសិក្សាមួយនេះនឹងមិនផ្តោតសំខាន់ទៅលើផ្នែកសេដ្ឋកិច្ចឡើយ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ នឹងក្លាយជាផ្នែកមួយនៃការចែករំលែកចំណេះដឹង និងការអភិវឌ្ឍនានារួមបញ្ចូលទាំងធនធានមនុស្ស និងសង្គមជាក់ស្តែង ហេតុដូចនេះវាមានសារៈសំខាន់ណាស់ចំពោះយើងខ្ញុំផ្ទាល់ យុវជនជំនាន់ក្រោយ និងសង្គមជាតិ។

ចំពោះយើងខ្ញុំ កិច្ចការមួយនេះនឹងពង្រឹង និងពង្រីកការយល់ដឹងរបស់យើងខ្ញុំទាក់ទងទៅនឹងស្ថានភាពសង្គម និងកិច្ចការងាររបស់រាជរដ្ឋាភិបាល។ បន្ថែមពីលើនេះ វានឹងបានផ្តល់ជាបទពិសោធន៍ដល់យើងខ្ញុំអំពីវិធីសាស្ត្រនៃការស្រាវជ្រាវនិងប្រមូលឯកសារ ទិន្នន័យ និងការចុះទៅស្រាវជ្រាវផ្ទាល់នៅមូលដ្ឋាន ដែលវានឹងក្លាយទៅជាមូលដ្ឋានគ្រឹះមួយដ៏សំខាន់សម្រាប់យើងខ្ញុំក្នុងការអភិវឌ្ឍខ្លួនបន្តទៅទៀតនាពេលអនាគត។ ជាពិសេស កិច្ចការដ៏មានតម្លៃមួយនេះនឹងអាចជួយឱ្យយើងខ្ញុំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានដោយជោគជ័យ។

ទន្ទឹមនឹងនេះ កិច្ចការស្រាវជ្រាវមួយនេះក៏អាចនឹងផ្តល់ផលប្រយោជន៍ទៅដល់យុវជនជំនាន់ក្រោយផងដែរ តាមរយៈការចែករំលែកជាបទពិសោធន៍ គំរូ វិធីសាស្ត្រ និងព័ត៌មានចំណេះដឹងអំពីទិដ្ឋភាពទូទៅ តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងចំណេះដឹងផ្សេងៗទៀត។ ការចែករំលែកដែលមាននៅក្នុងឯកសារមួយនេះអាចនឹងក្លាយទៅជាមូលដ្ឋានគ្រឹះមួយដល់អ្នកអាន ក៏ដូចជាយុវជនជំនាន់ក្រោយផ្សេងទៀត សម្រាប់យកទៅប្រើប្រាស់ក្នុងការសិក្សា ការអភិវឌ្ឍ ការប្រៀបធៀប និងតម្រូវការផ្សេងៗទៀត។

ចំពោះសង្គមជាតិវិញ ឯកសារមួយនេះនឹងក្លាយទៅជាទិន្នន័យ និងកំណត់ត្រាមួយដ៏មានតម្លៃសម្រាប់បង្ហាញពីបម្រែបម្រួលនៅក្នុងសង្គម ហើយវាអាចនឹងរួមចំណែកមួយនៅក្នុងការពង្រឹងលំនឹង និងស្ថេរភាពសង្គមដោយតម្លាភាពផងដែរ។ ការរួមចំណែកទៅក្នុងសង្គមមួយនេះ នឹងពង្រឹងការយល់ដឹងរបស់អ្នកអាន និងជួយបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាឱ្យមកចាប់អារម្មណ៍ និងរួមចំណែកនៅក្នុងការអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព។

អាស្រ័យហេតុនេះ យើងអាចនិយាយបានថា កិច្ចការស្រាវជ្រាវមួយនេះមានតម្លៃ និងសារៈសំខាន់ខ្លាំងណាស់ចំពោះក្រុមយើងខ្ញុំផ្ទាល់ និងសង្គមជាតិនៅក្នុងកិច្ចការអភិវឌ្ឍសង្គម និងធនធានមនុស្ស។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះ ក្រុមយើងខ្ញុំបានសម្រេចជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវចម្រុះមកអនុវត្តដែលមានប្រើបរិមាណវិធីនិងគុណវិធី ដើម្បីឆ្លុះបញ្ចាំងឱ្យបានគ្រប់ជ្រុងនៃទស្សនវិស័យ និងដើម្បីបក

ស្រាយទៅលើពហុទិដ្ឋភាពនៃសំណួរមួយចំនួន។

**ក. ក្របខណ្ឌនៃការសិក្សាស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវមួយនេះ បានកំណត់ទៅលើព័ត៌មាន និងឯកសារនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញនៅក្នុងឆ្នាំ២០២៣-២០២៤ និងការយល់ឃើញរបស់ប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ២០២៤តែប៉ុណ្ណោះ។

**ខ. ការប្រមូលទិន្នន័យ**

ដើម្បីសម្រេចនូវកិច្ចការស្រាវជ្រាវមួយនេះប្រកបដោយគុណភាពនិងប្រសិទ្ធភាព ក្រុមយើងខ្ញុំបានប្រមូលទិន្នន័យ និងបែងចែកវាជាពីរប្រភេទគឺ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។ ចំពោះទិន្នន័យចម្បងយើងខ្ញុំទទួលបានដោយផ្ទាល់ពីការចូលរួមរបស់ (១)មន្ត្រីជំនាញរបស់សាលារាជធានីភ្នំពេញ (២)ប្រជាពលរដ្ឋនៅក្នុងការស្ទង់មតិ (៣)ប្រជាពលរដ្ឋនៅក្នុងការផ្តល់បទសម្ភាស និង(៤)របាយការណ៍របស់រដ្ឋបាលសាលារាជធានីភ្នំពេញជាក់ស្តែងតែម្តង(មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ)។ សម្រាប់ទិន្នន័យបន្ទាប់បន្សំ យើងខ្ញុំទទួលបានតាមរយៈការប្រមូលផ្តុំនៅ ច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ឯកសារពាក់ព័ន្ធ កិច្ចការស្រាវជ្រាវ និងសៀវភៅផ្សេងៗដែលមានទំនាក់ទំនងនឹងប្រធានបទនេះ។

**គ. ការសំយោគទិន្នន័យ**

នៅក្នុងដំណើរការនៃការវិភាគទិន្នន័យនេះយើងខ្ញុំបានធ្វើការពិនិត្យ និងបែងចែកទិន្នន័យទៅតាមប្រភេទនីមួយៗ។ បន្ទាប់មកយើងធ្វើការវិភាគទិន្នន័យដោយប្រើប្រាស់មធ្យោបាយពីរគឺ ការសិក្សាវិភាគទៅលើចំណុចបី និងវិធីសាស្ត្រប្រៀបធៀប។ ចំពោះការសិក្សាវិភាគទៅលើចំណុចបី យើងប្រើប្រាស់ ដើម្បីពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តជាក់ស្តែងរបស់អាជ្ញាធរមូលដ្ឋាននៃសាលារាជធានីភ្នំពេញ ដើម្បីឆ្លើយតបទៅនឹងបីចំណុចសំខាន់ៗគឺ ភាពខ្លាំង កន្លែងបំពេញបន្ថែម និងការប្រឈម។ សម្រាប់វិធីសាស្ត្រប្រៀបធៀបវិញ យើងប្រើប្រាស់វា ដើម្បីឆ្លើយតប និងប្រៀបធៀបរវាងការអនុវត្តជាក់ស្តែងនឹងទ្រឹស្តីនិងច្បាប់។ បន្ថែមពីនេះ យើងក៏នឹងប្រើប្រាស់វា ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពសង្គមកម្ពុជានៅរាជធានីភ្នំពេញក្នុងឆ្នាំ២០២៤នេះផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

នៅក្នុងកិច្ចរៀបចំការសិក្សាស្រាវជ្រាវនៃប្រធានបទ "**ការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ ២០២៣-២០២៤**" នេះឱ្យមានរបៀប និងងាយយល់ យើងបានបែងចែករចនាសម្ព័ន្ធនៃកិច្ចការស្រាវជ្រាវមួយនេះដូចខាងក្រោម៖

- **សេចក្តីថ្លែងអំណរគុណ៖** យើងខ្ញុំ សម្តែងការថ្លែងអំណរគុណចំពោះលោកអ្នកមានគុណ សាស្ត្រាចារ្យណែនាំ ឯកឧត្តមសាកលវិទ្យាធិការ អាជ្ញាធរដែលចូលរួម ប្រជាពលរដ្ឋ និងអ្នកដែលរួមចំណែកផ្សេងៗទៀត។
- **អារម្ភកថា៖** យើងខ្ញុំ បរិយាយអំពី មូលហេតុដែលយើងខ្ញុំសម្រេចចិត្តធ្វើកិច្ចការមួយនេះ ចំណាប់អារម្មណ៍របស់យើងខ្ញុំចំពោះប្រធានបទ និងការរំពឹងទុករបស់យើងខ្ញុំ។
- **សេចក្តីផ្តើម៖** យើងខ្ញុំ ធ្វើការបកស្រាយចំពោះទិដ្ឋភាពទូទៅនៃកិច្ចការងាររដ្ឋបាល ដើម្បីជាគ្រឹះនៅក្នុងសិក្សាកិច្ចការមួយនេះ ដែលទិដ្ឋភាពនោះរួមបញ្ចូលពីការកកើតនៃកិច្ចការរដ្ឋបាល សារៈសំខាន់នៃរដ្ឋបាលសាធារណៈនៅក្នុងពិភពលោក និងនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីនេះយើងក៏បានលើកឡើងពីចំណោទបញ្ហា ដើម្បីផ្តួចផ្តើមជាគំនិតខ្លះអំពីកិច្ចការមួយនេះ និងបានបកស្រាយពីគោលបំណងនៃការងារស្រាវជ្រាវផងដែរ។ បន្ថែមពីនេះ យើងបានកំណត់អំពីដែនកំណត់ និងវិសាលភាពនៃកិច្ចការស្រាវជ្រាវមួយនេះ រួមទាំងសារៈសំខាន់របស់វាចំពោះយើងខ្ញុំផ្ទាល់ យុវជនដ៏ទៃទៀត និងសង្គមជាតិ។ វិធីសាស្ត្រនៅក្នុងការស្រាវជ្រាវ និងការបែងចែករចនាសម្ព័ន្ធរបស់យើងក៏ត្រូវបានកំណត់នៅក្នុងនេះផងដែរ ដើម្បីបង្ហាញពីដំណើរការនៃកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំ ។
- **ជំពូកទី១ សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលនៅក្នុងប្រទេសកម្ពុជា៖** ចំណុចនេះយើងខ្ញុំ បកស្រាយអំពី ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលនៅក្នុងប្រទេសកម្ពុជា នៅក្នុងពេលអតីតកាលរហូតមកដល់ពេលបច្ចុប្បន្ន។ បន្ទាប់មក យើងធ្វើការបកស្រាយស៊ីជម្រៅអំពីប្រព័ន្ធរដ្ឋបាលទាំងបី គឺប្រព័ន្ធមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ(សហគ្គិភាពរវាងវិមជ្ឈការ និងវិសហមជ្ឈការ) ហើយយើងនឹងបកស្រាយអំពីក្របខណ្ឌគតិយុត្តមួយចំនួនដែលទាក់ទងទៅនឹងការគ្រប់គ្រងកិច្ចការងាររដ្ឋបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។
- **ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ៖** ចំណុចនេះយើងខ្ញុំ បកស្រាយអំពីទិដ្ឋភាពទូទៅរបស់រាជធានីភ្នំពេញ សេវាសាធារណៈ និងរបៀបរបបការងាររបស់សាលារាជធានីភ្នំពេញ។ លើសពីនេះទៅទៀត យើងខ្ញុំនឹងបកស្រាយអំពីរចនាសម្ព័ន្ធ សមាសភាព តួនាទី និងសិទ្ធិអំណាចរបស់សមាសភាពនីមួយៗដែលមានចែងដោយច្បាប់ រួមទាំងទំនាក់ទំនងរវាងសាលារាជធានីភ្នំពេញ និងស្ថាប័នផ្សេងៗទៀត។
- **ជំពូកទី៣ សមិទ្ធផលរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០២៣-២០២៤៖** ចំណុចនេះយើងខ្ញុំ បកស្រាយអំពីលទ្ធផលនៃសកម្មភាពនានា ដែលសាលារាជធានីភ្នំពេញបានសម្រេចនៅក្នុងឆ្នាំ២០២៣ និងឆ្នាំ២០២៤ ដោយផ្អែកទៅលើរបាយការណ៍ និងឯកសារពាក់ព័ន្ធនានា ដើម្បីបង្ហាញពីសមិទ្ធផល ទិសដៅ

នៅពេលអនាគត និងបញ្ហាប្រឈមដែលបាននឹងកំពុងជួបប្រទះ រួមទាំងករណីនៅក្នុងពេលអនាគតផងដែរ។

- **ជំពូកទី៤ របកកំហើញនៃការសិក្សា៖** ចំណុចនេះយើងខ្ញុំ បកស្រាយអំពីការសិក្សាវិភាគ និងប្រៀបធៀបរវាងទ្រឹស្ដី ការស្រាវជ្រាវនៅតាមបណ្ដាប្រទេសមួយចំនួន មកនឹងប្រទេសកម្ពុជា។ ការសិក្សានៃជំពូកនៃគឺដើម្បីបង្ហាញពីស្ថានភាពនៃគម្លាតអន្តរកម្មរវាងអាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ ក្រៅពីនេះវាក៏មានគោលបំណងបង្ហាញពីកត្តាជះឥទ្ធិពលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ សេវាសាធារណៈ និងការវាយតម្លៃនៃការអនុវត្ត ការរៀបចំគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញផងដែរ។
- **សេចក្ដីសន្និដ្ឋាន និងអនុសាសន៍៖** ចំណុចនេះជាចំណុចចុងក្រោយបង្អស់របស់សារណាមួយនេះ ហើយយើងខ្ញុំនឹងធ្វើការសង្ខេបឡើងមកវិញខ្លឹមសារសំខាន់ៗមួយចំនួនទៅតាមចំណុច បកស្រាយពីទស្សនៈនិងក្ដីសង្ឃឹមរបស់យើងខ្ញុំ និងផ្ដល់នៅអនុសាសន៍មួយចំនួនផងដែរ

# ជំពូកទី១

# សញ្ញាណទូទៅ

# នៃ

# ការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា

# ជំពូកទី១ សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា

## ១.១. ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា

ប្រទេសកម្ពុជា បានចាប់កំណើតនៅលើដែនដីអាស៊ីអាគ្នេយ៍តាំងពីយូរលុងណាស់មកហើយ ពោលគឺតាំងពីមុនគ្រិស្តសករាជមកម្លេះ រីឯប្រព័ន្ធរដ្ឋបាលរបស់កម្ពុជាវិញក៏ចាប់មានកំណើតទន្ទឹមគ្នានឹងនេះដែរ។ គិតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានឆ្លងកាត់នៅសម័យកាលធំៗចំនួន១៦ ដែលចរិកលក្ខណៈនៃប្រព័ន្ធរដ្ឋបាល និងការគ្រប់គ្រងរបស់សម័យកាលនីមួយៗមានលក្ខណៈខុសប្លែកពីគ្នាទៅតាមបរិបទសង្គមជាក់ស្តែង។

តារាងទី១៖ ឈ្មោះ និងកាលបរិច្ឆេទនៃសម័យកាលរបស់កម្ពុជា[12]

| លេខរៀង | សម័យកាល | ឆ្នាំនៃសម័យកាល |
|---|---|---|
| ១ | បុរេប្រវត្តិ | មុនគ្រិស្តសករាជ |
| ២ | នគរភ្នំ ឬហ៊្វូណន | សតវត្សទី១-៥៥០ |
| ៣ | ចេនឡា | សតវត្សទី៦-៨០២ |
| ៤ | អង្គរ | ៨០២-១៤៣១ |
| ៥ | ចតុមុខ | ១៤៣១-១៥១៦ |
| ៦ | លង្វែក | ១៥១៦-១៦២០ |
| ៧ | ឧដុង្គ | ១៦២០-១៨៦៣ |
| ៨ | អាណានិគមនិយមបារាំង | ១៨៦៣-១៩៥៣ |
| ៩ | អាណានិគមជប៉ុន | ១៩៤១-១៩៤៥ |
| ១០ | សង្គមរាស្ត្រនិយម | ១៩៥៥-១៩៧០ |
| ១១ | សាធារណរដ្ឋខ្មែរ (លន់ នល់) | ១៩៧០-១៩៧៥ |
| ១២ | កម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) | ១៩៧៥-១៩៧៩ |
| ១៣ | សាធារណរដ្ឋប្រជាមានិតកម្ពុជា | ១៩៧៩-១៩៨៩ |
| ១៤ | រដ្ឋកម្ពុជា | ១៩៨៩-១៩៩៣ |
| ១៥ | អ៊ុនតាក់ (អង្គការសហប្រជាជាតិ) | ១៩៩២-១៩៩៣ |
| ១៦ | ព្រះរាជណាចក្រកម្ពុជា | ១៩៩៣-បច្ចុប្បន្ន |

[12] ដកស្រង់ និងកែសម្រួលមកពីៈ ងឹម ហួរ និងច្រើនរូបទៀត, *អរិយធម៌ខ្មែរ (បោះពុម្ពលើកទី៦),* វិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ២០២០, ទំព័រ ៦១-៦៨ &ស៊ន សំណាង និងច្រើនរូបទៀត, *ប្រវត្តិវិទ្យា*, ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧.

ចំពោះវិស័យរដ្ឋបាលសាធារណៈនៅកម្ពុជាវិញ គេបានកំណត់និងបែងចែកការវិវត្តនៃរដ្ឋបាលជាបីដំណាក់កាលធំៗគឺ ប្រព័ន្ធរដ្ឋបាលមុនសម័យបារាំង ប្រព័ន្ធរដ្ឋបាលនៅសម័យបារាំង និងប្រព័ន្ធរដ្ឋបាលក្រោយសម័យបារាំង។ ចំពោះប្រព័ន្ធរដ្ឋបាលមុនសម័យបារាំង ការដឹកនាំប្រទេសជាតិគឺធ្វើតាមរបបរាជានិយមដែលទាំងអំណាចនយោបាយ និងអំណាចរដ្ឋបាលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះមហាក្សត្រ នាំឱ្យការគ្រប់គ្រងរដ្ឋបាលមានលក្ខណៈមជ្ឈការ។ ច្បាប់ទម្លាប់នៅក្នុងការដឹកនាំប្រទេសជាតិភាគច្រើនដកស្រង់ចេញពីគម្ពីរវេទ និងទំនៀមទម្លាប់[13] រីឯការបែងចែកដែនដីនៃកិច្ចការរដ្ឋបាលវិញត្រូវបានកំណត់តាមរយៈការតែងតាំងរបស់ព្រះមហាក្សត្រ ដែលភាគច្រើនស្តេចត្រាញ់ទាំងនោះមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ។[14] មកដល់សម័យកាលអាណានិគមនិយមបារាំងវិញ ប្រទេសកម្ពុជាបានក្លាយខ្លួនទៅជាសហជីពឥណ្ឌូចិនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលសៃហ្គន (Saigon) ដែលដឹកនាំដោយអគ្គទេសាភិបាលបារាំងមួយរូប។ ចំពោះការគ្រប់គ្រងដែនដីតំបន់នីមួយៗមានរ៉េស៊ីដង់មួយរូបសម្រាប់ដឹកនាំ និងធ្វើគម្រោងផែនការមូលដ្ឋាន។ នៅក្នុងឆ្នាំ ១៩០១ កំណែទម្រង់ដ៏សំខាន់មួយបានកើតឡើង ដែលកំណែទម្រង់នោះបានកំណត់អំពីការបោះឆ្នោតជ្រើសរើសមេស្រុក (ក្រោយមកពាក្យមេស្រុកត្រូវបានប្តូរមកត្រឹមមេឃុំវិញ) ដើម្បីបង្កើនប្រសិទ្ធភាព និងសម្រួលដល់ការប្រមូលពន្ធឱ្យបានល្អ។[15] ក្រៅពីនេះ នៅក្នុងសម័យបារាំងកំណែទម្រង់របស់បារាំងបានលុបបំបាត់របបទាសភាព បង្កើតច្បាប់ថ្មី បង្កើតកម្មសិទ្ធិដីថ្លី និងបានជះឥទ្ធិពលមួយចំនួនដល់ប្រពៃណីវប្បធម៌។[16] ក្រោយឆ្លងកាត់សម័យកាលអាណានិគមនិយមបារាំងរួចមក ប្រព័ន្ធរដ្ឋបាលទទួលបានការកែប្រែជាបន្តបន្ទាប់ ដូចជាការផ្លាស់ប្តូររបបនយោបាយពីរបបរាជានិយម ទៅរបបកុំម្មុយនីស្ត ក្រោយមកទៅជារបបប្រជាធិបតេយ្យ និងកំណែទម្រង់ប្រព័ន្ធរដ្ឋបាលសាធារណៈផ្សេងៗទៀត ដែលមានជះឥទ្ធិពលរហូតមកដល់ពេលបច្ចុប្បន្ននេះ។

### ១.១.១. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

បន្ទាប់ពីមានការដួលរលំរបស់របបសាធារណរដ្ឋខ្មែរ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងសម័យកាលមួយទៀតគឺសម័យកម្ពុជាប្រជាធិបតេយ្យ ដែលវាស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុំម្មុយនីស្តកម្ពុជា (ប.ក.ក)។ ប.ក.ក. នេះបានចាត់តាំងខ្លួនឯងថាជា "**អង្គការបដិវត្ត**" ដែលពួកគេយល់ ឃើញថា ការលុបបំបាត់អ្វីៗទាំងអស់ គឺជាគន្លឹះក្នុងការសម្រេចឱ្យបាននៅស្វយ័តជាតិ និងយុត្តិធម៌ក្នុងសង្គម។ អង្គការបដិវត្តនេះក៏បាន

[13] ស៊ាប សារុធ &លី វ៉ាម៉ាន, *កំណែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្ន (២០១៥-២០២០)*, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០២០, ទំព័រទី១២.

[14] Michael D.Coe. *The Khmer Empire: The Oxford World History of Empire.* Oxford University Press, 2021, pp 430-449.

[15] សៅ ឡាយ, *សេចក្តីផ្តើមរដ្ឋបាលសាធារណៈ (បោះពុម្ពលើកទី២)*, ២០០៨, ទំព័រ៨-៩.

[16] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ២-៣.

រៀបចំរចនាសម្ព័ន្ធរដ្ឋបាល និងផែនការបួនឆ្នាំសម្រាប់អភិវឌ្ឍប្រទេសកម្ពុជាផងដែរ ដែលវាបាននាំមកនូវវិបត្តិជាច្រើន និងសេចក្តីវេទនាដល់ប្រជាជនខ្មែរ។

**១.១.១.១. រចនាសម្ព័ន្ធរដ្ឋបាល**

**ក. រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ**

កម្ពុជាបានបើកមហាសន្និបាតជាតិលើកទី៣នៅក្នុងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ ដែលបានសម្រេចអនុម័តនូវរដ្ឋធម្មនុញ្ញថ្មីមួយជាផ្លូវការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។ ប្រទេសកម្ពុជាត្រូវបានប្តូរឈ្មោះជាផ្លូវការថា "**កម្ពុជាប្រជាធិបតេយ្យ**" ដែលមានសភាតំណាងប្រជាជនចំនួន២៥០អាសនៈ ដែលក្នុងនោះត្រូវបានកំណត់ដូចខាងក្រោម៖

- ១៥០រូបតំណាងវណ្ណៈកសិករ
- ៥០រូបតំណាងវណ្ណៈកម្មករ និងពលករ
- ៥០រូបតំណាងកងទ័ពបដិវត្តន៍កម្ពុជា។

រដ្ឋធម្មនុញ្ញនេះពុំមានចែងអ្វីទាំងអស់អំពី បក្សកុំម្មុយនីស្តកម្ពុជា(ប.ក.ក.) ហើយរដ្ឋសភាបានបើកប្រជុំតែម្តងគត់គឺនៅខែមេសា ឆ្នាំ១៩៧៦។ ចំពោះចម្រៀងជាតិវិញត្រូវបានឱ្យឈ្មោះថា ១៧ មេសា មហាជោគជ័យ។[17]

**ខ. រចនាសម្ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋ**

អង្គការបដិវត្ត គឺជាអង្គការតែមួយគត់ដែលមានអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអង្គការនេះត្រូវបានបែងចែកដូចខាងក្រោម៖

- លោក **ខៀវ សំផន** ជាប្រធានគណៈប្រធានរដ្ឋ ឬប្រមុខរដ្ឋ
- លោក **នួន ជា** ជាប្រធានសភាតំណាងប្រជាជនកម្ពុជា
- លោក **ប៉ុល ពត** ជានាយករដ្ឋមន្ត្រី
- លោក **អៀង សារី** ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
- លោក **វន វ៉េត** ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
- លោក **សុន សេន** ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
- លោក **ចេង អន** ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

[17] ឌីខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) (បោះពុម្ពលើកទី២)*, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០១១, ទំព័រ ២៥.

ចំពោះរចនាសម្ព័ន្ធមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា(១៩៧៦-១៩៧៨)វិញ **ប៉ុល ពត** ត្រូវបានកំណត់ថាជាលេខាបក្ស និង**នួន ជា** ជាអនុលេខាបក្ស និងមានសមាជិកដូចជា៖ សោ ភឹម, អៀង សារី, សុន សេន, ឈិត ជឿន(តាម៉ុក), វន វ៉េត, កែ ពក, ញឹម រស់, ខៀវ សំផន,...។[18]

## គ. ការបែងចែកភូមិសាស្ត្ររដ្ឋបាល

នៅក្នុងឆ្នាំ១៩៧៦ បក្សកុំម្មុយនីស្តកម្ពុជាបានបែងចែកកម្ពុជាប្រជាធិបតេយ្យជា ៦ភូមិភាគ ដែលរួមមាន៣២តំបន់។ ភូមិភាគនីមួយៗកើតចេញពីការយកខេត្តពីរ ឬច្រើនមកបញ្ចូលគ្នា ឬកាត់ចេញពីខេត្តនេះខ្លះ ឬខេត្តនោះខ្លះមកបញ្ចូលគ្នា ហើយភូមិភាគទាំងអស់នោះក៏ត្រូវបានកំណត់លេខសម្គាល់ផងដែរ។ ភូមិភាគនីមួយៗត្រូវបានចែកចេញជាច្រើនតំបន់ និងតំបន់នីមួយៗត្រូវបានចែកជាស្រុក ឃុំ និងសហករណ៍។

*រូបភាពទី១៖ ភូមិភាគ និងតំបន់នៅសម័យកម្ពុជាប្រជាធិបតេយ្យ*[19]




១. **ភូមិភាគបូព៌ា** (ភូមិភាគ២០៣) ដឹកនាំដោយ សោ ភឹម ស្លាប់នៅឆ្នាំ១៩៧៨។ ភូមិភាគនេះមានចែកជាប្រាំតំបន់គឺតំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និងតំបន់២៤ ដែលវាត្រូវបានបង្កើតចេញពី

[18] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ១៦-១៧.

[19] David Chandler. *A History of Cambodia (3rd Edition).* Westview Press, 2009, pp. 256.

ខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល ផ្នែកខ្លះនៃខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តកណ្ដាល(...)។

២. **ភូមិភាគនិរតី** (ភូមិភាគ៤០៥) ដឹកនាំដោយ ឈិត ជឿន ហៅតាម៉ុក។ ភូមិភាគនេះមានចែកជាបួនតំបន់គឺតំបន់១៣ តំបន់៣៣ តំបន់៣៥ និងតំបន់២៥ ដែលវាត្រូវបានបង្កើតចេញពីខេត្តកំពត និងខេត្តតាកែវទាំងមូល ផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ និងខេត្តកណ្ដាល(...)។

៣. **ភូមិភាគឧត្តរ** (ភូមិភាគ៣០៣) ដឹកនាំដោយ កុយ ធួន(១៩៧០-១៩៧៦) កែ ពក (១៩៧៦-១៩៧៧) និងកង ចាប។ ភូមិភាគនេះមានចែកជាបីតំបន់គឺតំបន់៤១ តំបន់៤២ និងតំបន់៤៣ ដែលវាត្រូវបានបង្កើតចេញពីកំពង់ធំទាំងមូល និងខាងលិចទាំងអស់នៃខេត្តកំពង់ចាម ផ្នែកខ្លះនៃខេត្តក្រចេះ(...)។

៤. **ភូមិភាគពាយ័ព្យ** (ភូមិភាគ៥៦០) ដឹកនាំដោយ ញឹម រស់។ ភូមិភាគនេះមានចែកជាប្រាំពីរតំបន់គឺតំបន់១ តំបន់២ តំបន់៣ តំបន់៤ តំបន់៥ តំបន់៦ និងតំបន់៧ ដែលវាត្រូវបានបង្កើតចេញពីខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងទាំងមូល។

៥. **ភូមិភាគបស្ចិម** (ភូមិភាគ៤០១) ដឹកនាំដោយ ជូ ជេត។ ភូមិភាគនេះមានចែកជាប្រាំតំបន់គឺតំបន់១១ តំបន់១៥ តំបន់៣១ តំបន់៣២ និងតំបន់៣៧ ដែលវាត្រូវបានបង្កើតចេញពីខេត្តកោះកុង និងខេត្តកំពុងឆ្នាំងទាំងមូល និងផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ។

៦. **ភូមិភាគឦសាន** (ភូមិភាគ១០៨) ដឹកនាំដោយ ណៃ សារ៉ាន់ ស្លាប់នៅឆ្នាំ១៩៧៦។ ភូមិភាគនេះមានចែកជាប្រាំមួយតំបន់គឺតំបន់១០១ តំបន់១០២ តំបន់១០៤ តំបន់១០៥ តំបន់១០៧ និងតំបន់៥០៥ ដែលវាត្រូវបានបង្កើតចេញពីខេត្តរតនគិរី និងខេត្តមណ្ឌលគិរីទាំងមូល និងផ្នែកខ្លះនៃខេត្តក្រចេះ និងខេត្តស្ទឹងត្រែង(...)។

ក្រោយមកនៅក្នុងឆ្នាំ១៩៧៦ កម្ពុជាបានបង្កើតតំបន់ស្វយ័តពីរផ្សេងទៀតដែលមិនចំណុះឱ្យភូមិភាគណាឡើយ និងមានទំនាក់ទំនងផ្ទាល់ជាមួយនឹងគណៈកម្មាធិការមជ្ឈិមបក្ស។ តំបន់ទាំងនេះគឺតំបន់១០៦ (សៀមរាប ឧត្ដរមានជ័យ) និងតំបន់១០៣ (ព្រះវិហារ)។ ក្រុងកំពង់សោមក៏ត្រូវបានចាត់តាំងដោយឡែកពីភូមិភាគដែរ។

នៅឆ្នាំ១៩៧៧ ភូមិភាគកណ្ដាលត្រូវបានបង្កើតឡើងដែលវាស្ថិតនៅត្រង់ភូមិភាគឧត្តរ និងភូមិភាគឧត្តរថ្មីត្រូវបានប្ដូរទីតាំងទៅតំបន់សៀមរាប-ឧត្តរមានជ័យ និងព្រះវិហារ។ តំបន់៥០៥ និងតំបន់១០៥ ក៏ត្រូវបានបំបែកចេញពីភូមិភាគ និងចាត់តាំងជាតំបន់ស្វយ័ត។[20]

[20] ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) (បោះពុម្ពលើកទី២)*, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០១១, ទំព័រ ២៨-៣១

### ១.១.១.២. ស្ថានភាពប្រជាជន

#### ក. វណ្ណៈសង្គម

នៅក្នុងសម័យនោះប្រជាជនកម្ពុជាត្រូវបានបែងចែកជាពីរវណ្ណៈគឺប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ (សំដៅដល់ប្រជាពលរដ្ឋដែលនៅតាមជនបទក្រោមការគ្រប់គ្រងរបស់ប.ក.ក.មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥) និងប្រជាជនថ្មី ឬប្រជាជន១៧មេសា (សំដៅដល់ប្រជាពលរដ្ឋដែលជម្លៀសចេញពីទីប្រជុំជន ឬទីក្រុងនៅខែមេសា ឆ្នាំ១៩៧៥) ដែលប្រជាជនចាស់ទទួលបានសិទ្ធិនិងការការពារប្រសើរជាងប្រជាជនថ្មី។

#### ខ. សន្តិសុខសង្គម

នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ មន្ទីរសន្តិសុខ(គុក)ត្រូវបានបង្កើតឡើងជាងពីររយកន្លែងទូរទាំងប្រទេស ដែលវាត្រូវបានបែងចែកជាប្រាំថ្នាក់គឺមន្ទីរសន្តិសុខថ្នាក់តំបន់ ថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់ភូមិភាគ និងថ្នាក់ខ្ពស់បំផុត(មន្ទីរសន្តិសុខមជ្ឈិម ឬមន្ទីរស-២១)។ ប្រព័ន្ធសន្តិសុខទាំងនេះ គឺជាកន្លែងដែលបង្កើតឡើងសម្រាប់អ្នកទោសដែលជាអតីតទាហាន និងមន្ត្រីរបស់រដ្ឋាភិបាលសាធារណៈរដ្ឋខ្មែរ អ្នកទោសលួចរបស់របរ ឬអាហារ អ្នកទោសរត់ចោលកន្លែង និងអ្នកទោសនិយាយអាក្រក់ពីអង្គការ។

ចំពោះការរស់នៅប្រចាំថ្ងៃវិញ ប្រជាជនត្រូវទទួលរងការគំរាមកំហែង ដកហូតសិទ្ធិសេរីភាព ការបង្ខំឱ្យធ្វើការជាទម្ងន់ បន្សុទ្ធកម្ម និងសម្លាប់រង្គាល។[21]

### ១.១.១.៣. គោលនយោបាយ និងផែនការអភិវឌ្ឍប្រទេស

នៅក្នុងការកាន់កាប់អំណាច និងដឹកនាំអង្គការបដិវត្តបានចែងនៅគោលការណ៍ចំនួន៨ ដើម្បីអនុវត្តទូរទាំងប្រទេស ដែលគោលការណ៍ទាំងនោះរួមមាន៖

១. ជម្លៀសប្រជាជនឱ្យចេញពីទីប្រជុំជនទាំងអស់ ជាពិសេសគឺរាជធានីភ្នំពេញ

២. លុបបំបាត់ទីផ្សារ

៣. លុបបំបាត់ការប្រើប្រាស់រូបិយប័ណ្ណ

៤. ផ្សឹកព្រះសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ឱ្យទៅធ្វើស្រែចម្ការនៅតំបន់មូលដ្ឋានជនបទ

៥. ប្រហារជីវិតមេដឹកនាំរបស់របបលន់ នល់

[21] ឌីខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) (បោះពុម្ពលើកទី២)*, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០១១, ទំព័រ ៥០-៥៧.

៦. បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស

៧. បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់

៨. បញ្ជូនទ័ពទៅតាមព្រំប្រទល់ជាពិសេសព្រំប្រទល់វៀតណាម។[22]

ចំពោះផែនការសេដ្ឋកិច្ចដែលមានរយៈពេលបួនឆ្នាំវិញ គឺបង្កើតឡើង ដើម្បីកសាងលទ្ធិសង្គមនិយមលើគ្រប់វិស័យ ដែលផែនការនេះត្រូវបានព្រាងទុកឱ្យចូលជាធរមាននៅខែកញ្ញា ឆ្នាំ១៩៧៦ ប៉ុន្តែវាពុំត្រូវបានប្រកាសជាផ្លូវការឡើយ។ ផែនការនេះតម្រូវឱ្យធ្វើសមូហភាវូបនីយកម្មលើកម្មសិទ្ធិឯកជនទាំងអស់ ហើយបានស្នើបង្កើនផលស្រូវទូទាំងប្រទេស ដែលមានគោលដៅទិន្នផលជាតិសរុបជាមធ្យម៣តោន ក្នុងមួយហិចតា។ លើសពីនេះផែនការនេះសង្ឃឹមលើប្រាក់ចំណូលពីអនុផលព្រៃឈើ ការនេសាទ ការចិញ្ចឹមសត្វ និងការដាំដើមឈើ។ គោលបំណងនៃការអភិវឌ្ឍនេះគឺ ដើម្បីបង្កើនផលិតផលនាំចេញ និងដើម្បីឆ្ពោះទៅរកឧស្សាហកម្មធន់ធ្ងន់ផងដែរ។

នៅក្នុងផែនការនេះ ប្រទេសកម្ពុជាបានបែងចែកដីស្រែជាពីរប្រភេទគឺដីស្រែលេខមួយ និងដីស្រែធម្មតា ដែលដីស្រែធម្មតាត្រូវផលិតស្រូវឱ្យបានបីតោនក្នុងមួយហិកតា រីឯដីស្រែលេខមួយគឺត្រូវផលិតឱ្យបានប្រាំមួយទៅប្រាំពីរតោនក្នុងមួយហិកតា។ ទិន្នផលស្រូវនេះ នឹងត្រូវបានបង្កើនជារៀងរាល់ឆ្នាំ។ ចំពោះការបែងចែកស្រូវវិញគឺត្រូវបានកំណត់ចែកជា៤ចំណែក គឺ (១)ចំណែកសម្រាប់ជាស្បៀងរបស់ប្រជាជនម្នាក់ៗ (២)ចំណែកសម្រាប់ធ្វើពូជស្រូវ (៣)ចំណែកសម្រាប់បម្រុងទុក និង(៤)ចំណែកសម្រាប់នាំចេញទៅក្រៅប្រទេស។ ចំពោះចំណែកទីមួយ គេកំណត់ឱ្យប្រជាជនម្នាក់ទទួលបានស្រូវត្រឹមតែ០,៨៥គីឡូក្រាមប៉ុណ្ណោះក្នុងមួយថ្ងៃ រីឯមួយចំណែកធំទៀតត្រូវបញ្ជូនទៅចំណែកទីបួន ដើម្បីប្តូរជាសាច់ប្រាក់ ដើម្បីទិញម៉ាស៊ីន សព្វាវុធ និងទំនិញផ្សេងៗ។

ចំពោះការអនុវត្តវិញគឺពុំបានសម្រេចដូចនឹងផែនការនោះទេ ដោយសារតែផែនការនេះពុំបានគិតទៅដល់កម្លាំងពលកម្មនៃពលករ លក្ខខណ្ឌអាហាររូបត្ថម្ភ ស្ថានភាពដី និងសុខភាពប្រជាពលរដ្ឋ។ ក្រៅពីនេះការកាប់សម្លាប់បញ្ញវន្ត និងការលុបបំបាត់ប្រព័ន្ធអប់រំក៏បានកើតមានឡើង ដែលនាំឱ្យប្រទេសខិតទៅរកភាពអន់ថយ។[23]

### ១.១.១.៤. ប្រព័ន្ធរដ្ឋបាលរាជធានីភ្នំពេញនៅសម័យកម្ពុជាប្រជាធិបតេយ្យ

ចំពោះរាជធានីភ្នំពេញវិញបន្ទាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនត្រូវបានជម្លៀសចេញទាំងស្រុងដោយបង្ខំក្រោមហេតុផលផ្សេងៗ។ គេហដ្ឋាន រចនាសម្ព័ន្ធនានាត្រូវបានបំផ្លាញនាំឱ្យទីក្រុងភ្នំពេញ

[22] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ១៥.

[23] David Chandler. *A History of Cambodia (3rd Edition).* Westview Press, 2009, pp. 252-255.

ក្លាយជាទីក្រុងខ្មោច។ ដូច្នេះភ្នំពេញពុំមានប្រព័ន្ធរដ្ឋបាលអ្វីទាំងអស់ក្រៅពីស្ថាប័នរបស់អង្គការ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបមានការវិលត្រឡប់មកវិញរបស់ប្រជាជន និងការរៀបចំជាបន្តបន្ទាប់។[24]

### ១.១.២. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា

បន្ទាប់ពីការដួលរលំរបស់របបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៩ កម្ពុជាបានឈានចូលទៅក្នុងសម័យកាលថ្មីមួយទៀតគឺសម័យកាលសាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅក្នុងសម័យកាលនេះ ប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការសំខាន់ៗចំនួនបួន និងពុំទាន់ទទួលបានសន្តិភាពពេញលេញនៅឡើយទេ ដោយសារមានសង្គ្រាមស៊ីវិល និងវិបត្តិនយោបាយនានាដែលបន្សល់ទុកមកពីសម័យកាលមុន។

#### ១.១.២.១.រចនាសម្ព័ន្ធរដ្ឋបាល

#### ក. រដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា

ប្រទេសកម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៨១ បន្ទាប់ពីសម័យប្រជុំពេញអង្គដំបូងបង្អស់ក្រោយការតែងតាំងរដ្ឋសភាបានកើតឡើង។ នៅក្នុងនោះ ប្រទេសកម្ពុជាបានប្តូរឈ្មោះផ្លូវការថ្មីមួយទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញថ្មីនោះគឺ "**សាធារណរដ្ឋប្រជាមានិតកម្ពុជា**" និងមានរដ្ឋសភាជាអង្គការកំពូលនៃរដ្ឋអំណាចដែលមានកៅអីចំនួន១១៧អាសនៈ[25] ហើយតំណាងប្រជាជនត្រូវបានជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសាកល ដែលមានបែបបទតាមច្បាប់បោះឆ្នោត។

រដ្ឋសភាត្រូវបើកសម័យប្រជុំដំបូង៦០ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ក្រុមប្រឹក្សារដ្ឋ និងត្រូវបើកសម័យប្រជុំជាសាមញ្ញ២ដង ក្នុង១ឆ្នាំ និងអាចបើកសម័យប្រជុំវិសាមញ្ញ បើក្រុមប្រឹក្សារដ្ឋយល់ឃើញថាចាំបាច់។ ចំពោះចម្រៀងជាតិវិញត្រូវបានកំណត់ដោយរដ្ឋសភា[26] ដែលត្រូវបានគេឱ្យឈ្មោះថាចម្រៀងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

#### ខ.រចនាសម្ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋ

រដ្ឋសភា គឺជាអង្គការកំពូលរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងសម័យកាលនោះ ដែលរដ្ឋសភាបានបង្កើតស្ថាប័នរដ្ឋសំខាន់ៗពីរសម្រាប់ធ្វើការដឹកនាំគឺរដ្ឋាភិបាល និងក្រុមប្រឹក្សារដ្ឋ។ ក្រុមប្រឹក្សារដ្ឋត្រូវបានកំណត់ជាអង្គការនីតិបញ្ញត្តិផង និងអង្គការនីតិប្រតិបត្តិផង។ រចនាសម្ព័ន្ធនៅក្នុងសម័យនោះត្រូវបានកំណត់ដូចខាងក្រោម៖

---

[24] សាលារាជធានីភ្នំពេញ, "*ភ្នំពេញសម័យប៉ុលពត*", ដកស្រង់នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤.

[25] David Chandler. *A History of Cambodia (3rd Edition).* Westview Press, 2009, pp. 267-270.

[26] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, "*ជំពូកទី៤៖ រដ្ឋសភា*", ១៩៨១, មាត្រា៤៩.

- លោក **ជា ស៊ីម** ជាប្រធានរដ្ឋសភា
- លោក **ហេង សំរិន** ជាប្រធានក្រុមប្រឹក្សារដ្ឋ និងមានសមាជិក៧រូបផ្សេងទៀត
- លោក **ប៉ែន សុវណ្ណ** ជានាយករដ្ឋមន្ត្រី (ខែមិថុនា ឆ្នាំ១៩៨១-ខែធ្នូ ឆ្នាំ១៩៨១)
- លោក **ចាន់ ស៊ី** ជានាយករដ្ឋមន្ត្រី (១៩៨២-១៩៨៤)
- លោក **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី (១៩៨៤-១៩៨៩)

ក្រៅពីនេះបុគ្គលសំខាន់ៗមួយចំនួនដែលចូលរួមក្នុងការដឹកនាំប្រទេសរួមមាន៖ ខាន សាវីន, ជា សុទ្ធ, គង់ សំអុល, (...)។[27] ការគ្រប់គ្រងនៃរដ្ឋាភិបាលនៅក្នុងសម័យនោះគឺត្រូវស្ថិតនៅក្រោមបក្សតែមួយប៉ុណ្ណោះគឺ គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលជាអង្គការសំខាន់មួយផងដែរក្រៅពីអង្គការទាំងបីខាងលើ។

សមាសភាពអ្នកគ្រប់គ្រងនាសម័យនោះត្រូវបានបែងចែកជាពីរគឺ រដ្ឋអំណាចខ្មែរ និងជំនាញការនិងកងទ័ពវៀតណាម ដែលរដ្ឋអំណាចខ្មែរត្រូវបានបែងចែកជាពីរទៀតគឺក្រុមអ្នកតស៊ូចាស់ៗ និងក្រុមអ្នកបានទៅរៀននៅវៀតណាម(...) រីឯកងទ័ពវៀតណាមវិញត្រូវធ្វើការអមនឹងរដ្ឋអំណាចខ្មែរគ្រប់លំដាប់ថ្នាក់ទាំងអស់រហូតដល់មូលដ្ឋាន(...)។ នៅក្នុងថ្នាក់ស្រុក និងខេត្តមន្ត្រីរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាព្យាយាមធ្វើការគ្រប់គ្រងតាមប្រព័ន្ធមជ្ឈការ ប៉ុន្តែពុំមានការប្រមូលពន្ធតឹងរឹង និងកែនទ័ពឡើយ។ ក្រៅពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា កម្ពុជាបានបែងចែកជាបីភាគីទៀតគឺ (១)កម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម (២)រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរប្រជាធិបតេយ្យ និង(៣)ក្រុមរាជានិយមរបស់សម្តេចសីហនុ ដែលភាគីទាំងបីនេះបានបង្កើតរដ្ឋាភិបាលសម្ព័ន្ធត្រីភាគីមួយនៅឆ្នាំ១៩៨២ ដើម្បីប្រឆាំងនឹងរដ្ឋាភិបាលប្រជាមានិតកម្ពុជា និងវត្តមានរបស់វៀតណាមនៅកម្ពុជា។[28]

### គ. ការបែងចែកភូមិសាស្ត្ររដ្ឋបាល

នៅក្នុងសម័យកាលសាធារណៈរដ្ឋប្រជាមានិតកម្ពុជាភូមិសាស្ត្ររដ្ឋបាលត្រូវបានបែងចែកជាដប់ប្រាំបីខេត្ត និងក្រុងពិសេសចំនួនពីរគឺភ្នំពេញ និងកំពង់សោម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលកណ្តាលដោយផ្ទាល់។ ខេត្តត្រូវបានបែងចែកជាស្រុក ស្រុកត្រូវបានបែងចែកជាឃុំ រីឯក្រុងត្រូវបែងចែកជាសង្កាត់ និងត្រូវមានគណៈកម្មាធិការប្រជាជនបដិវត្តនៅគ្រប់មូលដ្ឋានទាំងអស់។ [29]

[27] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី២*, Mou Seth, ២០០៨, ទំព័រ ១៩៩-២០២.

[28] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ២៥-២៧.

[29] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, *"ជំពូកទី៧៖ គណៈកម្មាធិការប្រជាជនបដិវត្តមូលដ្ឋាន"*, ១៩៨១, មាត្រា៧១-៧២.

### ១.១.២.២. ស្ថានភាពប្រជាជន

បន្ទាប់ពីឈានចូលមកក្នុងសម័យកាលថ្មីមួយទៀត កម្ពុជាពុំទាន់ទទួលបានសន្តិភាពពេញលេញនៅឡើយទេ និងមានជួបប្រទះនៅសង្គ្រាមស៊ីវិលរវាងភាគីទាំងបួន និងវត្តមានរបស់កងទ័ពវៀតណាមនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីនេះប្រជាជនរាប់ម៉ឺននាក់បានផ្លាស់ទីលំនៅ និងត្រូវបានគេសម្លាប់ចោល ដែលក្នុងនោះមានប្រជាជនប្រមាណជាបួនម៉ឺនប្រាំពាន់នាក់បានរត់ទៅនៅប្រទេសថៃ ដើម្បីគេចខ្លួនពីសង្គ្រាម។ ប្រជាជនមួយផ្នែកធំទៀតបានស្លាប់ដោយសារកង្វះអាហារ និងជំងឺគ្រុនចាញ់។ ចំពោះសំណង់ និងហេដ្ឋារចនាសម្ព័ន្ធវិញ ភាគច្រើនត្រូវបានខូចខាត ដែលសល់តាំងសម័យកាលមុនមក និងមានការខ្វះខាតសម្ភារៈប្រើប្រាស់។ ខុសពីសម័យកាលមុន នៅក្នុងសម័យកាលនេះប្រជាជនខ្មែរទទួលបានសេរីភាពផ្ទាល់ខ្លួនមួយចំនួន ដែលវាមានលក្ខណៈល្អប្រសើរជាងមុន។[30]

### ១.១.២.៣. គោលនយោបាយ និងផែនការអភិវឌ្ឍប្រទេស

នៅក្នុងដំណើរការអភិវឌ្ឍប្រទេសនៅក្នុងសម័យកាលនេះ ប្រទេសកម្ពុជាបានប្រឈមមុខនឹងបញ្ហាសំខាន់ៗចំនួនប្រាំគឺ (១)ការមិនព្រមទទួលស្គាល់ពីសំណាក់អង្គការសហប្រជាជាតិ (២)ការកសាងប្រទេសឡើងវិញទាំងស្រុង (៣)វិបត្តិអាណានិគមកិច្ចរបស់ប្រទេសវៀតណាម (៤)ជម្លោះផ្ទៃក្នុងរវាងក្រុមប៉ែន សុវណ្ណ និងក្រុមជា ស៊ីម-ហេង សំរិន (៥)ជម្លោះរវាងភាគីរដ្ឋាភិបាលទាំងពីរ។ ដើម្បីដោះស្រាយ និងកសាងប្រទេសជាតិឡើងវិញ ប្រទេសកម្ពុជាបានរៀបចំផែនការមួយចំនួនដូចជា ការបង្កើតឡើងនៃក្រុមសាមគ្គីបង្កបង្កើនផលទាំងបីប្រភេទដើម្បីដោះស្រាយវិបត្តកង្វះអាហារ ការដកកងទ័ពវៀតណាមចេញពីកម្ពុជា ផែនការក៥ដើម្បីការពារព្រំដែនកម្ពុជា និងគោលនយោបាយបង្រួបបង្រួមជាតិរបស់កម្ពុជា។ ក្រៅពីនេះ ផែនការរៀបចំប្រព័ន្ធអប់រំ ប្រព័ន្ធសុខាភិបាល សេដ្ឋកិច្ច ក៏ត្រូវបានរៀបចំដែរ ប៉ុន្តែពុំសូវមានការយកចិត្តទុកដាក់ខ្លាំងនោះទេដោយសារស្ថានភាពសង្គមមានភាពស្មុគស្មាញ។

ចំពោះផែនការក្រុមសាមគ្គីបង្កបង្កើនផលវិញ បានកំណត់ចែកផលទៅតាមកម្លាំងពលកម្មរបស់ប្រជាពលរដ្ឋដែលវាត្រូវបានបែងចែកជាបីប្រភេទគឺ កម្លាំងពេញ កម្លាំងមធ្យម និងកម្លាំងខ្សោយ ដែលផែនការអភិវឌ្ឍនេះត្រូវទទួលរងការរិះគន់ពីសំណាក់ប្រជាពលរដ្ឋមួយចំនួនធំ ដោយយោងថាវាមិនមានភាពយុត្តិធម៌ដោយហេតុឥទ្ធិពលនៃសម័យកាលចាស់បានបន្សល់ទុក ពោលគឺដោយសារកម្លាំង ឧបករណ៍ និងសម្ភារៈធ្វើស្រែចំការមិនស្មើគ្នា។ យ៉ាងណាមិញ ផែនការបង្កបង្កើនផលនេះទទួលបាននៅការកែប្រែជាបន្តបន្ទាប់។[31]

---

[30] David Chandler. *A History of Cambodia (3rd Edition).* Westview Press, 2009, pp. 271-272.

[31] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី២*, Mou Seth, ២០០៨, ទំព័រ ១៩៩-២៧៥.

### ១.១.២.៤. ប្រព័ន្ធរដ្ឋបាលរាជធានីភ្នំពេញនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា

ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ទីក្រុងភ្នំពេញទទួលបាននូវកំណើនប្រជាជនដែលផ្លាស់ទីពីជនបទមកជាបន្តបន្ទាប់ និងត្រូវបានចាត់ទុកជាក្រុងពិសេសដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋាភិបាលកណ្តាល និងបានអនុវត្តប្រព័ន្ធមជ្ឈការខ្លះៗក្នុងការគ្រប់គ្រង និងដឹកនាំ។

### ១.១.៣. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យរដ្ឋកម្ពុជា

បន្ទាប់ពីបានអនុវត្តផែនការចរចារសន្តិភាពទាំងពីរលើក ដែលមានលើកទីមួយធ្វើនៅប្រទេសបារាំងក្នុងឆ្នាំ១៩៨៧ និងលើកទីពីរនៅប្រទេសឥណ្ឌូនេស៊ីឆ្នាំ១៩៨៨ កម្ពុជាបានសម្រេចនៅលទ្ធផលមួយចំនួនផ្នែកនយោបាយនិងយោធា និងបានវិវត្តខ្លួនចូលទីក្នុងសម័យកាលថ្មីមួយទៀតគឺសម័យរដ្ឋកម្ពុជា។ សម័យកាលនេះតាមពិតទៅគឺមានលក្ខណៈស្រដៀងគ្នាខ្លាំងទៅនឹងសម័យកាលប្រជាមានិតកម្ពុជាដែរ ដោយគ្រាន់តែមានការផ្លាស់ប្តូរឈ្មោះ និងកំណែរទម្រង់មួយចំនួនប៉ុណ្ណោះ នៅក្នុងសម័យនេះ សង្គមកម្ពុជាបានកើតមានឡើងនូវភាពច្របូកច្របល់បន្ថែមទៀត និងមានការចូលរួមពីអង្គការសហប្រជាជាតិ(UNTAC) ដើម្បីជួយដោះស្រាយវិបត្តិ និងទំនាស់ទាំងនោះផងដែរ។

#### ១.១.៣.១. រចនាសម្ព័ន្ធរដ្ឋបាល

#### ក. រដ្ឋធម្មនុញ្ញរបស់រដ្ឋកម្ពុជា

*រូបភាពទី២៖ ទង់ជាតិរបស់ប្រទេសកម្ពុជានៅសម័យកាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា*[32]



រដ្ឋធម្មនុញ្ញថ្មីមួយរបស់រដ្ឋកម្ពុជាត្រូវបានបង្កើតឡើង ក្រោយពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅក្នុងថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ១៩៨៩ ដែលមួយផ្នែកធំនៃរដ្ឋធម្មនុញ្ញនេះគឺយកគំរូទៅតាមរដ្ឋធម្មនុញ្ញសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាលើកលែងចំណុចមួយចំនួនត្រូវបានកែប្រែ ដែលចំណុចទាំងអស់នោះរួមមាន៖

– ការប្តូរឈ្មោះពី "**សាធារណរដ្ឋប្រជាមានិតកម្ពុជា**" ទៅជា "**រដ្ឋកម្ពុជា**"

---

[32] ដកស្រង់ និងកែសម្រួលមកពី៖ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, ១៩៨១ &រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា, ១៩៨៩

- ការផ្លាស់ប្តូរទង់ជាតិ និងភ្លេងជាតិ
- លុបចោលច្បាប់ប្រហារជីវិត
- ទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ
- បង្កើតទីផ្សារសេរី
- ផ្តល់សេរីភាពសារព័ត៌មាន និងបង្កើតអង្គការសង្គមស៊ីវិល។

**ខ.រចនាសម្ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋ**

ចំពោះរចនាសម្ព័ន្ធរដ្ឋបាលរបស់សម័យកាលនេះវិញក៏មានលក្ខណៈស្រដៀងគ្នាខ្លាំងទៅនឹងសម័យកាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ ប៉ុន្តែគណៈកម្មាធិការប្រជាជនបដិវត្តមូលដ្ឋានត្រូវបានប្តូរឈ្មោះមកជាគណៈកម្មាធិការប្រជាជនវិញ។ នៅក្នុងដំណើរការគ្រប់គ្រងរដ្ឋនៅពេលនោះក៏មានការចូលអន្តរាគមន៍ពីអង្គការសហប្រជាជាតិផងដែរ ដោយសារតែមានការវាយប្រហារគ្នាទៅមកបន្ទាប់ពីកិច្ចចរចារសន្តិភាពរួច ដែលអង្គការនោះមានឈ្មោះកាត់ថា UNTAC ឬAPRONUC។ ការចូលមកអន្តរាគមន៍ពី អង្គការសហប្រជាជាតិមួយនេះក៏ត្រូវបានគេរាប់បញ្ចូលជាសម័យកាលថ្មីមួយទៀតផងដែរ។[33]

**គ. ការបែងចែកភូមិសាស្ត្ររដ្ឋបាល**

ចំពោះការបែងចែកភូមិសាស្ត្ររដ្ឋបាលរបស់ប្រទេសកម្ពុជាវិញ ក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងសម័យកាលមុនដែរ ប៉ុន្តែនៅក្នុងសម័យកាលនេះរដ្ឋាភិបាលលោក ហេង សំរិន បានកាន់កាប់ជាង៩០% (ភាគរយ)នៃទឹកដីកម្ពុជាទាំងមូលទៅហើយ ចំណែកឯខ្មែរក្រហមវិញត្រូវបានសង្គមអន្តរជាតិថ្កោលទោសពីបទប្រល័យពូជសាសន៍។[34] ចំពោះប្រព័ន្ធរដ្ឋបាល និងមុខងារសាធារណៈវិញទទួលបានកំណែរទម្រង់ជាបន្តបន្ទាប់ដែលមានលក្ខណៈល្អប្រសើរជាមុន។

### ១.១.៣.២. ស្ថានភាពប្រជាជន

**ក. ស្ថានភាពសង្គម**

នៅក្នុងសម័យនោះប្រជាជនពុំទាន់ទទួលបានការគិតគូរច្បាស់លាស់វិញនៅឡើយទេ ដែលនៅតាមតំបន់ជនបទខ្លះមានស្ថានភាពកាន់តែពិបាកជាងមុនទៅទៀត។ នៅក្រៅទីក្រុងភ្នំពេញ ប្រជាជនមានភាពក្រីក្រខ្លាំង សុខភាពទន់ខ្សោយ និងពុំមានទទួលបានសេវាសាធារណៈគ្រប់គ្រាន់ទេ។

---

[33] ហែម ឡាច, *ការវិវត្តនៃរដ្ឋបាលដែនដីខ្មែរ(តាំងពីសម័យមុនអង្គរ រហូតដល់ឆ្នាំ១៩៩៣)*, ២០២២.

[34] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី៣*, Mou Seth, ២០១០, ទំព័រ ៩-១០.

*ស្ថានភាពផ្នែកសេវាសាធារណៈគឺជាស្ថានភាពដ៏អាក្រក់ជាងគេចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩២០មក។*[35]

ក្រៅពីនេះអត្រាមរណរបស់ទារកមានការកើនឡើងជាខ្លាំង ដែលវាស្ថិតនៅក្នុងកម្រិតខ្ពស់បំផុតមួយក្នុងចំណោមអាត្រាខ្ពស់ៗបំផុតនៅក្នុងពិភពលោក។ ជំងឺរាតត្បាតផ្សេងៗដូចជា ជំងឺគ្រុនចាញ់ ជំងឺគ្រុនក្ដៅ ជំងឺផ្លូវចិត្ត និងជំងឺអេដស៍បានរីករាយរាលដាល និងកើនឡើងទូទាំងប្រទេស។ សាលារៀន និងមន្ទីរពេទ្យក៏មិនមានចំនួនគ្រប់គ្រាន់ដែរ ដែលធ្វើឱ្យស្ថានភាពជនបទនៅប្រទេសកម្ពុជាប្រៀបដូចជាប្រទេសក្រីក្រជាងគេមួយចំនួននៅលើពិភពលោក។

ចំពោះអ្នកនៅរាជធានីភ្នំពេញវិញ ការរស់នៅប្រចាំថ្ងៃមានលក្ខណៈល្អប្រសើរឡើង និងមានការរីកចម្រើនកើនឡើងជាបន្តបន្ទាប់ ហើយសេវាសាធារណៈ និងជីវភាពរបស់អ្នកទីក្រុងក៏មិនលំបាកដូចអ្នកនៅតាមជនបទដែរ។

### ខ. សន្តិសុខសង្គម

សន្តិសុខសង្គមវិញក៏មានលក្ខណៈទន់ខ្សោយដែរ ដោយមានការកើនឡើងនៃអំពើខុសច្បាប់ជាច្រើនដូចជា ការជួញដូរឈើ ធនធានធម្មជាតិ ដោយខុសច្បាប់ទៅប្រទេសថៃ និងវៀតណាម។ នៅតាមព្រំដែនដូចជាព្រំដែនខេត្តកោះកុង និងខេត្តរតនគិរីគ្មានច្បាប់ទម្លាប់ និងសណ្ដាប់ធ្នាប់អ្វីទាំងអស់។ ក្រៅពីនេះការលិចឡើងនៃទីផ្សារងងឹតក៏បានលិចឡើងច្រើននៅក្នុងសម័យកាលនេះផងដែរ។[36]

## ១.១.៣.៣. គោលនយោបាយ និងផែនការអភិវឌ្ឍប្រទេស

នៅក្នុងស្ថានភាពដ៏ស្មុគស្មាញនេះ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានជួបប្រទះនៅបញ្ហាធំៗជាច្រើនដែលស្រដៀងគ្នាទៅនឹងសម័យកាលមុនដែរ បញ្ហាទាំងនោះគឺមានទាក់ទងទៅនឹងសន្តិសុខសង្គម វិបត្តិនយោបាយសង្គ្រាមស៊ីវិល និងបញ្ហាសង្គមផ្សេងៗទៀត។ នៅក្នុងដំណើរការដោះស្រាយបញ្ហាទាំងអស់នេះ អង្គការសហប្រជាជាតិបានចំណាយទឹកប្រាក់ប្រមាណជា បីពាន់លានដុល្លា ដើម្បីបំពេញសកម្មភាពបួនយ៉ាងគឺ (១)ដកហូតអាវុធពីភាគីទាំងបួន (២)បញ្ចូលរដ្ឋអំណាចទាំងបួនបញ្ចូលគ្នា (៣)រៀបចំការបោះឆ្នោតដោយសេរីនៅកម្ពុជា និង (៤)នាំជនភៀសខ្លួនខ្មែរជាង ៣៥០.០០០នាក់ត្រឡប់មកវិញ។[37] ក្រៅពីនេះកម្ពុជាក៏មានលិចឡើងនូវអភិក្រមសន្តិភាពទាំងបួនចំណុច ការអនុម័តថវិកាជាច្រើនសម្រាប់ការអភិវឌ្ឍនិងសាងសង់វត្តអារាម កំណែទម្រង់មុខងារសាធារណៈ និងផែនការរំសាយចោល៧០ភាគរយនៃកម្លាំងយោធារបស់ភាគីនីមួយ ហើយដោះស្រាយ

[35] ដេវីឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ (បោះពុម្ពលើកទី៣)*, មជ្ឈមណ្ឌលខេមរសិក្សា, ២០០៩, ២៧៧-២៨០.
[36] ដេវីឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ (បោះពុម្ពលើកទី៣)*, មជ្ឈមណ្ឌលខេមរសិក្សា, ២០០៩, ២៧៧-២៨០.
[37] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ៣១.

សន្តិវិធី។ ទោះបីជាមានគោលនយោបាយ និងផែនការថ្មីៗ ដើម្បីដោះស្រាយវិបត្តិជាតិក៏ដោយ ក៏នៅមុនពេលការបោះឆ្នោតបានកើតឡើង ព្រឹត្តិការណ៍មួយចំនួនបានលេចឡើង ក្នុងរូបភាពដែលបង្ហាញពីអស្ថេរភាពសង្គមនៅក្នុងសង្គមកម្ពុជាដូចជាការប៉ះទង្គិចគ្នារវាងភាគីពាក់ព័ន្ធ។[38]

### ១.១.៣.៤. ប្រព័ន្ធរដ្ឋបាលរាជធានីភ្នំពេញនៅសម័យរដ្ឋកម្ពុជា

នៅក្នុងសម័យកាលនេះ ប្រព័ន្ធរដ្ឋបាលរាជធានីភ្នំពេញទទួលបានការអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ការសាងសង់ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុងភ្នំពេញបានកើតឡើងជាបន្តបន្ទាប់ ហើយក្នុងកំឡុងពេលរីកចម្រើននេះ គេក៏កត់សម្គាល់ឃើញនៅការលិចឡើងរបស់ពួកធូរធារមួយក្រុមតូចផងដែរ ដែលពួកគេមានឡានជិះ ភូមិគ្រឹះរស់នៅ។ ចំពោះទីផ្សារសេរីនៅទីក្រុងភ្នំពេញក៏មានការរីកចម្រើនខ្លាំងដែរ និងពុំមានការដាក់កំហិតទៅលើអចលនទ្រព្យឡើយ។ នៅក្នុងសម័យកាលនេះការលិចឡើងនៃអំពើពុករលួយនៅក្នុងរាជធានីភ្នំពេញក៏ពុំសូវមានភាពខ្លាំងខ្លាដែរ ប្រសិនបើធៀបទៅនឹងសម័យសម្តេចព្រះសីហនុ និងសេនាប្រមុខលន់ នល់ ដោយនេះអាចបណ្តាលមកពីភាពក្រីក្រនៅក្នុងសង្គម និងអវត្តមាននៃវណ្ណសហគ្រិន។[39]

### ១.១.៤. ការគ្រប់គ្រងរដ្ឋបាលក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២

បន្ទាប់ពីទទួលបានការអន្តរាគមន៍ពី UNTAC (APRONUC) កម្ពុជាបានសម្រេចនៅការបោះឆ្នោតមួយដោយសេរីនិងយុត្តិធម៌ និងជាលទ្ធផល សម័យកាលថ្មីមួយរបស់កម្ពុជាក៏បានកើតឡើងចាប់តាំងពីពេលនោះមករហូតមកដល់ពេលបច្ចុប្បន្ន(១៩៩៣-២០២៤)។ សម័យកាលថ្មីមួយនេះត្រូវបានគេស្គាល់ថាជា "**សម័យព្រះរាជាណាចក្រកម្ពុជា(ទី២)**" ដែលអាចសន្និដ្ឋានបានថានេះ គឺជាសម័យកាលដំបូងដែលកម្ពុជាទទួលបានសន្តិភាពពេញលេញផ្នែកសន្តិសុខ និងនយោបាយពោល គឺមិនពឹងផ្អែកទៅលើអង្គការ ឬបរទេស។

នៅក្នុងសម័យកាលនេះ សង្គមកម្ពុជាមានការអភិវឌ្ឍ និងការវិវត្តជាបន្តបន្ទាប់គ្រប់វិស័យទាំងអស់ និងបានសម្រេចយករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ[40] ព្រមទាំងបានប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សមកធ្វើជាមាគ៌ាក្នុងការដឹកនាំប្រទេស។[41] ការគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងសម័យកាលនេះត្រូវបានកំណត់ និងបង្កើតឡើងដោយច្បាប់ និងលិខិតគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ដើម្បីធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍ។

[38] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី៣*, Mou Seth, ២០១០.

[39] ដេវីឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ (បោះពុម្ពលើកទី៣)*, មជ្ឈមណ្ឌលខេមរសិក្សា, ២០០៩, ២៧៧-២៧៩.

[40] សំ សារ៉ាក់, *នីតិរដ្ឋបាលស្តីពីចំណេះដឹងការងាររដ្ឋបាលកិច្ចការលេខាធិការ និងបណ្ណសារដ្ឋាន*, ២០១១, ទំព័រ ៦.

[41] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, *"ជំពូកទី១ អំពីអធិបតេយ្យ"*, ២០២៣, មាត្រា១.

### ១.១.៤.១. រចនាសម្ព័ន្ធរដ្ឋបាល

#### ក. រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាទី២

នៅក្នុងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីមួយរបស់ប្រទេសកម្ពុជាត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ដែលនៅក្នុងនោះខ្លឹមសារសំខាន់ៗជាច្រើនបានកំណត់ដូចជា៖

- ការផ្លាស់ប្តូររបបនយោបាយថ្មីមកជាលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស
- ការកំណត់នៅអត្តសញ្ញាណជាតិជាថ្មី ដែលមានភ្លេងជាតិឈ្មោះ "**ភ្លេងជាតិ នគររាជ**"
- ការបែងចែកអំណាចទាំងបីឱ្យដាច់ពីគ្នា (អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)
- ការកំណត់អំពីសេដ្ឋកិច្ចទីផ្សារសេរី
- ការកំណត់អំពីការគ្រប់គ្រងរដ្ឋបាល(...)

បើគិតត្រឹមឆ្នាំ២០២៤នេះ រដ្ឋធម្មនុញ្ញនេះបានធ្វើវិសោធនកម្មចំនួន១០លើក ដែលលើកចុងក្រោយបង្អស់ធ្វើឡើងនៅក្នុងឆ្នាំ២០២២។[42]

រូបភាពទី៣៖ ទង់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា (ទី២)[43]



#### ខ.រចនាសម្ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋ

ចំពោះការគ្រប់គ្រងរដ្ឋវិញ ព្រះរាជាណាចក្រកម្ពុជាបានបែងចែករចនាសម្ព័ន្ធនៃអំណាចឱ្យដាច់ដោយឡែកពីគ្នាតាមការកំណត់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលអំណាចកំពូលមានបីគឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ នៅក្នុងនោះអង្គការនីតិបញ្ញត្តិត្រូវបានបែងចែកជាពីរថ្នាក់គឺរដ្ឋសភា និងព្រឹទ្ធសភា។

រដ្ឋសភានៅក្នុងនីតិកាលទី១ មានចំនួន ១២០អាសនៈដែលត្រូវបានបែងចែកតាមលទ្ធផលនៃការបោះឆ្នោតដូចខាងក្រោម៖

[42] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, "*កំណត់សម្គាល់*", ២០២៣, ទំព័រ ១០៩-១១២.

[43] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, "*ឧបសម្ព័ន្ធទី១ ទង់ជាតិ*", ២០២៣, ទំព័រ ៧៥.

- គណបក្សហ៊្វុនស៊ិនប៉ិច (នរោត្តមរណឫទ្ធិ) ទទួលបាន ៥៨អាសនៈ
- គណបក្សប្រជាជនកម្ពុជា ទទួលបាន ៥១អាសនៈ
- គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ទទួលបាន ១០អាសនៈ
- គណបក្សម៉ូលីណាកា និងអ្នកស៊ូខ្មែរ ទទួលបាន ១អាសនៈ[44]

នៅក្នុងពេលបច្ចុប្បន្ន(២០២៤)រដ្ឋសភាបានឈានចូលមកដល់នីតិកាលទី៧ ដែលចំនួនអាសនៈនៃអង្គការមួយនេះបានកើនឡើងដល់ចំនួន១២៥អាសនៈ ដែលមានការបែងចែកតាមលទ្ធផលនៃការបោះឆ្នោតដូចខាងក្រោម៖

- គណបក្សប្រជាជនកម្ពុជា ទទួលបាន ១២០អាសនៈ
- គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ៥អាសនៈ[45]

ចំពោះព្រឹទ្ធសភាវិញចំនួនអាសនៈច្រើនបំផុតគឺពាក់កណ្ដាលនៃចំនួនអាសនៈរដ្ឋសភា[46]ដោយឡែកនៅក្នុងនីតិកាលទី១គឺមានចំនួន៦១អាសនៈ ដែលកើតឡើងតាមរយៈការបោះឆ្នោតអសកល និងការជ្រើសតាំងនឹងមានការបែងចែកដូចខាងក្រោម៖

- គណបក្សប្រជាជនកម្ពុជា ទទួលបាន ៣១អាសនៈ
- គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ២១អាសនៈ
- គណបក្សសមរង្ស៊ី ទទួលបាន ៧អាសនៈ
- ព្រះបរមរាជវាំង ទទួលបាន ២អាសនៈ

ចំពោះពេលបច្ចុប្បន្ន(២០២៤)នីតិកាលទី៥ ព្រឹទ្ធសភាបានកើនឡើងដល់ ៦២អាសនៈ ដែលសមាសភាពក្នុងនោះត្រូវបានបែងចែកដូចខាងក្រោម៖

- គណបក្សប្រជាជនកម្ពុជា ទទួលបាន ៥៧អាសនៈ
- គណបក្សឆន្ទៈខ្មែរទទួលបាន ៣អាសនៈ
- ព្រះបរមរាជវាំង ទទួលបាន ២អាសនៈ។[47]

ក្រៅពីស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិក៏ដើរតួរយ៉ាងសំខាន់នៅក្នុងការដឹកនាំប្រទេសជាតិផងដែរ

---

[44] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ៣២.

[45] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, *តារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតនៃការជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧*, ២០២៣.

[46] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, "*ជំពូកទី៨ថ្មី អំពីព្រឹទ្ធសភា*", ២០២៣, មាត្រា៩៩ថ្មី.

[47] ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា, "*គេហទំព័រអ៊ីនធឺណិត៖ ថ្នាក់ដឹកនាំ*", ដកស្រង់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤.

អង្គការមួយនេះមានឈ្មោះថារាជរដ្ឋាភិបាល ដែលដឹកនាំដោយគណៈរដ្ឋមន្ត្រី។[48] នៅក្នុងនីតិកាលទី១ ប្រទេសកម្ពុជាបានដឹកនាំដោយនាយករដ្ឋមន្ត្រីពីររូបក្នុងពេលតែមួយ ដែលវាជាព្រឹទ្ធការណ៍ដែលពុំធ្លាប់មានពីមុនមក ដែលព្រឹត្តិការណ៍កើតឡើង ដើម្បីជាដំណោះស្រាយដល់បក្សនយោបាយ និងដើម្បីជៀសវាងការកើតឡើងបន្តនៃសង្គ្រាមស៊ីវិល។[49] ជាដំណោះស្រាយនៅក្នុងនីតិកាលទី១នេះ**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីទី១ រីឯ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីទី២ដែលលោកទាំងពីរមានតួនាទីដឹកនាំរាជរដ្ឋាភិបាលកម្ពុជា។

បន្ទាប់ពីបានទទួលនៅសន្តិភាពពេញលេញរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាទទួលបាននូវផែនការ ក៏ដូចជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍជាបន្តបន្ទាប់ ហើយនៅក្នុងពេលបច្ចុប្បន្ននេះ(២០២៤) ប្រទេសកម្ពុជាមានក្រសួងស្ថាប័នរដ្ឋចំនួន៣៥ (មិនគិតព្រឹទ្ធសភា និងរដ្ឋសភា)[50] និងត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបគឺ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត។**

ក្រៅពីអង្គការនៃអំណាចឯករាជ្យទាំងពីរនេះ ប្រទេសកម្ពុជាក៏មានអង្គការ ស្ថាប័ននៃអំណាចតុលាការ ដែលជាអំណាចឯករាជ្យទី៣ផងដែរ។ នៅក្នុងអំណាចនេះ ឧត្តមក្រុមប្រឹក្សាអង្គចៅក្រមគឺជាស្ថាប័នមួយដែលត្រួតពិនិត្យទៅលើសកម្មភាពរបស់ចៅក្រម ដែលឯករាជ្យភាពនៃស្ថាប័នមួយនេះត្រូវបានកំណត់ធានាដោយព្រះមហាក្សត្រ។[51]

### គ. ការបែងចែកភូមិសាស្ត្ររដ្ឋបាល

បន្ទាប់ពីការបង្កើតរដ្ឋធម្មនុញ្ញថ្មី ប្រទេសកម្ពុជាក៏បានបែងចែកភូមិសាស្ត្ររដ្ឋបាលមួយសារជាថ្មីដែលមានលក្ខណៈច្បាស់លាស់ និងល្អប្រសើរជាមុនផងដែរ។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ភ្នំពេញត្រូវបានកំណត់ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា រីឯការគ្រប់គ្រងរដ្ឋបាលវិញត្រូវបានកំណត់បែងចែកដូចខាងក្រោម៖

*ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។*[52]

---

[48] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, "*ជំពូកទី១០ថ្មី អំពីរាជរដ្ឋាភិបាល*", ២០២៣, មាត្រា១១៨ថ្មី(មួយ).

[49] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី៣*, Mou Seth, ២០១០, ទំព័រ ៧៦-៨០.

[50] ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, "*គេហទំព័រអ៊ីនធឺណិត៖ ក្រសួងនិងស្ថាប័នរដ្ឋ*", ដកស្រង់នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០២៤.

[51] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, "*ជំពូកទី១១ថ្មី អំពីអំណាចតុលាការ" ទង់ជាតិ*", ២០២៣, មាត្រា១២៨ថ្មី-មាត្រា១៣៥ថ្មី.

[52] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, "*ជំពូកទី១៣ថ្មី អំពីការគ្រប់គ្រងរដ្ឋបាល*", ២០២៣, មាត្រា១៤៥ថ្មី(មួយ).

នៅក្នុងដើមសម័យកាលនេះប្រទេសកម្ពុជាមានត្រឹមតែ ២០ខេត្តក្រុងតែប៉ុណ្ណោះ រហូតមកដល់ឆ្នាំ ២០០៨ ខេត្តបីទៀតត្រូវបានបង្កើតឡើងគឺខេត្តកែប[53] ខេត្តប៉ៃលិន[54] ខេត្តព្រះសីហនុ។[55] បន្ទាប់មកឆ្នាំ២០១៣ ខេត្តត្បូងឃ្មុំ ត្រូវបានបង្កើតឡើងដែលកើតចេញពីការបំបែកខេត្តកំពង់ចាម។[56] ក្រៅពីការបង្កើតភូមិសាស្ត្ររដ្ឋបាលធំៗ(ខេត្ត) ភូមិសាស្ត្ររដ្ឋបាលចំណុះក៏មានការបង្កើតឡើងជាបន្តបន្ទាប់ផងដែរ ជាពិសេសគឺនៅក្នុងរាជធានីភ្នំពេញ។ ដូចនេះមកដល់ពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាមានភូមិសាស្ត្ររដ្ឋបាលសរុបចំនួន២៥ខេត្តក្រុងរួមបញ្ចូលទាំងរាជធានីភ្នំពេញ។

### ១.១.៤.២. ស្ថានភាពប្រជាជន

ចំពោះស្ថានភាពសង្គមរបស់ប្រទេសកម្ពុជាវិញ នៅក្នុងដើមសម័យកាលព្រះរាជាណាចក្រកម្ពុជាទី២ នេះប្រជាជននៅតែជួបប្រទះនៅការលំបាកនៅឡើយទេ ពោលគឺជំងឺរាតត្បាត កង្វះខាតចំណីអាហារ ជីវភាពក្រីក្រ អំពើហិង្សា ការកាប់បំផ្លាញព្រៃឈើ និងចោរកម្មនៅកើតមានឡើងខ្លាំងពេញផ្ទៃប្រទេសនៅឡើយទេ។ ក្រៅពីនេះសង្គ្រាមស៊ីវិលផ្ទុះឡើងម្តងទៀតនៅក្នុងឆ្នាំ១៩៩៧ ដែលបង្កជាភាពចលាចលនៅក្នុងផ្ទៃប្រទេស និងការខូចខាតមួយចំនួនផងដែរ បើទោះបីជាទំហំនៃជម្លោះលើកនេះតូចជាងសម័យមុនៗក្តី។ យ៉ាងណាមិញ ស្ថានភាពទាំងនេះបានប្រសើរឡើង បន្ទាប់ពីការបោះឆ្នោតនីតិកាលទី២ និងការអភិវឌ្ឍកសាងសង្គម រួមទាំងស្ថានភាពប្រជាជនត្រូវបានលូតលាស់។

ក្រាហ្វិកទី១៖ សូចនាករចោរកម្ម និងអំពើហិង្សានៅកម្ពុជាពីឆ្នាំ១៩៩២រហូតមកដល់២០១២[57]




[53] ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៣៨៣ ចុះនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨.

[54] ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៣៨៤ ចុះនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨.

[55] ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៣៨៥ ចុះនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨.

[56] ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤៥ ចុះនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣.

[57] Roderic Broadhurst et al. *Violence and the civilizing process in Cambodia*. Cambridge University Press, 2015, pp. 246-270.

យោងតាមរបាយការណ៍នៃការសិក្សារបស់សាកលវិទ្យាល័យ Cambridge សូចនាករចោរកម្ម និងហិង្សានៅក្នុងប្រទេសកម្ពុជាមានការកើនឡើងខ្លាំងក្នុងឆ្នាំ១៩៩៣ និងបានធ្លាក់ចុះមកវិញត្រឹមចំណុចក្រោម៥ករណីក្នុង១សែននាក់គិតត្រឹមឆ្នាំ២០១២។

ក្រៅពីការធ្លាក់ចុះនៃករណីចោរកម្ម និងអំពើហិង្សាក្នុងសង្គមបើធៀបទៅនឹងសម័យកាលមុនៗសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងកំណើននៃធនធានមនុស្សក៏មានការកើនឡើងជាបន្តបន្ទាប់ផងដែរ។ នៅក្នុងឆ្នាំ២០២២ កម្ពុជាសម្រេចបានសូចនាករអភិវឌ្ឍធនធានមនុស្សដល់កម្រិតមធ្យម(០.៦) ដែលសូចនាករនេះស្ថិតនៅក្នុងកម្រិតទាប(០.៣៩)តែប៉ុណ្ណោះនៅក្នុងឆ្នាំ១៩៩៣។[58] ក្រៅពីការធ្លាក់ចុះនៃអសន្តិសុខសង្គម និងកំណើននៃធនធានមនុស្ស ចំនួនប្រជាសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏មានការកើនឡើងខ្លាំងដែរ ពោលគឺមានចំនួន ១៥.៥៥លាននាក់នៅក្នុងឆ្នាំ២០១៩ ដែលច្រើនជាងឆ្នាំ២០០៨រហូតដល់ទៅ១៤.១ភាគរយ។[59] ដោយយោងតាមភស្តុតាងទាំងនេះយើងអាចសន្និដ្ឋានបានថាស្ថានភាពរបស់ប្រជាជន និងសង្គមរបស់ព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងតែខិតទៅរកភាពប្រសើរឡើង។

ចំពោះការធានានៅរបបសន្តិសុខវិញ រាជរដ្ឋាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជាបានរៀបចំប្រព័ន្ធយុត្តិធម៌យ៉ាងច្បាស់លាស់ ដោយមានរចនាសម្ព័ន្ធ ច្បាប់ នីតិវិធី និងដែនយុត្តាធិការ។ ដើម្បីធានាឯករាជ្យភាពរបស់ខ្លួន កម្ពុជាបានរៀបចំក្រសួងការពារជាតិ[60] ដែលមានកងទ័ពទាំងបីប្រភេទ(គោក ទឹក និងអាកាស) កងរាជអាវុធហត្ថលើផ្ទៃប្រទេស នាយកដ្ឋានបញ្ជូនសារ និងកងយុទ្ធពលខេមរភូមិន្ទដែលជាអ្នករក្សាសន្តិភាពជាតិពីបរទេស។[61] ចំពោះការរក្សាសន្តិភាពផ្ទៃក្នុងវិញប្រទេសកម្ពុជារៀបចំឱ្យមាននគរបាលជាតិ និងមន្ត្រីរាជការស៊ីវិលដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ដើម្បីរក្សាសណ្តាប់ធ្នាប់ និងផ្តល់សេវាសាធារណៈជូនប្រជាជន។[62] ក្រៅពីនេះកម្ពុជាក៏មាននគរបាលយុត្តិធម៌ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ដែលជាអ្នកធានានូវភាពត្រឹមត្រូវនៃការអនុវត្តច្បាប់ និងជាជំនួយការរបស់អំណាចតុលាការនៅក្នុងការអនុវត្តច្បាប់។[63] ចំពោះប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាវិញ ត្រូវបានកំណត់ និងបែងចែកជាបីថ្នាក់គឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។[64] ដូចនេះយើងអាចសន្និដ្ឋានបានថារបបសន្តិសុខនៅក្នុងសម័យកាលនេះមាន

[58] UNDP. "*Retrieved from Webpage: Human Development Index*" 29, June. 2024.

[59] ក្រសួងផែនការ, *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩*, វិទ្យាស្ថានជាតិស្ថិតិ, ២០១៩, ទំព័រ ១២-១៣.

[60] ច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ, ១៩៩៦, មាត្រា២.

[61] ក្រសួងការពារជាតិ, *"គេហទំព័រអ៊ីនធឺណិត៖ អង្គភាព ខ.ភ.ម"*, ដកស្រង់នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤.

[62] ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ, ១៩៩៦, មាត្រា២.

[63] អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌.

[64] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, *"ជំពូកទី១ បទបញ្ញត្តិទូទៅ"*, ២០១៤, មាត្រា៣.

ភាពត្រឹមត្រូវ និងល្អប្រសើរជាងសម័យកាលមុនៗ។

### ១.១.៤.៣. គោលនយោបាយ និងផែនការអភិវឌ្ឍប្រទេស

ចំពោះផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយនៅក្នុងការអភិវឌ្ឍវិញព្រះរាជាណាចក្រកម្ពុជាបានជួបប្រទះនឹងបញ្ហាមួយចំនួនធំផងដែរនៅក្នុងដើមសម័យកាលនេះ ដែលបញ្ហាទាំងនោះរួមមានបញ្ហាសន្តិសុខសង្គម វិបត្តិនយោបាយ កំណើនមរណភាព ការខូចខាតនៃហេដ្ឋារចនាសម្ព័ន្ធជាតិ និងវិបត្តិសេដ្ឋកិច្ច។[65]

ដើម្បីឆ្លើយតប និងដោះស្រាយចំពោះវិបត្តិទាំងនេះរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំផែនការយ៉ាងសកម្ម និងច្បាស់លាស់ដោយបែងចែកជាដំណាក់កាលៗ ដើម្បីធានាឱ្យបាននៅគុណភាព និងសមិទ្ធផល។ នៅក្នុងដំណើរការអភិវឌ្ឍសង្គមជាតិប្រទេសកម្ពុជាបានធ្វើការបែងចែកប្រព័ន្ធរដ្ឋបាលជាពីរថ្នាក់គឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ[66] ក្រៅពីនេះប្រទេសកម្ពុជាបានជ្រើសរើសយកប្រព័ន្ធរដ្ឋបាលវិមជ្ឈការ និងវិសហមជ្ឈការមកធ្វើជាមធ្យោបាយក្នុងការអភិវឌ្ឍន៍ជាតិ។[67]

គិតចាប់តាំងពីឆ្នាំ១៩៩៣មក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងអនុវត្តនៅផែនការអភិវឌ្ឍប្រទេសជាតិធំៗចំនួន៤គឺ រាជរដ្ឋាភិបាលសេដ្ឋកិច្ច(១៩៩៣-១៩៩៨) យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណដែលយុទ្ធសាស្ត្រទាំងនេះមានការបែងចែកជាដំណាក់កាលៗ និងទិសដៅខុសប្លែកពីគ្នាទៅតាមដំណាក់កាលនីមួយៗ។

- យុទ្ធសាស្ត្រត្រីកោណ (១៩៩៨-២០០៣) បែងចែកមុំបីសំខាន់ៗគឺ (១)សន្តិភាពូបនីយកម្ម (២)សមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់ និងសហគមន៍អន្តរជាតិ និង(៣)ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។[68]
- យុទ្ធសាស្ត្រចតុកោណ (២០០៤-២០២៣) ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖ មានអភិបាលកិច្ចល្អជាស្នូល និងមានមុំទាំងបួនដែលផ្ដោតលើកំណែទម្រង់ចំនួនបួនគឺ៖
  - + ការលុបបំបាត់អំពើពុករលួយ
  - + កំណែទម្រង់រដ្ឋបាលសាធារណៈរួមទាំងវិមជ្ឈការ និងវិសហមជ្ឈការ
  - + កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ
  - + កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាពិសេសការកាត់រំសាយទ័ព។

[65] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី៣*, Mou Seth, ២០១០, ទំព័រ២០៩-២១២.

[66] ច្បាប់ស្ដីពីការរៀបចំអង្គការ, មាត្រា៨.

[67] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "*ជំពូកទី១ អំពីបទប្បញ្ញត្តិទូទៅ*", ២០០៨, មាត្រា២.

[68] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ៣៤-៣៥.

មុំទាំងបួននេះមានគោលដៅសម្រាប់កំណើនសេដ្ឋកិច្ចដូចជា៖

+ ជំរុញវិស័យកសិកម្ម
+ ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ
+ ការស្តារនីតិសម្បទា និងការស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ
+ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។[69]

យុទ្ធសាស្ត្រនេះត្រូវបានបែងចែកជាបួនដំណាក់កាលគឺ៖

+ ដំណាក់កាលទី១ (២០០៤-២០០៨)
+ ដំណាក់កាលទី២ (២០០៨-២០១៣)
+ ដំណាក់កាលទី៣ (២០១៣-២០១៨)
+ ដំណាក់កាលទី៤ (២០១៨-២០២៣)។[70]

– យុទ្ធសាស្ត្របញ្ចកោណ (២០២៣-បច្ចុប្បន្ន) ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព៖ យុទ្ធសាស្ត្រនេះមានមុំចក្ខុវិស័យសំខាន់ៗ៥គឺ៖

+ សង្គមជាតិមួយដ៏រស់រវើក
+ ប្រទេសមានចំណូលខ្ពស់ និងមានសេដ្ឋកិច្ចធន់រឹងមាំ
+ ប្រជាជនកម្ពុជាមានចំណេះដឹង និងជំនាញមួយយ៉ាងតិចប្រចាំជីវិត
+ ប្រជាជនកម្ពុជារស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គមប្រកបដោយសមធម៌ ស្មើសិទ្ធិ ស្មើឱកាស
+ បរិស្ថានរូបវន្ត និងធម្មជាតិប្រកបដោយសុខដុមភាព, ភាពធន់, បរិយាបន្ននិងតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិ។

នៅក្នុងផែនការនេះអាទិភាពគន្លឹះត្រូវបានបែងចែកជា៥ដូចគ្នាគឺ៖

+ បញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស
+ បញ្ចកោណទី២៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង
+ បញ្ចកោណទី៣៖ ការអភិវឌ្ឍវិស័យឯកជន និងការងារ

[69] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី១*, ២០០៤, ទំព័រ ៧-៩.

[70] ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤, ទំព័រ ៣៦.

+ បញ្ចកោណទី៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព, បរិយាបន្ន
+ បញ្ចកោណទី៥៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។[71]

ក្រៅពីផែនការយុទ្ធសាស្ត្រធំៗទាំងនេះហើយ កម្ពុជាក៏មានការអភិវឌ្ឍតាមរយៈកំណែទម្រង់ និងការបង្កើតច្បាប់ផ្សេងៗទៀតដើម្បីរក្សាស្ថេរភាពសង្គម ក្នុងនោះអភិក្រមទាំងប្រាំរបស់**សម្ដេចតេជោហ៊ុន សែន**ក៏បានដើរតួរយ៉ាងសំខាន់ផងដែរ នៅក្នុងការរក្សាសណ្តាប់ធ្នាប់ និងការគោរពច្បាប់ទម្លាប់របស់មន្ត្រីសាធារណៈ។ ជាលទ្ធផលនៃផែនការយុទ្ធសាស្ត្រទាំងនេះ ប្រទេសកម្ពុជាបានទទួលកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ពោលគឺពី ២.៥៣ពាន់លានដុល្លានៅក្នុងឆ្នាំ១៩៩៣ មកដល់៣១.៧៧ពាន់លានដុល្លានៅក្នុងឆ្នាំ២០២៣ ដែលមានកំណើនជាមធ្យម(GDP per capita growth) ៥.២៤ភាគរយរាងរាល់ឆ្នាំ។[72] យោងតាមឯកសារ និងព័ត៌មានទាំងនេះយើងអាចសន្និដ្ឋានបានថាយុទ្ធសាស្ត្រដែលបានសម្រេចកន្លងមកពិតជាមានប្រសិទ្ធភាពដល់ដំណើរការអភិវឌ្ឍប្រទេសជាតិពិតមែន។

### ១.១.៤.៤. ប្រព័ន្ធរដ្ឋបាលរាជធានីភ្នំពេញនៅសម័យព្រះរាជាណាចក្រកម្ពុជាទី២

ចំពោះប្រព័ន្ធរដ្ឋបាលនៅក្នុងរាជធានីភ្នំពេញវិញ ការកែប្រែក៏បានកើតឡើងជាបន្តបន្ទាប់ផងដែរ។ នៅក្នុងដើមសតវត្សនៃសម័យកាលនេះរាជធានីភ្នំពេញត្រូវបានកំណត់បែងចែកដែនរដ្ឋបាលជា ៧ខណ្ឌ និង២៤មន្ទីរ ដែលខណ្ឌទាំងនោះមានគឺ (១)ខណ្ឌ៧មករា (២)ខណ្ឌដូនពេញ (៣)ខណ្ឌទួលគោក (៤)ខណ្ឌចំការមន (៥)ខណ្ឌមានជ័យ (៦)ខណ្ឌឫស្សីកែវ និង(៧)ខណ្ឌដង្កោ។ ចំពោះចំនួនមន្ត្រីសាធារណៈវិញគឺមានចំនួន ១៩១៣៨រូបជាមន្ត្រីក្របខណ្ឌរដ្ឋ ១៩២២រូបជាមន្ត្រីអំណែត និង៥៧៦រូបជាមន្ត្រីស្វយ័ត។[73]

មកដល់ពេលបច្ចុប្បន្ននេះ(២០២៤) រាជធានីភ្នំពេញបានបង្កើតតំបន់រដ្ឋបាលបន្ថែមដែលមានចំនួនរហូតទៅដល់១៤ខណ្ឌ ដែលខណ្ឌថ្មីៗទាំងនោះមានដូចជា៖ ខណ្ឌសែនសុខ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ ខណ្ឌព្រែកព្នៅ ខណ្ឌបឹងកេងកង និងខណ្ឌកំបូល។[74] ការគ្រប់គ្រងដែនរដ្ឋបាលរបស់រាជធានីភ្នំពេញបច្ចុប្បន្នស្ថិតនៅក្រោមបន្ទុករបស់ក្រសួងមហាផ្ទៃ[75] ចំពោះប្រព័ន្ធរដ្ឋបាលសម្រាប់គ្រប់គ្រងការងារ និងការដឹកនាំវិញ ថ្នាក់ដឹកនាំតំបន់នីមួយៗត្រូវអនុវត្តទៅតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី

[71] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដំណាក់កាលទី១*, ២០២៣, ទំព័រ ២៤-៣៤.

[72] World Bank Open Data, "*Retrieved from Webpage: GDP per capita growth (annual%) - Cambodia*", 2023.

[73] ជា សុជាតា, *រដ្ឋបាលរាជធានីភ្នំពេញ*, ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ, ១៩៩៨, ទំព័រ ២០-២១.

[74] សុខ សុវត្ថិ, "ឈ្មោះសង្កាត់ទាំង១០៥ ក្នុងខណ្ឌទាំង១៤នៃរាជធានីភ្នំពេញ", *ខ្មែរ*, ០១ មេសា ២០១៩.

[75] ច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ, ១៩៩៦, មាត្រា២.

ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ជាគោល និងតាមកំណែទម្រង់ផ្សេងៗ ដែលរាជរដ្ឋាភិបាលកម្ពុជាដាក់ឱ្យដូចជា កំណែទម្រង់សេវាសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ តាមវិមជ្ឈការ និងវិសហមជ្ឈការជាដើម។

## ១.២. ប្រព័ន្ធរៀបចំ គ្រប់គ្រងរដ្ឋបាលនៅកម្ពុជា

### ១.២.១. ប្រព័ន្ធមជ្ឈការ

#### ក. និយមន័យ

មជ្ឈការតាមវិទ្យាសាស្ត្ររដ្ឋបាល គឺជាគំរូមួយនៃមជ្ឈកម្មដែលជារបៀបក្នុងការគ្រប់គ្រងមានឋានានុក្រមតឹងរឹង និងត្រួតតាទឹកដីទាំងមូលដោយអំណាចកណ្ដាលតែមួយ។[76] ស្រដៀងគ្នានេះដែរ ប្រទេសកម្ពុជាយើងបានឱ្យនិយមន័យចំពោះពាក្យមជ្ឈការថា៖

*មជ្ឈការ គឺជាការប្រមូលផ្តុំអំណាចសម្រេចរដ្ឋបាលទាំងអស់នៅលើរដ្ឋាភិបាលបាលពោលគឺ សេចក្តីសម្រេចស្ថិតនៅលើនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ ការប្រមូលផ្តុំអំណាចរដ្ឋបាលក៏ត្រូវមានកម្រិតដែរ។ ការប្រមូលផ្តុំអំណាចរដ្ឋបាលខ្លាំងនៅពេល ដែលរដ្ឋបាលថ្នាក់ជាតិសម្រេចកិច្ចការគ្រប់យ៉ាងទាំងអស់។ ការប្រមូលផ្តុំអំណាចរដ្ឋបាលមិនសូវខ្លាំង កាលណាអំណាចសម្រេចកិច្ចការខ្លះ ត្រូវបានប្រគល់ទៅឱ្យភ្នាក់ងាររបស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកាន់កិច្ចការងារមណ្ឌលរដ្ឋបាលនីមួយៗ។*[77]

ដូចនេះយើងអាចសន្និដ្ឋានបានថា ប្រព័ន្ធមជ្ឈការ គឺជាប្រព័ន្ធរដ្ឋបាលមួយដែលអំណាចសម្រេចចិត្ត និងអំណាចក្នុងការដឹកនាំរដ្ឋទាំងមូលជារបស់រដ្ឋបាលកណ្ដាល(រដ្ឋបាលថ្នាក់ជាតិ)។

រូបភាពទី៤៖ គំរូរដ្ឋបាលបែបប្រព័ន្ធមជ្ឈការ




[76] សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល(បោះពុម្ពលើកទី២)*, Edition Angkor, ២០១៥, ទំព័រ ៦៩.

[77] គន យឿន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា(បោះពុម្ពលើកទី៤)*, សមូហកម្ម គន យឿន, ២០២៤, ទំព័រ២១-២២.

ឧទាហរណ៍. រដ្ឋាភិបាល(រដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលកណ្ដាល) ធ្វើការដឹកនាំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ(អាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) ដោយផ្ទាល់។ (ប្រព័ន្ធមជ្ឈការ)

បើមើលមកលើប្រទេសកម្ពុជាវិញ ប្រព័ន្ធមជ្ឈការមិនត្រូវបានប្រើប្រាស់ទេនៅក្នុងពេលបច្ចុប្បន្ននេះ ក៏ប៉ុន្តែវាមានប្រើប្រាស់នៅក្នុងសម័យកាលមុនៗ ដូចជាសម័យកាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលប្រមុខរដ្ឋមានតួនាទីជាអង្គនីតិបញ្ញត្តិផង និងអង្គនីតិប្រតិបត្តិផង(ធ្វើច្បាប់ផង និងអនុវត្តច្បាប់ផង) និងការគ្រប់គ្រងរដ្ឋបាលទូទៅនៅក្នុងសម័យកាលនោះក៏មានលក្ខណៈមជ្ឈការផងដែរ។

**ខ. គុណសម្បត្តិ**

ការគ្រប់គ្រង និងដឹកនាំតាមប្រព័ន្ធមជ្ឈការមានគុណសម្បត្តិមួយចំនួនដូចជា៖

- **ពង្រឹងអំណាចរដ្ឋ៖** គ្រប់កិច្ចការងាររដ្ឋបាលនៅក្រោមស្ថាប័នរដ្ឋបាលថ្នាក់ជាតិទាំងអស់ត្រូវតែឆ្លងកាត់រដ្ឋបាលថ្នាក់ជាតិ ដោយមិនគិតពីសារៈសំខាន់ និងទំហំ ដែលអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ជាតិអាចគ្រប់គ្រងកិច្ចការទូទាំងប្រទេស។
- **ពង្រឹងឯកភាពជាតិ៖** ដោយសារគ្រប់កិច្ចការទាំងអស់ត្រូវឆ្លងកាត់រដ្ឋបាលថ្នាក់ជាតិ នាំឱ្យដំណើរការសកម្មភាព ផែនការ និងគោលការណ៍អនុវត្តទាំងអស់ត្រូវតែដូចៗគ្នា។
- **សមភាពចំពោះប្រជាពលរដ្ឋ៖** ការបែងចែកផលិតផល កម្មសិទ្ធិ និងសេវាដល់ប្រជាពលរដ្ឋគឺស្មើគ្នាទាំងអស់។ កាតព្វកិច្ចរបស់ប្រជាពលរដ្ឋដូចជាការបង់ពន្ធ ការបំពេញការងារ និងកិច្ចការផ្សេងៗទៀតក៏ត្រូវតែស្មើគ្នាដែរ។

**គ. គុណវិបត្តិ**

ចំពោះគុណវិបត្តិនៃប្រព័ន្ធមជ្ឈការវិញមានដូចជា៖

- **រដ្ឋបាលថ្នាក់ជាតិទទួលបន្ទុកការងារច្រើនពេក៖** ការអនុវត្តប្រព័ន្ធនេះនាំការលំបាកដល់រដ្ឋបាលថ្នាក់ជាតិខ្លាំងពេក ដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីត្រូវជាអ្នកសម្រេចនៅរាល់កិច្ចការងារទាំងអស់គ្រប់ជាន់ថ្នាក់ ដែលអាចនាំឱ្យកិច្ចការមានភាពយឺតយ៉ាវ និងគ្មានប្រសិទ្ធភាព។
- **ការប្រមូលផ្តុំនៃអំណាចនៅរដ្ឋបាលថ្នាក់ជាតិ៖** ការអនុវត្តប្រព័ន្ធនេះបង្កឱ្យរដ្ឋបាលថ្នាក់ជាតិមានអំណាចធំធេងពេកចំពោះថ្នាក់លើ ដែលធ្វើឱ្យការងាររដ្ឋបាលថ្នាក់ក្រោមជាតិគ្មានភាពបត់បែន និងដំណើរការដូចជាម៉ាស៊ីនដែលការវិវត្ត ឬរីកចម្រើនយឺត។
- **ប្រសិទ្ធភាពនៃផែនការ និងគម្រោងផែនការអភិវឌ្ឍ៖** ការអនុវត្តប្រព័ន្ធនេះធ្វើឱ្យផែនការអភិវឌ្ឍរបស់

រដ្ឋបាលកណ្តាល និងតម្រូវការរបស់ប្រជាពលរដ្ឋមិនត្រូវគ្នា និងគ្មានប្រសិទ្ធភាពដោយសារគម្លាតរវាងបុគ្គលទាំងពីរឆ្ងាយគ្នាពេក។[78]

## ១.២.២. ប្រព័ន្ធវិមជ្ឈការ

### ក. និយមន័យ

វិមជ្ឈការ នៅក្នុងនីតិរដ្ឋបាលសំដៅដល់ការទទួលស្គាល់ពីអំណាច និងសិទ្ធិក្នុងការធ្វើស្វ័យសម្រេចចិត្តរបស់នីតិបុគ្គលសាធារណៈ ឬអាជ្ញាធរមូលដ្ឋាន ដោយក្របខណ្ឌច្បាប់។[79] សម្រាប់បរិបទសង្គមកម្ពុជាយើងវិញ ប្រព័ន្ធវិមជ្ឈការមានន័យថា៖

*វិមជ្ឈការ គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហានេះ។ ក្នុងន័យនេះ រាល់កិច្ចការនានាដែលបានធ្វើវិមជ្ឈការទៅឱ្យក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការទាំងនោះនៅមូលដ្ឋានរបស់ខ្លួន។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផងដែរ។[80]*

ជារួម យើងអាចនិយាយបានថាប្រព័ន្ធវិមជ្ឈការគឺជាប្រព័ន្ធមួយដែលរដ្ឋបាលកណ្តាលរំលែកអំណាចមួយចំនួនឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការគ្រប់គ្រង ដឹកនាំ និងសម្រេចដោយឯករាជ្យ និងស្របតាមច្បាប់។ ប្រព័ន្ធនេះគឺជាប្រព័ន្ធមួយដែលមានប្រើសព្វថ្ងៃ(២០២៤)នៅក្នុងប្រទេសកម្ពុជា។

រូបភាពទី៥៖ គំរូរដ្ឋបាលបែបប្រព័ន្ធវិមជ្ឈការ




[78] ឥន យឿន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា(បោះពុម្ពលើកទី៤)*, សមូហកម្ម ឥន យឿន, ២០២៤, ទំព័រ២២-២៣.

[79] សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល(បោះពុម្ពលើកទី២)*, Edition Angkor, ២០១៥, ទំព័រ ៦៨.

[80] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលរាជធានីតាមបែបវិមជ្ឈការ(សម្រាប់ក្រុមប្រឹក្សារាជធានី)*, NSLA, ២០១៩, ទំព័រ ៣.

ឧទាហរណ៍. (ករណីសិក្សានៃការអភិវឌ្ឍតាមប្រព័ន្ធវិមជ្ឈការ) នៅក្នុងឆ្នាំ២០១៩ ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ទទួលបានថវិកាវិនិយោគចំនួន៦៤៤,៧៧៣,០០០រៀល ហើយឃុំមានសិទ្ធិសម្រេច និងរៀបចំផែនការអភិវឌ្ឍ ដើម្បីចាត់ចែងថវិកានេះទៅតាមគម្រោង និងតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ក្នុងករណីនេះ ឃុំបានចំណាយថវិកាទៅលើការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន រដ្ឋបាល និងសន្តិសុខ។[81]

**ខ. ប្រភេទនៃវិមជ្ឈការ**

ប្រព័ន្ធវិមជ្ឈការត្រូវបានកំណត់ និងបែងចែកជាប្រាំប្រភេទគឺ៖

១. **វិមជ្ឈការនយោបាយ៖** សំដៅចំពោះស្ថានភាពទាំងឡាយណា ដែលផ្នែកខ្លះនៃអំណាចនយោបាយត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធិផលនៃសេវាសាធារណៈ។ ឧទាហរណ៍៖ ស្វយ័តប្រជាធិបតេយ្យ ភាវូបនីយកម្មការបោះឆ្នោត។

២. **វិមជ្ឈការរដ្ឋបាល៖** សំដៅចំពោះការផ្ទេរទាំងស្រុង ឬផ្នែកណាមួយនៃសិទ្ធិអំណាចក្នុងការសម្រេចចិត្ត ធនធាន និងការទទួលខុសត្រូវសម្រាប់ការផ្តល់សេវាសាធារណៈមួយចំនួនដែលត្រូវបានជ្រើសរើសពីរដ្ឋាភិបាលកណ្តាល ទៅកាន់រដ្ឋាភិបាលភ្នាក់ងារ និងការិយាល័យរបស់ភ្នាក់ងារពាក់ព័ន្ធរបស់រដ្ឋាភិបាលកណ្តាលដែលមានកម្រិតទាបជាង។ ឧទាហរណ៍៖ ប្រតិភូកម្ម(Delegation) និងការផ្ទេរសិទ្ធិទាំងស្រុង/វិមជ្ឈការពេញលេញ(Devolution)។

៣. **វិមជ្ឈការហិរញ្ញវត្ថុ៖** សំដៅចំពោះការវិភាជធនធានទៅដល់រដ្ឋបាលមូលដ្ឋាន ដែលអនុញ្ញាតឱ្យរដ្ឋបាលមូលដ្ឋាននេះ អនុវត្តនៅមុខងារមួយចំនួន ដែលត្រូវបានធ្វើវិមជ្ឈការ។ឧទាហរណ៍៖ ការរកប្រាក់ចំណូល ការរៀបចំប្រាក់ចំណាយចំណូល។

៤. **វិមជ្ឈការសេដ្ឋកិច្ច៖** សំដៅចំពោះការផ្ទេរនៃមុខងារដែលបំពេញផ្តាច់មុខដោយរាជរដ្ឋាភិបាលទៅឱ្យឯកជនអ្នកអនុវត្ត ដែលវាជួយលើកកម្ពស់ការចូលរួមពីអង្គការជំនាញ និងអង្គការមិនមែនរដ្ឋាភិបាល (NGO)។ ឧទាហរណ៍៖ អនិយ័តកម្ម ឬការបន្ធូរបន្ថយផ្លូវច្បាប់(Deregulation) ឯកជនភាវូបនីយកម្ម (Privatization) និងសារជីវកម្មភាវូបនីយកម្ម(Corporatization)។[82]

[81] ជី ឧត្តម &ថា ចាន់ធាន, *ការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការ*, ស.ភ.ន.វ.ស, ២០២០, ទំព័រ ៣០-៣១.

[82] សឿន សោភ័ណ, *សេចក្តីផ្តើមរដ្ឋបាលសាធារណៈ (បោះពុម្ពលើកទី១)*, ណៃ ដារ៉ា, ២០១៩, ទំព័រ ៦៧-៧០.

៥. **វិមជ្ឈការបច្ចេកទេស៖** សំដៅចំពោះការផ្ទេរនៃសិទ្ធិអំណាច និងទំនួលខុសត្រូវនៃ មុខងារបច្ចេកទេសណាមួយទៅឱ្យអាជ្ញាធរបច្ចេកទេសមួយគ្រប់គ្រងតាមច្បាប់ ដើម្បីបម្រើផលប្រយោជន៍ទូទៅប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍៖ ការផ្ទេរទំនួលខុសត្រូវពីរដ្ឋាភិបាលទៅឱ្យ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(ម.ស.ម.ក.)។ ខ្លឹមសារនៃព្រះរាជក្រឹត្យ៖

*មាត្រា៣៖ ម.ស.ម.ក. ត្រូវបំពេញភារកិច្ចដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ។ ភារកិច្ចទាំងឡាយណាដែលមានចែងនៅក្នុងមាត្រា៤ មាត្រា៥ នៃព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ត្រូវផ្ទេរជូនអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយមីន ជាអ្នកអនុវត្ត និងទទួលខុសត្រូវជំនួសវិញ។ ការទទួលខុសត្រូវក្នុងការកំទេចគ្រាប់មីនដូចមានចែងខាងលើ គឺជាបន្ទុករបស់ ម.ស.ម.ក។*[83]

**គ. គុណសម្បត្តិ**

ប្រព័ន្ធវិមជ្ឈការមានគុណសម្បត្តិធំៗចំនួនបីគឺ៖

- **ផ្នែកសង្គមកិច្ច៖** ការអនុវត្តឱ្យមានប្រព័ន្ធវិមជ្ឈការពិតប្រាកដប្រកបដោយអំណាចសម្រេចស្វ័យភាពជាក់ស្តែងនាំឱ្យមានការរីកចម្រើនដល់សង្គម និងប្រជាពលរដ្ឋ ដែលវាអនុញ្ញាតឱ្យប្រជាពលរដ្ឋយល់ដឹងច្បាស់ពី របៀបរបបនៃការគ្រប់គ្រងរដ្ឋបាលនៅមូលដ្ឋានរបស់ពួកគេ។[84]
- **ផ្នែកនយោបាយ៖** ប្រព័ន្ធនេះបន្ថយអំណាចលើសលុបរបស់រដ្ឋបាលកណ្តាល និងបង្កើនលក្ខណៈប្រជាធិបតេយ្យនៅតាមមូលដ្ឋាន ពោលគឺផ្តល់ឱកាសឱ្យមានការចូលរួមក្នុងកិច្ចការអភិវឌ្ឍប្រទេសជាតិពីតំបន់មូលដ្ឋាន។
- **ផ្នែករដ្ឋបាល៖** ប្រព័ន្ធនេះពង្រឹងការទទួលខុសត្រូវរបស់រដ្ឋបាលមូលដ្ឋាន បង្កើនគំនិតក្នុងការធ្វើផែនការអភិវឌ្ឍ និងលើកស្ទួយការគិតប្រយោជន៍ទូទៅឱ្យបានប្រសើរជាងមុន។

**ឃ. គុណវិបត្តិ**

ប្រព័ន្ធវិមជ្ឈការមានគុណវិបត្តិចំនួនពីរគឺ៖

- **ផ្នែកនយោបាយ៖** ប្រទេសជាតិអាចប្រឈមនឹងការបាត់បង់ឯកភាពជាតិ ដោយសារការកើនឡើងខ្លាំង

[83] ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦៤ ចុះនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១.

[84] សាយ បូរី, *នីតិរដ្ឋបាលទូទៅ (បោះពុម្ពលើកទី៥),* Editions Angkor, ២០១២, ទំព័រ ៤០០.

នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានឯករាជ្យភាពខ្លាំង នោះរដ្ឋបាលថ្នាក់ក្រោមជាតិអាចនឹងមិនស្តាប់តាម និងមិនអនុវត្តតាមថ្នាក់លើ(រដ្ឋបាលថ្នាក់ជាតិ)។

- **ផ្នែករដ្ឋបាល៖** ប្រព័ន្ធមួយនេះទាមទារឱ្យមានធនធានមនុស្សច្រើន(អ្នកចេះដឹង) ព្រោះបើផ្ទេរវិមជ្ឈការសិទ្ធិអំណាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយ ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិមិនមានធនធានមនុស្សគ្រប់គ្រាន់ មិនចេះធ្វើផែនការ និងមិនអាចបំពេញកិច្ចការបានល្អនោះនឹងធ្វើឱ្យការអភិវឌ្ឍគ្មានប្រសិទ្ធភាព និងតម្រូវការប្រជាជនមិនបានត្រូវបានឆ្លើយតប។[85]

### ១.២.៣. ប្រព័ន្ធវិសហមជ្ឈការ

#### ក.និយមន័យ

យោងតាមក្រសួងមហាផ្ទៃប្រព័ន្ធវិសហមជ្ឈការត្រូវបានឱ្យនិយមន័យដូចខាងក្រោម៖

*វិសហមជ្ឈការ គឺជាការដែលរដ្ឋាភិបាល ឬក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តនៅក្នុងនាមរដ្ឋាភិបាល ឬក្រសួងស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មនោះ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអនុវត្តកិច្ចការទាំងនោះតាមការណែនាំ ឬចង្អុលបង្ហាញពីរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន ហើយការទទួលខុសត្រូវចុងក្រោយចំពោះការអនុវត្តកិច្ចការទាំងនេះនៅតែជារបស់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មដដែល។*[86]

ក្នុងន័យសាមញ្ញ ប្រព័ន្ធវិសហមជ្ឈការ គឺជាប្រព័ន្ធមួយដែលរដ្ឋបាលថ្នាក់ជាតិអនុញ្ញាតឱ្យរដ្ឋបាលមូលដ្ឋានបំពេញមុខងារមួយចំនួនជំនួសរដ្ឋបាលថ្នាក់ជាតិ ក្នុងនាមរដ្ឋបាលថ្នាក់ជាតិ និងតាមគោលការណ៍នីតិវិធីដែលរដ្ឋបាលថ្នាក់ជាតិបានកំណត់ឱ្យ។ ហើយប្រព័ន្ធរដ្ឋបាលបែបនេះក៏ជាប្រព័ន្ធមួយដែលមានប្រើប្រាស់សព្វថ្ងៃ(២០២៤)នៅក្នុងប្រទេសកម្ពុជាផងដែរ។

ឧទាហរណ៍៖ រាជរដ្ឋាភិបាលកម្ពុជាមានក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ បានធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ។[87] នៅក្នុងន័យនេះក្រសួងនឹងផ្តល់នូវធនធាន ការបណ្តុះបណ្តាល លក្ខន្តិក

[85] តន យឿន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា(បោះពុម្ពលើកទី៤)*, សមូហកម្ម តន យឿន, ២០២៤, ទំព័រ២៤-២៥.

[86] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលរាជធានីតាមបែបវិមជ្ឈការ(សម្រាប់ក្រុមប្រឹក្សារាជធានី)*, NSLA, ២០១៩, ទំព័រ ៣.

[87] អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ.

ផ្សេងៗដល់រដ្ឋបាលមូលដ្ឋានសម្រាប់អនុវត្តក្នុងនាមរដ្ឋបាលកណ្តាល។

**ខ. គុណសម្បត្តិ**

ប្រព័ន្ធវិសហមជ្ឈការមានគុណសម្បត្តិចំនួនពីរសំខាន់ៗគឺ៖

- **ផ្នែកនយោបាយ៖** កាត់បន្ថយបន្ទុករបស់រដ្ឋបាលថ្នាក់ជាតិ តាមរយៈការផ្ទេរមុខងារ និងអំណាចមួយចំនួនឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញជំនួស ដែលវាអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ជាតិបំពេញការងារបានល្អប្រសើរ។
- **ផ្នែករដ្ឋបាល៖** កាត់បន្ថយគម្លាតសង្គមរវាងរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ ដោយរដ្ឋបាលថ្នាក់ជាតិនៅទទួលបានព័ត៌មានគ្រប់គ្រាន់ពីមូលដ្ឋាន។

**គ. គុណវិបត្តិ**

ប្រព័ន្ធវិសហមជ្ឈការមានគុណវិបត្តិចំនួន២សំខាន់ៗគឺ៖

- **ផ្នែកនយោបាយ៖** រដ្ឋបាលថ្នាក់ក្រោមជាតិអាចនឹងប្រើប្រាស់អំណាចដើម្បីបម្រើប្រយោជន៍ផ្ទាល់ខ្លួន ដោយប្រើនាមរដ្ឋបាលកណ្តាលដែលអាចប៉ះពាល់ដល់ស្ថេរភាពសង្គម។
- **ផ្នែករដ្ឋបាល៖** រដ្ឋបាលថ្នាក់ជាតិពិបាកក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទៅលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញភារកិច្ចក្នុងនាមរបស់ខ្លួន។[88]

### ១.២.៤. សហាគ្គិភាពរវាងវិមជ្ឈការ និងវិសហមជ្ឈការ

សហគ្គិភាពរវាងវិមជ្ឈការ និងវិសហមជ្ឈការគឺជាបច្ចេកទេសនៃការគ្រប់គ្រងរដ្ឋបាលមួយប្រភេទដែលអនុញ្ញាតឱ្យមានការអនុវត្តលាយបញ្ចូលគ្នារវាងប្រព័ន្ធវិមជ្ឈការ និងប្រព័ន្ធវិសហមជ្ឈការ ដើម្បីជួយបំពេញបន្ថែម និងដោះស្រាយចំពោះគុណវិបត្តិដែលប្រព័ន្ធនីមួយៗមានស្រាប់ (អំណាចនៃបច្ចេកទេសនេះមានលក្ខណៈសម្របសម្រួល)។[89]

ឧទាហរណ៍៖ ការអនុវត្តនៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈតាមបែបមជ្ឈការ និងបែបវិសហមជ្ឈការ។ ការអនុវត្តនេះបានបំពេញបន្ថែមចំណុចអវិជ្ជមានឱ្យគ្នា ដោយការប្រគល់នូវភាពជាម្ចាស់ចំពោះមុខងារ និងសិទ្ធិអំណាចមួយចំនួន ដើម្បីស្វ័យភាពមូលដ្ឋាន រួមជាមួយនឹងការធ្វើប្រតិភូកម្មចំពោះមុខងារមួយចំនួនទៀត ដែលមានសារៈសំខាន់ខ្លាំង

[88] គន យឿន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា(បោះពុម្ពលើកទី៤)*, សមូហកម្ម គន យឿន, ២០២៤, ទំព័រ២៧.
[89] ង៉ីយ ធឿន, *ប្រព័ន្ធរដ្ឋបាលកម្ពុជា*, សាលាភូមិន្ទរដ្ឋបាល, ២០១៨, ទំព័រ ១៣.

ហើយទាមទារការដឹងឮពីរដ្ឋបាលកណ្តាល។

## ១.៣. ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា

### ១.៣.១. ក្របខណ្ឌគតិយុត្ត

នៅក្នុងគោលដៅកំណែទម្រង់រដ្ឋបាលសាធារណៈ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យឱ្យកាន់ល្អប្រសើរឡើងចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយគ្រប់គ្រងតាមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញដើម្បីឱ្យស្របទៅនឹងការគ្រប់គ្រងរដ្ឋបាលនាពេលបច្ចុប្បន្ន។ នៅក្នុងការឆ្លើយតបទៅនឹងការគ្រប់គ្រងរដ្ឋបាលសម័យទំនើបវិសោធនកម្មមាត្រា១៤៥ថ្មី(មួយ) និងមាត្រា១៤៦ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ត្រូវបានធ្វើឡើង។[90]

ក្រៅពីវិសោធនកម្មនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បានរៀបចំឡើងនូវច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗទៀតដើម្បីរៀបចំ និងគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព និងរបៀបរៀបរយផងដែរ។ មូលដ្ឋានច្បាប់ទាំងអស់នោះមានដូចខាងក្រោម៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[90] តន យឿន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា(បោះពុម្ពលើកទី៤)*, សមូហកម្ម តន យឿន, ២០២៤, ទំព័រ១៣៤-១៣៦.

- អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- ប្រកាសលេខ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃស្តីពី ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- ប្រកាសលេខ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃស្តីពី ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- សៀវភៅណែនាំស្តីពី កិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥
- និងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងកិច្ចការនេះ។

### ១.៣.២. មូលហេតុនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

មូលហេតុនៃការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចំពោះការរៀបចំ និងកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិគឺដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយគម្លាតរវាងសេវាសាធារណៈ និងប្រជាពលរដ្ឋមូលដ្ឋាន។ ការអនុវត្តបែបនេះមានការរំពឹងថានឹងនាំមកនូវប្រយោជន៍មួយចំនួនដូចជា៖

- ប្រជាពលរដ្ឋមានលទ្ធភាពក្នុងការចូលរួមយ៉ាងសកម្ម ក្នុងការធ្វើការសម្រេចចិត្តនៅមូលដ្ឋានដែលវាជួយពង្រឹង និងពង្រីកការចូលរួមជាសាសធារណៈក្នុងការអភិវឌ្ឍប្រទេសជាតិ។ យោងតាមលទ្ធផលនៃការចូលរួមនេះ តម្រូវការ និងអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ត្រូវបានគិតគូរយកចិត្តទុកដាក់ និងឆ្លើយតប ដែលវាធ្វើឱ្យការសម្រេចចិត្ត និងការប្រើប្រាស់ធនធាននានាកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព។
- ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័នថ្នាក់ ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាពព្រោះអ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈទាំងអស់នេះត្រូវបានផ្ទេរ ឬបង្វិតឱ្យទៅមូលដ្ឋានដែលនៅជិតនឹងប្រជាពលរដ្ឋ។

- ការបង្កើនលទ្ធភាពក្នុងការកៀរគរប្រភពធនធាននៅមូលដ្ឋាន សម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍបន្ថែមទៀត ដោយផ្អែកលើឆន្ទៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ក៏ដូចជាការកៀរគរធនធានពីវិស័យឯកជននានា ឱ្យចូលរួមជាមួយប្រភពធនធានរបស់អាជ្ញាធរមូលដ្ឋានសម្រាប់ការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។[91]

### ១.៣.៣. គោលដៅនៃកំណែទម្រង់រដ្ឋបាល

ការបង្កើតនិងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាទិដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ កំណែទម្រង់នេះមានគោលដៅយុទ្ធសាស្ត្រចំនួនបីគឺៈ

- ពង្រឹងលិទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន
- លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច
- ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ។

ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្រខាងលើនេះកំណែទម្រង់ចាំបាច់ត្រូវបានរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងដើម្បី (១) ធានានិរន្តភាពនៃការអភិវឌ្ឍដោយពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចមូលដ្ឋាន (២)ធានាចំពោះភាពស្មើគ្នានៃឱកាសក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការមូលដ្ឋានរបស់ប្រជាពលរដ្ឋគ្រប់រូប និង(៣)បង្កើតនូវបរិយាកាសប្រកបដោយប្រសិទ្ធភាពសម្រាប់គ្រប់គ្រងធនធានធម្មជាតិ និងសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព។[92]

### ១.៣.៤. គំនូសប្រៀបធៀបការរៀបចំរដ្ឋបាលដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា

ខាងក្រោមនេះ ជាគំនូសតាងប្រៀបធៀប ដើម្បីបង្ហាញពីបម្រែបម្រួល និងលក្ខណៈនៃរដ្ឋបាលដែនដីរបស់ព្រះរាជាណាចក្រកម្ពុជាទី២មុន និងក្រោយពេលធ្វើកំណែទម្រង់ និងវិសោធនកម្ម។

នៅក្នុងនោះយើងសង្កេតឃើញថា នៅក្នុងពេលអតីតកាលរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងមានថ្នាក់ស្មើគ្នា ឬស្ថិតនៅក្នុងថ្នាក់តែមួយ។ ប៉ុន្តែនៅក្នុងប្រព័ន្ធរដ្ឋបាលថ្មីរាជធានី ត្រូវបានចាត់ទុកជារដ្ឋបាលថ្នាក់ស្មើខេត្ត ចំណែកឯរដ្ឋបាលក្រុងវិញ ត្រូវបានប្តូរមកជារដ្ឋបាលចំណុះឱ្យរដ្ឋបាលខេត្តវិញ។ ដោយឡែក ចំពោះចំនួនថ្នាក់នៃរដ្ឋបាលដែនដីនេះ គឺមិនមានការកែប្រែឡើយ។

[91] គ.ជ.អ.ប., *សៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ*, ២០០៩, ទំព័រ ៧.
[92] គ.ជ.អ.ប., *សៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ*, ២០០៩, ទំព័រ ៨.

រូបភាពទី៦៖ គំនូសបំព្រួញអំពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា[93]




[93] យកគំរូ និងកែសម្រួលមកពី៖ ឥន យឿន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា(បោះពុម្ពលើកទី៤)*, សម្ងហកម្ម ឥន យឿន, ២០២៤, ទំព័រ១៣៨.

# ជំពូកទី២

# ដំណើរការគ្រប់គ្រងរដ្ឋបាល

# របស់

# សាលារាជធានីភ្នំពេញ

# ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ

## ២.១. ទិដ្ឋភាពទូទៅរបស់រាជធានីភ្នំពេញ

ដើម្បីសិក្សាទិដ្ឋភាពទូទៅរបស់រាជធានីភ្នំពេញ ចំណុចសំខាន់ៗចំនួន៤ នឹងត្រូវបានលើកយកមកបង្ហាញដែលក្នុងនោះមានដូចជាៈ ភូមិសាស្ត្រ អាកាសធាតុ ផ្ទៃដីនិងប្រជាជន និងសេដ្ឋកិច្ច។

### ២.១.១. ភូមិសាស្ត្រ

នៅក្នុងប្រទេសកម្ពុជា រាជធានីភ្នំពេញគឺជារាជធានី និងជាទីក្រុងធំជាងគេបង្អស់។ បន្ថែមពីនេះរាជធានីភ្នំពេញក៏ជាមជ្ឈមណ្ឌលសន្តិសុខ នយោបាយ សេដ្ឋកិច្ច សម្បត្តិវប្បធម៌ និងការទូតផងដែរ។ រាជធានីនេះមានព្រំប្រទល់ទាំងបួនជាប់នឹងខេត្តកណ្តាល[94] និងទទួលបានការកែសម្រួលដែនដី ព្រំប្រទល់ ទាំងអស់ប្រាំដំណាក់កាលគិតចាប់ពីក្រោយរបបប្រល័យពូជសាសន៍(សម័យកាលកម្ពុជាប្រជាធិបតេយ្យ ឬរបបប៉ុលពត)មក ដែលដំណាក់កាលទាំងប្រាំនោះមានៈ

១. លើកទី១ គឺការបញ្ចូលស្រុកដង្កោ

២. លើកទី២ គឺការបង្កើតខណ្ឌឫស្សីកែវ

៣. លើកទី៣ គឺការបញ្ចូល៤ភូមិ របស់ឃុំកន្ទោក មកក្នុងដែនដីរដ្ឋបាលរាជធានីភ្នំពេញ

៤. លើកទី៤ គឺការបញ្ចូល២០ឃុំ របស់ស្រុក៥(ពញាឮ មុខកំពូល កៀនស្វាយ កណ្តាលស្ទឹង អង្គស្នួល) នៃខេត្តកណ្តាល មកក្នុងដែលដីរដ្ឋបាលរាជធានីភ្នំពេញ។

៥. លើកទី៥ គឺការបញ្ចូល៥ភូមិ របស់សង្កាត់៤(ដើមមៀន ព្រែកឫស្សី តាក្តុល ព្រែកហូរ) នៃខេត្តកណ្តាល មកក្នុងដែនដីរដ្ឋាលរាជធានីភ្នំពេញ។[95]

រាជធានីភ្នំពេញស្ថិតនៅក្នុងតំបន់ខាងត្បូង-កណ្តាលនៃព្រះរាជាណាចក្រកម្ពុជា នៅចំណុចប្រសព្វនៃទន្លេមេគង្គនិងទន្លេបាសាក់ ដែលទន្លេទាំងពីរនេះផ្តល់នៅអេកូឡូស៊ីទឹកសាប និងទន្លេប្រកបដោយសក្តានុពលជាធនធានដ៏សំខាន់សម្រាប់លក្ខខណ្ឌបរិស្ថានប្រកបដោយចីរភាព សោភ័ណភាព ធម្មជាតិ និងវប្បធម៌ប្រកបដោយភាពចម្រុងចម្រើងតាំងពីអតីតកាលរហូតមកដល់ពេលបច្ចុប្បន្នសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ។ ភ្នំពេញស្ថិតនៅចំពីមុខទន្លេមេគង្គ(មានបណ្តោយប្រវែង ៤២០០គីឡូម៉ែត្រ) ដែលជាទន្លេ

[94] ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១២០.

[95] ព្រះរាជក្រឹត្យ នស/រកត/១០២០/១១០៨ ចុះនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០.

ដ៏សំខាន់មួយនៅអាស៊ី។ ទន្លេនេះមានប្រភពដើមមកពីតំបន់ខ្ពង់រាបទីបេ នៃប្រទេសចិន និងហូរកាត់ប្រទេសកម្ពុជាពីជើងទៅត្បូងមានបណ្ដោយប្រវែងសរុបប្រវែង ៤៨៦គីឡូម៉ែត្រ ហើយកាត់ភូមិសាស្ត្ររាជធានីភ្នំពេញ ដែលជាចំណុចប្រសព្វទន្លេបួនមុខ(ទន្លេចតុមុខ) បង្កើតបានជាប្រព័ន្ធអេកូឡូស៊ី និងទឹកសាប ដ៏គួរឱ្យទាក់ទាញមួយសម្រាប់រាជធានីភ្នំពេញ។[96]

## ២.១.២. អាកាសធាតុ

រាជធានីភ្នំពេញមានអាកាសធាតុក្ដៅពេញមួយឆ្នាំ ដោយគ្រាន់តែមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ និងមានសីតុណ្ហភាពចាប់ពី ១៨អង្សារដល់ ៣៨អង្សារសេ ដែលត្រូវនឹង ៦៤ដល់១០០អង្សារហ្វារិនហាយ។ ចំពោះរដូវវិញគឺត្រូវបានកំណត់បែងចែកជាពីរគឺ៖

- រដូវប្រាំង ចាប់ពីខែធ្នូ ដល់ខែឧសភា (រយៈពេល៦ខែ)
- រដូវវស្សា ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា (រយៈពេល៦ខែ)[97]

ចំពោះបរិមាណទឹកភ្លៀងនៅក្នុងរាជធានីភ្នំពេញគិតជាមធ្យមគឺ ១.៣៧៨ មម/ឆ្នាំ។

## ២.១.៣. ផ្ទៃដី និងប្រជាជន

រាជធានីភ្នំពេញមានសណ្ឋានដីជាវាលទំនាប ដែលមានផ្ទៃក្រឡាសរុប ៦៩៥.៤៦គម$^{2}$(គីឡូម៉ែត្រការ៉េ) និងមានប្រជាជនសរុបប្រមាណជា ២.២៨១.៩៥១នាក់(យោងតាមជំរឿនប្រជាជនឆ្នាំ២០១៩) រួមជាមួយនឹងដង់ស៊ីតេប្រជាជន ៣.២៨១នាក់/គម$^{2}$។

តារាងទី២៖ លទ្ធផលជំរឿនប្រជាជនឆ្នាំ២០១៩[98]

| ប្រភេទព័ត៌មាន | ចំនួន |
|---|---|
| ចំនួនប្រជាជនសរុប | ២.២៨១.៩៥១ នាក់ |
| ស្រី | ១.១៧៦.២៧៨ នាក់ |
| ប្រុស | ១.១០៥.៦៧៣ នាក់ |
| ចំនួនគ្រួសារ | ៤៩៩.២៩៩ គ្រួសារ |
| ទំហំគ្រួសារ | ៤,៥៧ |

[96] សាលារាជធានីភ្នំពេញ, *"គេហទំព័រអ៊ីនធឺណិត៖ រាជធានីភ្នំពេញ"*, ដកស្រង់នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤.
[97] សាលារាជធានីភ្នំពេញ, *"គេហទំព័រអ៊ីនធឺណិត៖ រាជធានីភ្នំពេញ"*, ដកស្រង់នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤.
[98] ដកស្រង់ និងកែសម្រួលមកពី៖ ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១១៩.

នៅក្នុងការគ្រប់គ្រងដែនដីដ៏ធំនេះ រាជធានីភ្នំពេញត្រូវបានបែងចែកជា ១៤ខណ្ឌ ១០៥សង្កាត់ និង ៩៥៨ភូមិ។[99] (ផែនទីរដ្ឋបាលរាជធានីភ្នំពេញមាននៅក្នុងឧបសម្ព័ន្ធទី៩)

### ២.១.៤. សេដ្ឋកិច្ច

យោងតាមឯកសាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានភាពរីកចម្រើនគ្រប់វិស័យទាំងអស់ ហើយនៅក្នុងឆ្នាំ២០២៣ ប្រទេសកម្ពុជាសម្រេចបាននៅផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់ ១៩១៧ដុល្លាអាមេរិក។ បន្ថែមពីនេះ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗនេះត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ២០៧១ដុល្លាអាមេរិកនៅក្នុងឆ្នាំ២០២៤។[100]

នៅក្នុងការគ្រប់គ្រងនិងលើកស្ទួយវិស័យសេដ្ឋកិច្ចនិងទីផ្សារ រាជធានីភ្នំពេញបច្ចុប្បន្នមានផ្សារសរុបចំនួន ២៨១ផ្សារ ដែលក្នុងនោះមានផ្សាររដ្ឋចំនួន២៧ ផ្សារឯកជនចំនួន៤៧ ផ្សារទំនើបធំៗចំនួន២៧ ផ្សារទំនើបតូចចំនួន១៦២ និងផ្សារផ្សេងៗទៀត(ដូចជាផ្សារក្រមួនជាដើម)ចំនួន១៨។[101] ក្រៅពីនេះរាជធានីភ្នំពេញមានច្រកទ្វារនៃកំណើនសេដ្ឋកិច្ចសំខាន់ពីរគឺ លិច-កើត៖ បាងកក-ភ្នំពេញ-ហូជីមិញ និងកើត-ត្បូង៖ ក្រុងព្រះសីហនុ-ភ្នំពេញ-តំបន់ទន្លេមេគង្គលើ។

ចំពោះផ្នែកទេសចរណ៍វិញ រាជធានីភ្នំពេញទទួលបានភ្ញៀវទេសចរណ៍ជាមធ្យមចំនួន ៩៥០.០០០នាក់ក្នុងមួយឆ្នាំ។[102]

ចំពោះឱកាសក្នុងការវិនិយោគ រាជធានីភ្នំពេញធ្វើការជំរុញនិងលើកទឹកចិត្តទៅលើវិស័យធំៗចំនួន៥គឺ៖ (១)ឧស្សាហកម្មកែច្នៃ (២)ឧស្សាហកម្មខ្នាតតូច-មធ្យម (៣)កសិ-ឧស្សាហកម្ម (៤)សេវាបម្រើទេសចរណ៍ និង (៥)ឧស្សាហកម្មអតិពលកម្ម។

## ២.២. ការរៀបចំសាលារាជធានីភ្នំពេញ

នៅក្នុងការរៀបចំគ្រប់គ្រងនិងអនុវត្តគោលនយោបាយនានា សាលារាជធានីភ្នំពេញត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ។[103] ចំពោះការដឹកនាំ និងការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញវិញ គឺត្រូវដឹកនាំដោយតួរអង្គសំខាន់ៗចំនួនពីរគឺ (១)ក្រុមប្រឹក្សារាជធានី និង(២)គណៈអភិបាលរាជធានីភ្នំពេញ។ នៅក្នុងការ

---

[99] ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១១៩-១២០.

[100] Cambodia communication, "Cambodia's per capita GDP to exceed 2000$ in 2024", *Japan-Cambodia Association*, No.23/80, 2024.

[101] ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១២៤.

[102] សាលារាជធានីភ្នំពេញ, *"គេហទំព័រអ៊ីនធឺណិត៖ រាជធានីភ្នំពេញ"*, ដកស្រង់នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤.

[103] ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ, ១៩៩៦, មាត្រា២.

បំពេញកិច្ចការងាររដ្ឋបាលរបស់សាលារាជធានីភ្នំពេញ សាលារាជធានីភ្នំពេញត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានសម្រេចដាក់ឱ្យប្រើប្រាស់ដោយក្រសួងមហាផ្ទៃ និងចំពោះកិច្ចការគតិយុត្តនានាគឺត្រូវអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធ។

ក្រៅពីនេះ សាលារាជធានីភ្នំពេញបានកំណត់នឹងបែងចែកយ៉ាងច្បាស់ផងដែរ ចំពោះរចនាសម្ព័ន្ធ និងសេវាសាធារណៈ(សេវារដ្ឋបាល)ដែលផ្តល់ឱ្យដោយសាលារាជធានីភ្នំពេញ។

### ២.២.១. រចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ

រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញនេះត្រូវបានរៀបចំឡើងដោយអនុលោមតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នៅក្នុងអនុក្រឹត្យនេះ រចនាសម្ព័ន្ធគ្រប់គ្រងកម្រិតរាជធានី ខេត្ត ត្រូវបានកំណត់ដូចតទៅ៖ (១)សាលារាជធានី ខេត្ត (២)លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង (៣)មន្ទីរ និងអង្គភាពជំនាញ (៤)ការិយាល័យ និង(៥)អង្គភាពថ្នាក់ក្រោមការិយាល័យ។ មុខតំណែងនៅក្នុងនេះត្រូវបានកំណត់បែងចែកជា(១)អភិបាលនៃគណៈអភិបាល (២)អភិបាលរងនៃគណៈអភិបាល (៣)ប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង (៤)នាយករដ្ឋបាល (៥)ប្រធានមន្ទីរ/នាយករងរដ្ឋបាល/អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង (៦)នាយកទីចាត់ការ/ប្រធានអង្គភាពលទ្ធកម្ម (៧) អនុប្រធានមន្ទីរ (៨) នាយករងទីចាត់ការ/អនុប្រធានអង្គភាពលទ្ធកម្ម (៩)ប្រធានការិយាល័យ (១០)អនុប្រធានការិយាល័យ និង (១០)មុខតំណែងថ្នាក់ក្រោមអនុប្រធានការិយាល័យ។[104]

ចំពោះរចនាសម្ព័ន្ធដឹកនាំរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានយ៉ាងច្រើនពីររូបជាជំនួយការ ដែលប្រធានការិយាល័យត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវដោយផ្ទាល់ចំពោះនាយកទីចាត់ការរបស់ខ្លួន និងនាយករដ្ឋបាលសាលារាជធានី។[105] ទីចាត់ការនីមួយៗត្រូវទទួលខុសត្រូវ ត្រួតពិនិត្យ និងគ្រប់គ្រងដោយផ្ទាល់ពីនាយកទីចាត់ការមួយរូប និងនាយករងទីចាត់ការយ៉ាងច្រើនពីររូបជាជំនួយការ ដែលនាយកទីចាត់ការត្រូវមានគណនេយ្យភាព និងទទួលខុសត្រូវដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលារាជធានី។ រីឯនាយករដ្ឋបាលសាលារាជធានី ដែលដឹកនាំ

[104] អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ.

[105] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

ដោយនាយកមួយរូប និងនាយករងបីរូបជាជំនួយការ ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះគណៈអភិបាល អភិបាល និងក្រុមប្រឹក្សារបស់ខ្លួន។[106]

រដ្ឋបាលសាលារាជធានីភ្នំពេញត្រូវបានរៀបចំឡើងឱ្យមានទីចាត់ការចំនួន៩ និងអង្គភាពចំនួន៣[107] គឺ៖

- ទីចាត់ការរដ្ឋបាល មានការិយាល័យ៤
- ទីចាត់ការផែនការនិងវិនិយោគ មានការិយាល័យ៤
- ទីចាត់ការហិរញ្ញវត្ថុ មានការិយាល័យ៣
- ទីចាត់ការរៀបចំក្រុង មានការិយាល័យ២
- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស មានការិយាល័យ២
- ទីចាត់ការអន្តរវិស័យ មានការិយាល័យ២
- ទីចាត់ការកិច្ចការច្បាប់និងសិទ្ធិមនុស្ស មានការិយាល័យ២
- ទីចាត់ការគ្រប់គ្រងសំណល់និងបរិស្ថាន មានការិយាល័យ២
- ទីចាត់ការទំនាក់ទំនងសាធារណៈនិងសហប្រត្តិបត្តិការអន្តរជាតិ មានការិយាល័យ២
- អង្គភាពលទ្ធកម្ម
- អង្គភាពច្រកចេញចូលតែមួយ
- រដ្ឋាករគ្រប់គ្រងសម្រាមនិងសំណល់រឹង។

រូបភាពទី៧៖ រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ[108]




[106] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[107] (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

[108] ដកស្រង់និងកែសម្រួលមកពី៖ (ឧបសម្ព័ន្ធទី១១) វណ្ណា សុរិទូ, រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ, ២០២៤.

### ២.២.២. សេវាសាធារណៈ

សេវាសាធារណៈ(សេវារដ្ឋបាល)ដែលរដ្ឋបាលសាលារាជធានីភ្នំពេញផ្តល់ឱ្យដោយផ្ទាល់គឺត្រូវអនុវត្ត ដោយអង្គភាពច្រកចេញចូលតែមួយ ដោយអនុលោមតាមអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ រដ្ឋបាលរាជធានី ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ តាមរយៈអង្គភាពច្រកចេញចូលតែមួយ មានដូចខាងក្រោម ៖

- ការងារនីត្យានុកូលកម្ម(ការបញ្ជាក់លើឯកសារថតចម្លង)
- ការងាររដ្ឋបាល
- វិស័យសុខាភិបាល
- វិស័យទេសចរណ៍
- វិស័យសាធារណការ និងដឹកជញ្ជូន
- វិស័យវប្បធម៌ និងវិចិត្រសិល្បៈ
- វិស័យព័ត៌មាន
- វិស័យបរិស្ថាន
- វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- វិស័យរ៉ែ និងថាមពល
- វិស័យពាណិជ្ជកម្ម
- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[109]

នៅក្នុងសេវាទាំង១៤ដែលផ្តល់ជូនឱ្យប្រជាពលរដ្ឋដោយរដ្ឋបាលសាលារាជធានីភ្នំពេញនេះ មាន១២ សេវាជាសេវា ដែលទទួលបានមកពីក្រសួងស្ថាប័ន និងសេវាចំនួន២ផ្សេងទៀតគឺជាសេវាផ្ទាល់របស់រដ្ឋបាលសាលារាជធានីភ្នំពេញ ដែលក្រសួងមហាផ្ទៃបានធ្វើប្រតិភូកម្មមកឱ្យ។ ការផ្តល់សេវាកម្មទាំង១៤នេះ គឺត្រូវធ្វើឡើងនៅអង្គភាពច្រកចេញចូលតែមួយនៃសាលារាជធានីភ្នំពេញ។

[109] អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ.

### ២.២.៣. ការផ្តល់ព័ត៌មានរបស់សាលារាជធានីភ្នំពេញ

នៅក្នុងដំណើរការនៃការផ្តល់ព័ត៌មានទាក់ទងនឹងសេវាសាធារណៈ រដ្ឋបាលសាលារាជធានីភ្នំពេញបាន ប្រើប្រាស់មធ្យោបាយជាច្រើន ដើម្បីធានានូវប្រសិទ្ធភាព តម្លាភាព និងភាពងាយស្រួលដល់ប្រជាពលរដ្ឋ ដែល ក្នុងនោះមានទាំងមធ្យោបាយផ្ទាល់ និងមធ្យោបាយឌីជីថល។

សម្រាប់ការផ្សព្វផ្សាយព័ត៌មានដោយផ្ទាល់សាលារាជធានីភ្នំពេញបានដាក់បង្ហាញពីសេវា និងតម្លៃ ដែលមានផ្តល់ឱ្យនៅលើកញ្ចក់ទូរទស្សន៍ នៅអង្គភាពច្រកចេញចូលតែមួយនៃសាលារាជធានីភ្នំពេញ ដើម្បី ភាពងាយស្រួលរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ក្រៅពីនេះប្រជាពលរដ្ឋក៏អាចសាកសួរព័ត៌មានពីមន្ត្រីដែល បម្រើការនៅទីនោះដោយផ្ទាល់ផងដែរ ចំពោះចម្ងល់ ឬតម្រូវការផ្សេងៗទាក់ទងនឹងសេវារដ្ឋបាលនេះ។[110] ក្រៅ ពីនេះ រដ្ឋបាលរាជធានីភ្នំពេញត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលារាជធានីភ្នំពេញនិងប្រើ ប្រាស់មធ្យោបាយផ្សេងៗទៀត ដែលសាធារណៈជនអាចពិនិត្យមើលបានដោយងាយស្រួល ហើយព័ត៌មាន ទាំងនេះត្រូវបិទផ្សាយឱ្យបានយ៉ាងតិចដប់(១០)ថ្ងៃ។[111]

ចំពោះការផ្តល់ព័ត៌មានទូទៅក្រសួងមហាផ្ទៃបានបង្កើតកម្មវិធីនៅក្នុងទូរសព្ទដែលមានឈ្មោះថា "MOI Mobile App" ដើម្បីផ្សព្វផ្សាយព័ត៌មាននានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ចំពោះការផ្តល់ព័ត៌មានទាក់ទងនឹងសេវារដ្ឋបាលខាងលើវិញ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួង មហាផ្ទៃបានបង្កើតកម្មវិធីក្នុងទូរសព្ទដៃមួយឈ្មោះថា "OWSM CAMBODIA" ដេម្បីផ្សព្វផ្សាយព័ត៌មានអំពី សេវារដ្ឋបាលថ្នាក់រាជធានីខេត្ត(...) ដែលនៅក្នុងនេះមានភ្ជាប់ផងដែរជាមួយនឹងប្រភេទសេវាដែលផ្តល់ឱ្យ តម្លៃសេវា និងរយៈពេលអតិបរិមានៃសេវានីមួយៗ ដំណើរការនៃឯកសារ និងសុពលភាពរបស់វា។ ក្រៅពីនេះ សាលារដ្ឋបាលរាជធានីក៏បានចូលរួមផ្សព្វផ្សាយព័ត៌មានទាំងនេះតាមរយៈ គេហទំព័រអ៊ីនធឺណិតរបស់សាលា រាជធានីភ្នំពេញផងដែរ ដែលមានឈ្មោះថាសាលារាជធានីភ្នំពេញ ដែលគេហទំព័រនេះមានផ្ទុកព័ត៌មានអំពី សេវាសាធារណៈ និងព័ត៌មានផ្សេងៗទៀតទាក់ទងនឹងរាជធានីភ្នំពេញ និងសាលារាជធានីភ្នំពេញ។

ក្រៅពីនេះរដ្ឋបាលរាជធានីភ្នំពេញ ក៏មានហ្វេសប៊ុកផេក(Facebook Page)ឈ្មោះរដ្ឋបាលរាជធានី ភ្នំពេញ ដែលជាកន្លែងផ្តល់ព័ត៌មានពីសកម្មភាព វិធានការ និងព័ត៌មានផ្សេងៗទៀតពីរដ្ឋបាលសាលារាជធានី

[110] (ឧបសម្ព័ន្ធទី៣) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ អង្គភាពច្រកចេញចូលតែមួយ នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤.

[111] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈ អភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

ភ្នំពេញផងដែរ។[112] ដូចនេះយើងអាចសន្និដ្ឋានបានថា ក្រសួងមហាផ្ទៃ និងសាលារាជធានីភ្នំពេញបានប្រើប្រាស់មធ្យោបាយជាច្រើនទាំងដោយផ្ទាល់ និងដោយមធ្យោបាយឌីជីថល ដើម្បីធានាថាប្រជាពលរដ្ឋនៅមូលដ្ឋានទទួលបានព័ត៌មានគ្រប់គ្រាន់អំពីតម្រូវការរបស់ពួកគេ។

## ២.៣. តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់សាលារាជធានីភ្នំពេញ

### ២.៣.១. ក្រុមប្រឹក្សារាជធានីភ្នំពេញ

ក្រុមប្រឹក្សារាជធានី គឺជាតួអង្គដ៏សំខាន់មួយដែលរួមចំណែកក្នុងការដឹកនាំ និងគ្រប់គ្រងកិច្ចការនៅរដ្ឋបាលរាជធានីភ្នំពេញ[113] ដែលក្រុមប្រឹក្សានេះត្រូវបង្កើតឡើងដោយស្របតាមច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ តាមរយៈវិធីសាស្ត្របោះឆ្នោតអសកល។ ក្រុមប្រឹក្សារាជធានី(...) គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[114]

ក្រុមប្រឹក្សារាជធានីមានអាណត្តិប្រាំឆ្នាំ ដែលត្រូវផុតកំណត់នៅពេលដែលក្រុមប្រឹក្សាថ្មីចូលមកកាន់តំណែង។ អាណត្តិក្នុងការដឹកនាំរបស់ក្រុមប្រឹក្សា ត្រូវចាប់គិតពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។[115]

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការបង្កើតឡើងនៃក្រុមប្រឹក្សារាជធានីនេះ គឺដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនេះរួមមាន៖

- ភាពតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌

---

[112] (ឧបសម្ព័ន្ធទី១៤) ប្រព័ន្ធឌីជីថលសម្រាប់ផ្តល់ព័ត៌មានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, ដកស្រង់នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤.

[113] ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១១៩.

[114] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ*, គ.ជ.អ.ប, ២០១១, ទំព័រ១០.

[115] ច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ, *"ជំពូកទី១ បទបញ្ញត្តិទូទៅ"*, ២០០៩, មាត្រា២.

- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។[116]

### ២.៣.១.១. លក្ខខណ្ឌ និងការជ្រើសរើសសមាជិកក្រុមប្រឹក្សារាជធានី

ចំពោះប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី(...) ចាំបាច់ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិមួយចំនួនដូចកំណត់ខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

ចំពោះការជ្រើសរើសក្រុមប្រឹក្សានីមួយៗ គឺត្រូវផ្អែកទៅតាមកត្តាប្រជាសាស្រ្ត និងកត្តាភូមិសាស្រ្ត នៅតាមតំបន់នីមួយៗ។[117] សម្រាប់រាជធានីភ្នំពេញក្នុងពេលបច្ចុប្បន្ន គឺត្រូវបានដឹកនាំដោយក្រុមប្រឹក្សាចំនួនម្ភៃប្រាំពីរ(២៧)រូប[118] ក្នុងនោះមានប្រធានមួយរូបដែលប្រធានក្រុមប្រឹក្សានេះគឺជាបេក្ខជនដែលនៅក្នុងលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សានឹងត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានច្រើនជាងគេ។[119]

### ២.៣.១.២. សមាសភាពក្រុមប្រឹក្សារាជធានី

យោងតាមមាត្រា១៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(២០០៨) ក្នុងរយៈពេលមួយរយម្ភៃ(១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចដាក់សំណើ ដើម្បីកំណត់អំពី ចំនួននៃសមាសភាពក្រុមប្រឹក្សារាជធានីដែលត្រូវបានកំណត់ដោយអនុក្រឹត្យ។ ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេ ចំនួនរបស់សមាជិកក្រុមប្រឹក្សានឹងត្រូវកំណត់យកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់។

ចំពោះការបាត់បង់សមាជិកភាពរបស់ក្រុមប្រឹក្សារាជធានីវិញ ក្រុមប្រឹក្សារាជធានីភ្នំពេញនឹងត្រូវបាត់បង់

[116] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ជំពូកទី១ អំពីបទបញ្ញត្តិទូទៅ",២០០៨, មាត្រា១១-មាត្រា១២.
[117] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ជំពូកទី២ អំពីក្រុមប្រឹក្សា",២០០៨, មាត្រា១៨, មាត្រា២១.
[118] ប្រកាសលេខ ២៧៤៧ ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ស្ដីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ.
[119] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ជំពូកទី២ អំពីក្រុមប្រឹក្សា",២០០៨, មាត្រា១៧.

សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីដែលសាមីខ្លួនបាត់បង់លក្ខណសម្បត្តិនិងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងករណីមួយចំនួនទៀតដែលបានកំណត់ដោយច្បាប់។ ចំពោះនីតិវិធីសម្រាប់អនុវត្តក្នុងករណីនេះ គឺត្រូវអនុវត្តទៅតាមមាត្រា២២ ដល់ មាត្រា២៦ នៃច្បាប់ខាងលើ។

យោងតាមប្រកាសលេខ២៧៤៧ ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ស្តីពី ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ នៅក្នុងពេលបច្ចុប្បន្ន(២០២៤) ក្រុមប្រឹក្សារាជធានីភ្នំពេញមានសមាជិកចំនួនម្ភៃប្រាំពីរ(២៧)រូប ដែល ដឹកនាំដោយ ឯកឧត្តម **ម៉ប់ សារិន** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ និងសមាជិកចំនួនម្ភៃប្រាំមួយ(២៦)រូបផ្សេងទៀត។

### ២.៣.១.៣. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារាជធានី

ក្រុមប្រឹក្សារាជធានីមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដើម្បីបំពេញមុខងារភារកិច្ចផ្សេងៗដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់កំណត់ ឬស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ចំពោះសិទ្ធិអំណាចវិញ ក្រុមប្រឹក្សារាជធានីមានសិទ្ធិអំណាចចំនួនពីរគឺ៖ (១)សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និង(២)សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។[120] ក្រុមប្រឹក្សាត្រូវប្រើប្រាស់អំណាចទាំងពីររបស់ខ្លួនដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធ។

ក្នុងនាមក្រុមប្រឹក្សារាជធានីរបស់ខ្លួន ប្រធានក្រុមប្រឹក្សារាជធានីមានសិទ្ធិក្នុងការចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលរាជធានីរបស់ខ្លួនទៅលើលិខិត និងឯកសារដូចតទៅ៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារាជធានី
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សារាជធានីបានអនុម័តរួច
- សំណើដកហូតអភិបាល ឬអភិបាលរងរាជធានីចេញពីមុខតំណែង តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារាជធានី

[120] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ជំពូកទី២ អំពីក្រុមប្រឹក្សា",២០០៨, មាត្រា២៩-មាត្រា៣០.

- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សារាជធានី
- ប្រតិទិនប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីសម្រាប់រយៈពេល១២ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារាជធានី
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលរាជធានីត្រូវជួយក្រុមប្រឹក្សារាជធានីក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនិងសំណើដកហូតអភិបាល ឬអភិបាលរងរាជធានីចេញពីមុខតំណែង។[121]

## ២.៣.១.៤. របៀបរបបការងាររបស់ក្រុមប្រឹក្សារាជធានី

ក្រុមប្រឹក្សារាជធានីអនុវត្តសិទ្ធិអំណាចរបស់ខ្លួនតាមរយៈ ការត្រួតពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួន ដែលទាក់ទងនឹងរបៀបរបបអនុវត្តការងារដូចតទៅ៖

- ក្រុមប្រឹក្សារាជធានីត្រូវបំពេញមុខងា និងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិតាមរយៈដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិ ដែលរាល់សេចក្តីសម្រេចទាំងពីរនេះ គឺត្រូវធ្វើឡើងនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារាជធានីរបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនេះ ត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ
- ក្រុមប្រឹក្សារាជធានីអាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ឬអនុកម្មាធិការ ឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ នៅក្នុងកិច្ចការអនុវត្តការងារនេះ គណៈអភិបាលរាជធានីត្រូវដឹកនាំនាយករដ្ឋបាលរាជធានី និងទីចាត់ការពាក់ព័ន្ធនៃសាលារាជធានី ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើព្រមទាំងធ្វើការសម្របសម្រួលណែនាំដល់ទីចាត់ការនានានៃសាលារាជធានី ក្នុងការរៀបចំសេចក្តីព្រាងដីការ ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានីពិនិត្យ ពិភាក្សា និងអនុម័ត។ បន្ថែមពីនេះ អភិបាលរាជធានីត្រូវធ្វើការណែនាំនាយករដ្ឋបាលសាលារាជធានីឱ្យរៀបចំដីកា ឬសេចក្តីសម្រេច ដែលក្រុមប្រឹក្សាអនុម័តរួច ឱ្យស្របតាមទម្រង់ដែលបានកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សារាជធានីចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សារាជធានីរបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលរាជធានី។

---

[121] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ*, គ.ជ.អ.ប, ២០១១, ទំព័រ១០-១១.

- ក្រុមប្រឹក្សារាជធានីត្រូវចាត់ឱ្យអភិបាលរាជធានីចាត់ចែង ផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេច ដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព
- ក្នុងករណីកិច្ចការណាមួយដែលតម្រូវការចាំបាច់នៃមូលដ្ឋាន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត មិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សារាជធានីត្រូវចាត់ចែងឱ្យអភិបាលរាជធានីធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សារាជធានី ពិនិត្យ និងអនុម័ត ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទ និងនីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ
- ក្នុងករណីណាមួយដែលច្បាប់ លិខិតបទដ្ឋានគតិយុត្ត បានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាមិនអាចអនុវត្តបានក្រុមប្រឹក្សារាជធានីត្រូវចាត់ឱ្យគណៈអភិបាលរាជធានីធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ ផ្អែកតាមយន្តការ គ.ជ.អ.ប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។[122]

### ២.៣.១.៥. កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានីត្រូវបានកំណត់និងបែងចែកជាពីរប្រភេទគឺៈ

១. កិច្ចប្រជុំសាមញ្ញៈ ក្រុមប្រឹក្សារាជធានី ត្រូវប្រជុំសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនយ៉ាងហោចណាស់ចំនួនដប់ពីរ(១២)ដង ជារៀងរាល់ឆ្នាំ ដែលកិច្ចប្រជុំសាមញ្ញនេះមិនត្រូវប្រារព្ធធ្វើមុនពេលម្ភៃប្រាំ(២៥)ថ្ងៃ និងលើសពេលសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ។

២. កិច្ចប្រជុំវិសាមញ្ញៈ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ ដែលកិច្ចប្រជុំវិសាមញ្ញនេះត្រូវធ្វើឡើងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី(១/៣)។[123]

[122] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ,* គ.ជ.អ.ប, ២០១១, ទំព័រ១១-១៣.

[123] សេចក្តីណែនាំលេខ ០១៥ ស.ណ.ន ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.

កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំទាំងនេះប្រព្រឹត្តទៅបានត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី។ សេចក្តីសម្រេចណាដែលធ្វើឡើងមិនដោយមិនមានភាពសមស្របនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។ ក្រៅពីនេះរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សារាជធានីត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលរាជធានី និងជាវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង ៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សារាជធានី
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលរាជធានី
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សារាជធានី
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សារាជធានី
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សារាជធានី ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានា តាមតម្រូវការរបស់ក្រុមប្រឹក្សារាជធានី
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានី
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ច របស់ក្រុមប្រឹក្សារាជធានី
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សារាជធានី ត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើ ក្រុមប្រឹក្សារាជធានីមានសិទ្ធិធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន៖

- ការកោះអញ្ជើញអភិបាលរាជធានី ឬអភិបាលរងរាជធានី ឬគណៈអភិបាលរាជធានី ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្ត សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សារាជធានី ឬហេតុការណ៍ណាមួយដែលកើតមានក្នុងរាជធានី ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធ។
- ការសម្រេចឱ្យសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតទៅលើករណីទាំងឡាយណា ដែលក្រុមប្រឹក្សារាជធានីយល់ថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំ ដល់គណៈអភិបាលរាជធានីអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យស្រាវជ្រាវ និងធ្វើសេចក្ដីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដែលប្រព្រឹត្តដោយក្រុមប្រឹក្សារាជធានី ឬសមាជិកក្រុមប្រឹក្សារាជធានី ឬគណៈអភិបាលរាជធានី ឬអភិបាលរាជធានី ឬអភិបាលរងរាជធានី ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សារាជធានី
- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ា របស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលរាជធានី
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី យល់ឃើញថាមានភាពចាំបាច់។[124]

## ២.៣.២. គណៈអភិបាលរាជធានីភ្នំពេញ

គណៈអភិបាលរាជធានីភ្នំពេញ គឺជាតួអង្គដ៏សំខាន់មួយអង្គទៀតដែលរួមចំណែកក្នុងការដឹកនាំ និងគ្រប់គ្រងកិច្ចការនៅរដ្ឋបាលរាជធានីភ្នំពេញ[125] ដែលគណៈអភិបាលនេះរួមមានអភិបាលរាជធានី និងអភិបាលរងរាជធានី។ គណៈអភិបាលរាជធានីត្រូវបានតែងតាំងឡើងដោយស្របតាមលក្ខខណ្ឌនៃច្បាប់ស្ដីពីការគ្រប់គ្រង

[124] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្ដីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ,* គ.ជ.អ.ប, ២០១១, ទំព័រ១៣-១៦.

[125] ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត,* អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១១៩.

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយអភិបាលរាជធានី អភិបាលរងរាជធានីមិនត្រូវជាសមាជិករបស់ក្រុមប្រឹក្សារាជធានីឡើយ។[126]

គណៈអភិបាលរាជធានីមានអាណត្តិការងារមិនលើសពីបួន(០៤)ឆ្នាំ ដោយឡែកសម្រាប់អភិបាលរងអាចត្រូវបានតែងតាំងបានបួន(០៤)ឆ្នាំបន្ថែម សម្រាប់អាណត្តិទី២ របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែរ។

ការបង្កើតឡើងនៃគណៈអភិបាល គឺដើម្បីជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ ដែលបានបែងចែក ឬបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់ ឬដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរបៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ។[127]

### ២.៣.២.១. លក្ខខណ្ឌ និងការតែងតាំងគណៈអភិបាលរាជធានី

ចំពោះការជ្រើសរើសតែងតាំងគណៈអភិបាលគឺត្រូវកំណត់បែងចែកជាពីរគឺ៖ (១)លក្ខខណ្ឌនិងការតែងតាំងសម្រាប់អភិបាលរាជធានី និង(២)លក្ខខណ្ឌនិងការតែងតាំងសម្រាប់អភិបាលរងរាជធានី។

អភិបាលរាជធានីត្រូវជ្រើសរើសតែងតាំង ដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមន្ត្រីនោះត្រូវជ្រើសរើសចេញពី ក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរស័ក្តឧត្តមមន្ត្រី
- មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានអតីតភាពការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

អភិបាលរងរាជធានីត្រូវជ្រើសរើសតែងតាំង ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមន្ត្រីនោះត្រូវជ្រើសរើសចេញពី ក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់

---

[126] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ*, គ.ជ.អ.ប, ២០១១, ទំព័រ១៧.

[127] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ជំពូកទី៣ អំពីគណៈកម្មាធិការក្រុមប្រឹក្សា និងគណៈអភិបាល", ២០០៨, មាត្រា១៤៧, មាត្រា១៥៦.

ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរស័ក្ត ចាប់ពីវរមន្ត្រីឡើងទៅ
- មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានអតីតភាពការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

ចំពោះករណីចាំបាច់ អភិបាល អភិបាលរង អាចជ្រើសរើសចេញពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ដែលមានស្ថិតក្នុងក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវបំពេញនូវលក្ខណសម្បត្តិដូចកំណត់ខាងលើនេះ។[128]

### ២.៣.២.២. សមាសភាពគណៈអភិបាលរាជធានី

យោងតាមមាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(២០០៨) អភិបាលរាជធានីត្រូវតែងតាំងដោយព្រះរាជក្រឹត្យ រីឯអភិបាលរងរាជធានីត្រូវតែងតាំងដោយអនុក្រឹត្យ ដើម្បីឱ្យចូលមកបំពេញការងារ តាមការកំណត់ខាងលើ។

ចំពោះការបាត់បង់មុខតំណែងរបស់គណៈអភិបាលមុនបញ្ចប់អាណត្តិការងាររបស់ខ្លួន គឺអាចកើតមានឡើងប្រសិនបើអភិបាលរាជធានី ឬអភិបាលរងរាជធានីដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬត្រូវបានដកហូតពីមុខតំណែង ដែលការដកហូតនេះកើតឡើងក្នុងករណីមួយចំនួនដែលបានកំណត់ដោយច្បាប់។ បន្ថែមពីនេះការបាត់បង់មុខតំណែងនេះអាចកើតមានផងដែរ ប្រសិនបើក្រុមប្រឹក្សាស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល ឬអភិបាលរងចេញពីមុខដំណែង ក្រោយពីធ្វើការស៊ើបអង្កេត។ ចំពោះនីតិវិធីសម្រាប់អនុវត្តក្នុងករណីនេះ គឺត្រូវអនុវត្តទៅតាមការកំណត់នៃច្បាប់ ឬនីតិវិធីពាក់ព័ន្ធ។

យោងតាមព្រះរាជក្រឹត្យ នស/រកត/០២២១/១១៥ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ នៅក្នុងពេលបច្ចុប្បន្ន (២០២៤) រាជធានីភ្នំពេញត្រូវបានដឹកនាំដោយអភិបាលមួយរូបគឺ ឯកឧត្តម **ឃួង ស្រេង**[129] និងអភិបាលរង

[128] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ជំពូកទី៣ អំពីគណៈកម្មាធិការក្រុមប្រឹក្សា និងគណៈអភិបាល", ២០០៨, មាត្រា១៤១-មាត្រា១៤៣, មាត្រា១៤៦ .

[129] ព្រះរាជក្រឹត្យ នស/រកត/០២២១/១១៥ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១.

ចំនួន១០រូបផ្សេងទៀត។[130]

### ២.៣.២.៣. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈអភិបាលរាជធានី

គណៈអភិបាលរាជធានីមានតួនាទី ភារកិច្ចចម្បងៗដូចខាងក្រោម៖

- ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានាដែលពាក់ព័ន្ធ នឹងសិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិ ដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖
    + ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សា និងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
    + ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធាន ដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
    + ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
    + ក្របខណ្ឌចំណាយរយៈពេលមធ្យម ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
    + គម្រោងថវិកាប្រចាំឆ្នាំ
    + ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យនានា
    + ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
    + ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក
    + ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សា
    + ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សា
    + ការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា
    + ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សា
    + ការរៀបចំយុទ្ធសាស្ត្រដើម្បីផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន

[130] ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១១៩.

ការបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មាន និងការស្ទះស្វែងរកមធ្យោបាយ ផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច

+ កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និង ដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

បន្ថែមពីការបំពេញតួនាទីក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានីគឺជាតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងការណែនាំ សម្របសម្រួល តម្រង់ទិស មន្ទីរអង្គភាពខ្សែរបណ្ដោយរបស់ក្រសួងស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះទៅទៀត អភិបាលត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាលតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងកិច្ចការងារសន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ រួមទាំងសិទ្ធិមនុស្សក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនផងដែរ។ នៅក្នុងការបំពេញតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ន អភិបាលរាជធានីត្រូវអនុវត្តលើកិច្ចដូចតទៅៈ

- ថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ ការិយាល័យអង្គភាពពាក់ព័ន្ធនានា ដើម្បីធានារក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងដែនសមត្ថកិច្ច
- ណែនាំដល់មន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅរាជធានីឱ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់មន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅរាជធានី ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលរាជធានីភ្នំពេញត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អភិបាលរាជធានីភ្នំពេញត្រូវធ្វើការសម្របសម្រួលតម្រង់ទិសដល់មន្ទីរ ការិយាល័យ អង្គភាព

និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅរាជធានីក្នុងការធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សារាជធានី។

- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារាជធានីភ្នំពេញជាមុន ក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅរាជធានី។ ក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលរាជធានីភ្នំពេញ ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះ ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដើម្បីពិនិត្យពិចារណា។ ក្នុងករណីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីឯកភាព តាមរបាយការណ៍របស់អភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាព ដែលបានស្នើឡើងឱ្យបានសមស្រប។ ក្នុងករណីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថា ហេតុផល ដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលរាជធានីពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលរាជធានី ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាពរវាងអភិបាលរាជធានីជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីទៅលើបេក្ខភាព ដែលស្នើតែងតាំងនោះ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ សម្រេច។ អភិបាលរាជធានី ត្រូវរាយការណ៍ករណីនេះជូនក្រុមប្រឹក្សារបស់ខ្លួននិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។
- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងមន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយ ឬការប្រព្រឹត្តខុសឆ្គងរបស់ ប្រធានមន្ទីរ ការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយ អភិបាលរាជធានីត្រូវធ្វើការណែនាំជាបន្ទាន់ទៅដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់។
- ក្នុងករណី ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះ មិនបានកែប្រែ ឬ ក្នុងករណីភាពមិនប្រក្រតីឬការប្រព្រឹត្ត ខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ អភិបាលរាជធានីត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនៃមន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារទាំងនោះ។ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីដោះស្រាយទៅតាមច្បាប់ ។
- អភិបាលរាជធានីមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខ

តំណែង នូវប្រធានមន្ទីរ ការិយាល័យ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយដែលប្រព្រឹត្ត ខុសឆ្គង ហើយដែលមិនអាចធ្វើយុត្តិកម្មបាន

- តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។[131]

### ២.៣.២.៤. របៀបរបបការងាររបស់គណៈអភិបាលរាជធានី

នៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន គណៈអភិបាលរាជធានី អភិបាលរាជធានី អភិបាលរងរាជធានីត្រូវធ្វើការត្រួតពិនិត្យ ពិចារណាលើចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

- ក្នុងកិច្ចការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលរាជធានីត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ដោយស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ក្នុងកិច្ចការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន និងការងារដទៃ ដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលរាជធានីត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារាជធានីរបស់ខ្លួន
- អភិបាលរាជធានី ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សារាជធានីអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរាជធានី។ អភិបាលរងរាជធានី ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលរាជធានីលើភារកិច្ចនានាដែលបានប្រគល់ឱ្យ ហើយត្រូវរួមជាមួយអភិបាលរាជធានីក្នុងការទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរាជធានីរបស់ខ្លួន។
- អភិបាលរាជធានី ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារាជធានីរបស់ខ្លួន លើកលែងតែលិខិតបទដ្ឋាន ដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សារាជធានីហត្ថលេខា ក្នុងនាមក្រុមប្រឹក្សារាជធានីរបស់ខ្លួន
- គណៈអភិបាលរាជធានី ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចរបស់ខ្លួនដល់អភិបាលរាជធានី និងអភិបាលរងរាជធានី ហើយសុំការសម្រេចពីក្រុមប្រឹក្សារាជធានី
- អភិបាលរាជធានីអាចប្រគល់សិទ្ធិដល់អភិបាលរងរាជធានីក្នុងការចុះហត្ថលេខាលើឯកសារលេខិតស្នាម

[131] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ*, ២០១៩, ទំព័រ ៤០-៤៣

រដ្ឋបាលចាំបាច់មួយចំនួនក្នុងក្របខណ្ឌនៃភារកិច្ច ដែលបានបែងចែកជូនអភិបាលរងនីមួយៗ។ អភិបាលរាជធានី ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ បែបបទ និងនីតិវិធីចំពោះឯកសារលិខិតស្នាម ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងរាជធានីទាំងនោះ

- អភិបាលរាជធានីមានសិទ្ធិក្នុងការដកហូតសិទ្ធិចុះហត្ថលេខាមកវិញពីអភិបាលរងណាមួយ ដែលប្រើប្រាស់អំណាចនេះ មិនស្របតាមច្បាប់ ឬមិនស្របតាមបែបបទ និងនីតិវិធី ដែលការប្រគល់ ឬការដកហូតសិទ្ធិនេះ អភិបាលត្រូវធ្វើការរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន
- ក្នុងករណីអភិបាលរាជធានីអវត្តមាន អភិបាលរាជធានីត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងរាជធានីមួយរូប ឱ្យទទួលជាអភិបាលរាជធានីស្តីទី។ ប្រសិនអភិបាលរាជធានីអវត្តមានដោយមិនបានផ្ទេរសិទ្ធិ អភិបាលរងរាជធានីដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលរាជធានីត្រូវធ្វើជាអភិបាលស្តីទី។ ក្នុងករណីអភិបាលរាជធានីស្តីទីអវត្តមាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាស ដើម្បីប្រគល់ភារកិច្ចដល់អភិបាលរងរាជធានីមួយរូប ឱ្យទទួលជាអភិបាលរាជធានីស្តីទី។ នៅពេលដែលអភិបាលរាជធានីមានវត្តមានវិញ អភិបាលរាជធានីស្តីទីត្រូវធ្វើការរាយការណ៍រាល់កិច្ចការទាំងអស់ដែលកើតមាន។
- គណៈអភិបាលរាជធានី ឬអភិបាលរាជធានី ឬអភិបាលរងរាជធានីដែលបានសម្រេច និង/ឬ ដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ហើយមិនបានទទួលការសម្រេចពីក្រុមប្រឹក្សារាជធានី ការសម្រេច ឬសកម្មភាពទាំងនោះពុំមានសុពលភាពឡើយ។ ក្រៅពីនេះគណៈអភិបាលរាជធានី ឬអភិបាលរាជធានី ឬអភិបាលរងរាជធានីត្រូវទទួលខុសត្រូវចំពោះសកម្មភាពទាំងនោះ។[132]

### ២.៣.២.៥. កិច្ចប្រជុំរបស់គណៈអភិបាលរាជធានី

កិច្ចប្រជុំរបស់គណៈអភិបាលរាជធានី គឺជាកិច្ចប្រជុំរវាងអភិបាល និងអភិបាលរងនៅក្នុងគណៈអភិបាលរបស់ខ្លួន។ ដើម្បីធានានូវគោលការណ៍នៃការអនុវត្តការងារ គណៈអភិបាលរាជធានីត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាសដែលការប្រជុំអឌ្ឍមាសទី២ នៃខែនីមួយៗជាការប្រជុំប្រចាំខែ។ បន្ថែមពីការប្រជុំអឌ្ឍមាស និងការប្រជុំប្រចាំខែ គណៈអភិបាលរាជធានីអាចកោះប្រជុំតាមការចាំបាច់ ដោយរៀងរាល់កិច្ចប្រជុំត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

[132] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ*, គ.ជ.អ.ប, ២០១១, ទំព័រ ២៣-២៦.

កិច្ចប្រជុំគណៈអភិបាលរាជធានីអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានអភិបាលរាជធានី អភិបាលរងរាជធានីលើសពីពាក់កណ្តាលនៃសមាសភាពគណៈអភិបាលរាជធានី។ ដើម្បីឱ្យសេចក្តីសម្រេចនៃកិច្ចប្រជុំគណៈអភិបាលរាជធានីអាចយកជាការបាន លុះត្រាតែសំឡេងអនុម័តនៃសមាសភាពគណៈអភិបាលរាជធានីទាំងមូលមានលើសពីពាក់កណ្តាល។ ក្នុងករណីចំនួនសំឡេងស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។

អភិបាលធានី គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីអភិបាលរាជធានីអវត្តមានអភិបាលស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំគណៈអភិបាលត្រូវមានកំណត់ហេតុដែលរៀបចំឡើងដោយនាយករដ្ឋបាល និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

នាយករដ្ឋបាល និងនាយករងរដ្ឋបាលមានភារកិច្ចចូលរួមគ្រប់កិច្ចប្រជុំរបស់គណៈអភិបាលទាំងអស់ ដើម្បីផ្តល់យោបល់បច្ចេកទេសផ្នែកច្បាប់ ទៅតាមការស្នើសុំ។ ក្រៅពីនេះអភិបាលក៏អាចអញ្ជើញអ្នកពាក់ព័ន្ធនានាចូលរួមក្នុងកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួនតាមការចាំបាច់។[133]

### ២.៣.៣. គណៈកម្មាធិការនានារបស់សាលារាជធានីភ្នំពេញ

នៅក្នុងពេលបច្ចុប្បន្ន(២០២៤) រាជធានីភ្នំពេញមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) និងការិយាល័យមួយ ដែលបង្កើតឡើងស្របតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលក្នុងនោះរួមមាន៖

១. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

២. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ

៣. គណៈកម្មាធិការលទ្ធកម្ម

៤. ការិយាល័យប្រជាពលរដ្ឋ។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានគតិយុត្តស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ។ បន្ថែមពីនេះទៅទៀត ក្រុមប្រឹក្សារាជធានីអាចបង្កើតគណៈកម្មាធិការផ្សេងៗទៀត ដើម្បីជួយសម្រួលកិច្ចការងារតាមការចាំបាច់ ដែលគណៈកម្មាធិការទាំងនោះមិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយនឹងគណៈកម្មាធិការទាំងបីខាងលើនេះឡើយ។ ក្រុមប្រឹក្សាអាច

[133] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី កិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០១៥, ទំព័រ ១៦៩.

បង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀត តាមការស្នើសុំរបស់គណៈកម្មាធិការនានា ឬគណៈអភិបាលរាជធានី ដែលអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬគណៈអភិបាលរាជធានី។[134]

យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋាភិបាលកម្ពុជាបានសម្រេចចេញអនុក្រឹត្យមួយ ដែលស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចុះនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្តល់សេវានិងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅរដ្ឋបាលថ្នាក់ជាតិ តាមរយៈការពង្រឹងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ យោងតាមអនុក្រឹត្យដដែរ ការិយាល័យប្រជាពលរដ្ឋត្រូវមានទំនាក់ទំនង និងមានគណនេយ្យភាពដោយផ្ទាល់ជាមួយក្រុមប្រឹក្សារាជធានី។[135]

### ២.៣.៣.១. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស[136]

ក្រុមប្រឹក្សារាជធានី ត្រូវរៀបចំឱ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ខ្លួន ដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីរបស់ខ្លួនលើបញ្ហាទាក់ទងនឹងការងារផែនការ ថវិកា ការសម្របសម្រួលកិច្ចការនានាជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារធនធានដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សារាជធានី។

#### ក. សមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការបច្ចេកទេសរបស់ក្រុមប្រឹក្សារាជធានី មានសមាសភាដូចខាងក្រោម៖

- អភិបាលរាជធានី ជាប្រធាន
- អភិបាលរងរាជធានី០១រូប ជាអនុប្រធាន

[134] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[135] អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ.

[136] អនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ.

- នាយករដ្ឋបាលសាលារាជធានី ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សារាជធានីយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅរាជធានី ជាសមាជិក
- នាយកទីចាត់ការទាំងអស់របស់សាលារាជធានី ជាសមាជិក
- អភិបាលខណ្ឌទាំងអស់នៅក្នុងរាជធានី ជាសមាជិក
- តំណាងសមាគមក្រុមប្រឹក្សាសង្កាត់ប្រចាំរាជធានី០២រូប ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី ត្រូវស្មើដោយអភិបាលរាជធានី។ ចំពោះតំណាងសមាគមក្រុមប្រឹក្សាសង្កាត់ប្រចាំរាជធានីពីរ(០២)រូប ត្រូវចាត់តាំងឡើងដោយគណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាសង្កាត់ប្រចាំរាជធានី ដែលតំណាងទាំងពីររូបនេះ ត្រូវមានស្ត្រីមួយរូប។

ក្រុមប្រឹក្សារាជធានីត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី។ សេចក្តីសម្រេចនេះ ហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានី។

**ខ. តួនាទី ភារកិច្ចគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានតួនាទី និងភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

**ខ.១. ផែនការអភិវឌ្ឍនិងថវិកា**

- ការដាក់បញ្ចូលផែនការអភិវឌ្ឍនិងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានា របស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខណ្ឌចំណាយរយៈពេលមធ្យមនិងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានី
- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងការធ្វើ

បច្ចុប្បន្នភាព

- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានី
- សេចក្តីព្រាងក្របខណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុនិងថវិការបស់ក្រុមប្រឹក្សារាជធានី
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគរាជធានី ដើម្បីគាំទ្រដល់កម្មវិធីនានារបស់រាជធានី
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគរាជធានី
- របាយការណ៍រីកចម្រើននានា ទាក់ទងដល់ការងារផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សារាជធានី។

### ខ.២. សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សារាជធានីជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សារាជធានីជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវានិងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬដោយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សារាជធានី ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានា ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍ ស្របតាមតម្រូវការរបស់មូលដ្ឋាន។

### ខ.៣. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខណ្ឌ

- ការរៀបចំយន្តការពិគ្រោះយោបល់និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពរាជធានី
- ការរៀបចំប្រព័ន្ធនិងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងរបស់ទីចាត់ការនានានៃសាលារាជធានី
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ទីចាត់ការនានានៃសាលារាជធានី។

### ខ.៤. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់នៅក្នុងរាជធានី

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ក្នុង

រាជធានី

- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះមិនអាចដោះស្រាយបាន
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាខណ្ឌ ឬ/និងក្រុមប្រឹក្សាសង្កាត់។

**ខ.៥. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត
- ការសម្រុះសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត។

**ខ.៦. ការងារទាក់ទងមុខងារនិងធនធាន**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងធនធាន
- ការរៀបចំនូវលក្ខណសម្បត្តិនិងមធ្យោបាយដើម្បីទទួលនិងអនុវត្តមុខងារ និងធនធានថ្មីដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលរាជធានី
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារនិងធនធានដែលគួរត្រូវបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលរាជធានី
- ការផ្តួចផ្តើមអំពីការធ្វើប្រតិភូកម្មនូវមុខងារនិងធនធានដល់រដ្ឋបាលខណ្ឌនិងរដ្ឋបាលសង្កាត់
- ការវាយតម្លៃលើការអនុវត្តមុខងារនិងធនធាន ដែលស្ថិតក្រោមការទទួលខុសត្រូវនៃរដ្ឋបាលរាជធានី។

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀត តាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

**២.៣.៣.២. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**[137]

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ(គ.ក.ស.ក) ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សារាជធានី និងត្រូវមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សារាជធានី

[137] ប្រកាសលេខ ៤៨០៧ ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៃរដ្ឋបាលរាជធានី រដ្ឋបានខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ.

គណៈអភិបាលរាជធានី អភិបាលរាជធានី និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សារាជធានី លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ ដែលស្ថិតនៅក្នុងអំណាចមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សារាជធានី។

### ក. សមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានីត្រូវមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| – សមាជិកក្រុមប្រឹក្សាជាស្ត្រី ដែលជ្រើសរើសដោយក្រុមប្រឹក្សា | ប្រធាន |
| – សមាជិកក្រុមប្រឹក្សា ដែលជ្រើសរើសដោយក្រុមប្រឹក្សា | អនុប្រធាន |
| – អភិបាលរងជាស្ត្រី ០១រូប | អនុប្រធាន |
| – ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| – ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| – នាយករងរដ្ឋបាល ០១រូប | សមាជិក |
| – ប្រធាន ឬអនុប្រធានមន្ទីរផែនការ | សមាជិក |
| – ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាល | សមាជិក |
| – ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| – ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| – ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| – ប្រធាន ឬអនុប្រធានមន្ទីរកសិកម្ម | សមាជិក |
| – ស្នងការ ឬតំណាងស្នងការដ្ឋាននគរបាល | សមាជិក |
| – នាយក ឬនាយករងទីចាត់ការអន្តរវិស័យ | សមាជិក |
| – ប្រធាន ឬអនុប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៃរាជធានី | សមាជិក |
| – តំណាងស្ថាប័ន ឬអង្គភាពផ្សេងៗទៀតតាមការចាំបាច់ | សមាជិក |

ក្រុមប្រឹក្សារាជធានី ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ(គ.ក.ស.ក)របស់ខ្លួន ដែលមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានី។

ចំពោះករណីដែលក្រុមប្រឹក្សារាជធានីពុំមានសមាជិកក្រុមប្រឹក្សាជាស្ត្រី ក្រុមប្រឹក្សាត្រូវជ្រើសរើសអភិបាលរងដែលជាស្ត្រីនៅក្នុងគណៈអភិបាលនៃរដ្ឋបាលរាជធានី ដើម្បីធ្វើជាប្រធាន "គ.ក.ស.ក" ។

**ខ. តួនាទី ភារកិច្ចគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**

គណៈពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ(គ.ក.ស.ក)មានតួនាទី និងភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ចូលរួមក្នុងការកសាងចក្ខុវិស័យ ជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ពន្ធ័នឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ប្រមូល និងវិភាគព័ត៌មាននិងទិន្នន័យ ដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិការបស់ក្រុមប្រឹក្សា
- ចូលរួមក្នុងការរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានីទាក់ទងនឹងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ស្វែងរកការគាំទ្រពីក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី និងគណៈកម្មាធិការផ្សេងទៀតនៃក្រុមប្រឹក្សារាជធានី ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ(គ.ក.ស.ក) របស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហា ឬសំណូមពរ ឬសំណើនានា ដែលគណៈកម្មាធិការនៃក្រុមប្រឹក្សាប្រភេទផ្សេងនោះ មិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន
- លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សារាជធានី ឬគណៈអភិបាលរាជធានីអំពីវិធានការសមស្របនានា ដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ
- ស្វែងរក និងទទួលបានរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការងាររបស់គណៈកម្មាធិការ

- ជំរុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍អំពីបញ្ហាដែលបានកើតមានជាប្រចាំពាក់ព័ន្ធនឹង សមភាព យេនឌ័រ ស្ត្រី យុវវ័យ និងកុមារ និងមានវិធានការដើម្បីឆ្លើយតប
- ស្វែងរកការគាំទ្រ ដើម្បីជំរុញឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចពាក់ពន្ធ័នឹងការងារអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនង កិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាប្រភេទផ្សេងទៀត មន្ទីរ អង្គភាពពាក់ព័ន្ធនានា អង្គការ សមាគម អ្នកផ្តល់សេវា ក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍ ដើម្បីធានាថាសកម្មភាពទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រី យុវវ័យ និងកុមារ
- ពិនិត្យមើលលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ជាពិសេសកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវានានា ដើម្បីលើកអនុសាសន៍ក្នុងការដោះស្រាយបញ្ហាទាំងនេះ
- រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់ស្ត្រី យុវវ័យ និងកុមារ ព្រមទាំងការងាររវាងសេវាសង្គមពាក់ព័ន្ធ
- គាំទ្ររាល់កិច្ចខិតខំប្រឹងប្រែងដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ រួមទាំងសេវាសង្គមផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សា។

### ២.៣.៣.២. គណៈកម្មាធិការលទ្ធកម្ម[138]

ក្រុមប្រឹក្សារាជធានីត្រូវរៀបចំឱ្យមានគណៈកម្មាធិការលទ្ធកម្មរៀងៗខ្លួន ដើម្បីធានាឱ្យការគ្រប់គ្រងដឹកនាំ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាប្រឹក្សាប្រព្រឹត្តទៅដោយរលូនប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងទាន់ពេលវេលា។

#### ក. សមាសភាពគណៈកម្មាធិការលទ្ធកម្ម

គណៈកម្មាធិការលទ្ធកម្មរបស់ក្រុមប្រឹក្សារាជធានីត្រូវមានសមាសភាពដូចខាងក្រោម៖

---

[138] ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.

| | |
|---|---|
| – អភិបាលរាជធានី | ប្រធាន |
| – អភិបាលរងរាជធានី ០១រូប | អនុប្រធាន |
| – ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| – សមាជិកក្រុមប្រឹក្សារាជធានីយ៉ាងច្រើន ០៣រូប | សមាជិក |
| – នាយករដ្ឋបាលនៃសាលារាជធានី | សមាជិក |
| – នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| – ប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី | លេខាធិការ |

សមាសភាពអនុប្រធានគណៈកម្មាធិការលទ្ធកម្មដែលជាអភិបាលរង ត្រូវស្នើដោយអភិបាលនៃគណៈអភិបាលរាជធានី ចំណែកឯសមាសភាពនៃគណៈកម្មាធិការលទ្ធកម្មរាជធានី ដែលជាសមាជិកក្រុមប្រឹក្សារាជធានីត្រូវជ្រើសរើសដោយក្រុមប្រឹក្សារាជធានី។

**ខ. តួនាទី ភារកិច្ចគណៈកម្មាធិការលទ្ធកម្ម**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានីមានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- គោរពឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្មដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត
- ណែនាំឱ្យអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃ កំណត់បុគលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន។ ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេច ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្នង់តម្លៃ ឬចរចាថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃឡើងវិញលើលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខមុនការសម្រេចប្រគល់កិច្ចសន្យា

- ជូនដំណឹង ស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារាជធានី
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមសង្កេតការណ៍ដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មលើកលែងតែដំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។

**២.៣.៣.២. ការិយាល័យប្រជាពលរដ្ឋ**[139]

ការិយាល័យប្រជាពលរដ្ឋត្រូវរៀបចំឡើងស្របតាមអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋ ដែលការិយាល័យប្រជាពលរដ្ឋនេះត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សារាជធានី។ ការបង្កើតឡើងនៃការិយាល័ប្រជាពលរដ្ឋនេះគឺដើម្បីជំរុញដល់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

ការិយាល័យប្រជាពលរដ្ឋរាជធានីនេះ ត្រូវកំណត់រៀបចំឱ្យមានពីរផ្នែកជាចំណុះគឺ៖

១. ផ្នែកទទួលពាក្យបណ្តឹងនិងកិច្ចការរដ្ឋបាល

២. ផ្នែកច្បាប់និងស៊ើបអង្កេត។

ផ្នែកទាំងពីរនេះត្រូវកំណត់ដឹកនាំដោយប្រធានមួយ(០១)រូប និងអនុប្រធានយ៉ាងច្រើនពីរ(០២)រូប រួមជាមួយនឹងបុគ្គលិកមួយចំនួនទៀតដែលរើសចេញពីក្របខណ្ឌមន្ត្រីរាជការស៊ីវិលដែលមានលក្ខណសម្បត្តិ សមត្ថភាព ជំនាញ និងបទពិសោធន៍ការងារសមស្រប។

[139] អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋ.

នៅក្នុងនេះផងដែរ ប្រធានផ្នែកត្រូវកំណត់ថាមានឋានៈស្មើនាយកទីចាត់ការសាលារាជធានី និងអនុប្រធានផ្នែកមានឋានៈស្មើនឹងនាយករងទីចាត់ការសាលារាជធានី (តែងតាំងដោយដីកា)។

### ក. សមាសភាពរបស់ការិយាល័យប្រជាពលរដ្ឋ

ការិយាល័យប្រជាពលរដ្ឋត្រូវមានសមាសភាពដឹកនាំសំខាន់ៗចំនួនពីរ(០២)រូបគឺ ប្រធាន(០១)រូប និងអនុប្រធានមួយ(០១)រូប។

ប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានីដូចដែលបានកំណត់នៅក្នុងអនុក្រឹត្យបង្កើតការិយាល័យប្រជាពលរដ្ឋ។

ប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ត្រូវទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់អភិបាលរាជធានី ផ្អែកតាមលទ្ធផលរបស់គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី។ បន្ថែមពីនេះ ប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ដែលទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរួចហើយ មិនកាន់មុខដំណែងផ្សេងទៀតក្នុងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រកបមុខរបរវិជ្ជាជីវៈណាមួយ ឬមុខរបរផ្សេងទៀតដែលមានទំនាស់ផលប្រយោជន៍នឹងមុខងាររបស់ខ្លួនឡើយ។

ប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី មានអាណត្តិការងារប្រាំ(០៥)ឆ្នាំ ហើយនៅពេលចប់អាណត្តិ ប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជាថ្មីទៀតបាន ដោយផ្អែកតាមលក្ខខណ្ឌ និងលក្ខណសម្បត្តិដូចមានចែងក្នុងអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋ។

### ខ. តួនាទី ភារកិច្ចការិយាល័យប្រជាពលរដ្ឋ

ការិយាល័យប្រជាពលរដ្ឋរាជធានីមានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ប្រមូលនិងទទួលពាក្យបណ្តឹងនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្រាំងនិងវាយតម្លៃពាក្យបណ្តឹងដែលទទួលបាន
- បញ្ជូនពាក្យបណ្តឹងទាំងឡាយដែលស្ថិតនៅក្រៅសមត្ថកិច្ចរបស់ខ្លួនទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងតាមដានការដោះស្រាយ ដើម្បីជូនព័ត៌មានទៅម្ចាស់ពាក្យបណ្តឹង

- ចាត់វិធានការស៊ើបអង្កេតបណ្តឹងរដ្ឋបាល លើកអនុសាសន៍អំពីវិធានការដោះស្រាយបណ្តឹង និងតាមដានការអនុវត្តវិធានការដោះស្រាយបណ្តឹងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្តល់ព័ត៌មានត្រឡប់ដល់ប្រជាពលរដ្ឋអំពីលទ្ធផលនៃការដោះស្រាយបណ្តឹង
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំយន្តការចាំបាច់នានាពាក់ព័ន្ធទៅនឹងដំណើរការទទួលនិងសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ខ្លួន
- រាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការអនុវត្តការងារនិងការដោះស្រាយបណ្តឹង។

## ២.៣.៤. នាយករដ្ឋបាលសាលារាជធានីភ្នំពេញ

ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីត្រូវមាននាយករដ្ឋបាលមួយរូបដែលតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយករដ្ឋបាលមានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការងាររដ្ឋបាលនិងធានានិរន្តភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។ បន្ថែមពីនេះនាយករដ្ឋបាលត្រូវធ្វើសេចក្តីរាយការណ៍ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។[140]

### ២.៣.៤.១. លក្ខខណ្ឌ និងការតែងតាំងនាយក នាយករងរដ្ឋបាល

នាយករដ្ឋបាល និងនាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ ត្រូវកំណត់តែងតាំងឡើងដូចខាងក្រោមៈ

- នាយករដ្ឋបាលសាលារាជធានីភ្នំពេញត្រូវតែងតាំងឡើងក្នុងចំណោមមន្ត្រីដែលស្ថិតនៅក្នុងឋានន្តរស័ក្តចាប់ពីអនុមន្ត្រីនៃក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញត្រូវតែងតាំងឡើងក្នុងចំណោមមន្ត្រីដែលស្ថិតនៅក្នុងឋានន្តរស័ក្តចាប់ពីនាយក្រមការនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

ចំពោះលក្ខណសម្បត្តិ និងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលរបស់សាលារាជធានីភ្នំពេញ និងនាយករងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បន្ថែមពីនេះនៅក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញប្រកាស ឬសេចក្តីណែនាំ អំពីតួនាទីភារកិច្ច និងរបៀបរបបការងាររបស់នាយករដ្ឋបាលសាលារាជធានីភ្នំពេញ និងនាយករងរដ្ឋបាលសាលារាជធានី

[140] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ជំពូកទី៤ អំពីបុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា", ២០០៨, មាត្រា១៨៣-មាត្រា១៨៤

ភ្នំពេញ។[141]

### ២.៣.៤.២. សមាសភាពនាយករដ្ឋបាល

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពី អភិបាលរាជធានីភ្នំពេញ យោងតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី។ ដូចគ្នានេះដែរ ចំពោះសមាសភាព របស់នាយករងរដ្ឋបាលសាលរាជធានីភ្នំពេញ ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពី អភិបាលរាជធានីភ្នំពេញ យោងតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី។[142]

នៅក្នុងពេលបច្ចុប្បន្ននេះ(២០២៤) សាលារាជធានីភ្នំពេញមាននាយករដ្ឋបាលមួយ(០១)រូបដឹកនាំគឺ លោក **សេខ វណ្ណៈ** និងនាយករងរដ្ឋបាលចំនួនប្រាំបួន(០៩)រូបផ្សេងទៀត។[143]

### ២.៣.៤.៣. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់នាយករដ្ឋបាល

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សារាជធានី គណៈ អភិបាលរាជធានី និងអភិបាលរាជធានី ក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាល ប្រចាំថ្ងៃក្នុងសាលារាជធានីភ្នំពេញ។ ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលារាជធានីត្រូវធ្វើរបាយការណ៍ និង ត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលរាជធានី អភិបាលរាជធានី និងក្រុមប្រឹក្សារបស់ខ្លួន។

ដើម្បីបំពេញនូវតួនាទីខាងលើនេះនាយករដ្ឋបាលមានភារកិច្ចមួយចំនួនដូចជា៖

- រៀបចំនិងដាក់ជូនគណៈអភិបាលរាជធានីពិនិត្យ និងសម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលា រាជធានី ផ្អែកតាមក្របខណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលរាជធានី ហើយត្រូវធានាថាកិច្ចការទាំង នោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាម រដ្ឋបាល
- រៀបចំនិងដាក់ជូនគណៈអភិបាលរាជធានីនូវវិធាននិងគោលការណ៍ក្នុងការអនុវត្តដីកានិងសេចក្តី សម្រេចនានារបស់ក្រុមប្រឹក្សារាជធានី
- ធ្វើជាសេនាធិការជូនអភិបាលរាជធានីនិងប្រធានក្រុមប្រឹក្សារាជធានី ក្នុងការត្រៀមរៀបចំសេចក្តីព្រាង

[141] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈ អភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[142] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈ អភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[143] ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១១៩, ២៦៣.

របៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សារាជធានី រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សារាជធានី ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្ដីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ ដែលនាយករដ្ឋបាលសាលារាជធានីបានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ត្រូវតែដាក់ជូនគណៈអភិបាលរាជធានី ដើម្បីពិនិត្យនិងផ្ដល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សារាជធានីក្នុងការរៀបចំនិងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សារាជធានី
- ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលរាជធានី តាមការណែនាំរបស់អភិបាលរាជធានី
- ធានាក្នុងការទទួលនិងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សារាជធានី អភិបាលរាជធានី និងអភិបាលរងរាជធានី ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា
- ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវនិងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី និងរដ្ឋបាលរបស់ខ្លួន
- គ្រប់គ្រងនិងប្រើប្រាស់ត្រារដ្ឋបាលរាជធានីភ្នំពេញឱ្យបានត្រឹមត្រូវតាមការកំណត់ ដូចមានចែងក្នុងមាត្រា៥៣ នៃអនុក្រឹត្យ ស្ដីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី អភិបាលរាជធានី ឬដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

បន្ថែមពីនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ មានសិទ្ធិចូលរួមនិងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សារាជធានី កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សារាជធានី និងកិច្ចប្រជុំគណៈអភិបាលរាជធានី ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលារាជធានីជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សារាជធានី។ ក្រៅពីនេះ នាយករដ្ឋបាលត្រូវធានាថានាយកទីចាត់ការ មន្ត្រី បុគ្គលិកទាំងអស់ អនុវត្តការងារឱ្យ

បានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។[144]

**២.៣.៤.៤. កិច្ចប្រជុំអន្តរអង្គភាពចំណុះរដ្ឋបាលរាជធានី**

កិច្ចប្រជុំអន្តរអង្គភាព គឺជាកិច្ចប្រជុំរវាងនាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធាន អនុប្រធានអង្គភាពទាំងអស់ចំណុះរដ្ឋបាលរាជធានី។ កិច្ចប្រជុំអន្តរអង្គភាពនៃរដ្ឋបាលរាជធានីភ្នំពេញនេះត្រូវបានហៅថា "កិច្ចប្រជុំអន្តរទីចាត់"។

**កិច្ចប្រជុំអន្តរទីចាត់ការ** នៃរដ្ឋបាលរាជធានីនេះ ត្រូវមានសមាសភាពចូលរួមដូចជា នាយករដ្ឋបាល នាយករងរដ្ឋបាល នាយកទីចាត់ការ នាយករងទីចាត់ការ ប្រធានអង្គភាព និងអនុប្រធានអង្គភាពទាំងអស់ចំណុះរដ្ឋបាលរាជធានីភ្នំពេញ។

នាយករដ្ឋបាល គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីដែលនាយករដ្ឋបាលអវត្តមាន នាយករដ្ឋបាលស្តីទីត្រូវធ្វើជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំអន្តរអង្គភាពត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយលេខាកត់ត្រា និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

បន្ថែមពីនេះទៅទៀត នាយករដ្ឋបាលក៏អាចអញ្ជើញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗទៀតដើម្បីចូលរួមក្នុងកិច្ចប្រជុំអន្តរអង្គភាពនេះផងដែរ តាមភាពចាំបាច់។

កិច្ចប្រជុំអន្តរអង្គភាពត្រូវរៀបចំជាទៀងទាត់ប្រចាំខែ។ ក្រៅពីកិច្ចប្រជុំប្រចាំខែ នាយករដ្ឋបាលអាចធ្វើការកោះប្រជុំអន្តរអង្គភាពតាមការចាំបាច់។ នាយករដ្ឋបាលត្រូវកំណត់កាលវិភាគ និងពេលវេលានៃកិច្ចប្រជុំប្រចាំខែសម្រាប់ឆ្នាំនីមួយៗ។

កិច្ចប្រជុំអន្តរអង្គភាពនេះធ្វើឡើងក្នុងគោលបំណងសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ចាត់ចែងការអនុវត្តសេចក្តីសម្រេច និងអនុសាសន៍របស់ក្រុមប្រឹក្សា គណៈអភិបាល គណៈ កម្មាធិការនានារបស់ក្រុមប្រឹក្សា
- ពិនិត្យលទ្ធផល និងបញ្ហាប្រឈមនានាក្នុងការអនុវត្តការងារ
- ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងការអនុវត្តការងារ
- រៀបចំផែនការការងារ ឬទិសដៅការងារសម្រាប់អង្គភាពនីមួយៗ

[144] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

– លើកយោបល់ និងអនុសាសន៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមពិនិត្យ និងដោះស្រាយ។[145]

## ២.៣.៥. ទីចាត់ការ និងការិយាល័យចំណុះ

ទីចាត់ការរបស់សាលារាជធានីភ្នំពេញគឺជាសេនាធិការរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈអភិបាលរាជធានីភ្នំពេញក្នុងការសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យ ទាក់ទងនឹងកិច្ចការសំខាន់នានា។ ដើម្បីអនុវត្តនូវកិច្ចការទាំងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្រោយពីមានការឯកភាពពី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ត្រូវចេញប្រកាសបង្កើតការិយាល័យចំណុះទីចាត់ការនីមួយៗនៃសាលារាជធានីភ្នំពេញ និងកំណត់អំពីតួនាទី ភារកិច្ច របៀបរបបការងាររបស់ការិយាល័យនីមួយៗឱ្យបានច្បាស់លាស់។[146]

នៅក្នុងការគ្រប់គ្រងដឹកនាំនាយកទីចាត់ការនីមួយៗត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល រីឯនាយកការិយាល័យចំណុះទីចាត់ការត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយកទីចាត់ការ។[147]

### ២.៣.៥.១. សមាសភាព និងការតែងតាំងនាយកទីចាត់ និងប្រធានការិយាល័យចំណុះទីចាត់ការ

យោងតាមមាត្រា៥៧ នៃអនុក្រឹត្យ លេខ២១៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ ទីចាត់ការនីមួយៗនៃសាលរាជធានីភ្នំពេញត្រូវដឹកនាំដោយនាយកទីចាត់ការមួយ(០១)រូប និងនាយករងទីចាត់ការយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ។

ចំណែកការិយាល័យចំណុះទីចាត់ការវិញ ត្រូវបានដឹកនាំដោយប្រធានការិយាល័យមួយ(០១)រូប និងអនុប្រធានការិយាល័យយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ។

ចំពោះលក្ខខណ្ឌសម្រាប់ការតែងតាំងនាយកទីចាត់ការ នាយករងទីចាត់ការ ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិកនៃទីចាត់ការនីមួយៗ ត្រូវផ្អែកតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

---

[145] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី កិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០១៥, ទំព័រ ១៧៥.

[146] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[147] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

### ២.៣.៥.២. តួនាទី ភារកិច្ចរបស់ទីចាត់ការ និងការិយាល័យចំណុះ

យោងតាមបទសម្ភាសជាមួយមន្ត្រីនៅសាលារាជធានីភ្នំពេញ នៅក្នុងពេលបច្ចុប្បន្ននេះ(២០២៤) សាលារាជធានីភ្នំពេញមានទីចាត់ការចំនួន៩ និងអង្គភាពចំនួន៣ ដែលទីចាត់ការទាំងនេះមានការិយាល័យចំណុះសរុបចំនួន ២៣ការិយាល័យ។[148]

**ក. ទីចាត់ការរដ្ឋបាល**

ទីចាត់ការរដ្ឋបាលមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការងារលេខិតស្នាម តម្កល់ឯកសារ និងការងារធ្វើនីត្យានុកូលកម្មលើឯកសារផ្សេងៗ
- ការគ្រប់គ្រងថែរក្សាត្រារបស់រដ្ឋបាលរាជធានីភ្នំពេញ
- ការងារព័ត៌មាន ការរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ និងការបិទផ្សាយព័ត៌មានលើក្តារព័ត៌មានសាធារណៈ
- ការគ្រប់គ្រងស្ថិតិ ទិន្នន័យប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន
- ការគាំទ្រការងារលេខាធិការដ្ឋានដល់ក្រុមប្រឹក្សារាជធានី។[149]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការរដ្ឋបាល មានការិយាល័យចំនួន៤ជាចំណុះគឺ[150]៖

**ក.១. ការិយាល័យរបៀប និងឯកសារ**

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ចដូចខាងក្រោម៖

- ទទួល និងបែងចែកលិខិតចេញ ចូល ទូរស័ព្ទ ទូរសារ
- ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែរក្សាត្រា
- ការងារបណ្ណាល័យ និងតម្កល់ឯកសារ
- រៀបចំកម្មវិធីការងារប្រចាំសប្តាហ៍របស់គណៈអភិបាលរាជធានី
- ការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងសាលារាជធានី។

---

[148] (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

[149] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[150] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

### ក.២. ការិយាល័យសរុប និងព័ត៌មាន

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ចដូចខាងក្រោម៖

- ប្រមូលផ្តុំព័ត៌មានអំពីមតិសាធារណៈ និងហេតុការណ៍ផ្សេងៗ សម្រាប់ជាមូលដ្ឋានរៀបចំព័ត៌មានជូនក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីធ្វើការដោះស្រាយឱ្យបានទាន់ពេលវេលា
- ប្រមូលផ្តុំព័ត៌មាន និងសភាពការណ៍ទូទៅគ្រប់វិស័យ សេចក្តីរាយការណ៍ពីទីចាត់ការនានា ពីខណ្ឌ និងពីសង្កាត់ក្នុងរាជធានីភ្នំពេញ សម្រាប់ជាមូលដ្ឋានរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំ និងបិទផ្សាយព័ត៌មានលើក្តារព័ត៌មានសាធារណៈ
- សហការរៀបចំព័ត៌មាន ឬកម្មវិធីនានាសម្រាប់ផ្សព្វផ្សាយតាមស្ថានីយវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត
- រៀបចំព្រឹត្តបត្រព័ត៌មាន ទស្សនាវដ្តី និងគេហទំព័ររបស់រដ្ឋបាលរាជធានី
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់រដ្ឋបាលរាជធានី
- រៀបចំការប្រជុំ និងកំណត់ហេតុប្រជុំរបស់គណៈអភិបាលរាជធានី។

### ក.៣. ការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ចដូចខាងក្រោម៖

- ជំរុញ និងគ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋក្នុងរាជធានី
- វិភាគ វាយតម្លៃអំពីស្ថានភាពនៃចំណូល និងចំណាកស្រុករបស់ប្រជាពលរដ្ឋក្នុងរាជធានី
- គាំទ្រ តាមដាន ត្រួតពិនិត្យ និងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន
- ពិនិត្យ និងផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមនីតិវិធីកំណត់
- ស្រាវជ្រាវ វិភាគ និងធ្វើការវាយតម្លៃអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព ដើម្បីបម្រើឱ្យកិច្ចការងារអត្រានុកូលដ្ឋាន
- ពិនិត្យ តាមដាន និងវាយតម្លៃការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយជនបរទេស
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន
- សិក្សា និងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការខាងមធ្យោបាយ និងសម្ភារៈទាក់ទងនឹងការងារអត្រានុកូលដ្ឋាននៅក្នុងរាជធានី ។

### ក.៤. ការិយាល័យលេខាធិការក្រុមប្រឹក្សា

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ចដូចខាងក្រោម៖

- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ លិខិតអញ្ជើញប្រជុំ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី
- សហការរៀបចំឯកសារតាមរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី
- ថែរក្សាកំណត់ហេតុប្រជុំ ដីកា សេចក្ដីសម្រេច និងឯកសាររបស់ក្រុមប្រឹក្សា និងរបស់គណៈកម្មាធិការ
- រៀបចំកន្លែងប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី
- សហការជាមួយទីចាត់ការ និងការិយាល័យពាក់ព័ន្ធក្នុងសាលារាជធានីភ្នំពេញ និងបណ្ដាញផ្សព្វផ្សាយដើម្បីធ្វើការជូនព័ត៌មានដល់សាធារណជនអំពីការប្រជុំ លទ្ធផលនៃការប្រជុំ សេចក្ដីសម្រេចនៃអង្គប្រជុំព្រមទាំងព័ត៌មានផ្សេងៗទៀតរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី
- សហការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមខណ្ឌនានាក្នុងរាជធានីភ្នំពេញ និងរៀបចំសេចក្ដីរាយការណ៍អំពីវេទិការនេះតាមការកំណត់។

### ខ. ទីចាត់ការផែនការនិងវិនិយោគ

ទីចាត់ការផែនការនិងវិនិយោគមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំនិងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ការគ្រប់គ្រងកិច្ចសន្យានិង/ឬអនុវត្តគម្រោងនានាដែលចុះកិច្ចសន្យាជាមួយរដ្ឋបាលរាជធានី
- កិច្ចសហការសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោងសម្រាប់បញ្ចូលក្នុងផែនការអភិវឌ្ឍរាជធានី និងគាំទ្របច្ចេកទេសដល់ខណ្ឌ សង្កាត់លើការងារទាំងនេះ
- ការគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខណ្ឌនិងសង្កាត់ ព្រមទាំងការអនុវត្តគម្រោងរបស់ខណ្ឌ សង្កាត់
- ការពិនិត្យនីត្យានុកូលភាពលើដីកានិងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌនិងសង្កាត់
- ការពិនិត្យនិងផ្ដល់យោបល់លើសំណើវិនិយោគនិងគម្រោងអភិវឌ្ឍរបស់ផ្នែកឯកជននិងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់រាជធានីភ្នំពេញ
- ការចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍនានារបស់រាជធានី ខណ្ឌ និង

សង្កាត់។[151]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការផែនការនិងវិនិយោគ មានការិយាល័យចំនួន៤ជាចំណុះគឺ[152]៖

### ខ.១. ការិយាល័យផែនការ

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការផែនការនិងវិនិយោគលើភារកិច្ចដូចខាងក្រោម៖

- សហការសម្របសម្រួលរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រាជធានី
- សហការសម្របសម្រួលរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី
- សហការរៀបចំអនុវត្តផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី
- សហការរៀបចំរបាយការណ៍រីកចម្រើនទាក់ទងដល់ការងារផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រាជធានី
- ទំនាក់ទំនងសហការជាមួយមន្ទីរ អង្គភាព ទាក់ទងនឹងទិន្នន័យ ផែនទី និងសេចក្តីត្រូវការជាអាទិភាពរបស់រាជធានី ខណ្ឌ និងសង្កាត់
- គ្រប់គ្រងកិច្ចសន្យា និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យានានាក្នុងកម្មវិធីវិនិយោគរបស់រាជធានី
- គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងបូកសរុបរបាយការណ៍នៃការអនុវត្តកិច្ចសន្យានានាដែលបានចុះហត្ថលេខារវាងរដ្ឋបាលរាជធានី និងភ្នាក់ងារអនុវត្ត
- សហការសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោង
- ពិនិត្យរបាយការណ៍រីកចម្រើននៃការអនុវត្តផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាខណ្ឌ និងសង្កាត់។

### ខ.២. ការិយាល័យគាំទ្រមូលដ្ឋាន

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការផែនការនិងវិនិយោគលើភារកិច្ចដូច

[151] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[152] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

ខាងក្រោម៖

- សម្របសម្រួល និងគាំទ្រដល់ខណ្ឌ និងសង្កាត់ក្នុងការកសាង និងការអនុវត្តផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- សម្របសម្រួល និងគាំទ្រដល់ខណ្ឌ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តគម្រោងនានារបស់ខណ្ឌ សង្កាត់
- គាំទ្រដល់ខណ្ឌ និងសង្កាត់ ក្នុងការសិក្សាគម្រោងរៀបចំប្លង់ ការប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោង
- ពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់ខណ្ឌ និងសង្កាត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការបំពេញការងាររបស់ក្រុមប្រឹក្សាខណ្ឌ សង្កាត់ ក្នុងការអនុវត្តលិខិតបទដ្ឋាន និងការចាត់ចែងកិច្ចការរដ្ឋបាលរបស់ខណ្ឌ សង្កាត់
- គាំទ្រដល់ខណ្ឌក្នុងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់សង្កាត់
- សិក្សាស្រាវជ្រាវអំពីការបង្កើត ការរំសាយ ការបំបែក ការបង្រួម និងការប្តូរឈ្មោះភូមិ សង្កាត់ និងខណ្ឌ ការផ្លាស់ប្តូរទីតាំងសាលាខណ្ឌ និងសាលាសង្កាត់
- សម្របសម្រួល និងជំរុញកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពពីបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន និងដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រការពង្រឹងសមត្ថភាពរដ្ឋបាលខណ្ឌ សង្កាត់ និងជួយកៀរគរធនធានសម្រាប់អភិវឌ្ឍខណ្ឌ សង្កាត់ ។

**ខ.៣. ការិយាល័យវិនិយោគ**

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការផែនការនិងវិនិយោគលើភារកិច្ចដូចខាងក្រោម៖

- សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ និងអង្គភាពផ្សេងៗទៀត ដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណើ សុំការលើកទឹកចិត្តលើការវិនិយោគគ្រប់ប្រភេទក្នុងរាជធានី
- សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ និងអង្គភាពផ្សេងៗទៀត ដើម្បីតាមដាន ត្រួតពិនិត្យការអនុវត្តយន្តការលើកទឹកចិត្តលើការវិនិយោគគ្រប់ប្រភេទក្នុងរាជធានី
- សហការក្នុងការសិក្សាអំពីគោលការណ៍ គោលនយោបាយ ដើម្បីជំរុញការវិនិយោគក្នុងរាជធានី
- រៀបចំកម្មវិធី ខ្លឹមសារ និងឯកសារលើការងារវិនិយោគ
- ពិនិត្យ និងផ្តល់យោបល់លើសំណើវិនិយោគ និងគម្រោងអភិវឌ្ឍរបស់ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់រាជធានី ។

### ខ.៤. ការិយាល័យអភិវឌ្ឍសហគមន៍អ្នកក្រីក្រ

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការផែនការនិងវិនិយោគលើភារកិច្ចដូចខាងក្រោម៖

- សិក្សា និងរៀបចំចងក្រងសហគមន៍អ្នកក្រីក្រ
- គ្រប់គ្រងទិន្នន័យសហគមន៍អ្នកក្រីក្រ
- រៀបចំផែនការអភិវឌ្ឍសហគមន៍ដោយមានការចូលរួម
- លើកកម្ពស់ភាពជាម្ចាស់របស់សហគមន៍នៅក្នុងការរៀបចំគម្រោងអភិវឌ្ឍនានា និងការកៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងអភិវឌ្ឍ និងការប្រើប្រាស់មូលនិធិអភិវឌ្ឍសហគមន៍អ្នកក្រីក្រ
- រៀបចំកម្មវិធី ដើម្បីផ្លាស់ប្តូរបទពិសោធន៍នៅក្នុងសហគមន៍ និងពីសហគមន៍មួយទៅសហគមន៍មួយផ្សេងទៀត
- ការងារផ្តល់ឥណទានមុខរបរខ្នាតតូចដល់សហគមន៍អ្នកក្រីក្រ
- រៀបចំលក្ខន្តិកៈនៃការខ្ចី និងការសងឥណទាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការប្រើប្រាស់ឥណទាន
- ការងារភូមិមួយផលិតផលមួយ និងការស្វែងរកទីផ្សារ
- សិក្សាអំពីទីតាំង និងបញ្ហាលំនៅដ្ឋានរបស់សហគមន៍អ្នកក្រីក្រ
- សិក្សា និងស្វែងរកដៃគូ ដើម្បីជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងលំនៅដ្ឋានក្នុងសហគមន៍អ្នកក្រីក្រ
- ស្វែងរក និងផ្តល់ឥណទានសាងសង់លំនៅដ្ឋានសម្រាប់សហគមន៍អ្នកក្រីក្រ។

### គ. ទីចាត់ការហិរញ្ញវត្ថុ

ទីចាត់ការហិរញ្ញវត្ថុមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំសេចក្តីព្រាងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យម
- ការងារហិរញ្ញវត្ថុ ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរបស់រាជធានី
- ការរៀបចំឱ្យមានការធ្វើសវនកម្មឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ
- ការគ្រប់គ្រងចំណូល ចំណាយ និងគណនេយ្យ
- ការគាំទ្រដល់ការងារហិរញ្ញវត្ថុខណ្ឌ និងសង្កាត់

- ការងារសារពើភណ្ឌ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានី
- ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាលារាជធានី។[153]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការហិរញ្ញវត្ថុ មានការិយាល័យចំនួន៣ជាចំណុះគឺ[154]៖

**គ.១. ការិយាល័យហិរញ្ញកិច្ច**

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការហិរញ្ញវត្ថុលើភារកិច្ចដូចខាងក្រោម៖

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលរាជធានី
- សហការរៀបចំនីតិវិធីហិរញ្ញវត្ថុ និងការប្រើប្រាស់ថវិការបស់រដ្ឋបាលរាជធានី
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តនីតិវិធីហិរញ្ញវត្ថុ និងការប្រើប្រាស់ថវិការបស់រដ្ឋបាលរាជធានី
- សហការរៀបចំលិខិតបទដ្ឋានតាមគោលការណ៍កំណត់សម្រាប់ប្រមូលចំណូល
- ចាត់វិធានការជំរុញការប្រមូលចំណូលគ្រប់ប្រភេទសម្រាប់ថវិការបស់រដ្ឋបាលរាជធានី
- រៀបចំអាណត្តិបើកប្រាក់ និងសំណើសុំចំណាយគ្រប់ប្រភេទ
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុ ។

**គ.២. ការិយាល័យគណនេយ្យ**

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការហិរញ្ញវត្ថុលើភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងបេឡាសាច់ប្រាក់ រដ្ឋទេយ្យចំណូល និងរដ្ឋទេយ្យបុរេប្រទាន និងគណនីរបស់រដ្ឋបាលរាជធានី
- ចុះបញ្ជី និងគ្រប់គ្រងចំណូលថវិការបស់រដ្ឋបាលរាជធានី
- ធ្វើសេចក្តីរាយការណ៍អំពីចំណូល ចំណាយ និងថវិកាតាមគណនីនានារបស់រដ្ឋបាលរាជធានី
- រៀបចំ និងបើកប្រាក់បៀវត្សជូនមន្ត្រី បុគ្គលិកក្នុងសាលារាជធានី
- ទទួលអាណត្តិបើកប្រាក់ និងរៀបចំឯកសារដកសាច់ប្រាក់
- ត្រួតពិនិត្យ និងបើកផ្តល់រាល់ការចំណាយ
- គ្រប់គ្រងឃ្លាំងសម្ភារៈ

[153] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[154] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

– សហការផ្គូផ្គងដើម្បីរៀបចំរបាយការណ៍សម្រេចទូទាត់ថវិការាជធានី។

### គ.៣. ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិ

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការហិរញ្ញវត្ថុលើភារកិច្ចដូចខាងក្រោមៈ

– គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យគ្រប់ប្រភេទរបស់រដ្ឋបាលរាជធានី
– ធ្វើសារពើភណ្ឌ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ ចលនទ្រព្យ និងអចលនទ្រព្យ
– សហការរៀបចំគោលការណ៍សម្រាប់គ្រប់គ្រង ចាត់ចែងប្រើប្រាស់ចលនទ្រព្យ និងអចលនទ្រព្យ
– រៀបចំឯកសារសម្រាប់ជំរះបញ្ជី លក់ ជួល វិនិយោគទៅលើទ្រព្យសម្បត្តិនានារបស់រដ្ឋបាលរាជធានី។

### ឃ. ទីចាត់ការរៀបចំក្រុង

ទីចាត់ការរៀបចំក្រុងមានកិច្ចការសំខាន់ៗដូចខាងក្រោមៈ

– ការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដី
– ការងារពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី ការសាងសង់សំណង់ និងការជួសជុលសំណង់នានា ព្រមទាំងការដោះស្រាយបទល្មើស នៃការសាងសង់សំណង់នានា
– ការកំណត់យុទ្ធសាស្ត្រក្នុងការរៀបចំ និងការអភិវឌ្ឍការតាំងទីលំនៅឋាន និងការតាំងទីលំនៅក្នុងរាជធានីភ្នំពេញ
– ការគ្រប់គ្រងសំណង់ចាស់ និងបេតិកភណ្ឌក្នុងរាជធានី
– ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូន ឧទ្យាន សួនច្បារ និងការបំភ្លឺសាធារណៈ។[155]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការរៀបចំក្រុង មានការិយាល័យចំនួន២ជាចំណុះគឺ[156]៖

### ឃ.១. ការិយាល័យនគរូបនីយកម្ម

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរៀបចំក្រុងលើភារកិច្ចដូចខាងក្រោមៈ

– សហការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីសម្រាប់រាជធានី
– ពិនិត្យ និងផ្តល់យោបល់លើគម្រោងអភិវឌ្ឍនានា ដើម្បីឱ្យស្របតាមប្លង់គោលប្រើប្រាស់ដីធ្លី និង

[155] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[156] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

ផែនការប្រើប្រាស់ដី

- តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍អំពីការអនុវត្តប្លង់គោលប្រើប្រាស់ដីធ្លី ផែនការប្រើប្រាស់ដី និងប្លង់សំណង់
- កំណត់យុទ្ធសាស្ត្រក្នុងការរៀបចំ និងការអភិវឌ្ឍការតាំងទីលំនៅក្នុងរាជធានី
- វិភាគ វាយតម្លៃអំពីកំណើនប្រជាពលរដ្ឋ បញ្ហាសេដ្ឋកិច្ច សង្គម ទាក់ទងទៅនឹងការតាំងទីលំនៅ
- គ្រប់គ្រង និងអភិវឌ្ឍសួនច្បារ ឧទ្យាន ការបំភ្លឺសាធារណៈ ។

**ឃ.២. ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់**

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរៀបចំក្រុងលើភារកិច្ចដូចខាងក្រោម៖

- ការងារពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី
- ការងារពាក់ព័ន្ធនឹងការសាងសង់សំណង់ និងការជួសជុលសំណង់នានា
- ពិនិត្យ និងផ្តល់យោបល់លើបទល្មើសនៃការសាងសង់សំណង់នានា
- គ្រប់គ្រងសំណង់ចាស់ និងបេតិកភ័ណ្ឌក្នុងរាជធានី
- សហការកំណត់អំពីគោលការណ៍ក្នុងការអភិវឌ្ឍ និងថែទាំ ជួសជុលហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងរាជធានី
- ការតាំងទីលំនៅថ្មី ការរក្សាសណ្តាប់ធ្នាប់ នគររូបនីយកម្ម និងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។

**ង. ទីចាត់ការគ្រប់គ្រងធនធានមនុស្ស**

ទីចាត់ការគ្រប់គ្រងធនធានមនុស្សមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការងារក្របខណ្ឌនិងការគ្រប់គ្រងមន្ត្រី បុគ្គលិកដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- ផែនការប្រើប្រាស់និងជ្រើសរើសទីប្រឹក្សាបច្ចេកទេស បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- ការផ្តល់គ្រឿងឥស្សរិយយស មេដាយ បណ្ណសរសើរដល់មន្ត្រី បុគ្គលិក និងសប្បុរសជននានា
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពនិងបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិក
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់មន្ត្រី បុគ្គលិក
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យចំណុះសាលារាជធានី
- ការកំណត់នីតិវិធីរដ្ឋបាលសម្រាប់ទីចាត់ការនិងលក្ខខណ្ឌការងាររបស់មន្ត្រី បុគ្គលិក

- ការផ្សព្វផ្សាយនិងតាមដានការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីរដ្ឋបាលដែលពាក់ព័ន្ធនឹងការងារបុគ្គលិក តួនាទី ភារកិច្ច លក្ខខលកខណ្ឌការងាររបស់មន្ត្រី បុគ្គលិក។[157]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស មានការិយាល័យចំនួន២ ជាចំណុះគឺ[158]៖

### ង.១. ការិយាល័យគ្រប់គ្រងបុគ្គលិក

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សលើភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការប្រើប្រាស់ក្របខណ្ឌ និងមន្ត្រី បុគ្គលិករដ្ឋបាលរាជធានី
- ការងារជ្រើសរើសមន្ត្រី បុគ្គលិក ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌ
- រៀបចំ និងការថែរក្សាសំណុំលិខិតមន្ត្រី បុគ្គលិករដ្ឋបាលរាជធានី
- រៀបចំតួនាទី ភារកិច្ច និងនីតិវិធីរដ្ឋបាលរបស់ទីចាត់ការ និងការិយាល័យនានារបស់សាលារាជធានី និងតាមដាន វាយតម្លៃការអនុវត្ត
- រៀបចំលក្ខខណ្ឌការងាររបស់មន្ត្រី បុគ្គលិក និងតាមដាន វាយតម្លៃការអនុវត្ត
- សិក្សា និងរៀបចំផែនការប្រើប្រាស់ និងជ្រើសរើសទីប្រឹក្សាបច្ចេកទេស មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- ពិនិត្យលើកយោបល់លើសំណើសុំតែងតាំងមុខតំណែង ការផ្លាស់ប្តូរភារកិច្ច ការផ្លាស់ប្តូរកន្លែងធ្វើការងារ ការស្នើសុំច្បាប់ឈប់សម្រាករបស់មន្ត្រី បុគ្គលិករដ្ឋបាលរាជធានី
- ពិនិត្យ ស្រាវជ្រាវលើកយោបល់លើការដាក់ពិន្ទុ និងមូលវិចារសម្រាប់ដំឡើងឋានន្តរស័ក្ត និងដំឡើងថ្នាក់ដល់មន្ត្រី បុគ្គលិករដ្ឋបាលរាជធានី
- រៀបចំ និងរក្សាទុកសំណុំលិខិតមន្ត្រី បុគ្គលិក ដែលដល់អាយុចូលនិវត្តន៍ ឈប់សម្រាកលម្ហែមាតុភាព ដាក់ឱ្យនៅក្រៅក្របខណ្ឌដើម ដាក់ឱ្យនៅក្រៅតំណែង ដាក់ឱ្យនៅក្រោមឱវាទ ដាក់ឱ្យនៅទំនេរគ្មានបៀវត្ស និងផ្ទេរក្របខណ្ឌ

[157] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[158] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

- ពិនិត្យស្រាវជ្រាវ និងលើកយោបល់ក្នុងការដាក់វិន័យ ការដកហូតមុខតំណែង និងការបណ្តេញចេញពីក្របខណ្ឌ
- រៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយស មេដាយ និងប័ណ្ណសរសើរដល់មន្ត្រី បុគ្គលិករដ្ឋបាលរាជធានី និងសប្បុរសជន
- លើកសំណើក្នុងការអនុវត្តរបបគោលនយោបាយដល់មន្ត្រី បុគ្គលិកដែលលាឈប់ពីការងារ បាត់បង់សម្បទា វិជ្ជាជីវៈ និងទទួលមរណភាព
- រៀបចំសំណើបង្កើត ឬកែសម្រួល ឬរំសាយទីចាត់ការ ឬការិយាល័យនៃសាលារាជធានី
- ពិនិត្យ និងលើកយោបល់លើសំណើបង្កើត ឬកែសម្រួល ឬរំសាយការិយាល័យនៃសាលាខណ្ឌ
- ពិនិត្យ និងលើកយោបល់ក្នុងការរៀបចំសមាសភាពគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី។

### ង.២. ការិយាល័យកសាងសមត្ថភាព

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សលើភារកិច្ចដូចខាងក្រោម៖

- សិក្សា កំណត់យុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់អភិវឌ្ឍសមត្ថភាពដល់មន្ត្រី បុគ្គលិករបស់រដ្ឋបាលរាជធានី
- វាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល និងការរៀបចំកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិករបស់រដ្ឋបាលរាជធានី
- សហការរៀបចំឯកសារ សម្ភារៈ និងបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិករដ្ឋបាលរាជធានី
- ផ្តល់យោបល់ក្នុងការជ្រើសរើស ចាត់បញ្ជូនមន្ត្រី បុគ្គលិកទៅទស្សនកិច្ចដកពិសោធន៍ការងារ និងសិក្សារយៈពេលខ្លី និងរយៈពេលវែងក្នុង និងក្រៅប្រទេស
- ផ្សព្វផ្សាយច្បាប់រៀបចំអង្គការ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ តួនាទីភារកិច្ចរបស់ទីចាត់ការ និងការិយាល័យនានា ព្រមទាំងលក្ខខណ្ឌការងាររបស់មន្ត្រី បុគ្គលិក។

### ច. ទីចាត់ការអន្តរវិស័យ

ទីចាត់ការអន្តរវិស័យមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- កិច្ចសហការសម្របសម្រួលក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន និងការទទួលខុសត្រូវដើម្បីផ្ទេរមកឱ្យរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់
- កិច្ចសហការសម្របសម្រួលក្នុងការធ្វើប្រតិភូកម្មមុខងារដល់រាជធានី ខណ្ឌ និងសង្កាត់

- កិច្ចសហការសម្របសម្រួលអនុវត្តមុខងារ ភារកិច្ចនានា ដែលទាក់ទងការងារសេដ្ឋកិច្ច ការលើកកម្ពស់សុខុមាលភាពសង្គម និងការផ្តល់សេវាសាធារណៈនានា លើកលែងតែមុខងារ ភារកិច្ចទាំងឡាយណាដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃសាលារាជធានី ដែលកំណត់ក្នុងអនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- ការអនុវត្តមុខងារ ភារកិច្ចថ្មីដែលបានផ្ទេរមកឱ្យរដ្ឋបាលរាជធានី លើកលែងតែមុខងារ ភារកិច្ចដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃសាលារាជធានីភ្នំពេញ ដែលបានកំណត់ក្នុងអនុក្រឹត្យពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- គ្រប់គ្រងការងារផ្សព្វផ្សាយពាណិជ្ជកម្ម។[159]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការអន្តរវិស័យ មានការិយាល័យចំនួន២ជាចំណុះគឺ[160]៖

### ច.១. ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការអន្តរវិស័យលើភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងស្ថិតិអំពីមូលដ្ឋានអាជីវកម្ម ផលិតកម្មគ្រប់ប្រភេទក្នុងរាជធានី
- សហការអនុវត្តការងារសេដ្ឋកិច្ច សង្គមកិច្ចជាមួយមន្ទីរជំនាញ និងអង្គភាពនានា តាមការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័ន
- សិក្សាលើកយោបល់អំពីការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងការប្រកបមុខរបរក្នុងរាជធានី
- រៀបចំ និងជំរុញការអនុវត្តគោលនយោបាយបង្កបង្កើនផលនៅតំបន់ជាយក្រុង
- កំណត់គោលការណ៍អំពីការគ្រប់គ្រងផ្សារ និងសត្តឃាតដ្ឋាន
- សហការសម្របសម្រួលក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ការទទួលខុសត្រូវ និងធនធាន ដើម្បីផ្ទេរមករដ្ឋបាលរាជធានី ព្រមទាំងការធ្វើប្រតិភូកម្មមុខងារ និងធនធានទៅឱ្យខណ្ឌនិងសង្កាត់
- សហការសម្របសម្រួល ដើម្បីលើកកម្ពស់ការផ្តល់សេវាអប់រំសុខាភិបាលក្នុងរាជធានី

[159] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[160] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

- សហការអប់រំផ្សព្វផ្សាយអំពីកម្មវិធីបង្ការជំងឺ សេវាសុខភាពសាធារណៈ
- សហការសម្របសម្រួល ដើម្បីដោះស្រាយបញ្ហានានាពាក់ព័ន្ធដល់ការជួយសង្គ្រោះជនទីទ័លក្រ និវត្តន៍ជន ជនពិការ កុមារកំព្រា ជនអនាថា ជនគ្មានទីពឹង
- វិធានការបង្ការអគ្គិភ័យ គ្រោះធម្មជាតិ គ្រោះថ្នាក់សង្គម និងការជួយសង្គ្រោះ ការដោះស្រាយបញ្ហាពលកម្ម ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការលើកកម្ពស់សុខុមាលភាពដល់ស្ត្រី កុមារ
- ការបញ្ជ្រាបយេនឌ័រក្នុងគ្រប់សកម្មភាពសង្គម
- សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងជំនឿ សាសនា វប្បធម៌ ប្រពៃណីក្នុងរាជធានី
- សម្របសម្រួលអន្តរវិស័យ ដើម្បីជំរុញនិងលើកកម្ពស់ការបង្កើតបរិស្ថានធុរកិច្ចល្អប្រសើរសម្រាប់ធ្វើសកម្មភាពសេដ្ឋកិច្ចគ្រប់ប្រភេទ សំដៅជំរុញឱ្យមានការវិនិយោគ និងការអភិវឌ្ឍវិស័យឯកជននៅក្នុងរាជធានី។

### ច.២. ការិយាល័យផ្សព្វផ្សាយពាណិជ្ជកម្ម

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការអន្តរវិស័យលើភារកិច្ចដូចខាងក្រោម៖

- រៀបចំបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការដាក់តាំងផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម ប្រអប់ភ្លើង របារកាត់ទទឹងផ្លូវ ស្លាកយីហោ និងការផ្សព្វផ្សាយតាមយានយន្តចល័តនានា
- ពិនិត្យ និងផ្តល់យោបល់ជុំវិញការស្នើសុំទីតាំងដាក់ផ្សាយពាណិជ្ជកម្ម
- ធ្វើស្ថិតិនៃការដាក់ផ្សព្វផ្សាយពាណិជ្ជកម្ម ដើម្បីលើកផែនការដាក់តាំងផ្សាយពាណិជ្ជកម្មរយៈពេលខ្លីរយៈពេលវែង និងការរៀបចំជាប្លង់មេសម្រាប់ផ្សព្វផ្សាយពាណិជ្ជកម្ម។

### ឆ. ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស

ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្សមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់និងការអនុវត្តច្បាប់
- ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ការគោរពសិទ្ធិមនុស្ស និងយេនឌ័រ
- ការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់រាជធានីនិងការដោះស្រាយវិវាទនៅមូលដ្ឋាន
- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការលើកកម្ពស់សុវត្ថិភាពសង្គម

- ការសម្រប់សម្រួលសកម្មភាពគណបក្សនយោបាយសមាគម អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សហជីព ដែលមានសកម្មភាពក្នុងរាជធានី
- ការធ្វើបាតុកម្ម កូដកម្មក្នុងរាជធានី
- កិច្ចសហការសម្របសម្រួលលើការងារតុលាការនិងពន្ធនាគារ។[161]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស មានការិយាល័យចំនួន២ជាចំណុះគឺ[162]៖

### ឆ.១. ការិយាល័យសុវត្ថិភាពសាធារណៈ

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធីមនុស្សភារកិច្ចដូចខាងក្រោម៖

- កំណត់គោលការណ៍ និងវិធានការអំពីការប្រើប្រាស់យានយន្ត និងមធ្យោបាយធ្វើដំណើរផ្សេងទៀតក្នុងរាជធានី និងសម្របសម្រួលតម្រង់ទិសការអនុវត្ត
- កំណត់គោលការណ៍ វិធានការអំពីសុវត្ថិភាពចរាចរក្នុងរាជធានី និងសម្របសម្រួលការអនុវត្ត
- គ្រប់គ្រងប្រព័ន្ធចរាចរ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទក្នុងរាជធានី
- កំណត់គោលការណ៍ និងវិធានការក្នុងការទប់ស្កាត់ និងប្រឆាំងឧក្រិដ្ឋកម្ម និងបទល្មើសនានា ព្រមទាំងរក្សាសុវត្ថិភាពក្នុងរាជធានី
- សហការស្រាវជ្រាវអំពីអ្នកញៀនគ្រឿងញៀន និងការរៀបចំគោលនយោបាយនានាស្តីពីការបង្ការទប់ស្កាត់ និងប្រឆាំងគ្រឿងញៀន
- គ្រប់គ្រងដំណើរការមជ្ឈមណ្ឌលឱកាសខ្ញុំ និងមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនផ្សេងៗទៀត
- សហការ សម្របសម្រួលជាមួយមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនក្នុងរាជធានី
- ចូលរួមក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរាជធានី និងសហការតាមដានការអនុវត្តការសម្រេចនៃកិច្ចប្រជុំនេះ ។

### ឆ.២. ការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធីមនុស្សភារកិច្ច

[161] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[162] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

ដូចខាងក្រោម៖

- អំពីការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់រាជធានី
- ទទួលពិនិត្យ និងលើកយោបល់អំពីការដោះស្រាយវិវាទនានានៅមូលដ្ឋាន
- ទទួលពិនិត្យ និងលើកយោបល់លើពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាលនានាក្នុងដែនសមត្ថកិច្ចរបស់រាជធានី
- លើកយោបល់ជុំវិញការអនុវត្តនូវអំណាចដែលបានទទួលប្រតិភូកម្មទាក់ទងទៅនឹងការអនុវត្តច្បាប់ និងការគោរពច្បាប់
- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់ និងការអនុវត្តច្បាប់
- អប់រំ ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និងការគោរពសិទ្ធិមនុស្ស
- ចូលរួមក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរាជធានី និងសហការតាមដានការអនុវត្តការសម្រេចនៃកិច្ចប្រជុំនេះ ។

**ជ. ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន**

ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថានមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- កសាងគោលការណ៍និងវិធានការលើការងារគ្រប់គ្រងកាកសំណល់
- ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានា ដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់
- អប់រំ ផ្សព្វផ្សាយដល់សាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងនិងការចូលរួមក្នុងការគ្រប់គ្រង កាកសំណល់
- សហការដោះស្រាយវិវាទបរិស្ថានដែលបណ្ដាលមកពីកាកសំណល់
- គ្រប់គ្រងការប្រើប្រាស់ឡើងវិញនិងការកែច្នៃសំរាម។[163]

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន មានការិយាល័យចំនួន២ជាចំណុះគឺ[164]៖

[163] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

[164] ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

### ជ.១. ការិយាល័យគ្រប់គ្រងកាកសំណល់

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថានលើភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងទីលានចាក់សំរាម
- គ្រប់គ្រងការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម
- គ្រប់គ្រងការបូម និងទុកដាក់កាកសំណល់រាវ។

### ជ.២. ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថានលើភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងទិន្នន័យកាកសំណល់
- កសាងផែនការគ្រប់គ្រងកាកសំណល់
- កសាងគោលការណ៍ និងវិធានការលើការងារគ្រប់គ្រងកាកសំណល់
- ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់
- អប់រំ ផ្សព្វផ្សាយដល់សាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹង និងចូលរួមក្នុងការគ្រប់គ្រងកាកសំណល់
- សហការជាមួយជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់ផលប៉ះពាល់បរិស្ថាន ដែលបណ្ដាលមកពីកាកសំណល់
- ដោះស្រាយវិវាទបរិស្ថានដែលបណ្ដាលមកពីកាកសំណល់ ។

### ឈ. ទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ[165]

ទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិមានកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ទំនាក់ទំនងទទួល និងផ្ដល់ព័ត៌មានជូនសាធារណជននានា ដែលមកមានទំនាក់ទំនងការងារនៅសាលារាជធានីភ្នំពេញ
- ទទួលបន្ទុកការងារពិធីការ និងរៀបចំពិធីបដិសណ្ឋារកិច្ចចំពោះគណៈប្រតិភូភ្ញៀវជាតិ និងអន្តរជាតិ

---

[165] ប្រកាសលេខ ៥៥១២ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ស្ដីពីការបង្កើតទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិនៅក្នុងរចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ.

ដែលមកបំពេញភារកិច្ច នៅក្នុងរាជធានីភ្នំពេញ និងសហការរៀបចំពិធីបុណ្យជាតិ អន្តរជាតិ ការសម្ពោធសមិទ្ធផល មិទ្ទិញ ឬពិធីការនានារបស់រាជធានីភ្នំពេញ

- កិច្ចការចងសម្ព័ន្ធមេត្រីភាពជាមួយរាជធានី ខេត្ត ក្រុង និងស្ថាប័ននានាជាដៃគូ
- រៀបចំឯកសារសេចក្ដីព្រាងអនុស្សារណៈ ឬកិច្ចព្រមព្រៀងនានារវាងរាជធានីភ្នំពេញ និងខេត្ត ខណ្ឌ និងក្រុង និងអង្គការជាតិ អន្តរជាតិនានា
- កិច្ចសហប្រតិបត្តិការ និងគាំទ្រពីរាជធានី ខេត្ត ក្រុងសម្ព័ន្ធមេត្រីភាព និងពីអង្គការជាតិ អន្តរជាតិនានា
- លើកគម្រោងសកម្មភាព សម្រាប់ទស្សនកិច្ច ពិធីបុណ្យ និងព្រឹត្តិការណ៍នានា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីកិច្ចសហប្រតិបត្តិការរវាងរាជធានីភ្នំពេញ និងខេត្ត ក្រុង ដែលជាដៃគូ។

ដើម្បីអនុវត្តកិច្ចការងារសំខាន់ៗទាំងនេះ ទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិមានការិយាល័យចំនួន២ជាចំណុះគឺ៖

### ឈ.១. ការិយាល័យទំនាក់ទំនងសាធារណៈ និងពិធីការ

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិលើភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកការងារពិធីការរបស់គណៈប្រតិភូជាតិ អន្តរជាតិ ដែលត្រូវអញ្ជើញមកចូលរួមកិច្ចប្រជុំ បំពេញទស្សនកិច្ចក្នុងរាជធានីភ្នំពេញ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ អន្តរជាតិ
- ទទួលបន្ទុករៀបចំលិខិតថ្វាយព្រះពរថ្វាយព្រះមហាក្សត្រ ជូនពរថ្នាក់ដឹកនាំរាជរដ្ឋាភិបាលអង្គទូត ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងឱកាសបុណ្យជាតិ និងអន្តរជាតិ
- ទំនាក់ទំនងទទួលនិងផ្តល់ព័ត៌មានជូនសាធារណជននានាដែលមកមានទំនាក់ទំនងការងារនៅសាលារាជធានីភ្នំពេញ
- ទទួលបន្ទុកការងារពិធីការ និងសហការរៀបចំពិធីបុណ្យជាតិ ការសម្ពោធសមិទ្ធផល មិទ្ទិញ ឬពិធីការនានារបស់រាជធានីភ្នំពេញ
- ទទួលបន្ទុកសហការរៀបចំការងារសន្តិសុខ សុវត្ថិភាព ការស្នាក់នៅ និងគោលដៅទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ ក្នុងកំឡុងពេលធ្វើដំណើរអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំ និងទស្សនកិច្ចនៅក្នុងរាជធានីភ្នំពេញ

- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងាររបស់ការិយាល័យតាមការកំណត់របស់ទីចាត់ការ
- បំពេញការងារផ្សេងៗទៀត ដែលនាយករដ្ឋបាល និងនាយកទីកចាត់ការប្រគល់ជូន។

**ឈ.២. ការិយាល័យទំនាក់ទំនងអន្តរជាតិ**

ការិយាល័យនេះមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិលើភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងចាត់ចែងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការជាមួយរាជធានី ខេត្ត ក្រុង ឬស្ថាប័ន នៃប្រទេសជាដៃគូ
- រៀបចំផ្តួចផ្តើមទំនាក់ទំនងជាមួយរាជធានី ខេត្ត ក្រុង ឬស្ថាប័ននៃប្រទេសជាដៃគូ ដើម្បីលើកយោបល់ ជូនក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ ពិនិត្យ សម្រេចអំពីការងាររៀបចំខ្លឹមសារចំណងមេត្រីភាពនៅពេលអនាគត
- រៀបចំឯកសារសេចក្តីព្រាងអនុស្សារណៈ ឬកិច្ចព្រមព្រៀងនានារវាងរាជធានីភ្នំពេញ និងខេត្ត ក្រុង និង អង្គការជាតិ អន្តរជាតិជាដៃគូ រាយការណ៍ជូនគណៈអភិបាលក្រុមប្រឹក្សារាជធានីភ្នំពេញ និងស្នើសុំទៅ ក្រសួងមហាផ្ទៃពិនិត្យ សម្រេច
- សម្របសម្រួលលើកិច្ចការចងសម្ព័ន្ធមេត្រីភាពរវាងខណ្ឌក្នុងរាជធានីភ្នំពេញ ជាមួយខេត្ត ក្រុង ស្រុកជាដៃគូនៃបណ្តាប្រទេសជាមិត្ត
- សហការអនុវត្តនូវអនុស្សារណៈ ឬកិច្ចព្រមព្រៀងនានា ដែលរដ្ឋបាលរាជធានីភ្នំពេញជាភាគីហត្ថលេខី
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីកិច្ចសហប្រតិបត្តិការរវាងរាជធានីភ្នំពេញ និងខេត្ត ក្រុងជាដៃគូ
- រៀបចំដំណើរទស្សនកិច្ចសិក្សាជូនក្រុមប្រឹក្សាគណៈអភិបាលអភិបាលរាជធានីភ្នំពេញ មន្ទីរ អង្គភាពពាក់ព័ន្ធទៅបណ្តាប្រទេស ខេត្ត ក្រុង សម្ព័ន្ធមេត្រីភាព និងអង្គការជាតិ អន្តរជាតិ ដៃគូ
- សិក្សាអំពីលទ្ធភាព និងកៀគរបណ្តាប្រទេស ខេត្ត ក្រុង ជាដៃគូ និងអង្គការជាតិ អន្តរជាតិ ដើម្បីស្វែងរកជំនួយក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាដៃគូនានា ដើម្បីចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមកលើគ្រប់វិស័យការងារគ្រប់គ្រងបរិស្ថាន ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ប្តូរដំណើរទស្សនកិច្ចពីគ្នាទៅវិញទៅមកក្នុងកម្រិតថ្នាក់រាជធានីភ្នំពេញ
- លើកគម្រោងសកម្មភាព សម្រាប់ទស្សនកិច្ច ពិធីបុណ្យ និងព្រឹត្តិការណ៍នានា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងាររបស់ការិយាល័យតាមការកំណត់របស់ទីចាត់ការ

- បំពេញការងារផ្សេងៗទៀត ដែលនាយករដ្ឋបាល និងនាយកទីចាត់ការប្រគល់ឱ្យ។

**៣. អង្គភាពលទ្ធកម្ម**[166]

អង្គភាពលទ្ធកម្ម គឺជាសេនាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ដែលមានប្រធានអង្គភាពលទ្ធកម្មជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម។ អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានីភ្នំពេញត្រូវមានកម្រិតស្មើនឹងទីចាត់ការសាលារាជធានីភ្នំពេញ ដែលប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មត្រូវមានឋានៈស្មើនឹងនាយក និងនាយករងទីចាត់ការសាលារាជធានីភ្នំពេញ។

អង្គភាពលទ្ធកម្មមានភារកិច្ចបំពេញកិច្ចការសំខាន់ដូចខាងក្រោម៖

- រៀបចំសេចក្ដីសម្រេចព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយសេចក្ដីជូនដំណឹងអំពីកិច្ចលទ្ធកម្មនីមួយៗ
- លក់ ឬផ្ដល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំទុកដាក់សំណើដេញថ្លៃដែលបានទទួលឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងត្រូវគ្រប់គ្រងឯកសារ ឬលិខិតស្នាមពាក់ព័ន្ធទាំងអស់មុនពេលបើកសំណើដេញថ្លៃ
- ចាត់ចែងរៀបចំទីកន្លែងសម្រាប់បើកសំណើដេញថ្លៃ
- រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ ដោយមានការដឹកនាំត្រួតពិនិត្យពីគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្ដីពីការបើកសំណើដេញថ្លៃ
- ជួយសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ
- ផ្ញើលិខិតជូនដំណឹងស្ដីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងលិខិតចម្លងជូនទៅឱ្យគ្រប់អ្នកដេញថ្លៃចាញ់

---

[166] ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.

- ធ្វើសេចក្តីព្រាងកិច្ចសន្យាឱ្យសមស្របតាមបទដ្ឋានឯកសារកិច្ចសន្យាដែលបានកំណត់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

### ជ. អង្គភាពច្រកចេញចូលតែមួយ

អង្គភាពច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព ដើម្បីផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋដែលស្ថិតនៅក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន។[167] សេវារដ្ឋបាលដែលអង្គភាពនេះផ្តល់ឱ្យមានសរុបចំនួន ១៤ប្រភេទ(ដូចមាននៅក្នុងឧបសម្ព័ន្ធទី១៣)។

អង្គភាពច្រកចេញចូលតែមួយនេះមានភារកិច្ចបំពេញកិច្ចការសំខាន់ៗដូចខាងក្រោម៖[168]

- ទទួល ពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារស្នើសុំសេវារដ្ឋបាលរបស់ប្រជាពលរដ្ឋ ព្រមទាំងផ្តល់លទ្ធផលសម្រេចជាផ្លូវការ
- លើកយោបល់លើការរៀបចំទម្រង់បែបបទ នីតិវិធីលម្អិត និងក្របខណ្ឌពេលវេលាសម្រាប់ផ្តល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រមូល ចងក្រងទិន្នន័យអាជីវកម្ម សិប្បកម្ម សេវាកម្ម និងទិន្នន័យពាក់ព័ន្ធ ដើម្បីរៀបចំបញ្ជីសេវារដ្ឋបាលតាមវិស័យនីមួយៗ និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំនូវបញ្ជីសេវារដ្ឋបាលទាំងនេះ ដោយសហការជាមួយមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ
- ផ្សព្វផ្សាយ និងផ្តល់ព័ត៌មាននានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ
- រៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន វេទិកាប្រចាំឆមាស និងវេទិកាប្រចាំឆ្នាំស្តីពីការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ
- សហការ សម្របសម្រួល និងធ្វើទំនាក់ទំនងជាមួយមន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានាក្នុងការផ្សព្វផ្សាយជំរុញការផ្តល់សេវា ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្ត ការផ្តល់សេវារដ្ឋបាល

[167] អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ.

[168] ប្រកាសលេខ ៣៨៧១ ប្រក ចុះថ្ងៃទ០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត.

- សម្របសម្រួលដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយ
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់អង្គភាពច្រកចេញចូលតែមួយ
- រៀបចំរបាយការណ៍ជាទៀងទាត់តាមគោលការណ៍កំណត់។

ដើម្បីអនុវត្តកិច្ចការសំខាន់ៗទាំងនេះ អង្គភាពច្រកចេញចូលតែមួយមានបែងចែកជា២ផ្នែកក្នុងការអនុវត្តគឺ៖

១. ផ្នែកជួរមុខ៖ គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួល ប្រគល់ពាក្យស្នើសុំ បង់ប្រាក់កម្រៃសេវា និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាល។ ផ្នែកជួរមុខត្រូវរៀបចំឱ្យមានបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន បុគ្គលិកទទួលបន្ទុកប្រគល់ឯកសារ និងបុគ្គលិកទទួលបន្ទុកការងារបេឡា។

២.ផ្នែកជួរក្រោយ៖ គឺជាកន្លែងពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំបែបបទនៃការស្នើសុំសេវារដ្ឋបាល។ ផ្នែកជួរក្រោយរួមមានបុគ្គលិកជំនាញបច្ចេកទេសតាមវិស័យនីមួយៗ ដែលត្រូវបានចាត់តាំងឱ្យមកបំពេញការងារនៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី និងបុគ្គលិកជំនាញបច្ចេកទេស ដែលត្រូវបានចាត់តាំងនៅតាមមន្ទីរ អង្គភាពសាមីនីមួយៗ ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើការផ្តល់សេវារដ្ឋបាល ព្រមទាំងបុគ្គលិកនៃទីចាត់ការ ឬអង្គភាពពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលរាជធានី។

**ដ.១. ផ្នែកជួរមុខ**[169]

នៅក្នុងអនុវត្តកិច្ចការរបស់អង្គភាពច្រកចេញចូលតែមួយ ផ្នែកជួរមុខមានភារកិច្ចដូចខាងក្រោម៖

- ផ្តល់ព័ត៌មានអំពីប្រភេទ តម្លៃ រយៈពេល និងសុពលភាពនៃសេវារដ្ឋបាល អំពីគោលការណ៍ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល ព្រមទាំងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ផ្តល់ពាក្យស្នើសុំ និងទម្រង់បែបបទភ្ជាប់នានាជូនប្រជាពលរដ្ឋដើម្បីបំពេញ
- ទទួល និងពិនិត្យពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ជូនប្រជាពលរដ្ឋអំពីភាពត្រឹមត្រូវ ឬចំណុចខ្វះខាតនៃពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់តាមលក្ខខណ្ឌកំណត់

[169] ប្រកាសលេខ ៣៨៧១ ប្រក ចុះថ្ងៃទ០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត.

- ទទួល និងពិនិត្យលើឯកសារថតចម្លងនានាតាមការកំណត់
- ចេញបង្កាន់ដៃទទួលពាក្យស្នើសុំដែលកត់ត្រាអំពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំ និងកំណត់កាលបរិច្ឆេទដែលត្រូវមកទទួលយកលទ្ធផលសម្រេចជាផ្លូវការ
- ទទួលប្រាក់កម្រៃសេវាពីប្រជាពលរដ្ឋ ព្រមទាំងចេញបង្កាន់ដៃបង់ប្រាក់ទៅតាមតម្លៃសេវា គោលការណ៍ដែលបានកំណត់
- បញ្ជូនពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ជូនប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីចាត់ចែងបញ្ជូនទៅផ្នែកជួរក្រោយតាមវិស័យជំនាញនីមួយៗ
- ផ្តល់លទ្ធផលសម្រេចជាផ្លូវការជូនប្រជាពលរដ្ឋ
- ទុកដាក់ ថែរក្សា និងធានាសុវត្ថិភាពសាច់ប្រាក់ដែលទទួលបានពីការផ្តល់សេវាតាមគោលការណ៍ និងនីតិវិធីកំណត់
- បង់ចំណូលដែលទទួលបានពីការផ្តល់សេវារដ្ឋបាលទៅតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់
- រៀបចំរបាយការណ៍អំពីចំនួនសេវា និងចំណូលជាទៀងទាត់តាមគោលការណ៍កំណត់។

### ដ.២. ផ្នែកជួរក្រោយ[170]

នៅក្នុងអនុវត្តកិច្ចការរបស់អង្គភាពច្រកចេញចូលតែមួយ ផ្នែកជួរក្រោយមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំឯកសារស្នើសុំសេវារដ្ឋបាល ដើម្បីដាក់ជូនអភិបាលពិនិត្យ និងសម្រេច
- ចុះសិក្សា ឬអង្កេតដល់ទីតាំងអាជីវកម្ម សិប្បកម្ម ឬសេវាកម្មរបស់អ្នកស្នើសុំសេវាដោយស្របតាមគោលការណ៍កំណត់
- ផលិតអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬលិខិតឆ្លើយតបចំពោះការស្នើសុំសេវារដ្ឋបាល
- ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តតាមលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ
- ចុះស្រង់ទិន្នន័យអាជីវកម្ម សិប្បកម្ម សេវាកម្ម និងទិន្នន័យពាក់ព័ន្ធ ដើម្បីចងក្រងបញ្ជីសេវារដ្ឋបាល និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវារដ្ឋបាលនេះជារៀងរាល់ឆ្នាំ
- ទុកដាក់ និងថែរក្សាសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងឯកសារទិន្នន័យពាក់ព័ន្ធនានាតាមការកំណត់

[170] ប្រកាសលេខ ៣៨៧១ ប្រក ចុះថ្ងៃទ០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត.

– រៀបចំរបាយការណ៍តាមគោលការណ៍កំណត់ និងតាមការណែនាំពីប្រធានអង្គភាពច្រកចេញចូលតែមួយ ឬប្រធានមន្ទីរ អង្គភាពសាមី។

**ឋ. រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង**[171]

យោងតាមសេចក្តីជូនដំណឹងលេខ ០០២/២៤ សជណ.ស ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ មកសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ(ស.ស.ភ)វិញ រាជរដ្ឋាភិបាលបានសម្រេចបង្កើត "សហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ(ស.ស.ភ)" ដើម្បីជំនួសឱ្យរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ។ សហគ្រាសនេះត្រូវកំណត់ជា សហគ្រាសសាធារណៈក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជាសហគ្រាសពាណិជ្ជកម្មមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន។ សហគ្រាសនេះ មានបេសកកម្មគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជននៅរាជធានីភ្នំពេញ ស្របតាមការកំណត់នៃច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងកិច្ចការងារនេះ។

### ២.៣.៥.៣. កិច្ចប្រជុំផ្ទៃក្នុងអង្គភាពចំណុះរដ្ឋបាលរាជធានីភ្នំពេញ[172]

កិច្ចប្រជុំផ្ទៃក្នុងអង្គភាព គឺជាកិច្ចប្រជុំនៅក្នុងទីចាត់ការ អង្គភាព ឬការិយាល័យនីមួយៗចំណុះ ដែលរដ្ឋបាលរាជធានីភ្នំពេញ។

ប្រធានអង្គភាព គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីប្រធានអង្គភាពអវត្តមាន ប្រធានអង្គភាពស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំផ្ទៃក្នុងអង្គភាពទាំងអស់ត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយលេខាកត់ត្រា និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

កិច្ចប្រជុំផ្ទៃក្នុងអង្គភាពត្រូវរៀបចំឡើងជាទៀងទាត់ប្រចាំខែ។ ប្រធានអង្គភាពនីមួយៗត្រូវកំណត់កាលវិភាគ និងពេលវេលានៃកិច្ចប្រជុំប្រចាំខែសម្រាប់ឆ្នាំនីមួយៗ ដើម្បីឱ្យមន្ត្រីក្រោមឱវាទទាំងអស់អាច ត្រៀមលក្ខណៈចូលរួមប្រជុំបានគ្រប់ៗគ្នា។

កិច្ចប្រជុំផ្ទៃក្នុងអង្គភាពធ្វើឡើងក្នុងគោលបំណងសំខាន់ៗមួយចំនួនដូចជា៖

---

[171] សេចក្តីជូនដំណឹងលេខ ០០២/២៤ សជណ.ស ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ មកសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ(ស.ស.ភ)វិញ.

[172] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី កិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០១៥, ទំព័រ ១៧៩.

- ចាត់ចែង និងណែនាំអំពីការអនុវត្តសេចក្តីសម្រេច និងអនុសាសន៍នៃកិច្ចប្រជុំអន្តរអង្គភាព
- ពិនិត្យលទ្ធផល និងបញ្ហាប្រឈមនានាក្នុងការអនុវត្តការងារ
- ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងការអនុវត្តការងារ
- រៀបចំផែនការការងារ ឬទិសដៅការងារសម្រាប់អង្គភាពរបស់ខ្លួន
- លើកយោបល់ និងអនុសាសន៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមពិនិត្យ និងដោះស្រាយ។

## ២.៤. ទំនាក់ទំនងកិច្ចការនានារបស់សាលារាជធានីភ្នំពេញ

### ២.៤.១. ទំនាក់ទំនងកិច្ចការរវាងក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី[173]

អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សារាជធានីភ្នំពេញបានសម្រេចរួចហើយ គណៈអភិបាលរាជធានីភ្នំពេញត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាលរាជធានីត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ។

ក្រុមប្រឹក្សារាជធានីត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលរាជធានី ដើម្បីធានាថាគណៈអភិបាលរាជធានីអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សារាជធានី។

គណៈអភិបាលរាជធានីភ្នំពេញមានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សារាជធានីភ្នំពេញ និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញទាំងសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ។

ចំពោះការស្នើសុំ ដើម្បីដាក់បញ្ចូលរបៀបវារៈណាមួយទៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរាជធានីអាចធ្វើការស្នើសុំទៅក្រុមប្រឹក្សារបស់ខ្លួន។ ក្រៅពីនេះ អភិបាលនៃគណៈអភិបាលក៏អាចធ្វើការស្នើកោះប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី ដើម្បីពិនិត្យ ពិភាក្សា និងអនុម័តលើកិច្ចការពិសេស និងបន្ទាន់ណាមួយ ដែលច្បាប់ និងលិខិតបទដ្ឋាននានាតម្រូវឱ្យសុំការសម្រេចពីក្រុមប្រឹក្សា។

[173] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

## ២.៤.២. ទំនាក់ទំនងកិច្ចការរវាងរដ្ឋបាលរាជធានី និងរដ្ឋបាលខណ្ឌ[174]

ក្រៅពីទំនាក់ទំនងផ្ទៃក្នុងរវាងក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី រដ្ឋបាលរាជធានីភ្នំពេញ ក៏ត្រូវមានទំនាក់ទំនងមួយចំនួនទៀតជាមួយនឹងរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញផងដែរ។ ទំនាក់ទំនងសំខាន់ទាំងនោះមានដូចជា៖

- ក្រុមប្រឹក្សាខណ្ឌត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី
- ដីកា ឬសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ ត្រូវស្ថិតនៅក្រោមការពិនិត្យនីត្យនុកូលភាពរបស់ក្រុមប្រឹក្សារាជធានី។ ក្នុងករណីដែលសេចក្តីសម្រេច ឬដីការរបស់ក្រុមប្រឹក្សាខណ្ឌមានភាពមិនត្រឹមត្រូវ និងមិនស្របតាមច្បាប់ ឬលិខិតគតិយុត្ត ឬហួសពីដែនសមត្ថកិច្ចដែលក្រុមប្រឹក្សារាជធានីបានធ្វើប្រតិភូកម្មឱ្យ គណៈអភិបាលរាជធានីត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដោយមានការបញ្ជាក់ច្បាស់លាស់អំពីកិច្ចការនោះ។ បន្ទាប់ពីមានការណែនាំ ក្រុមប្រឹក្សាខណ្ឌត្រូវធ្វើការកែតម្រូវតាមការណែនាំក្នុងពេលយ៉ាងយូរ១៥ថ្ងៃ។ ចំពោះករណីដែលក្រុមប្រឹក្សាខណ្ឌមិនគោរពអនុវត្តតាមការណែនាំ គណៈអភិបាលរាជធានីត្រូវធ្វើសេចក្តីរាយការណ៍ទៅកាន់ក្រុមប្រឹក្សារាជធានីជាបន្ទាន់ ដើម្បីធ្វើការសម្រេច និងរាយការណ៍ទៅក្រសួងមហាផ្ទៃផ្អែកតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជធានី ដើម្បីធ្វើការសម្រុះសម្រួល និងដោះស្រាយទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។
- ក្រុមប្រឹក្សារាជធានី ត្រូវធានាធ្វើប្រតិភូកម្មនូវមុខងារ និងភារកិច្ចសមស្របដល់ក្រុមប្រឹក្សាខណ្ឌ ដើម្បីឱ្យក្រុមប្រឹក្សាខណ្ឌនីមួយៗលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋ ក្នុងគោលបំណងជំរុញ និងធានានូវចីរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមខណ្ឌនីមួយៗ។
- ក្រុមប្រឹក្សាខណ្ឌត្រូវអនុវត្តមុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានីបានធ្វើប្រតិភូកម្មឱ្យ និងត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ និងចំពោះក្រុមប្រឹក្សាសង្កាត់ដែលនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។ បន្ថែមពីនេះ ក្រុមប្រឹក្សាខណ្ឌត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារាជធានីអំពីភាពត្រឹមត្រូវតាមច្បាប់នៃការអនុវត្តមុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មទាំងនោះ។
- ដើម្បីធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សារាជធានីត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផល ក្នុង

[174] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

ការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចសមស្របទៅឱ្យក្រុមប្រឹក្សាខណ្ឌ ឬសង្កាត់ទៅតាមភាពពាក់ព័ន្ធ និងលក្ខខណ្ឌចាំបាច់នានាក្នុងការធ្វើសហប្រតិបត្តិការរវាងក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងការអនុវត្តមុខងារ និងភារកិច្ចទាំងនោះ។

- ចំពោះកិច្ចជាតំណាងរាជរដ្ឋាភិបាល គណៈអភិបាលរាជធានីត្រូវធ្វើការដឹកនាំ ណែនាំ សម្របសម្រួលដល់គណៈអភិបាលខណ្ឌ ដើម្បីធានារក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ ការគោរពសិទ្ធិមនុស្ស ការគោរពច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខណ្ឌនីមួយៗ។
- គណៈអភិបាលរាជធានី ត្រូវធានាឱ្យគណៈអភិបាលខណ្ឌនីមួយនៃរាជធានីធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា ដើម្បីរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ ការគោរពសិទ្ធិមនុស្ស និងការគោរពច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់រាជធានី។
- អភិបាលខណ្ឌត្រូវទំនាក់ទំនងជាមួយគណៈអភិបាលរាជធានី ដើម្បីធ្វើការស្នើសុំការដឹកនាំ ណែនាំ និងសម្របសម្រួលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការខាងលើនេះ។
- ក្រុមប្រឹក្សារាជធានីត្រូវធានាផ្តល់មធ្យោបាយ សម្ភារៈធនធាននានារួមទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការបណ្តុះបណ្តាល ការកសាងសមត្ថភាពក្រុមប្រឹក្សាខណ្ឌ និងបុគ្គលិកក្រុមប្រឹក្សាខណ្ឌ ដើម្បីអនុវត្តមុខងារ និងភារកិច្ច ដែលក្រុមប្រឹក្សារាជធានីបានធ្វើប្រតិភូកម្មឱ្យ។
- ក្រុមប្រឹក្សារាជធានី ត្រូវធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃការអនុវត្តមុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាខណ្ឌ ដើម្បីធានាថាក្រុមប្រឹក្សាខណ្ឌអនុវត្តមុខងារ និងភារកិច្ចទាំងនេះក្នុងក្របខណ្ឌនៃការងារដែលបានធ្វើប្រតិភូកម្មឱ្យ លើមូលដ្ឋាននៃកិច្ចការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងធានាថាខណ្ឌបានឆ្លើយតបយ៉ាងល្អប្រសើរបំផុតចំពោះតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

### ២.៤.៣. ទំនាក់ទំនងកិច្ចការរវាងរដ្ឋបាលរាជធានី និងរដ្ឋបាលសង្កាត់[175]

ចំពោះរដ្ឋបាលសង្កាត់វិញ រដ្ឋបាលរាជធានីភ្នំពេញត្រូវមានទំនាក់ទំនងលើកិច្ចការសកម្មភាពមួយចំនួនដូចជា៖

- ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី
- ក្រុមប្រឹក្សារាជធានីត្រូវធ្វើការត្រួតពិនិត្យលើនីត្យានុកូលភាពនៃការអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើ

[175] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

ប្រតិភូកម្មឱ្យសង្កាត់ ដើម្បីធានាពីការភាពត្រឹមត្រូវនៃការអនុវត្តរបស់សង្កាត់ចំពោះមុខងារ ភារកិច្ច ទាំងនោះ ដោយគោរពតាមក្របខណ្ឌគតិយុត្ត ព្រមទាំងធានាចំពោះការឆ្លើយតបបានយ៉ាងល្អបំផុត ចំពោះតម្រូវការប្រជាពលរដ្ឋ។

- ដើម្បីរួមចំណែកក្នុងការធានាឱ្យក្រុមប្រឹក្សារាជធានីលើកកម្ពស់ការបង្កើត ការជំរុញ និងការធ្វើឱ្យមាន ចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្រុមប្រឹក្សាសង្កាត់ត្រូវទទួលខុសត្រូវចំពោះ៖
  + ការផ្តល់យោបល់ និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារាជធានី ដើម្បីធានាថា ក្រុមប្រឹក្សា រាជធានីនៅតែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចខ្លួន
  + ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សារាជធានីអំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សា សង្កាត់ មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមាន
  + អនុវត្តមុខងារ និងភារកិច្ចទាំងឡាយដែលត្រូវបានធ្វើប្រតិភូកម្មឱ្យដោយក្រុមប្រឹក្សារាជធានី
  + ធ្វើសហប្រតិបត្តិការឱ្យបានពេញលេញជាក្រុមប្រឹក្សារាជធានីក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។
- ក្រុមប្រឹក្សារាជធានីត្រូវធានាធ្វើប្រតិភូកម្មឱ្យបានសមស្របនូវមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ ក្នុងរាជធានីរបស់ខ្លួន ដើម្បីធានាឱ្យក្រុមប្រឹក្សាសង្កាត់មានលទ្ធភាពកាន់តែច្រើនថែមទៀត ក្នុងការ បង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយផ្ទាល់ដល់ ប្រជាពលរដ្ឋនៅតាមសង្កាត់នីមួយៗ
- មុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានីត្រូវធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ គឺជាមុខងារ ភារកិច្ច ដែលមានការពាក់ព័ន្ធដោយផ្ទាល់ដល់ការផ្តល់សេវាកម្ម ការអភិវឌ្ឍ និងសេចក្តីត្រូវការនៃជីវភាពប្រចាំ ថ្ងៃរបស់ប្រជាពលរដ្ឋតាមសង្កាត់នីមួយៗ
- ក្រុមប្រឹក្សារាជធានី ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផលក្នុងការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចសមស្របទៅឱ្យ ក្រុមប្រឹក្សាខណ្ឌ ឬទៅឱ្យក្រុមប្រឹក្សាសង្កាត់ និងលក្ខខណ្ឌចាំបាច់នានាក្នុងការធ្វើសហប្រតិបត្តិការរវាង ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងការអនុវត្តមុខងារ និងភារកិច្ចទាំងនោះ
- ក្រុមប្រឹក្សារាជធានីត្រូវធានាផ្តល់មធ្យោបាយ សម្ភារៈ ធនធាននានា រួមទាំងធនធានហិរញ្ញវត្ថុ ធនធាន មនុស្ស និងការបណ្តុះបណ្តាលការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុម ប្រឹក្សាសង្កាត់ ដើម្បីអនុវត្តមុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានីបានធ្វើប្រតិភូកម្មឱ្យ ។

### ២.៤.៤. ទំនាក់ទំនងកិច្ចការរវាងរដ្ឋបាលរាជធានី និងក្រសួង ស្ថាប័ននានា[176]

ក្រៅពីទំនាក់ទំនងជាមួយនឹងរដ្ឋបាលចំណុះរាជធានី រដ្ឋបាលរាជធានីភ្នំពេញក៏ត្រូវមានទំនាក់ទំនងមួយចំនួនទៀតផងដែរ ជាមួយនឹងក្រសួងស្ថាប័ន ដែលទំនាក់ទំនងនៃកិច្ចការទាំងនោះរួមមានៈ

- ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវស្ថិតនៅក្រោមក្របខណ្ឌអំណាចប្រតិបត្តិរបស់ប្រទេសកម្ពុជា
- នៅក្នុងក្របខណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ រាជរដ្ឋាភិបាលមានសិទ្ធិធ្វើការណែនាំ និងត្រួតពិនិត្យនីត្យានុកូលភាពនៃការសម្រេច និងការធ្វើសកម្មភាពរបស់ក្រុមប្រឹក្សារាជធានី ដើម្បីធានាឱ្យបានថាក្រុមប្រឹក្សារាជធានីគោរពរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយជាតិបានត្រឹមត្រូវ
- ក្រសួង ស្ថាប័ននានាអាចធ្វើទំនាក់ទំនង និងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលខណ្ឌ ឬរដ្ឋបាលសង្កាត់តាមការចាំបាច់ ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលរាជធានី
- ក្នុងករណីមានភាពមិនចុះសម្រុងគ្នាកើតឡើងរវាងរដ្ឋបាលរាជធានីជាមួយរដ្ឋបាលខណ្ឌ ឬរដ្ឋបាលសង្កាត់ ឬរវាងរដ្ឋបាលណាមួយក្នុងចំណោមរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់ ក្រសួងមហាផ្ទៃត្រូវធ្វើការសម្របសម្រួលដោះស្រាយតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ក្នុងការអនុវត្តការងាររបស់ខ្លួន ក្រុមប្រឹក្សារាជធានីត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយក្រសួង ស្ថាប័ននានា ដើម្បីពិគ្រោះយោបល់អំពីការគាំទ្រ និងការចូលរួមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយអំពីតម្រូវការនានារបស់ប្រជាពលរដ្ឋ ដែលក្រុមប្រឹក្សារាជធានីមិនអាចដោះស្រាយបានដោយផ្អែកលើសមត្ថភាព និងធនធានដែលក្រុមប្រឹក្សាមាន
- ក្នុងករណីមិនចុះសម្រុងគ្នារវាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលជាមួយក្រុមប្រឹក្សារាជធានី គ.ជ.អ.ប ត្រូវសម្របសម្រួលដោះស្រាយ ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្នុងករណីមិនអាចសម្របសម្រួលដោះស្រាយបាន គ.ជ.អ.ប ត្រូវធ្វើសេចក្ដីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- គណៈអភិបាលរាជធានីត្រូវអនុវត្តការងារប្រចាំថ្ងៃ ដើម្បីធានាដល់ទំនាក់ទំនងរវាងក្រសួង ស្ថាប័ននានាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន
- នៅក្នុងទំនាក់ទំនងរដ្ឋបាលរវាងរដ្ឋបាលរាជធានី និងក្រសួង ស្ថាប័ននានា អភិបាលរាជធានីភ្នំពេញ

[176] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

ត្រូវរៀបចំ និងចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលទាំងនោះ។ បន្ថែមពីនេះ រាល់លិខិតស្នាមពីក្រសួង ស្ថាប័ន គឺត្រូវបញ្ជូនមកកាន់អភិបាលរាជធានីភ្នំពេញ លើកលែងមានបទប្បញ្ញត្តិចែងខុសពីនេះ។

# ជំពូកទី៣

# សមិទ្ធផលរបស់សាលារាជធានីភ្នំពេញ

# ឆ្នាំ២០២៣-២០២៤

# ជំពូកទី៣ សមិទ្ធផលរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០២៣-២០២៤

បន្ទាប់ពីបានសិក្សាទៅលើទ្រឹស្តី និងច្បាប់មួយចំនួនដែលកំណត់អំពីសកម្មភាព តួនាទី ភារកិច្ច និងរចនាសម្ព័នរបស់រដ្ឋបាលសាលារាជធានីភ្នំពេញរួចមក យើងបានដឹងពីសារៈសំខាន់របស់ការគ្រប់គ្រងរដ្ឋបាលនៅក្នុងការគ្រប់គ្រងនិងដឹកនាំប្រទេសឱ្យឈានទៅរកភាពរីកចម្រើន។ យោងទៅតាមការសិក្សាស្រាវជ្រាវជាក់ស្តែងនៅសាលារាជធានីភ្នំពេញ និងការរស់នៅប្រចាំថ្ងៃ យើងសង្កេតថារាជធានីភ្នំពេញមានការរីកចម្រើនទៅគ្រប់វិស័យ។ ដើម្បីបង្ហាញពីផែនការសកម្មភាពរបស់រដ្ឋបាលរាជធានីភ្នំពេញក្នុងការគ្រប់គ្រង និងដឹកនាំរាជធានីភ្នំពេញ ជំពូកនេះនឹងធ្វើការបង្ហាញអំពីចំណុចធំចំនួនបីសំខាន់ៗគឺ (១)សមិទ្ធផលសកម្មភាពក្នុងឆ្នាំ២០២៣ដល់ឆ្នាំ២០២៤ (២)បញ្ហាប្រឈមក្នុងពេលបច្ចុប្បន្ននិងអនាគត (៣)ទិសដៅនិងផែនការសកម្មភាពសម្រាប់គ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញនៅពេលខាងមុខ។ នៅក្នុងនេះ យើងនឹងផ្តោតទៅលើវិស័យ និងចំណុចធំៗមួយចំនួន ដែលជាតម្រូវការ និងជាចំណាប់អារម្មណ៍ខ្លាំងរបស់ប្រជាពលរដ្ឋដែលរស់នៅរាជធានីភ្នំពេញដូចជាការគ្រប់គ្រងសេវារដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងសន្តិសុខនិងសុវត្ថិភាពសាធារណៈ និងការគ្រប់គ្រងចរាចរណ៍ជាដើម។ លទ្ធផលនិងសកម្មភាពនៃការគ្រប់គ្រងកិច្ចការទាំងនេះ នឹងឆ្លុះបញ្ចាំងពីការគិតគូរនិងភាពរឹងមាំនៃរដ្ឋបាលមូលដ្ឋានផ្ទាល់។

## ៣.១. សកម្មភាពរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០២៣-២០២៤

### ៣.១.១. ការគ្រប់គ្រងសេវាសាធារណៈ(សេវារដ្ឋបាល)[177]

អង្គភាពច្រកចេញចូលតែមួយ គឺជាកន្លែងផ្តល់សេវាសាធារណៈ(សេវារដ្ឋបាល) របស់សាលារាជធានីភ្នំពេញ។ យោងតាមរបាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំឆ្នាំ ២០២៣ និងប្រចាំឆមាសទី១ ឆ្នាំ២០២៤ ដែលយើងបានទទួលកំឡុងពេលចុះកម្មសិក្សាស្រាវជ្រាវឯកសារ យើងសង្កេតឃើញថាកំណើននៃប្រជាពលរដ្ឋដែលមានតម្រូវការសេវារដ្ឋបាលមានការកើនឡើងយ៉ាងខ្លាំងជាបន្តបន្ទាប់។

យោងតាមឯកសារទាំងពីរខាងនេះ យើងសង្កេតឃើញថាកំណើននៃតម្រូវការសេវារដ្ឋបាលមានកំណើនខ្លាំង ជាពិសេសទៅលើវិស័យបីធំៗគឺ (១)វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២)វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង(៣)ការងារនីត្យានុកូលកម្ម(ការបញ្ជាក់លើឯកសារថតចម្លង)។ នៅក្នុងចំណោមវិស័យទាំងបីនេះ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាវិស័យមួយដែលមានតម្រូវការ

[177] អង្គភាពច្រកចេញចូលតែមួយ, *របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំឆ្នាំ២០២៣*, សាលារាជធានីភ្នំពេញ, ២០២៣. & អង្គភាពច្រកចេញចូលតែមួយ, *របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំ ឆមាសទី១ ឆ្នាំ២០២៤*, សាលារាជធានីភ្នំពេញ, ២០២៤.

ខ្ពស់ជាងគេ និងមានកំណើនកើនឡើងខ្ពស់ជាងគេផងដែរ ពោលគឺមានប្រជាពលរដ្ឋចំនួន ៣៤.៧២៩នាក់ មកទទួលសេវានេះក្នុងឆ្នាំ២០២៣ ទាំងមូល និងចំនួន៣៨.០៦៥នាក់នៅក្នុងឆមាសទីមួយឆ្នាំ២០២៤។ នេះបង្ហាញថាតម្រូវការនៃសេវានេះកើនឡើងពីរដងក្នុងឆ្នាំ២០២៤បើធៀបទៅនឹងឆ្នាំ២០២៣។

តារាងទី៣៖ របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវាប្រចាំឆ្នាំ២០២៣&២០២៤(ឆមាសទី១)[178]

| ល.រ | វិស័យ | ប្រចាំឆមាស ឆ្នាំ២០២៣ | | ប្រចាំឆ្នាំ២០២៣ | ប្រចាំឆមាស ឆ្នាំ២០២៤ |
|---|---|---|---|---|---|
| | | ឆមាសទី១ | ឆមាសទី២ | | ឆមាសទី១ |
| ១ | នីត្យានុកូលកម្ម | ៧.៤៤៦ | ៥.៤៩៥ | ១២.៩៤១ | ៥.៨៩១ |
| ២ | ការងាររដ្ឋបាល | ១១ | ១២ | ២៣ | ២៤ |
| ៣ | សុខាភិបាល | ៦២៨ | ៦៣០ | ១.២៥៨ | ៦២៤ |
| ៤ | ទេសចរណ៍ | ៣៦៧ | ៤០៩ | ៧៧៦ | ៤៨២ |
| ៥ | សាធារណការ និងដឹកជញ្ជូន | ៥៣ | ៤៦ | ៩៩ | ៩២ |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | - | - | - | - |
| ៧ | ព័ត៌មាន | ១៥២ | ១៧៧ | ៣២៩ | ១៧៦ |
| ៨ | បរិស្ថាន | ៥៤ | ៥៨ | ១១២ | ៨២ |
| ៩ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ២៣២ | ៤០៨ | ៦៤០ | ២០៣ |
| ១០ | រ៉ែ និងថាមពល | - | - | - | ៣៣ |
| ១១ | ពាណិជ្ជកម្ម | ១ | ១ | ២ | ១ |
| ១២ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក)+(ខ) | ១៧.៦៣៣ | ១៧.០៩៦ | ៣៤.៧២៩ | ៣៨.០៦៥ |
| ១៣ | កសិកម្ម រុក្ខប្រមាញ់ និងនេសាទ | ៨.៨៥៧ | ៧.៦៧១ | ១៦.៥២៨ | ៧.៥៧៩ |
| ១៤ | ការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៥៥ | ៤៨ | ១០៣ | ១២ |
| សរុបរួម | | ៣៥.៤៨៩ | ៣២.០៥១ | ៦៧.៥៤០ | ៥៣.២៦៤ |

សមិទ្ធផលនៃសេវារដ្ឋបាលរបស់សាលារាជធានីភ្នំពេញនេះ បង្ហាញពីកំណើននៃតម្រូវការសេវារដ្ឋបាល និងការប្រែប្រួលនៃតម្រូវការរបស់ប្រជាពលរដ្ឋទៅតាមវិស័យនីមួយៗក្នុងរាជធានីភ្នំពេញ។ ជារួមយើងសង្កេតថាសម្ទុះនៃកំណើននេះស្ថិតនៅក្នុងចំណុចមួយខ្ពស់ ពោលគឺនៅឆមាសទី១ ឆ្នាំ២០២៤ មានប្រជាពលរដ្ឋមក

[178] ដកស្រង់ និងកែសម្រួលមកពី៖ អង្គភាពច្រកចេញចូលតែមួយ, *របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំឆ្នាំ ២០២៣*, សាលារាជធានីភ្នំពេញ, ២០២៣. & អង្គភាពច្រកចេញចូលតែមួយ, *របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូល ប្រចាំ ឆមាសទី១ ឆ្នាំ២០២៤*, សាលារាជធានីភ្នំពេញ, ២០២៤.

ទទួលសេវាច្រើនជាងឆមាសទី១ ឆ្នាំ២០២៣ ចំនួន៥០.០៨% ដែលចំនួននេះស្មើនឹង ៧៨.៨៦% នៃសមិទ្ធផលសេវាប្រចាំឆ្នាំ២០២៣ទាំងមូល។

### ៣.១.២. ការគ្រប់គ្រងធនធានមនុស្ស

យោងតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៃរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា កិច្ចការគ្រប់គ្រងធនធានមនុស្ស គឺជាតម្រូវការចាំបាច់ដែលមិនអាចខ្វះបាននៅក្នុងដំណើរការកសាងប្រទេសជាតិឱ្យមានភាពរីកចម្រើន។ ការអភិវឌ្ឍធនធានមនុស្សអាចជួយជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ចប្រទេសជាតិប្រកបដោយបរិយាបន្ន និងភាពធន់។[179] អនុលោមតាមផែនការអភិវឌ្ឍនេះ សាលារាជធានីភ្នំពេញបានសម្រេច និងកំពុងអនុវត្តនូវសកម្មភាព និងផែនការមួយចំនួន ដើម្បីធានានូវវឌ្ឍនភាពនៃធនធានមនុស្សរបស់ខ្លួន ក្នុងគោលបំណងធានានូវប្រសិទ្ធភាពនៃការបម្រើសេវាដល់ប្រជាពលរដ្ឋ។ យោងតាមបទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ រាជធានីភ្នំពេញក្នុងពេលបច្ចុប្បន្ន (២០២៤) មានមន្ត្រីបម្រើការចំនួន៥៣២ រូប។

តារាងទី៤៖ ចំនួនមន្ត្រីរបស់សាលារាជធានីភ្នំពេញ[180]

| ឆ្នាំ | មន្ត្រីក្របខណ្ឌ | | មន្ត្រីកិច្ចសន្យា | | សរុបរួម |
|---|---|---|---|---|---|
| | ស្រី | សរុប | ស្រី | សរុប | |
| ១៩៩៨ | ៥៨ | ៣៨៩ | ៣ | ៤៤ | ៤៣៣ |
| ២០២៤ | ១០១ | ២៧៧ | ៩៣ | ២៥៥ | ៥៣២ |

នៅក្នុងកិច្ចការគ្រប់គ្រងធនធានមនុស្ស ដែលទទួលបន្ទុកដោយទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃសាលារាជធានីភ្នំពេញ សាលារាជធានីបានអនុវត្តនៅផែនការសកម្មភាពមួយចំនួន ដើម្បីធានានូវប្រសិទ្ធភាព និងគុណភាពនៃសេវា ដែលផ្តល់ឱ្យដោយមន្ត្រីរបស់ខ្លួន។ នៅក្នុងកិច្ចការគ្រប់គ្រងធនធានមនុស្សនេះ សកម្មភាពសំខាន់ៗចំនួនពីរ(២) ត្រូវបានអនុវត្តគឺ ការសិក្សាពីតម្រូវការរបស់មន្ត្រី និងការកសាងសមត្ថភាពមន្ត្រី។

ដើម្បីសិក្សាពីតម្រូវការ និងភាពចាំបាច់នានាក្នុងការបណ្តុះបណ្តាលសមត្ថភាពមន្ត្រី សាលារាជធានីបាន

---

[179] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០,* ២០២៣, ទំព័រ ៥១-៥៩.

[180] ដកស្រង់ និងកែសម្រួលមកពី៖ ជា សុផារ៉ា, *រដ្ឋបាលរាជធានីភ្នំពេញ,* ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ, ១៩៩៨, ទំព័រ ២០-២១. & (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

អនុវត្តវិធីសាស្ត្រចំនួនពីរយ៉ាងគឺៈ ការប្រមូលទិន្នន័យផ្ទាល់ និងការប្រមូលទិន្នន័យតាមរយៈប្រព័ន្ធឌីជីថល។ គោលបំណងនៃវិធីសាស្ត្រទាំងពីរនេះ គឺដើម្បីធ្វើការប៉ាន់ប្រមាណពីតម្រូវការការបណ្តុះបណ្តាលសមត្ថភាពរបស់មន្ត្រីនីមួយៗ។

ចំពោះការបណ្តុះបណ្តាលវិញ សាលារាជធានីភ្នំពេញបានចេញនូវចំណាត់ការបណ្តុះបណ្តាលមន្ត្រីទៅតាមភាពចាំបាច់ និងតម្រូវការ ដើម្បីបម្រើប្រជាពលរដ្ឋ ដែលការបណ្តុះបណ្តាលទាំងនោះមានដូចជាៈ

១. ការបណ្តុះបណ្តាលនៅសាលារាជធានីភ្នំពេញផ្ទាល់

២. ការបណ្តុះបណ្តាលនៅតាមអង្គការដៃគូអភិវឌ្ឍ

៣. ការបណ្តុះបណ្តាលនៅក្រៅក្រសួង ស្ថាប័ន អង្គភាព

៤. ការបណ្តុះបណ្តាលនៅក្រៅប្រទេស។[181]

ជាលទ្ធផល នៅក្នុងឆ្នាំ២០២៣ សាលារាជធានីបានចូលរួមសកម្មភាពក្នុងការបណ្តុះបណ្តាលចំនួនបួន(៤)ប្រភេទធំៗគឺៈ

១. សកម្មភាពអភិវឌ្ឍសមត្ថភាពតាមការកំណត់របស់ថ្នាក់ជាតិ

២. សកម្មភាពអភិវឌ្ឍសមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលរាជធានី ខេត្ត

៣. សកម្មភាពអភិវឌ្ឍសមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

៤. សកម្មភាពអភិវឌ្ឍសមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលឃុំ សង្កាត់។

នៅក្នុងសកម្មភាពអភិវឌ្ឍមន្ត្រីនេះ ប្រភេទនៃសកម្មភាពអភិវឌ្ឍនីមួយៗត្រូវបានកំណត់បែងចែកជាប្រធានបទ និងនៅក្នុងប្រធានបទត្រូវបានបែងចែកជាវគ្គ។ ជាលទ្ធផលនៃការកសាងសមត្ថភាពមន្ត្រី ប្រភេទទាំងអស់នៃសកម្មភាពបណ្តុះបណ្តាលនៅក្នុងឆ្នាំ២០២៣ មានប្រធានបទសរុបចំនួន ២៣ប្រធានបទ ដែលត្រូវបានបែងចែកជាវគ្គសរុបចំនួន ៨៤វគ្គ។

យោងតាមរបាយការណ៍ ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញប្រចាំឆ្នាំ២០២៣ សកម្មភាពបណ្តុះបណ្តាលសមត្ថភាពមន្ត្រីទាំង ៤ប្រភេទនេះមានអ្នកចូលរួមចំនួន ១០.៦២៦ នាក់ ដែលនៅក្នុងនោះមានស្រីចំនួន ៤.៧០២នាក់។

---

[181] (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

តារាងទី៥៖ តារាងរបាយការណ៍ ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០២៣[182]

| ប្រភេទកម្មវិធីសិក្សា | ចំនួនប្រធានបទ | ចំនួនវគ្គ | ចំនួនអ្នកចូលរួម | |
|---|---|---|---|---|
| | | | ស្រី | សរុប |
| សកម្មភាពអភិវឌ្ឍសមត្ថភាពតាមការកំណត់របស់ថ្នាក់ជាតិ | ០៣ | ១៣ | ១.០៨៧ | ១.៤៤៨ |
| សកម្មភាពអភិវឌ្ឍសមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលរាជធានី ខេត្ត | ១៥ | ៦១ | ២.៧៥៧ | ៧.៤៣៥ |
| សកម្មភាពអភិវឌ្ឍសមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | ០៤ | ០៨ | ៧៧១ | ១.៣៦៥ |
| សកម្មភាពអភិវឌ្ឍសមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលឃុំ សង្កាត់ | ០១ | ០២ | ៨៧ | ៣៧៨ |

បន្ទាប់ពីបានសម្រេចនូវសកម្មភាពបណ្តុះបណ្តាលទាំងនេះ សាលារាជធានីភ្នំពេញបានសង្កេតឃើញនូវកាលានុវត្តភាពមួយចំនួនទៀតផងដែរ សម្រាប់មន្ត្រីរាជការរបស់ខ្លួន។ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួនឱ្យកាន់តែមានភាពប្រសើរឡើងនាពេលអនាគត សាលារាជធានីភ្នំពេញនឹងនៅតែបន្តសហការជាមួយនឹងស្ថាប័នជំនាញនានា និងពង្រីកដៃគូរសហការរបស់ខ្លួនបន្ថែមទៀត ដែលដៃគូរសហការទាំងនោះមានដូចជា សាកលវិទ្យាល័យ និងគ្រឹះស្ថានជំនាញ។[183]

### ៣.១.៣. ការគ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពសាធារណៈ

ការគ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពសាធារណៈ គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងការធានានូវប្រសិទ្ធភាពនៃកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍជាតិប្រកបដោយបរិយាបន្ន និងចីរភាព។ នៅក្នុងពេលកន្លងទៅការអនុវត្តគោលនយោបាយ ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការរក្សាសុវត្ថិភាពមូលដ្ឋានដូចជា ការបង្រ្កាបបទល្មើស ការរក្សាអធិបតេយ្យភាពជាតិ ការទប់ស្កាត់ភេរវកម្មនានា និងការគ្រប់គ្រងច្រកព្រំដែនជាដើម។[184]

---

[182] ដកស្រង់ និងកែសម្រួលមកពីៈ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស, *របាយការណ៍ ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញ ប្រចាំឆ្នាំ២០២៣,* សាលារាជធានីភ្នំពេញ, ២០២៣.

[183] (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

[184] ក្រសួងមហាផ្ទៃ, *ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ ២០២៤-២០២៨*, ២០២៤, ទំព័រ ២.

យោងតាមអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលរាជធានីភ្នំពេញ ត្រូវមានគណៈបញ្ជាការឯកភាព ដែលគណៈបញ្ជាការឯកភាពនេះមានលេខាធិការដ្ឋានជាជំនួយការការងាររបស់ខ្លួន។ ការបង្កើតឡើងនៃគណៈបញ្ជាការឯកភាពរាជធានីនេះ គឺដើម្បីពង្រឹងតួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការពារធនធានព្រៃឈើ ផលផលតំបន់ការពារធម្មជាតិ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសនានានៅទូទាំងប្រទេស។ សមាសភាព តួនាទី និងភារកិច្ចរបស់គណៈបញ្ជាការឯកភាពនេះត្រូវបានកំណត់ដោយអនុក្រឹត្យខាងលើ ចំណែកលេខាធិការដ្ឋានរបស់គណៈបញ្ជាការនេះ ត្រូវកំណត់ដោយប្រកាសដោយឡែក របស់ក្រសួងមហាផ្ទៃ។[185]

ក្រៅពីការបង្កើតឡើងនៃគណៈបញ្ជាការនេះនិងគោលនយោបាយភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព ក្រសួងមហាផ្ទៃក៏បានរៀបចំនៅផែនការយុទ្ធសាស្ត្រមួយទៀតផងដែរ សម្រាប់ពង្រឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាពសាធារណៈនៅមូលដ្ឋានគឺ "ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ឆ្នាំ២០២៤-២០២៨"។ នៅក្នុងផែនការនេះ ការគ្រប់គ្រងសុវត្ថិភាពសាធារណៈ ស្ថិតនៅក្នុងយុទ្ធសាស្ត្រទី២ ដែលត្រូវបានកំណត់បែងចែកជាសកម្មភាពចំនួន៥ សំខាន់ៗគឺ៖

**សកម្មភាពទី១៖** ការការពារសន្តិភាព ឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី និងខឿនសន្តិសុខជាតិ

**សកម្មភាពទី២៖** ការក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម (គោលនយោបាយ ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព)

**សកម្មភាពទី៣៖** ការពង្រឹង និងការអភិវឌ្ឍការងារនគរបាល និងសហគមន៍

**សកម្មភាពទី៤៖** ការពង្រឹងការគ្រប់គ្រងច្រកទ្វារព្រំដែន ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ ការបង្កើនការផ្តល់សេវាអន្តោប្រវេសន៍ និងពង្រឹងពង្រីកចំណងមិត្តភាព សហប្រតិបត្តិការជាតិ និងអន្តរជាតិ

**សកម្មភាពទី៥៖** ការពង្រឹងការងារអត្តសញ្ញាណកម្មដើម្បីធានាសម្រេចបានគោលដៅ "បុគ្គលម្នាក់មានអត្តសញ្ញាណតែមួយ" និង "មនុស្សទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណ"។

[185] អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.

បន្ថែមពីនេះ ផែនការយុទ្ធសាស្ត្រនេះក៏មានយុទ្ធសាស្ត្រ(ទី៦)ផ្តោតទៅលើការប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធឌីជីថលផងដែរ ដែលវាមានគោលដៅសកម្មភាពធំៗចំនួន៣គឺ៖

**សកម្មភាពទី១៖** ការពង្រឹងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល

**សកម្មភាពទី២៖** ការលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថលបម្រើដល់ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការគ្រប់គ្រងរដ្ឋបាលទូទៅ

**សកម្មភាពទី៣៖** ការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ការផ្សព្វផ្សាយអប់រំ ការបញ្ជ្រាបចំណេះដឹង និងការពង្រឹងជំនាញឌីជីថល។

នៅក្នុងការបំពេញកិច្ចការគ្រប់គ្រងសុវត្ថិភាព សន្តិសុខសាធារណៈ ក្រសួងមហាផ្ទៃមានសូចនាករជារួមដូចខាងក្រោម៖

តារាងទី៦៖ សូចនាករនៃការពង្រឹងសន្តិសុខ សុវត្ថិភាពសាធារណៈជារួម[186]

| សូចនាករ | ដើមគ្រា | ២០២៤ | ២០២៦ | ២០២៨ |
|---|---|---|---|---|
| ចំនួនបទល្មើសព្រហ្មទណ្ឌកើតឡើងក្នុងចំនួនប្រជាជន ១០ម៉ឺននាក់ | ២២ | ២០ | ២០ | ២០ |
| ភាគរយនៃការបង្ក្រាបបទល្មើសព្រហ្មទណ្ឌធៀបនឹងបទល្មើសដែលកើតឡើងក្នុងឆ្នាំនីមួយៗ | ៩០% | ៨០-៩០% | ៨០-៩០% | ៨០-៩០% |
| ចំនួនឃុំ-សង្កាត់មានសុវត្ថិភាពគ្មានបទល្មើសព្រហ្មទណ្ឌ | ៦០៥ | ៦២៣ | ៦៥៩ | ៦៩៥ |

### ៣.១.៤. ការគ្រប់គ្រងរៀបចំក្រុង (រាជធានីភ្នំពេញ)

ការគ្រប់គ្រងរៀបចំក្រុងនៃរាជធានីភ្នំពេញ គឺសំដៅដល់ការប្រើប្រាស់ដីនៃរាជធានីភ្នំពេញ ដែលការរៀបចំឡើង និងអនុវត្តកិច្ចការនេះ ត្រូវមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាច្រើនដូចជា៖ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្រសួងស្ថាប័ននានាដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាល

[186] ដកស្រង់ និងកែសម្រួលមកពី៖ ក្រសួងមហាផ្ទៃ, *ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ ២០២៤-២០២៨*, ២០២៤, ទំព័រ ២៨-៣៧.

រាជធានីភ្នំពេញ។[187] ដោយផ្អែកតាមរចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ ទីចាត់ការរៀបចំក្រុងគឺជាសេនាធិការរបស់រដ្ឋបាលរាជធានីភ្នំពេញក្នុងការបំពេញកិច្ចការមួយនេះ។

នៅក្នុងកិច្ចរៀបចំប្រើប្រាស់ដីនៃរាជធានីភ្នំពេញក្នុងពេលបច្ចុប្បន្ន(២០២៤) រាជធានីភ្នំពេញត្រូវអនុវត្តទៅតាម "ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥" ដែលអនុម័តដោយ អនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី ការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ។ នៅក្នុងអនុក្រឹត្យនេះបានកំណត់ផងដែរ អំពីការធ្វើការកែសម្រួលក្នុងរយៈពេលប្រាំ(៥)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

នៅក្នុងកិច្ចការរៀបចំក្រុងនិងប្រើប្រាស់ដីធ្លីនេះ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ គឺជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ។ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំប្លង់គោលប្រើប្រាស់ដីទៅតាមខណ្ឌដើម្បីធានានៅការអភិវឌ្ឍ និងការអភិរក្សនគរូបនីយកម្ម ការប្រើប្រាស់ដីធ្លីនិងសក្តានុពលដែលមានស្រាប់ឱ្យបានត្រឹមត្រូវនិងចំទិសដៅ ប្រកបដោយភាពឆ្លាត គុណភាព តុល្យភាព ចីរភាព និងបរិយាបន្ន តាមរយៈការគ្រប់គ្រងនិងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។[188]

យោងតាមប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥ រាជធានីភ្នំពេញត្រូវបានកំណត់នឹងបែងចែកការរៀបចំជា ៧ចំណុចសំខាន់ៗ គឺ៖ (១)ដង់ស៊ីតេអាគារ (២)សំណង់សាធារណៈ (៣)បណ្តាញបង្ហូរទឹកស្អុយ (៤)បណ្តាញប្រឡាយទឹក (៥)តំបន់ការពារ-តំបន់ធម្មជាតិនិងកសិកម្ម តំបន់បុរាណវិទ្យា តំបន់ច្រាំងទន្លេត្រូវការពារ (៦)បណ្តាញផ្លូវ និង(៧)ការដឹកជញ្ជូននិងទំនិញ។[189] (មានក្នុងឧបសម្ព័ន្ធ១០)

ដោយសំយោគទៅលើប្លង់គោលប្រើប្រាស់ដីខណ្ឌចំនួន ៨ខណ្ឌ (ខណ្ឌទួលគោក ខណ្ឌ៧មករា ខណ្ឌមានជ័យ ខណ្ឌជ្រោយចង្វារ ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌដូនពេញ និងខណ្ឌព្រែកព្នៅ) ដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យើងសង្កេតឃើញថាការរៀបចំដីធ្លីនៅក្នុងខណ្ឌចំណុះរាជធានីភ្នំពេញត្រូវបានកំណត់បែងចែកជាផ្នែកសំខាន់ៗមួយចំនួនដូចជា៖

– យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន៖ ផ្តោតទៅលើ(១)ការអភិវឌ្ឍ

---

[187] អនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី ការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ.

[188] សេចក្តីសម្រេចលេខ ០៧៩ សសរ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌ៧មករា.

[189] គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ, "*ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥*" ២០១៦.

នគរូបនីយកម្ម (២)ការគ្រប់គ្រងនិងប្រើប្រាស់ដី (៣)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (៤)ការអភិវឌ្ឍសេដ្ឋកិច្ច (៥)ការអភិវឌ្ឍសង្គមកិច្ច (៦)ការការពារបរិស្ថាននិងគ្រប់គ្រងសំណល់ (៧)ការទប់ស្កាត់គ្រោះមហន្តរាយ និង(៨)ការពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន

- ផែនការសកម្មភាព៖ ផ្តោតទៅលើ(១)ការរៀបចំបទប្បញ្ញត្តិ (២)ការផ្សព្វផ្សាយ (៣)ការអនុវត្តគម្រោងតាមវិស័យ (៤)ការអនុវត្តគម្រោងរយៈពេលខ្លី មធ្យម និងវែង និង(៥)គម្រោងអាទិភាព
- ធនធានហិរញ្ញវត្ថុ
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ៖ ដែលផ្តោតទៅលើ(១)យន្តការ (២)គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និង(៣)ភារកិច្ច នីតិវិធី និងគោលការណ៍។

ដែលខ្លឹមសារ នីតិវិធី និងគម្រោងអាទិភាពនៃប្លង់គោលរបស់ខណ្ឌនីមួយៗនៃរាជធានីភ្នំពេញនេះ មានលក្ខណៈខុសៗគ្នាទៅតាមស្ថានភាពជាក់ស្តែងនៃខណ្ឌទាំងនោះ។

### ៣.១.៥. ការគ្រប់គ្រងចរាចរណ៍

នៅក្នុងការគ្រប់គ្រងចរាចរណ៍នៅរាជធានីភ្នំពេញ គឺសំដៅដល់ការគ្រប់គ្រងមធ្យាបាយធ្វើដំណើរ និងការគ្រប់គ្រងភាពកកស្ទះនៅក្នុងរាជធានីភ្នំពេញ។ ដើម្បីដោះស្រាយបញ្ហាចោទដ៏ស្មុគស្មាញនៃស្ថានការណ៍ចរាចរណ៍ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញបាននឹងកំពុងសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ក្នុងកិច្ចការរៀបចំគម្រោងផែនការមេដឹកជញ្ជូនរាជធានីភ្នំពេញឆ្នាំ២០៣៥។[190] គម្រោងនេះគឺជាគម្រោងទីបីដែលទីភ្នាក់ងារមួយនេះបានសហការសិក្សា ដែលគម្រោងទី១ គឺចាប់ផ្តើមនៅក្នុងឆ្នាំ២០០១ជាមួយនឹងទិសដៅឆ្នាំ២០១៥ និងគម្រោងទី២ គឺការកែលម្អគម្រោងនៃការដឹកជញ្ជូនទីក្រុងនៅតំបន់ទីក្រុងភ្នំពេញ (២០០៧-២០១០) ដែល JICA បានសិក្សាស្វែករកការលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាសម្រាប់ការកែលម្អផ្លូវប្រសព្វ ការដំឡើងសញ្ញាចរាចរណ៍ និងសុវត្ថិភាពចរាចរណ៍ទៅកាន់ដៃគូរគម្រោងនៅក្នុងរាជធានីភ្នំពេញ។ គួរបញ្ជាក់ផងដែរថា ការសាងសង់ផ្លូវ ត្រូវបានបញ្ចប់លឿនជាងការគ្រោងទុកក្នុងសមាជ JICA ឆ្នាំ២០០១។[191]

ក្រៅពីការសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនេះ រាជធានីភ្នំពេញក៏បានដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងចរាចរណ៍ទំនើបចាប់តាំងពីឆ្នាំ២០១៩មកដល់បច្ចុប្បន្ន បន្ទាប់ពីបានដាក់សាក

---

[190] JICA. *The Project for Comprehensive Urban Transport Plan in Phnom Penh Capital City.* 2014.

[191] (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

ល្បងជាច្រើនខ្សែចមក។ នៅក្នុងការដាក់ដំណើរការនេះ ប្រព័ន្ធភ្លើងស្តុបទំនើបមានសរុបចំនួន ១១៥ទីតាំង (២០១៩)។ ដោយយោងតាមលទ្ធផលនៃការដាក់សាកល្បងនោះ ប្រព័ន្ធគ្រប់គ្រងចរាចរណ៍ទំនើបនេះបានរួមចំណែកក្នុងការកាត់បន្ថយបញ្ហាចរាចរណ៍បានមួយកម្រិតផងដែរ។[192]

ដើម្បីរួមចំណែកក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍ និងការចំណាយលើការធ្វើដំណើររាជធានីភ្នំពេញក៏បានរៀបចំឱ្យមានសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងផងដែរ ដែលសេវានេះមានដំណើរការជាប្រចាំចាប់ពីម៉ោង ៥,៣០នាទីព្រឹក ដល់ម៉ោង៨,៣០នាទីយប់។ សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញនេះ ត្រូវបានគ្រប់គ្រងដោយរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ។ ចំពោះការគ្រប់គ្រងថ្លៃសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញនេះវិញ តម្លៃសំបុត្រសម្រាប់មនុស្សម្នាក់គឺ ១៥០០រៀល(២០២៤) និងលើកលែងមិនគិតថ្លៃចំពោះព្រះសង្ឃ ចាស់ជរា ជនពិការ កម្មករ កម្មការិនី សិស្ស និស្សិត និងកុមារកម្ពស់ក្រោមមួយម៉ែត្រ។[193] សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងរបស់រាជធានី បច្ចុប្បន្នមានតម្រាយខ្សែរត់ចំនួន ២១ខ្សែ។

ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានគ្រប់គ្រាន់អំពីខ្សែរត់របស់សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង នៅក្នុងឆ្នាំ២០១៩ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង និងក្រុមជំនាញការនៃភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានអនុញ្ញាតឱ្យក្រុមហ៊ុន ITSUMO បង្កើតប្រព័ន្ធតាមដានទីតាំងរថយន្តក្រុងដែលមានឈ្មោះថា “City Bus Official App” ដែលបានដាក់ដំណើរការសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់។ ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធកម្មវិធីនេះ គឺដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋដែលបំណងប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ ដោយកម្មវិធីមានភ្ជាប់មកជាមួយនូវទីតាំង និងពេលវេលាពិតប្រាកដនៃការមកដល់ចំណតរបស់ឡានក្រុងនីមួយៗ។[194]

យោងតាមសេចក្តីជូនដំណឹងរបស់សាលារាជធានីភ្នំពេញដដែរនេះ សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងនេះ ទទួលបានការគាំទ្រ និងប្រើប្រាស់ពីប្រជាពលរដ្ឋរាជធានីភ្នំពេញយ៉ាងច្រើនផងដែរ។ ក្នុងនោះបើគិតជាមធ្យមចំនួនអ្នកប្រើប្រាស់សរុបមានចន្លោះពី ២៦.០០០នាក់ទៅ ៣០.០០០នាក់ ក្នុងមួយថ្ងៃ។

---

[192] ក្រសួងព័ត៌មាន, *"រដ្ឋបាលរាជធានីភ្នំពេញ សម្ពោធដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងចរាចរណ៍ទំនើប"*, ២០១៩.

[193] សាលារាជធានីភ្នំពេញ, *"គេហទំព័រអ៊ីនធឺណិត៖ រាជធានីភ្នំពេញ"*, ដកស្រង់នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤.

[194] សេចក្តីជូនដំណឹងលេខ ០៤៨/១៩ សជណ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រព័ន្ធតាមដានចលនាបម្លាស់ទីរថយន្តក្រុង (CITY BUS APP).

រូបភាពទី៨៖ ផែនទីតម្រាយផ្លូវរត់រថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ[195]




## ៣.២. បញ្ហាប្រឈម

យោងតាមបទសម្ភាសជាមួយមន្ត្រីជំនាញនៃសាលារាជធានីភ្នំពេញ សាលារាជធានីភ្នំពេញបាននឹងកំពុងជួបប្រទះបញ្ហាសំខាន់ៗចំនួនពីរយ៉ាង ដែលវាបានជះផលប៉ះពាល់ដល់ប្រសិទ្ធភាព និងល្បឿននៃសេវាសាធារណៈដែលផ្តល់ឱ្យដោយសាលារាជធានីភ្នំពេញ។ បញ្ហាប្រឈមទាំងពីរនេះរួមមាន កត្តាប្រជាពលរដ្ឋ និងកត្តាធនធានមនុស្ស។

### ៣.២.១. កត្តាប្រជាពលរដ្ឋ

ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាមូលដ្ឋានគ្រឹះនៅក្នុងការអភិវឌ្ឍបែបប្រជាធិបតេយ្យ។ ការចូលរួម និងកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះផែនការសកម្មភាព និងកម្មវិធីនយោបាយមូលដ្ឋានរបស់អាជ្ញាធរមូលដ្ឋានមានឥទ្ធិពលយ៉ាងខ្លាំងចំពោះប្រសិទ្ធភាពនៃការបំពេញកិច្ចការងាររបស់មន្ត្រីសាធារណៈ។ ក្រៅពីនេះ កម្រិតនៃការយល់ដឹងនិងការចូលរួមសហការរបស់ប្រជាពលរដ្ឋ ក៏រួមចំណែកនៅក្នុងការអភិវឌ្ឍនៅក្នុងមូលដ្ឋានផងដែរ។ នៅពេលដែលប្រជាពលរដ្ឋនៅមូលដ្ឋាន មានការយល់ដឹងអំពីនីតិវិធី ផែនការ

[195] សេចក្តីជូនដំណឹងលេខ ១៥៥ សជណ.រដស ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបើកប្រតិបត្តិការសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង(City Bus)រាជធានីភ្នំពេញ.

សកម្មភាព និងកិច្ចការគតិយុត្តនានានៅមូលដ្ឋាន ប្រជាពលរដ្ឋអាចធ្វើការចូលរួមសកម្មភាពជាមួយអាជ្ញាធរមូលដ្ឋានបានកាន់តែប្រសើរ ដែលអន្តរកម្មនេះនឹងរួមចំណែកក្នុងការបម្រើផលប្រយោជន៍សាធារណៈ និងគណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន។[196]

យោងតាមបទសម្ភាសជាមួយមន្ត្រីជំនាញនៃសាលារាជធានីភ្នំពេញ សកម្មភាពមួយចំនួនរបស់ប្រជាពលរដ្ឋ និងកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋមានឥទ្ធិពលយ៉ាងខ្លាំងចំពោះប្រសិទ្ធភាព និងល្បឿននៃសេវាសាធារណៈ។ នៅក្នុងនោះសកម្មភាពរបស់ប្រជាពលរដ្ឋដូចជា (១)ការខ្វះនៅទំនួលខុសត្រូវ (២)កម្រិតនៃការយល់ដឹងទាក់ទងនឹងតម្រូវការរបស់ខ្លួននៅមានកម្រិត និង(៣)ការប្រើប្រាស់សេវាសាធារណៈដើម្បីបម្រើជាប្រយោជន៍ខ្លួនដោយពុំសមស្រប។

នៅក្នុងការបម្រើសេវាសាធារណៈ រដ្ឋបាលរាជធានីភ្នំពេញបានជួបនៅសកម្មភាពមួយចំនួនដែលមានការខ្វះខាតផ្នែកទំនួលខុសត្រូវពីប្រជាពលរដ្ឋ ដែលសកម្មភាពនេះបង្កជាការលំបាក និងការខាតបង់ពេលវេលារបស់ភាគីទាំងសងខាង។ ជាឧទាហរណ៍ ដូចជាការបំពេញពាក្យ និងបែបបទស្នើសុំផ្សេងៗជាដើម។ នៅក្នុងករណីខ្លះប្រជាពលរដ្ឋ ដែលមកទទួលសេវាសាធារណៈនៅសាលារាជធានីភ្នំពេញ មិនបានបំពេញពាក្យ បែបបទ និងព័ត៌មានផ្សេងៗដោយខ្លួនឯងនោះទេ គឺគាត់ឱ្យអ្នកផ្សេងជាអ្នកបំពេញឱ្យ ដោយមិនមានការត្រួតពិនិត្យឡើងវិញបានត្រូវ ព័ត៌មានដែលឱ្យអាជ្ញាធរមូលដ្ឋានមានភាពមិនត្រឹមត្រូវ ដែលក្នុងករណីនេះទាមទារឱ្យប្រជាពលរដ្ឋបំពេញ ឬធ្វើលិខិតស្នើសុំនោះសារជាថ្មី។ ជាលទ្ធផលសកម្មភាពនេះបានធ្វើឱ្យខាតបង់ពេលវេលារបស់ភាគីទាំងសងខាង។[197]

ក្រៅពីនេះ កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះតម្រូវការរបស់ខ្លួនក៏បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការផ្តល់សេវាផងដែរ។ ដោយការយល់ដឹងពីសេវាសាធារណៈ សមិទ្ធផល និងផែនការ និងការស្វែងយល់ពីប្រព័ន្ធរដ្ឋបាលរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ(គិតជារួម)នៅមានកម្រិតនៅឡើយ ដូចនេះការបំពេញការងាររបស់មន្ត្រីក៏អាចនឹងមានស្មុគស្មាញខ្លះដែរ។ ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញមួយផ្នែកធំមានការយល់ដឹង និងការស្វែងយល់ពីកិច្ចការរដ្ឋបាលនៅក្នុងកម្រិតមធ្យម ប៉ុន្តែមានទំនោរទៅរកភាពខ្សោយ។ យោងតាមលទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤ ចំនួនប្រជាពលរដ្ឋដែលការយល់ដឹងកម្រិតទាបមានចំនួនច្រើនជាង

[196] Zellatifanny Cut Medika, Rumata Vience Mutiara, &Sakinah Awit Muarwati. "The impact of public information awareness and service towards public engagement" *Jurnal Studi Kumunikasi*, Vol. 5, 2021, pp. 439-452.

[197] (ឧបសម្ព័ន្ធទី៣) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីអង្គភាពច្រកចេញចូលតែមួយ នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

ប្រជាពលរដ្ឋដែលមានការយល់ដឹងខ្ពស់ស្មើតែពីរដង។[198] ជាលទ្ធផលនៃការយល់ដឹងនៅមានកម្រិតនេះ សាលារាជធានីភ្នំពេញក៏បានជួបនៅបញ្ហាមួយចំនួនផងដែរ ទាក់ទងនឹងការពិនិត្យស្តង់ដារអាជីវកម្ម។ ក្នុងករណីមួយ ប្រជាពលរដ្ឋបានដាក់ស្នើបើកអាជីវកម្ម ប៉ុន្តែពុំមានលក្ខណៈគ្រប់គ្រាន់ ហេតុនេះអាជ្ញាធរមូលដ្ឋានមិនអាចអនុញ្ញាតឱ្យ ហើយប្រជាពលរដ្ឋបានធ្វើការទាមទារមកវិញនៅថ្លៃសេវាដែលបានបង់ជូនអាជ្ញាធរ ដែលតាមលក្ខខណ្ឌគតិយុត្ត គឺមិនអាចសងមកវិញបានទេចំពោះប្រាក់ដែលបង់ចូលរដ្ឋហើយ។ ដូចនេះបញ្ហាបានបង្កជាការលំបាក និងការខាតបង់ជូនភាគីទាំងសងខាង។ យ៉ាងណាមិញ រាជរដ្ឋាភិបាលក៏បានធ្វើការកែប្រែមួយចំនួនសម្រាប់ដោះស្រាយបញ្ហានេះផងដែរ ដូចជាការចេញបង្កាន់ដៃបណ្តោះអាសន្ន និងបង់ប្រាក់តាមក្រោយវិញ។

ក្រៅពីនេះ បញ្ហាមួយទៀតដែលមន្ត្រីសាលារាជធានីភ្នំពេញធ្លាប់បានជួបប្រទះក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន គឺការប្រើប្រាស់សេវារបស់រដ្ឋបាលមូលដ្ឋាន ដើម្បីការពារនិងបម្រើប្រយោជន៍របស់ខ្លួនក្នុងផ្លូវមិនត្រឹមត្រូវ។ សកម្មភាពទាំងនេះអាចបង្កជាការលំបាកដល់អាជ្ញាធរមូលដ្ឋានក្នុងការបំពេញការងារ និងការផ្តល់សេវាសាធារណៈ បន្ថែមពីនេះសកម្មភាពទាំងនេះថែមទាំងបានធ្វើឱ្យខាតបង់ពេលវេលាផងដែរ។ បញ្ហានេះភាគច្រើនកើតឡើងនៅក្នុងកិច្ចការអចលនទ្រព្យ ឬដីធ្លី ដោយក្នុងករណីខ្លះប្រជាពលរដ្ឋបានដាក់ស្នើសុំសេវាផ្សេងៗចំពោះទ្រព្យសម្បត្តិរបស់ខ្លួន ដែលទ្រព្យនោះពុំទាន់បានដោះស្រាយបញ្ហារួច(ដូចជាការចែកមិនដាច់ស្រេចរវាងគ្រួសារ ការទាមទារសិទ្ធិ និងផលប្រយោជន៍)។ ក្នុងករណីនេះ ដោយមានអ្នកជំទាស់នឹងការប្រើប្រាស់ទ្រព្យនោះ អាជ្ញាធរ និងមន្ត្រីបច្ចេកទេសមិនអាចធ្វើការសិក្សាត្រួតពិនិត្យបានឡើយ ដូច្នេះប្រជាពលរដ្ឋមានការមិនពេញចិត្ត និងតវ៉ាចំពោះការពន្យាពេលនៃការផ្តល់សេវា។ [199]

សរុបមកវិញ យើងអាចសន្និដ្ឋានបានថាកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះកិច្ចការងារ និងនីតិវិធីរបស់អាជ្ញាធរមូលដ្ឋានគឺជាចំណែកមួយនៅក្នុងការជះឥទ្ធិពលដល់ប្រសិទ្ធភាព គុណភាព និងល្បឿននៃសេវារបស់អាជ្ញាធរដែលមានភារកិច្ចផ្តល់ជូននោះ។ ជាដំណោះស្រាយសម្រាប់បញ្ហាដ៏ស្មុគស្មាញមួយនេះ ការគិតគូរយល់ពីតម្រូវការ និងភារកិច្ចរបស់គ្នាទៅវិញទៅមក អាចជាគន្លឹះមួយយ៉ាងសំខាន់។ បន្ថែមពីកម្រិតនៃការយល់ដឹងពីគ្នាទៅវិញទមកនេះ ការចូលរួមសហការជាមួយគ្នាដោយលុបបំបាត់នូវផ្នត់គំនិតអវិជ្ជមាននានាចំពោះគ្នាក៏រួមចំណែកយ៉ាងសំខាន់ផងដែរនៅក្នុងកិច្ចការនេះ។

[198] (ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

[199] (ឧបសម្ព័ន្ធទី៣) ទេព និនរស្មី &វន់ វិបុល, *"បទសម្ភាសជាមួយមន្ត្រីជំនាញ ទីអង្គភាពច្រកចេញចូលតែមួយ នៃសាលារាជធានីភ្នំពេញ"*, ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

### ៣.២.២. កត្តាធនធានមនុស្ស

ធនធានមនុស្ស គឺជាកត្តាមួយដែលមានឥទ្ធិពលទៅលើប្រសិទ្ធភាព និងគុណភាពរបស់ការផ្តល់សេវាសាធារណៈ។ សម្រាប់សាលារាជធានីភ្នំពេញ ការគ្រប់គ្រងធនធានមនុស្សនេះ គឺជាកិច្ចមួយដែលមានសារៈសំខាន់ណាស់ ដែលវាត្រូវបានគ្រប់គ្រងដោយទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃសាលារាជធានីភ្នំពេញ។

យោងតាមការសិក្សាស្រាវជ្រាវមួយចំនួន បញ្ហាធនធានមនុស្សអាចត្រូវបានជះឥទ្ធិពលដោយកត្តាជាច្រើន ដែលក្នុងនេះកត្តាមួយដែលប្រទេសភាគច្រើនជួបប្រទះគឺ កត្តាកំណើនប្រជាសាស្ត្រ។

*ក្នុងករណីសិក្សាមួយនៅក្នុងរដ្ឋវិចតូរីយ៉ារបស់ប្រទេសអូស្ត្រាលី (Australian State of Victoria) ចំនួនប្រជាពលរដ្ឋដែលស្ថិតនៅក្នុងវ័យធ្វើការ(អាយុ១៥-៦៤ឆ្នាំ) មានការធ្លាក់ចុះពី៦៧%មក៦៥% នៅក្នុង ឆ្នាំ២០២១ ដែលបម្រែបម្រួលនៃចំនួនប្រជាសាស្ត្រនេះបានជះជាបញ្ហាចោទចំនួនពីរដល់វិស័យសាធារណៈ។ បញ្ហាទីមួយ(បញ្ហាក្នុងពេលខ្លី) គឺមន្ត្រីពុំអាចឆ្លើយតបទាន់ពេលទៅនឹងកំណើនយ៉ាងឆាប់រហ័សរបស់ប្រជាពលរដ្ឋនេះបាន និងបញ្ហាមួយទៀតនោះ(បញ្ហាក្នុងពេលវែង) ប្រសិនបើស្ថានការនេះនៅតែបន្តចំនួនមន្ត្រីចូលនិវត្តន៍នឹងមានការកើនឡើង ខណៈចំនួនប្រជាជនក៏កើនឡើង នោះរដ្ឋាភិបាលនឹងអាចមានភាពជាប់គាំង និងប្រសិទ្ធភាពការងារផ្សេងៗនឹងធ្លាក់ចុះ។*[200]

ស្រដៀងគ្នានេះដែរ រដ្ឋបាលរាជធានីភ្នំពេញបច្ចុប្បន្ន(២០២៤) ក៏បាននឹងជួបប្រទះនឹងបញ្ហាវិសមភាពរវាងន្ត្រីរាជការចូលនិវត្តន៍ និងមន្ត្រីចូលថ្មី និងបញ្ហាកំណើនប្រជាសាស្ត្រនេះដែរ។ យោងតាមបទសម្ភាសជាមួយមន្ត្រីជំនាញរបស់ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ បញ្ហាចោទខាងលើនេះគឺជាការព្រួយបារម្ភមួយរបស់សាលារាជធានីភ្នំពេញ ដែលនៅក្នុងពេលបច្ចុប្បន្នការអនុវត្តបរិវត្តកម្មឌីជីថល (Digitalization) គឺជាមធ្យោបាយបឋមក្នុងការដោះស្រាយ ដែលវាក៏បានរួមចំណែកក្នុងការធ្វើឱ្យមានភាពប្រសើរឡើងនៃសេវាសាធារណៈផងដែរ។[201]

ដើម្បីពិនិត្យមើលឱ្យកាន់តែស៊ីជម្រៅចំពោះបញ្ហានេះ យើងនឹងធ្វើការប្រៀបធៀបចំនួនមន្ត្រី និងចំនួនប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ រួមជាមួយនឹងកំណើននៃតម្រូវការ។ ដោយនៅក្នុងការប្រៀបធៀបនេះគឺយើងធ្វើការកំណត់សម្គាល់ពីចំនួនប្រជាពលរដ្ឋ ដែលមន្ត្រីម្នាក់ៗត្រូវទទួលខុសត្រូវ។ ឧទាហរណ៍. ចំនួនម/ប ១:១៥ មានន័យថា មន្ត្រីម្នាក់ត្រូវទទួលខុសត្រូវបម្រើប្រជាពលរដ្ឋចំនួន១៥នាក់។

---

[200] Ronald J. Burke, Amanda F. Allisey, &Andrew J. Noblet, "The importance of human resource management in the public sector, future challenges and the relevance of the current collection" *Human Resource Management in the Public Sector*, 2013, pp. 1-13.

[201] (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤.

ដើម្បីបង្ហាញពីបញ្ហាប្រឈមមួយនេះ យើងនឹងធ្វើការប្រៀបធៀបរវាងកាលវេលាពីរ គឺដើមសម័យកាលព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៨ និងពេលបច្ចុប្បន្នគឺឆ្នាំ២០២៤។

ក្រាហ្វិកទី២៖ ការប្រៀបធៀបរវាងអាត្រាកំណើនមន្ត្រី និងប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ[202]




តារាងទី៧៖ លទ្ធផលសមាមាត្រចំនួនប្រជាពលរដ្ឋដែលមន្ត្រីម្នាក់ត្រូវមានទំនួលខុសត្រូវ

| ឆ្នាំ | មន្ត្រីក្របខណ្ឌៈប្រជាពលរដ្ឋ | មន្ត្រីសរុបៈប្រជាពលរដ្ឋ |
|---|---|---|
| ១៩៩៨ | ១:២២១៦ | ១:១៩៩១ |
| ២០២៤ | ១:៨២៣៨ | ១:៤២៨៩ |

យោងតាមលទ្ធផលនៃផលធៀបខាងលើនេះយើងសង្កេតឃើញថា នៅក្នុងដើមសម័យកាលព្រះរាជាណាចក្រកម្ពុជាទី២(ឆ្នាំ១៩៩៨) មន្ត្រី១រូប(គិតតែមន្ត្រីក្របខណ្ឌ)ត្រូវមានទំនួលខុសត្រូវក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋចំនួន២២១៦នាក់ ឬ ១៩៩១នាក់ ប្រសិនបើគិតទាំងមន្ត្រីជាប់កិច្ច ឬមន្ត្រីអណ្តែត។ រហូតមកដល់ឆ្នាំ២០២៤(២៦ឆ្នាំក្រោយមក) ចំនួនគណនេយ្យភាពនេះត្រូវបានកើនឡើងរហូតដល់ទៅ ៣.៧២ដងសម្រាប់មន្ត្រីក្របខណ្ឌ ឬ២.១៥ដង បើគិតដោយមន្ត្រីសរុប។ ដូចនេះមន្ត្រីម្នាក់ៗនឹងត្រូវចំណាយពេលវេលា

[202] ដកស្រង់ និងកែសម្រួលមកពី៖ ជា សុផារ៉ា, *រដ្ឋបាលរាជធានីភ្នំពេញ,* ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ, ១៩៩៨, ទំព័រ ១០-២១. & (ឧបសម្ព័ន្ធទី២) ទេព និនរស្មី &វន់ វិបុល, "*បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ*", ធ្វើនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤. &ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០២៤, ទំព័រ ១១៩.

ច្រើនជាងមុនរួមនឹងត្រូវមានសមត្ថភាពខ្ពស់ជាងមុន ដើម្បីឆ្លើយតបទៅនឹងកំណើននៃប្រជាសាស្ត្រនេះ។ បន្ថែមពីលទ្ធផលនៃកំណើនប្រជាពលរដ្ឋនេះ សង្កេតឃើញកំណើននៃតម្រូវការប្រចាំឆ្នាំក៏មានការកើនឡើងយ៉ាងឆាប់រហ័សផងដែរ ដែលនៅក្នុងឆមាសទី១ នៃឆ្នាំ២០២៤ មានកំណើនតម្រូវការសេវាប្រហែលនឹង១.៥ដង ធៀបនឹងតម្រូវការនៃសេវារបស់ប្រជាពលរដ្ឋនៅក្នុងឆមាសទី១ ឆ្នាំ២០២៣។

ដូចនេះប្រសិនបើករណីនៃបញ្ហានេះមិនបានឆ្លើយតប ដោយដំណោះស្រាយសមស្របណាមួយទេ រួមផ្សំជាមួយនឹងកំណើននៃប្រជាសាស្ត្រ និងសេវាសាធារណៈនេះ នៅក្នុងពេលខាងមុខរដ្ឋបាលសាលារាជធានីភ្នំពេញអាចនឹងមានការជាប់គាំង ឬមានការធ្លាក់ចុះនៃគុណភាព និងប្រសិទ្ធភាពសេវាសាធារណៈ ដែលស្រដៀងគ្នានឹងករណីដែលកើតឡើងនៅក្នុងប្រទេសអូស្ត្រាលីដែរ។

# ជំពូកទី៤

# របកគំហើញនៃការសិក្សា

# ជំពូកទី៤ របកគំហើញនៃការសិក្សា

## ៤.១. គម្លាតអន្តរកម្មរវាងរដ្ឋបាលរាជធានីភ្នំពេញ និងប្រជាពលរដ្ឋ

ការសិក្សាទៅគម្លាតអន្តរកម្មរវាងរដ្ឋបាលរាជធានីភ្នំពេញ និងប្រជាពលរដ្ឋមូលដ្ឋាន គឺមានគោលបំណងឆ្លុះបញ្ចាំងពីការយល់ដឹងពីគ្នាទៅវិញទៅមករវាងសាលារាជធានីភ្នំពេញ និងប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ។ ដូចបានបង្ហាញនៅជំពូកទី៣ ការចូលរួមនិងកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសកម្មភាពរបស់រដ្ឋបាលមូលដ្ឋាន គឺរួមចំណែកយ៉ាងសកម្មនៅក្នុងអភិវឌ្ឍ ហេតុដូចនេះ ចំណុចនេះនឹងធ្វើការសិក្សាទៅលើកម្រិតនៃការយល់ដឹងរបស់មន្ត្រីចំពោះប្រជាពលរដ្ឋ តាមរយៈការគិតគូរចំពោះការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធ្វើការសិក្សាស៊ីជម្រៅទៅលើការយល់ដឹងពីមធ្យោបាយ និងព័ត៌មាននានាដែលប្រជាពលរដ្ឋគួរដឹងពីមន្ត្រីមូលដ្ឋាន។

យោងតាមការសិក្សានៅតាមបណ្ដាប្រទេសធំៗមួយចំនួននៅក្នុងពិភពលោកដូចជា ប្រទេសម៉ិកស៊ិក ប្រទេសប្រេស៊ីល និងប្រទេសឥណ្ឌាជាដើម ប្រសិទ្ធភាពនៃអន្តរកម្មរវាងរដ្ឋបាលមូលដ្ឋាន និងប្រជាពលរដ្ឋត្រូវបានកំណត់ដោយកត្តាសំខាន់ៗចំនួនពីរគឺ រចនាសម្ព័ន្ធប្រព័ន្ធរដ្ឋបាល និងកម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន។[203]

### ៤.១.១. កម្រិតនៃការយល់ដឹងរបស់មន្ត្រីចំពោះប្រជាពលរដ្ឋ

នៅក្នុងការសិក្សាអំពីកម្រិតនៃការយល់ដឹងរបស់មន្ត្រីចំពោះប្រជាពលរដ្ឋ យើងនឹងប្រើប្រាស់ព័ត៌មានដែលទទួលបានពីប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ មកធ្វើការសិក្សានិងកំណត់ពីតម្រូវការ។ ដោយសារទំហំនៃតម្រូវការមានចំនួនច្រើនលើសលុប យើងនឹងប្រើប្រាស់ព័ត៌មានទាំងនេះមកកំណត់ជាតម្រូវការចំនួន៥ ដែលក្នុងនេះមាន៣ជាតម្រូវការដែលមានការសំណូមពរច្រើន និង២ជាតម្រូវការដែលពុំសូវមានអ្នកត្រូវការ។ ដើម្បីសន្និដ្ឋានពីកម្រិតនៃការយល់ដឹងរបស់មន្ត្រីចំពោះប្រជាពលរដ្ឋ គឺអាស្រ័យទៅលើផែនការ និងការឆ្លើយតបរបស់រដ្ឋបាលមូលដ្ឋានទៅលើតម្រូវការទាំងនោះ។

តារាងទី៨៖ តម្រូវការរបស់ប្រជាពលរដ្ឋ និងផែនការរបស់អាជ្ញាធរមូលដ្ឋាន

| តម្រូវការ | កម្រិតនៃតម្រូវការ | ការឆ្លើយតប |
|---|---|---|
| ពង្រឹងប្រព័ន្ធគ្រប់គ្រង និងការផ្ដល់សេវារដ្ឋបាល | ច្រើន | ✓ |
| ពង្រឹងសណ្ដាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពសាធារណៈ | ច្រើន | ✓ |

[203] Robert H. Wilson. "Understanding local governance: An international perspective" *Revista de Administrcao de Empresas,* Vol.2, No.2, 2000, pp. 51-63.

| | | |
|---|---|---|
| ការគ្រប់គ្រងដីសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធរាជធានី | ច្រើន | ✓ |
| ការគ្រប់គ្រងកែសម្រួលក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងារ | តិច | ✓ |
| លើកកម្ពស់ការគ្រប់គ្រងសំណល់ក្នុងរាជធានីភ្នំពេញ | តិច | ✓ |

នៅក្នុងការសិក្សាស្វែងយល់ និងរៀបចំផែនការសកម្មភាពនានា ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន យើងសង្កេតឃើញថាក្រសួងស្ថាប័នពាក់ព័ន្ធ និងសាលារាជធានីភ្នំពេញមិនដឹងនិងគិតគូរនៅគ្រប់ចំណុចទាំងអស់ ទាំងតម្រូវការខ្ពស់ និងតម្រូវការទាប។ យោងតាមលទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋ និងបទសម្ភាសជាមួយប្រជាពលរដ្ឋស្ម័គ្រចិត្ត យើងទទួលបានលទ្ធផលនៃតម្រូវការចំនួន៥ ដែលក្នុងនោះមាន បី(០៣)ជាតម្រូវការខ្ពស់ និងពីរ(០២)ជាតម្រូវការទាប ដែលលទ្ធផលនៃបានមកពីការចូលរួមរបស់ប្រជាពលរដ្ឋ ១៩០រូបនៃរាជធានីភ្នំពេញ។ តម្រូវការទាំងអស់នោះត្រូវបានគិតគូរនឹងឆ្លើយតបដូចមានខាងក្រោម៖

### ៤.១.១.១. តម្រូវការនៃការពង្រឹងប្រព័ន្ធគ្រប់គ្រង និងសេវារដ្ឋបាល

នៅក្នុងការទទួលសេវារដ្ឋបាលនានា និងការងារនីត្យានុកូលកម្ម បញ្ហាចោទចំនួនពីរត្រូវបានកត់សម្គាល់គឺ ល្បឿននៃសេវា និងភាពស្មុគស្មាញនៃនីតិវិធី។[204] ទោះបីជាការផ្តល់ព័ត៌មាន និងសេវារបស់រដ្ឋបាលមូលដ្ឋានបានអនុវត្តបរិវត្តកម្មឌីជីថលក្តី ប្រព័ន្ធគ្រប់គ្រងទាំងនោះនៅមានកម្រិតនៅឡើយដោយវាប្រើប្រាស់ពេលវេលាច្រើន ដើម្បីដំណើរការ។[205] ហេតុនេះការគ្រប់គ្រងប្រព័ន្ធឌីជីថលទាំងនេះ ទាមទារការសម្រួល និងពង្រឹងឱ្យប្រសើរជាងមុន។ បន្ថែមពីបញ្ហាល្បឿននេះ ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញមួយចំនួននៅមានជួបប្រទះនៅឡើយចំពោះការទទួលបានព័ត៌មានគ្រប់គ្រាន់ និងការយល់ដឹងពីនីតិវិធីនៃសេវា។

នៅក្នុងការដោះស្រាយ និងឆ្លើយតបទៅនឹងតម្រូវការទាំងនេះ រដ្ឋបាលរាជធានីភ្នំពេញ និងក្រសួងមហាផ្ទៃ មានរៀបចំផែនការសកម្មភាពមួយចំនួន ដើម្បីឆ្លើយតប។ ក្រសួងមហាផ្ទៃបានរៀបចំឱ្យមានផែនការយុទ្ធសាស្ត្រ ស្តីពី ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ឆ្នាំ២០២៤-២០២៨។ នៅក្នុងនោះ យុទ្ធសាស្ត្រទី១ ទី៥ និងទី៦ មានទំនាក់ទំនង និងគោលដៅឆ្លើយតបនឹងតម្រូវការនេះ។ យុទ្ធសាស្ត្រទី១ គឺការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរាជធានីភ្នំពេញ នឹងទទួលបានការសិក្សាពីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារនៅក្នុងឆ្នាំ២០២៥ មុននឹងការធ្វើ

[204] (ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

[205] (ឧបសម្ព័ន្ធទី៤) ទេព និនរស្មី &វន់ វិបុល, *"បទសម្ភាសជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ"*, ធ្វើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤.

កំណែទម្រង់ថ្មី។ យុទ្ធសាស្ត្រទី៥ គឺការលើកកម្ពស់ការផ្តល់សេវាសាធារណៈក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ដែលនៅក្នុងគោលដៅធំៗរួមមាន ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ និងបញ្ជីអត្តសញ្ញាណកម្ម។ ផែនការយុទ្ធសាស្ត្រនេះ នឹងចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០២៥។ យុទ្ធសាស្ត្រទី៦ ការងារបច្ចេកវិទ្យាឌីជីថល ដែលនៅក្នុងនោះរួមមានការគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ(Data Center) ការផ្លាស់ប្តូរទិន្នន័យ ការតភ្ជាប់ទិន្នន័យរវាងអង្គភាពពាក់ព័ន្ធ ការគ្រប់គ្រងសុវត្ថិភាព(SOC) ការបង្កើតកម្មវិធីជំនួយបន្ថែម និងកិច្ចការឌីជីថលផ្សេងៗទៀត។[206] កិច្ចការទាំងបីនៃយុទ្ធសាស្ត្រខាងលើនេះនឹងជួយជំរុញដល់ប្រសិទ្ធភាព និងល្បឿននៃសេវាសាធារណៈ(សេវារដ្ឋបាល)នៅរាជធានីភ្នំពេញក្នុងពេលខាងមុខ។

**៤.១.១.២. តម្រូវការនៃការពង្រឹងសណ្តាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពសាធារណៈ**

យោងតាមលទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋ ការគ្រប់គ្រងសណ្តាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពសាធារណៈ គឺជាកិច្ចការមួយ ដែលប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញមានការព្រួយបារម្ភ និងសំណូមពរឱ្យមានចំណាត់ការ។ នៅក្នុងនោះការលិចឡើងនៃក្មេងទំនើង ដែលបង្កភាពអសន្តិសុខជាពិសេសនៅពេលយប់ បានបង្កការរំខានដល់ប្រជាពលរដ្ឋ រួមទាំងភ្ញៀវបរទេសក្នុងការធ្វើដំណើរនៅក្នុងរាជធានីភ្នំពេញ។ សកម្មភាពអសន្តិសុខ ដែលបង្កជារូបភាព និងគំរូមិនល្អដល់ក្មេងជំនាន់ក្រោយមួយចំនួនដូចជា ការប្រើប្រាស់គ្រឿងញៀន រួមមានបារីអគ្គិសនីជាដើម។[207]

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើបញ្ហានេះ យើងបានទទួលឯកសារមួយចំនួនផងដែរទាក់ទងនឹងផែនការនីតិវិធីទប់ស្កាត់បញ្ហានេះ។ ដូចមានបង្ហាញនៅក្នុងជំពូកទី៣ ការគ្រប់គ្រងកិច្ចសន្តិសុខ សុវត្ថិភាពសាធារណៈរដ្ឋបាលរាជធានីភ្នំពេញត្រូវរៀបចំឱ្យមានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីក្នុងការអនុវត្តនិងរក្សាស្ថេរភាពសង្គម ក្រៅពីនេះផែនការយុទ្ធសាស្ត្រ ស្តីពី ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ឆ្នាំ២០២៤-២០២៨ ក៏បានរួមចំណែកក្នុងការកំណត់នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពផ្សេងៗ ដើម្បីធានានូវប្រសិទ្ធភាពការរក្សាសុវត្ថិភាពនោះ។ នៅក្នុងនោះ គោលនយោបាយគ្រប់គ្រងគ្រឿងញៀនក៏ត្រូវបានលើកយកមកពិភាក្សាដែរ។ នៅក្នុងសូចនាករនោះ ភាគរយនៃឃុំ សង្កាត់ដែលទទួលបានចំណាត់ថ្នាក់លេខ១ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព ត្រូវបានរំពឹងថានឹងមានអត្រា៧០% នៅក្នុងឆ្នាំ២០២៤ និង៨២% នៅក្នុងឆ្នាំ២០២៨ ពោល

---

[206] ក្រសួងមហាផ្ទៃ, *ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ ២០២៤-២០២៨*, ២០២៤, ទំព័រ ២៨-៣៧.

[207] (ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

គឺមានកំណើន៣% ក្នុងមួយឆ្នាំ។ ចំពោះបញ្ហាគ្រឿងញៀនវិញ សូចនាករបានបង្ហាញថានឹងដំណោះស្រាយនឹងត្រូវបានអនុវត្ត តាមរយៈគោលនយោបាយភូមិ ឃុំ-សង្កាត់ គ្មានគ្រឿងញៀននៅក្នុងឆ្នាំ២០២៤ ដោយយ៉ាងតិចមានភូមិ២ នៃខេត្តជាប់ព្រំដែននីមួយៗត្រូវបានអនុវត្ត និងអនុវត្តទូទាំងប្រទេសនៅក្នុងឆ្នាំ២០២៨។[208]

តារាងទី៩៖ សូចនាករគោលនយោបាយភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព និងគ្មានគ្រឿងញៀន

| សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|
| ភាគរយនៃឃុំ សង្កាត់ដែលទទួលបានចំណាត់ថ្នាក់លេខ១ក្នុងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព | ៧០ | ៧៣ | ៧៦ | ៧៩ | ៨២ |
| ចំនួនភូមិអនុវត្តគោលនយោបាយភូមិ ឃុំ-សង្កាត់គ្មានគ្រឿងញៀន | យ៉ាងតិច២ ភូមិនៃខេត្ត ជាប់ព្រំដែន | យ៉ាងតិច២ ភូមិនៃខេត្ត ជាប់ព្រំដែន | ភូមិទាំង អស់នៃខេត្ត ជាប់ព្រំដែន | ៥០%នៃ ភូមិទូទាំង ប្រទេស | ភូមិទូទាំង ប្រទេស |

### ៤.១.១.៣. តម្រូវការនៃការគ្រប់គ្រងដីសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរាជធានី

ចំពោះតម្រូវការទាក់ទងនឹងការគ្រប់គ្រងដីសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរាជធានី ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញបានជួបប្រទះនៅបញ្ហាមួយចំនួនដែលទាមទារឱ្យមានការរឹតបណ្ដឹងច្បាប់ទម្លាប់ និងការកែប្រែ។ សកម្មភាពមួយចំនួន ដែលប្រជាពលរដ្ឋគិតថាចាំបាច់ក្នុងការកែតម្រូវរួមមាន ការគ្រប់គ្រងតំបន់នឹងដីសាធារណៈ ការគ្រប់គ្រងចិញ្ចើមផ្លូវឱ្យបានល្អប្រសើរ និងការរៀបចំដើមឈើ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សម្រស់រាជធានីភ្នំពេញ។[209]

ចំពោះការឆ្លើយតបនៃតម្រូវការនេះ រាជធានីភ្នំពេញបានរៀបចំឱ្យមានប្លង់គោលឆ្នាំ២០៣៥ ដែលជាប្លង់គំរូក្នុងការអភិវឌ្ឍ និងប្រើប្រាស់ដីនៅក្នុងរាជធានីភ្នំពេញ។ នៅក្នុងការគ្រប់គ្រងដីទាំងអស់នេះ រដ្ឋបាលរាជធានីភ្នំពេញមានសិទ្ធិ នៅលើដែនសមត្ថកិច្ចរបស់ខ្លួនដែលបានផ្ទេរប្រតិភូកម្មឱ្យដោយរាជរដ្ឋាភិបាល ចំពោះការអភិវឌ្ឍវិញ ឃុំ សង្កាត់ និងខណ្ឌត្រូវអនុវត្តការពិនិត្យមើលការប្រើប្រាស់ដី ដោយអនុលោមទៅតាមប្លង់គោលរាជធានីភ្នំពេញឆ្នាំ២០២៥។ ជាឧទាហរណ៍. ខណ្ឌព្រែកព្នៅត្រូវអនុវត្តគ្រប់គ្រងដីរបស់ខ្លួនទៅតាមប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥ ដែលប្លង់នេះត្រូវបានសិក្សាបង្កើតឡើង ឱ្យស្រប

[208] ក្រសួងមហាផ្ទៃ, *ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ ២០២៤-២០២៨*, ២០២៤, ទំព័រ ២៨-៣៧.

[209] (ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

ទៅនឹងប្លង់គោលរាជធានី។ នៅក្នុងនោះ ការគ្រប់គ្រងបរិស្ថាននៃខណ្ឌត្រូវបែងចែកជា៣តំបន់ដូចជា តំបន់ដងផ្លូវសាធារណៈ តំបន់ដងទន្លេ បឹងតាមោក បឹងសំរោង ព្រែកព្នៅ ប្រឡាយ និងតំបន់សហគមន៍។ នៅក្នុងនេះវិធានការសំខាន់ៗមួយចំនួន ដើម្បីថែរក្សាតំបន់ទាំងអស់នេះក៏ត្រូវបានដាក់ចំណាត់ការផងដែរ។ ដើម្បីធានានូវប្រសិទ្ធភាពនៃផែនការទាំងនេះ ផែនការសកម្មភាព និងនីតិវិធីសម្រាប់ការតាមដានត្រួតពិនិត្យក៏ត្រូវបានកំណត់នៅក្នុងប្លង់គោលនៃខណ្ឌផងដែរ។[210] ដូចនេះខណ្ឌនីមួយៗមានកាតព្វកិច្ចអនុវត្តកិច្ចការទាំងឡាយដែលបានកំណត់ចែងនៅក្នុងប្លង់គោល ដែលប្លង់គោលនីមួយៗត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

### ៤.១.១.៤. តម្រូវការនៃការគ្រប់គ្រងកែសម្រួលក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងារ

យោងតាមបទសម្ភាសជាមួយប្រជាពលរដ្ឋនៃរាជធានីភ្នំពេញ និងលទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងរាជធានីភ្នំពេញ ក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងាររបស់មន្ត្រីនៃសាលារាជធានីភ្នំពេញ ក៏ត្រូវបានលើកឡើងមកជាសំណូមពរផងដែរ។ បើទោះបីជាមានសំណូមពរ ឬតម្រូវការទាក់ទងនឹងបញ្ហានេះមានចំនួនតិចក្តី ផែនការនានារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក៏បានលើកយកបញ្ហាមួយនេះមកធ្វើការសិក្សាពិចារណាដែរ។ តម្រូវការមួយចំនួនដែលប្រជាពលរដ្ឋលើកឡើង រួមមានការសំណូមពរការយោគយល់អនុគ្រោះ ការពង្រឹងវិន័យ និងការបង្កើនគណនេយ្យភាពរបស់មន្ត្រីរាជការ។ បន្ថែមពីនេះតម្រូវការទាក់ទងនឹងការពង្រឹងសមត្ថភាពមន្ត្រី ក៏រួមចំណែកនៅក្នុងកិច្ចការនេះផងដែរ។[211]

នៅក្នុងការឆ្លើយតបនឹងតម្រូវការនេះ រដ្ឋបាលរាជធានីភ្នំពេញមានកាតព្វកិច្ចអនុវត្តការគ្រប់គ្រងសកម្មភាពរបស់ខ្លួន និងត្រូវមានគណនេយ្យភាពដូចដែលបានកំណត់ចែងនៅក្នុងសៀវភៅណែនាំ ស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នៅក្នុងនោះ ខ្សែគណនេយ្យភាព ម៉ោងធ្វើការ វិន័យ និងទណ្ឌកម្មរបស់មន្ត្រីសាលារាជធានីត្រូវបានកំណត់។[212] បន្ថែមពីនេះ ក្រសួងមហាផ្ទៃនៅក្នុងផែនការយុទ្ធសាស្ត្រ ស្តីពី ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ឆ្នាំ ២០២៤-២០២៨ បានកំណត់នៅសកម្មភាពមួយចំនួន ដើម្បីពង្រឹងកិច្ចការនេះផងដែរ។ នៅក្នុងនោះសកម្មភាពមួយចំនួនដូចជា ការរៀបចំ និងកែសម្រួលក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងារ(នឹងអនុវត្តនៅឆ្នាំ២០២៥) ការវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្ម(នឹងអនុវត្តនៅឆ្នាំ២០២៥) និងផែនការបណ្តុះបណ្តាលមន្ត្រីនៅសាលា

[210] គណៈកម្មាធិការជាតិរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រោមជាតិ, *ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥ (បោះពុម្ពលើកទី១)*, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២០២១.

[211] (ឧបសម្ព័ន្ធទី៤) ទេព និនរស្មី &វន់ វិបុល, *"បទសម្ភាសជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ"*, ធ្វើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤.

[212] ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី កិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០១៥, ទំព័រ ៩៨-១២២.

ជាតិរដ្ឋបាលមូលដ្ឋាន។[213] ការកំណត់ផែនការសកម្មភាពទាំងនេះ គឺមានគោលបំណងពង្រឹងវិន័យ របស់មន្ត្រីរដ្ឋបាល និងអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីឱ្យកាន់តែមានភាពប្រសើរឡើង និងត្រឹមត្រូវ។ ដូចនេះការគិតគូរនេះនឹងរួមចំណែកនៅក្នុងការដោះស្រាយ និងផ្តល់ជូនប្រជាពលរដ្ឋទៅតាមតម្រូវការរបស់គាត់។

**៤.១.១.៥. តម្រូវការនៃការគ្រប់គ្រងសំណល់**

ការលើកកម្ពស់ការរួមចំណែកថែរក្សាបរិស្ថានតាមរយៈការគ្រប់គ្រងកាកសំណល់ គឺជាតម្រូវការមួយដែលប្រជាពលរដ្ឋមួយផ្នែកនៃរាជធានីភ្នំពេញត្រូវការ។ តម្រូវការរួមមាន ការកំណត់ឱ្យបានច្បាស់ពីការបែងចែកប្រភេទសំរាម ការប្រមូលសំរាម និងនីតិវិធីពាក់ព័ន្ធ។ បន្ថែមពីនេះ ប្រជាពលរដ្ឋមួយក្រុមតូចក៏បានសំណូមពរ ឱ្យមានការផ្សព្វផ្សាយយ៉ាងសកម្មតាមរយៈមធ្យោបាយនានាផងដែរ ដើម្បីលើកទឹកចិត្តការចូលរួមពីប្រជាពលរដ្ឋដទៃទៀត។[214]

នៅក្នុងការឆ្លើយតប និងដោះស្រាយចំពោះបញ្ហានេះ យើងសង្កេតឃើញមានសកម្មភាព និងដំណោះស្រាយមួយចំនួនត្រូវបានលើកឡើងមកពិភាក្សា។ នៅក្នុងនោះ យើងសង្កេតឃើញវត្តមាននៃគោលនយោបាយ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ ដែលគោលនយោបាយនេះដើរតួរជាគោលនយោបាយគោលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះមានវិធានការបី(០៣) គឺវិធានការរយៈពេលខ្លី(១-២ឆ្នាំ) វិធានការរយៈពេលមធ្យម(៣-៥ឆ្នាំ) និងវិធានការរយៈពេលវែង(៦-១០ឆ្នាំ)។[215] ក្រៅពីនេះយោងតាមសេចក្តីប្រកាសរបស់រដ្ឋបាលរាជធានីភ្នំពេញ ការគ្រប់គ្រងសំរាម សំណល់រឹងត្រូវបានគ្រប់គ្រងដោយសហគ្រាសគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនរាជធានីភ្នំពេញ ដែលជាក្រុមហ៊ុនរដ្ឋមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំ។[216] ការសម្រេចឱ្យការគ្រប់គ្រងសំរាម សំណល់រឹងស្ថិតនៅក្នុងការគ្រប់គ្រងដោយក្រុមហ៊ុនរដ្ឋនេះ នឹងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសេវានេះនៅក្នុងរាជធានីភ្នំពេញ។ លទ្ធផលនៃការសិក្សា ក្នុងកិច្ចការគ្រប់គ្រងសំណល់នៅទីក្រុងហ្គាបូរ៉ូន(Gaborone) នៃប្រទេសបូតស្វាណា(Botswana) បានបង្ហាញថាការគ្រប់គ្រងសំណល់រឹងតាមរបៀបក្រុមហ៊ុន ដែលមាន

---

[213] ក្រសួងមហាផ្ទៃ, *ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ ២០២៤-២០២៨*, ២០២៤, ទំព័រ ២៨-៣៧.

[214] (ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

[215] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០*, ២០២១.

[216] សេចក្តីជូនដំណឹងលេខ ០០២/២៤ សជណ.ស ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ មកសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ(ស.ស.ភ)វិញ.

ស្វ័យភាពពេញលេញ គឺមានភាពល្អប្រសើរជាងការគ្រប់គ្រងដោយរដ្ឋ ក្នុងលក្ខខណ្ឌប្រសិទ្ធភាពការងារ និងគុណភាពសេវាកម្ម។[217]

### ៤.១.២. កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះមន្ត្រី

កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ មានសារៈសំខាន់ណាស់សម្រាប់រដ្ឋបាលមូលដ្ឋានក្នុងកិច្ចដំណើរការរបស់រដ្ឋបាលមូលដ្ឋាន។ កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ គឺជាផ្នែកមួយ ដែលជំរុញមានការចូលរួមសហការរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន[218] មិនតែប៉ុណ្ណោះប្រជាពលរដ្ឋដែលបានយល់ដឹងពីដំណើរការរបស់រដ្ឋបាលមូលដ្ឋាន ភាគច្រើនអាចចូលរួមក្នុងសកម្មភាពមូលដ្ឋានបានល្អប្រសើរជាងប្រជាពលរដ្ឋដែលមិនបានដឹងពីដំណើរនៃកិច្ចការងារ។ ការសិក្សាបានបង្ហាញថា ប្រជាពលរដ្ឋដែលពុំបានដឹង និងទទួលបានព័ត៌មានគ្រប់គ្រាន់ពីដំណើរការ កិច្ចការ និងផែនការនានារបស់រដ្ឋបាលមូលដ្ឋាន អាចនឹងមានការមិនទុកចិត្តចំពោះអាជ្ញាធរមូលដ្ឋាន និងអាចបង្កជាការលំបាកក្នុងកិច្ចដំណើរការនានា។[219] ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពសង្គមនៅក្នុងរាជធានីភ្នំពេញ ការសិក្សាពីការយល់ដឹងរបស់ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញ និងត្រូវកំណត់បែងចែកជាបី(០៣)ប្រភេទ នៃការយល់ដឹងគឺ (១)ការយល់ដឹងពីសារៈសំខាន់នៃចំណេះដឹងទាក់ទងនឹងការងាររបស់រដ្ឋបាលមូលដ្ឋាន (២)ការយល់ដឹងពីប្រព័ន្ធ និងរចនាសម្ព័ន្ធរដ្ឋបាល និង(៣)ការយល់ដឹងពីផែនការយុទ្ធសាស្ត្រ និងសកម្មភាពរបស់រដ្ឋបាលមូលដ្ឋាន។

#### ៤.១.២.១. ការយល់ដឹងពីសារៈសំខាន់នៃចំណេះដឹងទាក់ទងនឹងកិច្ចការរដ្ឋបាលមូលដ្ឋាន

ផ្នត់គំនិតរបស់ប្រជាពលរដ្ឋម្នាក់ៗ ដើរតួរយ៉ាងសំខាន់នៅក្នុងសង្គមរបស់រាជធានីភ្នំពេញ ដែលវាជាផ្នែកមួយ ដែលជំរុញដល់ការយល់ដឹង និងការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាលមូលដ្ឋាន។ នៅក្នុងការសិក្សារបស់ចិត្តវិទ្យា ផ្នត់គំនិតរបស់មនុស្សម្នាក់គឺជាកត្តាមួយក្នុងការជំរុញសកម្មភាពរបស់មនុស្សម្នាក់ៗ និងការអភិវឌ្ឍចំណេះដឹងរបស់ខ្លួន។[220] ដោយមើលឃើញពីសារៈសំខាន់នៃផ្នត់គំនិតរបស់ប្រជាពលរដ្ឋនៅក្នុងអន្តរកម្មសង្គមមួយនេះ ការប្រមូលទិន្នន័យពីប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញទាក់ទងនឹងការយល់ឃើញពីសារៈសំខាន់នៃចំណេះដឹងពីកិច្ចការរបស់រដ្ឋបាលមូលដ្ឋានពុំអាចខ្វះបានឡើយ។ នៅក្នុងការប្រមូលទិន្នន័យមួយប្រជាពលរដ្ឋចំនួន ១៩០រូប ត្រូវបានស្នើសុំឱ្យវាយតម្លៃពី ១- ដល់ ៥-។ ឧទាហរណ៍. ប្រជាពលរដ្ឋដែលឱ្យតម្លៃ ១- មានន័យថា ប្រជាពលរដ្ឋម្នាក់នោះ គិតថាចំណេះដឹងទាក់ទងនឹងប្រព័ន្ធរដ្ឋបាល និងរាជរដ្ឋាភិបាល

---

[217] Benjamin Bolaane, &Emmanuel Isaac. "Privatization of solid waste collection services: Lesson from Gaborone" *Waste Management*, Vol. 40, 2015, pp. 14-21.

[218] Zellatifanny Cut Medika, Rumata Vience Mutiara, &Sakinah Awit Muarwati. "The impact of public information awareness and service towards public engagement" *Jurnal Studi Kumunikasi*, Vol. 5, 2021, pp. 439-452.

[219] Chanda Chansa Thelma. "Civic education and citizen participation in local government: A case of Lusaka District, Zambia" *International Journal of Research Publication and Reviews, Vol. 5*(3), 2024, pp. 4628-4637.

[220] Dweck Carol Susan. *Mindset The new psychology of success.* Random House, 2006.

គ្មានសារៈសំខាន់នោះទេ រីឯប្រជាពលរដ្ឋដែលឱ្យតម្លៃ ៥- មានន័យថាគាត់គិត ចំណេះដឹងមួយនេះមានសារៈសំខាន់ណាស់។

ក្រាហ្វិកទី៣៖ លទ្ធផលការវាយតម្លៃរបស់ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញទាក់ទងនឹងសារៈសំខាន់[221]




យោងទៅតាមលទ្ធផលនេះ ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញប្រមាណជា៤៥% យល់ឃើញថា ចំណេះដឹងមួយនេះមានសារៈសំខាន់ណាស់ និងប្រមាណជា៤៥% ទៀតយល់ថាការយល់ដឹងពីប្រព័ន្ធរដ្ឋបាលមូលដ្ឋាន និងរាជរដ្ឋាភិបាលស្ថិតនៅក្នុងចំណុចសំខាន់ និងសំខាន់ខ្លាំង។ ចំពោះប្រជាពលរដ្ឋដែលគិតថាព័ត៌មាន និងចំណេះដឹងមួយនេះមិនមានសារៈ ឬសំខាន់តិចតួចគឺមានតែប្រមាណជា៩% តែប៉ុណ្ណោះនៃចំនួនប្រជាពលរដ្ឋសរុបចំនួន ១៩០រូប។ ដូចនេះយើងអាចសន្និដ្ឋានបានថា ជារួមផ្នត់គំនិតរបស់ប្រជាពលរដ្ឋខ្មែរនៅក្នុងរាជធានីភ្នំពេញ ស្ថិតនៅក្នុងចំណុចល្អប្រសើរ(៤/៥) ដែលនេះមានន័យប្រជាពលរដ្ឋមានចំណេះដឹង ឬគ្រឹះមូលដ្ឋានសម្រាប់ជំរុញការចូលរួមនានា។

### ៤.១.២.២. ការយល់ដឹងពីប្រព័ន្ធ និងរចនាសម្ព័ន្ធរដ្ឋបាល

ចំណេះដឹងទាក់ទងនឹងប្រព័ន្ធរដ្ឋបាល ក៏ដូចជារចនាសម្ព័ន្ធរដ្ឋបាលអាចដើរតួរជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកទឹកចិត្ត និងទំនុកចិត្តរបស់ប្រជាពលរដ្ឋក្នុងចូលរួមសហការ និងឃោគយល់គ្នា។ ករណី

221 ដកស្រង់ និងកែសម្រួលមកពី៖(ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

សិក្សានៅក្នុងប្រទេស ជាឧទាហរណ៍ នៅក្នុងការសិក្សានេះបានបង្ហាញថាប្រជាពលរដ្ឋ ដែលមានចំណេះដឹងមូលដ្ឋានតិចតួចទាក់ទងនឹងកិច្ចរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន ពុំសូវមានភាពក្លាហាននៅក្នុងការចូលរួមពិភាក្សា ឬសហការស្វែងរកដំណោះស្រាយឡើយ។ បន្ថែមពីនេះ អាជ្ញាធរមូលដ្ឋានអាចនឹងជួបប្រទះបញ្ហាច្រើននៅក្នុងការអនុវត្តកិច្ចការ និងផែនការសកម្មភាពនានា ដោយសារតែកត្តាចំណេះដឹងនៅមានកម្រិតនេះ។ ការសន្និដ្ឋាននោះ គឺខណៈពេលដែលប្រជាពលរដ្ឋមានចំណេះដឹងពីកិច្ចការ និងប្រព័ន្ធដំណើរការតិចតួច ប្រជាពលរដ្ឋអាចនឹងជួបការលំបាកក្នុងការសហការជាមួយអាជ្ញាធរមូលដ្ឋាន(ការទទួលសេវាផ្សេងៗ) មិនតែប៉ុណ្ណោះ ការយោគយល់គ្នា និងទំនុកចិត្តក៏អាចមានកម្រិតទាប ដោយសារកម្រិតនៃចំណេះដឹងនេះ។[222] ដើម្បីសិក្សាពីបញ្ហាមួយនេះ ប្រភពទិន្នន័យសំខាន់ៗចំនួន២ ត្រូវបានប្រើប្រាស់ និងប្រមូលគឺការធ្វើបទសម្ភាសជាមួយប្រជាពលរដ្ឋ និងការស្ទង់មតិ។ ជាលទ្ធផលយើងសង្កេតឃើញថា ប្រជាពលរដ្ឋដែលមានកម្រិតការយល់ដឹងទាបមានចំនួនច្រើនជាងប្រជាពលរដ្ឋដែលកម្រិតនៃការយល់ដឹងខ្ពស់។

ក្រាហ្វិកទី៤៖ លទ្ធផលកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងប្រព័ន្ធរដ្ឋបាល[223]




លទ្ធផលខាងលើនេះបានបង្ហាញថា ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញភាគច្រើនមានការយល់ដឹងកម្រិតមធ្យម(៣/៥)ពីប្រព័ន្ធរដ្ឋបាលដែលរួមមាន ប្រព័ន្ធអនុវត្ត រចនាសម្ព័ន្ធ សមាសភាព និងតួនាទី។ បើ

[222] Mukandala Rwekaza. *Decentralization and Democratization in Tanzania (Barkan J. edition).* Five Monographs on Decentralization and Democratization in Sub-Saharan Africa, University of Iowa, 1998.

[223] ដកស្រង់ និងកែសម្រួលមកពី៖(ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វ៉ន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

ទោះបីជាប្រពលរដ្ឋប្រមាណជា៥០% មានការយល់ដឹងកម្រិតមធ្យមក៏ដោយ លទ្ធផលនេះបានបង្ហាញថា ប្រជាពលរដ្ឋ ដែលមានការយល់ដឹងកម្រិតខ្សោយ(១/៥ និង២/៥) មានចំនួនច្រើនរហូតដល់ទៅ៣១% ខណៈ ប្រជាពលរដ្ឋដែលបានយល់ដឹងច្រើន(៤/៥ និង៥/៥) មានត្រឹមតែ១៧.២% តែប៉ុណ្ណោះ។ យោងតាមលទ្ធផល នេះ យើងអាចសន្និដ្ឋានបានថា ជាមធ្យមប្រជាពលរដ្ឋ ដែលរស់នៅក្នុងរាជធានីភ្នំពេញមានកម្រិតនៃការយល់ ដឹងអំពីប្រព័ន្ធរដ្ឋបាលមូលដ្ឋានកម្រិតមធ្យម ដែលនេះអាចជាកត្តាមួយដែលធ្វើឱ្យពួកគាត់ពុំអាចចូលរួមយ៉ាង សកម្មនៅក្នុងការចូលរួមសហការ និងអាចមានបញ្ហានៅក្នុងការទទួលសេវាកម្មនានា។ ដើម្បីបំពេញបន្ថែមនូវ ចំណុចខ្វះខាតនៃលទ្ធផលនេះ បទសម្ភាសរបស់ប្រជាពលរដ្ឋពីរ(០២)រូបដែលរស់នៅក្នុងរាជធានីភ្នំពេញ លើសពី៤ឆ្នាំ នឹងផ្ដល់ព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហានេះ។ យោងទៅតាមបទសម្ភាស ប្រជាពលរដ្ឋមានការ យល់ដឹងទាក់ទងនឹងប្រព័ន្ធរដ្ឋបាលត្រឹមកម្រិតមធ្យម ឬខ្សោយប៉ុណ្ណោះ ដោយពួកគាត់បានដឹងត្រឹមគោល បំណងនៃប្រព័ន្ធរដ្ឋបាល (បង្កើតឡើង ដើម្បីសម្រួលដល់ការគ្រប់គ្រង) ប៉ុន្តែពួកគាត់ពុំបានដឹងពីរចនាសម្ព័ន្ធ គ្រប់គ្រង នីតិវិធី ឬក៏ខ្សែរគណនេយ្យភាពឡើយ។ នៅក្នុងនេះដែរ កត្តាសំខាន់ចំនួនបី ដែលរាំងស្ទះចំពោះការ យល់ដឹងនេះគឺ កត្តាខ្លួនឯង កត្តាពេលវេលា និងភាពចាំបាច់។ កត្តាខ្លួនឯង មានន័យថាប្រជាពលរដ្ឋមិនបាន ចាប់អារម្មណ៍ និងចង់ដឹងស៊ីជម្រៅទាក់ទងនឹងកិច្ចការនេះ បន្ថែមពីនេះប្រជាពលរដ្ឋអះអាងថាពួកគាត់មិនមាន ពេលវេលាគ្រប់គ្រាន់ សម្រាប់តាមដាន ឬសិក្សាពីព័ត៌មានទាំងនេះឡើយ។ ម្យ៉ាងទៀត ប្រជាពលរដ្ឋនៃរាជធានី ភ្នំពេញយល់ឃើញថា ការសិក្សាស្វែងយល់ពីកិច្ចការទាំងនេះពុំមានភាពចាំបាច់ឡើយ ដោយគាត់គិតថាគាត់ ពុំត្រូវការប្រើប្រាស់វានៅក្នុងជីវភាពប្រចាំថ្ងៃ ដូចនេះគាត់ស្វែងរកព័ត៌មានទាំងនេះ សម្រាប់តែពេលដែលគាត់ ត្រូវការប្រើប្រាស់សេវា ឬតម្រូវការនានាតែប៉ុណ្ណោះ។ [224]

### ៤.១.២.៣. ការយល់ដឹងពីផែនការ យុទ្ធសាស្ត្រ និងសកម្មភាពរបស់រដ្ឋបាលមូលដ្ឋាន

ការយល់ដឹងពីផែនការយុទ្ធសាស្ត្រ និងសកម្មភាពនានារបស់រដ្ឋបាលមូលដ្ឋានអាចអនុញ្ញាតឱ្យ ប្រជាពលរដ្ឋមានឱកាសក្នុងការរួមចំណែកនៅក្នុងសកម្មភាពនានាបានប្រសើរជាមុន។ ប្រជាពលរដ្ឋដែល បានទទួលព័ត៌មានគ្រប់គ្រាន់ អាចរួមចំណែកនៅក្នុងការកែប្រែ និងពង្រឹងប្រព័ន្ធរដ្ឋបាលមូលដ្ឋានប្រកប ដោយប្រសិទ្ធភាព ដែលនេះមិនខ្វះបានឡើយនៅក្នុងសង្គមប្រជាធិបតេយ្យ។ ការយល់ដឹងពីព័ត៌មានទាំង នេះ អាចឱ្យប្រជាពលរដ្ឋឈ្វេងយល់ពីបញ្ហានៅក្នុងសង្គម ឈ្វេងយល់ពីការឆ្លើយតបនឹងតម្រូវការរបស់ខ្លួន និងបានដឹងពីកន្លែងនិងនីតិវិធីក្នុងការទទួលសេវាកម្មនានា។[225] ដើម្បីឈ្វេងយល់ពីបញ្ហានេះនៅក្នុងរាជធានី

[224] (ឧបសម្ព័ន្ធទី៤) ទេព និនរស្មី &វន់ វិបុល, *"បទសម្ភាសជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ"*, ធ្វើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤.

[225] Chanda Chansa Thelma. "Effects of Civic Education on Learners' response to governance tenets: A case of selected secondary schools in Kitwe District of Copperbelt province, Zambia" *GSJ, Vol. 11*(7), 2023, pp. 2320-9186.

ភ្នំពេញ យើងនឹងសិក្សាទៅលើកម្រិតនៃព័ត៌មានដែលប្រជាពលរដ្ឋនៅរាជធានីភ្នំពេញទទួលបាន និងប្រភពផ្លូវការដែលប្រជាពលរដ្ឋបានដឹងនិងស្គាល់។ នៅក្នុងនេះ សំណួរទាំងបីនៃលទ្ធផលការស្ទង់មតិប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញនឹងបង្ហាញពីចំនួនប្រជាពលរដ្ឋ ស្ថិតនៅក្នុងកម្រិតនីមួយៗគឺ ១ដល់៥ ដែល ១មានន័យថាមិនដឹងសោះ និង៥មានន័យថាបានដឹងច្រើន ឬទាំងអស់។

ក្រាហ្វិកទី៥៖ លទ្ធផលកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងផែនការ យុទ្ធសាស្ត្រ និងសកម្មភាព[226]




លទ្ធផលនៃការសិក្សាស្រាវជ្រាវ បានបង្ហាញថាប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញមានការយល់ដឹងពីផែនការ និងយុទ្ធសាស្ត្រនានាក្នុងកម្រិតមធ្យម និងខ្សោយប៉ុណ្ណោះ។ ជាលទ្ធផលប្រជាពលរដ្ឋម្នាក់ក្នុងចំណោមពលរដ្ឋបី(០៣)នាក់មានការយល់ដឹងពីផែនការនានាកម្រិតមធ្យម ហើយបើមើលទៅលើកម្រិតល្អប្រសើរវិញ(កម្រិត៤/៥ និង៥/៥) ក្នុងចំណោមប្រជាពលរដ្ឋដប់(១០)នាក់ គឺមានតែម្នាក់ប៉ុណ្ណោះដែលមានការយល់ដឹងច្រើនទាក់ទងនឹងបញ្ហានេះ។ ប្រជាពលរដ្ឋប្រមាណជា ៤០%មានការយល់ដឹងកម្រិតខ្សោយពីផែនការសកម្មភាព និងយុទ្ធសាស្ត្ររបស់អាជ្ញាធរមូលដ្ឋាន ដែលនេះអាចបង្កជាការលំបាកដល់ប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ក្នុងការចូលរួម ឬទទួលសេវា និងមានការលំបាកចំពោះអាជ្ញាធរក្នុងការផ្តល់សេវា។ ដើម្បីយល់ដឹងពីបញ្ហានេះ ព័ត៌មានដែលបានពីបទសម្ភាសជាមួយនឹងប្រជាពលរដ្ឋបានបង្ហាញថា ក្រៅពីកត្តាសំខាន់ៗទាំងបីខាងលើ មូលហេតុដែលប្រជាពលរដ្ឋពុំអាចទទួលបានព័ត៌មានគ្រប់គ្រាន់នោះគឺ កត្តា

[226] ដកស្រង់ និងកែសម្រួលមកពី៖(ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វ៉ន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

ប្រភពព័ត៌មាន។ លទ្ធផលនៃបទសម្ភាសបានបង្ហាញថាប្រជាពលរដ្ឋបានស្គាល់ប្រភពព័ត៌មានផ្លូវការ នៅក្នុងកម្រិតទាបនៅឡើយ ដោយភាគច្រើនប្រជាពលរដ្ឋបានស្គាល់ និងប្រើប្រាស់ប្រភពព័ត៌មានតែពីរ(០២) ប៉ុណ្ណោះក្នុងការទទួលព័ត៌មាន។

តារាងទី១០៖ ប្រភពព័ត៌មានផ្លូវការដែលប្រជាពលរដ្ឋភាគច្រើនបានស្គាល់[227]

| ប្រភពព័ត៌មាន | លទ្ធផល |
|---|---|
| ការផ្សព្វផ្សាយផ្ទាល់នៅសាលារាជធានី( ក្តារព័ត៌មាន ទូរទស្សន៍ ...) | - |
| គេហទំព័រអ៊ីនធឺណិតសាលារាជធានីភ្នំពេញ (ឬ/និងក្រសួងមហាផ្ទៃ) | - |
| កម្មវិធីផ្តល់ព័ត៌មាន និងសេវា (MOI App និង OWSM Cambodia) | - |
| គេហទំព័រហ្វេសប៊ុក (Facebook Page) | ✓ |
| ប្រភពផ្សេងៗទៀត (Telegram និងសារព័ត៌មាន) | ✓ |

ផ្អែកទៅលើបទសម្ភាសជាមួយប្រជាពលរដ្ឋ ប្រភពព័ត៌មានសំខាន់ៗដែលប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញបានដឹង និងកំពុងតែប្រើប្រាស់មានចំនួនពីរ(០២)គឺ ប្រភពគេហទំព័រហ្វេសប៊ុក(Facebook Page) និងប្រភពតេឡេក្រាម(Telegram)។ ប្រជាពលរដ្ឋពុំបានដឹងពីប្រភពព័ត៌មានផ្លូវការសំខាន់ៗផ្សេងទៀតដូចជាកម្មវិធី(Application) គេហទំព័រអ៊ីនធឺណិត(Website) និងកន្លែងផ្តល់ព័ត៌មានដោយផ្ទាល់នោះទេ ដែលនេះអាចជាផ្នែកមួយធ្វើឱ្យប្រជាពលរដ្ឋខ្វះការចូលរួមសហការ និងជួបការលំបាកក្នុងការបំពេញតម្រូវការនានា។ ដូចនេះយើងអាចសន្និដ្ឋានបានថា ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញពុំសូវបានទទួលព័ត៌មានគ្រប់គ្រាន់ពីផែនការសកម្មភាព និងយុទ្ធសាស្ត្រនានា ដោយសារបញ្ហាពេលវេលា ការចាប់អារម្មណ៍ផ្ទាល់ខ្លួន ភាពចាំបាច់ និងរួមផ្សំជាមួយកង្វះខាតប្រភពព័ត៌មាន។

## ៤.២. ប្រសិទ្ធភាពនៃសេវាសាធារណៈ

នៅក្នុងការសិក្សាស្រាវជ្រាវពីប្រសិទ្ធភាពនៃសេវាសាធារណៈ មធ្យោបាយជាច្រើនត្រូវលើកឡើង ដើម្បីប្រើប្រាស់។ នៅក្នុងនោះការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈ គឺជាសូចនាករមួយដែលការប្រើប្រាស់ច្រើន ដើម្បីឆ្លុះបញ្ចាំងនិងបង្ហាញពីទិដ្ឋភាពទូទៅនៃប្រសិទ្ធភាពនៃការគ្រប់គ្រង និងផ្គត់ផ្គង់សេវាទាំងនោះ។ បើទោះបីជាការពេញចិត្តរបស់ប្រជាពលរដ្ឋអាចផ្លាស់ប្តូរដោយសារកត្តាតម្លៃ ល្បឿន និងភាពងាយស្រួលក្នុងការទទួលសេវាក្តី ការពេញចិត្តជារួមអាចឆ្លើយតប និងបង្ហាញនូវទិដ្ឋភាពនៃប្រសិទ្ធភាពសេវាកម្ម។[228]

[227] (ឧបសម្ព័ន្ធទី៤) ទេព និនរស្មី &វន់ វិបុល, *"បទសម្ភាសជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ"*, ធ្វើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤.

[228] Baredes Barbara. "Serving citizens: Measuring the performance of services for a better user experience" *OECD Working papers on Public Governance*, No.52, 2022.

បន្ថែមពីនេះ មធ្យោបាយនេះក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយផងដែរ នៅក្នុងបណ្ដាប្រទេសនានាទូទាំងពិភពលោក។[229] ដើម្បីសិក្សាពីប្រសិទ្ធភាព និងលក្ខខណ្ឌនៃសេវាសាធារណៈនៅក្នុងរាជធានីភ្នំពេញ មធ្យោបាយសំខាន់ៗពីរ(០២)ត្រូវបានប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវមួយនេះ។ មធ្យោបាយទី១ គឺដូចទៅនឹងបណ្ដាប្រទេសនានារបស់OECDដែរ គឺយើងប្រើប្រាស់ការពេញចិត្តរបស់ប្រជាពលរដ្ឋដែលបានទទួលសេវាដើម្បីបង្ហាញអំពីប្រសិទ្ធភាពនៃការឆ្លើយតប រីឯមធ្យោបាយទី២គឺយើងប្រើប្រាស់ទស្សនៈអន្តរកម្មសង្គមដែលសិក្សាខាងលើមកបង្ហាញពីស្ថានភាព និងកត្តាពាក់ព័ន្ធផ្សេងៗមួយចំនួនទៀត។

### ៤.២.១. ការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈ

ការពេញចិត្តរបស់ប្រជាពលរដ្ឋ គឺជាលទ្ធផលនៃប្រសិទ្ធភាពសេវាសាធារណៈ ដោយសារការពេញចិត្តរបស់ប្រជាពលរដ្ឋកើនឡើង ឬធ្លាក់ចុះ អាស្រ័យនឹងការឆ្លើយតបនៃសេវានីមួយៗ។ ដើម្បីបង្ហាញថាទស្សនៈខាងលើនេះមានភាពត្រឹមត្រូវនៅក្នុងស្ថានភាពសង្គមរាជធានីភ្នំពេញ ករណីសិក្សានៃបទសម្ភាសជាមួយប្រជាពលរដ្ឋនៃរាជធានីភ្នំពេញនឹងបង្ហាញពីទំនាក់ទំនងនេះ។ យោងទៅតាមបទសម្ភាសជាមួយប្រជាពលរដ្ឋ ប្រជាពលរដ្ឋទាំងពីររូបទើបនឹងទទួលប្រើប្រាស់សេវាសាធារណៈក្នុងកំឡុងពេលប្រាំមួយ(០៦)ខែចុងក្រោយនេះប៉ុណ្ណោះ(២០២៤) ដូចនេះលទ្ធផលរបស់ពួកគេនឹងបង្ហាញពីស្ថានភាពជាក់ស្ដែងចុងក្រោយបង្អស់នៃទំនាក់ទំនងនេះ។

នៅក្នុងវាយតម្លៃពី ១-ដល់៥- ដែល១-មានន័យថាមិនពេញចិត្តសោះ និង៥-មានន័យថាពេញចិត្តខ្លាំង ប្រជាពលរដ្ឋទាំងពីររូបឱ្យតម្លៃការផ្ដល់សេវា៣- និង៤-។ មូលហេតុដែលការពេញចិត្តត្រឹមតែ៣- ឬ៤- គឺប្រជាពលរដ្ឋទាំងពីរ(០២)រូបបានជួបប្រទះនូវបញ្ហាមួយចំនួនក្នុងពេលទទួលសេវា ដូចជាកំហុសបច្ចេកទេស និងភាពតឹងរឹងនៃសេវា។ នេះបានបង្ហាញថាប្រសិទ្ធភាពនៃសេវាដែលផ្ដត់ផ្គង់មិនបានត្រូវនឹងតម្រូវការ និងការរំពឹងទុកទាំងស្រុងទើបការវាយតម្លៃមិនបានពេញ(៥/៥)។[230] ដូចនេះយើងអាចសន្និដ្ឋានបានថា ការពេញចិត្តរបស់ប្រជាពលរដ្ឋគឺពិតជាបង្ហាញពីប្រសិទ្ធភាពនៃសាធារណៈពិតមែន ហើយដើម្បីបង្ហាញពីប្រសិទ្ធភាពនៃសេវាសាធារណៈរបស់រាជធានីភ្នំពេញលទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋនឹងត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញពីបញ្ហានេះ។

លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋបានបង្ហាញថាប្រជាពលរដ្ឋនៃរាជធានីភ្នំពេញ ដែលបានទទួលសេវាសាធារណៈក្នុងពេលប្រាំមួយ(៦)ខែចុងក្រោយនេះ ភាគច្រើនមានការពេញចិត្តកម្រិតមធ្យមចំពោះសេវា

[229] OECD. *Building trust to reinforce democracy: Main findings from the 2021 OECD survey on drivers of trust in public institutions*. OECD Publishing, 2022.

[230] (ឧបសម្ព័ន្ធទី៤) ទេព និនរស្មី &វ៉ន់ វិបុល, *"បទសម្ភាសជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ"*, ធ្វើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤.

សាធារណៈ(៣/៥)។ ចំណែកឯប្រជាពលរដ្ឋដែលមានការពេញចិត្តខ្លាំង(៤/៥ និង៥/៥)វិញគឺមានចំនួនប្រមាណជា៣៨% និងប្រជាពលរដ្ឋដែលពុំសូវមានការពេញចិត្ត(១/៥ និង២/៥)មានត្រឹមតែ២៤.៤% ប៉ុណ្ណោះ។ នេះបង្ហាញថា ការពេញចិត្តរបស់ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញភាគច្រើនស្ថិតនៅក្នុងចំណុចមធ្យមទៅល្អប្រសើរ ដែលចំនួនមានលើសពី៧០% នៃចំនួនប្រជាពលរដ្ឋសរុប។

ក្រាហ្វិកទី៦៖ លទ្ធផលកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាសាធារណៈ[231]




ដើម្បីសន្និដ្ឋានពីប្រសិទ្ធភាពនៃការផ្តត់ផ្គង់សេវានេះ យើងសម្រេចយកចំណុចមធ្យមនៃការឱ្យតម្លៃមកបង្ហាញ។ ជាមធ្យមកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋស្ថិតនៅក្នុងចំណុចការពេញចិត្តមធ្យមទៅការពេញចិត្តខ្លាំង(៣.២/៥) ដែលតួរលេខនេះបានបង្ហាញថាប្រសិទ្ធភាពនៃសេវាសាធារណៈមានលទ្ធផលល្អ ប៉ុន្តែមានចំណុចខ្លះគួរពង្រឹង និងកែប្រែបន្ថែមទៀត។

### ៤.២.២. ស្ថានភាពនៃសេវាសាធារណៈតាមលក្ខខណ្ឌអន្តរកម្ម

យោងទៅតាមបំណកស្រាយនៃអន្តរកម្មរវាងប្រជាពលរដ្ឋនិងមន្ត្រីសាធារណៈខាងលើ រួមជាមួយនឹងភស្តុតាងដែលបានលើកឡើង យើងអាចសន្និដ្ឋានបានថាកត្តាដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃសេវាសាធារណៈគឺ កត្តាអ្នកទទួលសេវា និងកត្តាអ្នកផ្តត់ផ្គង់សេវា។ នៅក្នុងការសិក្សាមួយនេះ កត្តាអ្នកទទួល

[231] ដកស្រង់ និងកែសម្រួលមកពី៖(ឧបសម្ព័ន្ធទី៥) ទេព និនរស្មី &វន់ វិបុល, *"លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤"*, ២០២៤.

សេវាមានឥទ្ធិពលទៅលើសាំញ៉ាំនៃសេវាសាធារណៈ ពោលបើអ្នកទទួលសេវាមានការយល់ដឹងច្បាស់ពីលក្ខខណ្ឌតម្រូវការ កន្លែងទទួលសេវា ទំនួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន នោះលទ្ធផលគឺមានភាពសាមញ្ញ ផ្ទុយទៅវិញបើអ្នកទទួលសេវាគ្មានលក្ខខណ្ឌទាំងនេះទេ ឬមានតិចតួច នោះលទ្ធផលគឺមានភាពស្មុគស្មាញ។ ចំពោះលក្ខខណ្ឌរបស់អ្នកផ្តល់សេវាវិញ ប្រសិនបើអ្នកផ្តល់សេវាមិនមានរៀបចំរចនាសម្ព័ន្ធ ពេលវេលានៃការឆ្លើយតប និងព័ត៌មានពីសេវាផ្គត់ផ្គង់បានត្រឹមត្រូវនោះទេ លទ្ធផលគឺមានភាពលំបាក។ បើផ្ទុយពីលក្ខខណ្ឌនេះ លទ្ធផលគឺមានភាពងាយស្រួល។

រូបភាពទី៩៖ គំនូសតាងអន្តរកម្មរវាងអ្នកទទួលសេវា និងអ្នកផ្តល់សេវា




យោងទៅតាមគំនូសតាងនៃទំនាក់ទំនងអន្តរកម្មរវាងអ្នកផ្តល់សេវានេះ យើងអាចប្រើប្រាស់ព័ត៌មានខាងលើ ដើម្បីបង្ហាញពីប្រសិទ្ធភាពនៃសេវាសាធារណៈនៅរាជធានីភ្នំពេញបាន។ យោងទៅតាមព័ត៌មាននៃជំពូកទី២ យើងអាចសន្និដ្ឋានបានថាសាលារាជធានីភ្នំពេញមានរចនាសម្ព័ន្ធច្បាស់លាស់ រួមជាមួយនឹងខ្សែគណនេយ្យភាពត្រឹមត្រូវល្អ ក្រៅពីនេះការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក៏មានលក្ខណៈល្អប្រសើរដែរដូចដែលបានបង្ហាញនៅខាងលើ។ ដូចនេះយើងអាចសន្និដ្ឋានបានថាអ្នកផ្តល់សេវាសាធារណៈ (សាលារាជធានីភ្នំពេញ)ស្ថិតនៅក្នុងចំណុចដែលមានភាពងាយស្រួល។ ចំពោះអ្នកទទួលសេវាវិញ យើងអាចសន្និដ្ឋានថាស្ថិតនៅក្នុងចំណុចស្មុគស្មាញ បើទោះបីជាស្ថានភាពប្រជាពលរដ្ឋស្ថិតនៅក្នុងចំណុចមធ្យមក៏ដោយ ប៉ុន្តែកម្រិតនៃការយល់ដឹងទាក់ទងនឹងប្រព័ន្ធរដ្ឋបាល និងផែនការយុទ្ធសាស្ត្រនៅមានភាពខ្វះខាតច្រើននៅឡើយ។ អាស្រ័យហេតុនេះ ប្រសិទ្ធភាពនៃសេវាសាធារណៈនៅរាជធានីភ្នំពេញស្ថិតនៅក្នុងចំណុចស្មុគស្មាញ និងងាយស្រួល (២/៣)។ ដើម្បីពង្រឹងស្ថានភាពនេះឱ្យខិតទៅរកភាពសាមញ្ញ និងងាយស្រួល ការចូលរួមសហការរវាងតួអង្គពាក់ព័ន្ធគឺពុំអាចខ្វះបានឡើយ។

## ៤.៣. ការវាយតម្លៃទៅលើការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ

ព័ត៌មាននៃការសិក្សាស្វែងយល់អំពីការគ្រប់គ្រងសាលារាជធានីភ្នំពេញ រួមផ្សំជាមួយនឹងព័ត៌មានផ្សេងៗទៀតដូចជាសមិទ្ធផល ការឆ្លើយតបនឹងតម្រូវការ និងប្រសិទ្ធភាពសេវាសាធារណៈ អាចអនុញ្ញាតឱ្យយើងធ្វើការសិក្សា និងវិភាគទៅលើប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញក្នុងឆ្នាំ២០២៤បាន ដោយផ្អែកតាមលក្ខខណ្ឌមួយចំនួនដែលបានសិក្សានេះ។ ការសិក្សា និងវាយតម្លៃទៅលើការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញនេះ នឹងគិតគូរទៅលើចំណុចសំខាន់ៗចំនួន៣គឺ ចំណុចខ្លាំង ចំណុចគួរបំពេញបន្ថែម និងការប្រឈម។

យោងទៅតាមព័ត៌មានដែលមានបកស្រាយនៅក្នុងអត្ថបទនេះយើងអាចសន្និដ្ឋានបានថាការគ្រប់គ្រងសាលារាជធានីភ្នំពេញមានលក្ខណៈដូចខាងក្រោម៖

ក្រាហ្វិកទី៧៖ លក្ខណៈសម្បត្តិនៃការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ(២០២៤)




អង្គភាព ឬស្ថាប័នគឺជាបណ្តុំនៃមនុស្សដែលមានរៀបចំគោលដៅ រចនាសម្ព័ន្ធ ផែនការសកម្មភាព និងមានទំនាក់ទំនងជាមួយបរិស្ថានខាងក្រៅ។[232] លក្ខណៈពិសេសនៃស្ថាប័នសាធារណៈដូចជាស្ថាប័នរដ្ឋគឺការគ្រប់គ្រងដោយផ្តោតទៅលើការគ្រប់គ្រងផ្តល់សេវាក្នុងវិធីសាស្ត្រមួយដែលចំណាយតិចបំផុតជាមុននឹង

[232] Richard L. Daft. *Organizational Theory and Design (10th ed.)*. Cengage Learning, 2010.

គុណភាពដែលប្រសើរបំផុតតាមដែលអាចធ្វើបាន។[233] នៅក្នុងការសិក្សាជាច្រើនពីអតីតកាល និងបច្ចុប្បន្ន របស់ប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ស្ថាប័នសាធារណៈមួយដែលមានលក្ខណៈរឹងមាំលុះត្រាតែបានបំពេញនូវធាតុសំខាន់ចំនួនបីដែលមិនអាចខ្វះបាន ដែលធាតុទាំងនោះរួមមាន(១)ឋានានុក្រម (២)រចនាសម្ព័ន្ធការងារ និង(៣)របៀបរបបការងារ។ ធាតុទាំងបីនេះគឺត្រូវមានជាចាំបាច់នៅក្នុងកិច្ចគ្រប់គ្រងស្ថាប័នសាធារណៈ ដោយហេតុស្ថាប័នសាធារណៈត្រូវបម្រើកិច្ចការច្រើនវិស័យ។ នៅក្នុងន័យនេះ ឋានានុក្រមសំដៅទៅដល់ការកំណត់តួនាទី សមាសភាព និងភារកិច្ច ដែលមានលក្ខណៈពីលើចុះក្រោម(Vertical level) ដើម្បីបង្កើតជាខ្សែគណនេយ្យភាពមួយដែលមានភាពច្បាស់លាស់ក្នុងកិច្ចដំណើរការសកម្មភាពរបស់ខ្លួន។[234] យោងទៅតាមទស្សនៈទាំងនេះ សាលារាជធានីភ្នំពេញបានបំពេញលក្ខណៈយ៉ាងល្អប្រសើរ ដើម្បីគ្រប់គ្រង និងផ្តត់ផ្គង់សេវាសាធារណៈ។ នៅក្នុងកិច្ចការសិក្សាស្រាវជ្រាវរបស់យើងសាលារាជធានីភ្នំពេញបានបំពេញលក្ខណៈឋានានុក្រមដោយការរៀបចំឱ្យមានតួនាទី សមាសភាព ភារកិច្ច និងខ្សែគណនេយ្យភាពច្បាស់លាស់មួយគឺ (១)គណនេយ្យភាពពីក្រោមឡើងលើ (២)គណនេយ្យភាពពីលើចុះក្រោម និង(៣)គណនេយ្យភាពផ្ទៃក្នុង។[235] ក្រៅពីនេះ សាលារាជធានីភ្នំពេញបានបំពេញលក្ខណៈសម្បត្តិទី២ ដែលស្តីពីការកំណត់រចនាសម្ព័ន្ធការងារផងដែរ។ ក្នុងន័យការកំណត់រចនាសម្ព័ន្ធការងារ(Division of labour)សំដៅទៅដល់ការបែងចែកការងារច្បាស់លាស់មួយ ដើម្បីបម្រើសេវាកម្មរបស់ខ្លួន ដែលមានលក្ខណៈអន្តរវិស័យ ឬច្រើនវិស័យ។ សាលារាជធានីភ្នំពេញបានរៀបចំឱ្យមានទីចាត់ការ និងអង្គភាពចំនួន១២ ដាច់ដោយឡែកពីគ្នា[236] ដើម្បីបម្រើការទៅលើកិច្ចផ្សេងៗគ្នា ក្រោមការដឹកនាំរបស់នាយករដ្ឋបាល ដែលជាតួរអង្គត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលរាជធានី និងក្រុមប្រឹក្សារាជធានី។[237] ការកំណត់បែងចែកការងារដាច់ដោយឡែកពីគ្នា និងមិនឱ្យមានការជាន់ដែនសមត្ថកិច្ចគ្នានេះអនុញ្ញាតឱ្យទីចាត់ការ និងអង្គភាពនីមួយៗដំណើរការបានយ៉ាងរលូន។ បន្ថែមពីនេះទៅទៀតសាលារាជធានីក៏មានរបៀបរបបការងារមួយយ៉ាងច្បាស់លាស់ផងដែរ ដែលដំណើរការនៃការគ្រប់គ្រងទាំងនោះត្រូវអនុវត្តទៅតាមសៀវភៅណែនាំ ស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ យោងតាមអំណះអំណាងទាំងអស់នេះ សាលារាជធានីភ្នំពេញអាចសន្និដ្ឋានបានថា ជាស្ថាប័នសាធារណៈមួយ ដែលមានលក្ខណៈរចនាសម្ព័ន្ធរឹងមាំ និងល្អប្រសើរនៅក្នុងការបម្រើ ក៏ដូចជាការផ្តល់សេវាកម្ម

[233] Christine W. Letts, William P. Ryan, & Allen Grossman. *High performance nonprofit organizations (1st ed.).* John Wiley &Sons, Inc., 1999.

[234] Tom Christensen, Per Laegreid, Paul G. Roness, &Kjell Arne Rovik. *Organization theory and the public sector: Instrument, culture and myth.* Routledge Taylor & Francis Group, 2007.

[235] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ,* ២០១៩, ទំព័រ ៤៥-៤៧.

[236] (ឧបសម្ព័ន្ធទី១១) វណ្ណា សុវិទូ, រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ, ២០២៤.

[237] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

ដល់ប្រជាពលរដ្ឋមូលដ្ឋាន(៥/៥)។

ចំពោះកិច្ចការដ៏សំខាន់មួយទៀតនោះគឺ ការរៀបចំផែនការសកម្មភាព ដែលការគ្រប់គ្រងរៀបចំផែនការនេះបានល្អនឹងជំរុញ ក៏ដូចជាបង្កើតទម្លាប់មួយដ៏ល្អប្រសើរចំពោះមន្ត្រីសាធារណៈ។ នៅក្នុងការសិក្សាសម័យកាលទំនើប ឬសម័យកាលបច្ចុប្បន្ននេះ បានបង្ហាញថាការប្រើប្រាស់ធនធានមិនបានត្រឹមត្រូវ និងធ្វើឱ្យខូចខាតដល់ការប្រព្រឹត្តទៅនៃអង្គភាពទាំងមូល។ ផ្ទុយទៅវិញការប្រើប្រាស់ធនធានទាំងនេះបានល្អនឹងពង្រីកសក្តានុពលនៃការគ្រប់គ្រងស្ថាប័នសាធារណៈ បន្ថែមពីនេះធនធានដែលកំណត់នៅក្នុងការសិក្សានោះរួមមានធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យា។[238] ការរីកចម្រើននៃបច្ចេកវិទ្យានៅក្នុងសម័យកាលចុងក្រោយនេះបានបង្កើតឱកាសក្នុងការបំពេញបន្ថែមជាច្រើន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកិច្ចការគ្រប់គ្រងនានា ជាពិសេសនៅក្នុងវិស័យរដ្ឋបាលសាធារណៈ។[239] ធៀបមករាជធានីភ្នំពេញយើងសង្កេតឃើញមានការប្រើប្រាស់បច្ចេកវិទ្យាជាច្រើននៅក្នុងការឆ្លើយតប និងកំណែទម្រង់នានា ដែលការប្រើប្រាស់ប្រព័ន្ធឌីជីថលនេះត្រូវបានកំណត់ជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំងប្រាំមួយនៃផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ ២០២៤-២០២៨ផងដែរ។ នេះបង្ហាញពីការគិតគូររៀបចំប្រើប្រាស់ធនធានឱ្យកម្រិតអតិបរមា ឬចំណុចល្អប្រសើរបំផុតតាមដែលអាចធ្វើបាន បន្ថែមពីនេះយោងតាមការសិក្សាខាងលើនេះអំពីកម្រិតនៃការយល់ដឹងរបស់មន្ត្រីចំពោះប្រជាពលរដ្ឋ យើងសង្កេតឃើញថារដ្ឋបាលមូលដ្ឋាន ក៏ដូចជាក្រសួងស្ថាប័នពាក់ព័ន្ធបានគិតគូរ និងរៀបចំផែនការយ៉ាងល្អប្រសើរ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋទាំងលក្ខខណ្ឌតម្រូវការច្រើន និងតម្រូវការតិច។ យោងទៅតាមផែនការនៃការប្រើប្រាស់ធនធានឱ្យបានល្អប្រសើរ និងផែនការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ សាលារាជធានីអាចសន្និដ្ឋានបានថាបានបំពេញយ៉ាងល្អប្រសើរចំពោះការរៀបចំផែនការសកម្មភាពរបស់ខ្លួន(៥/៥)។

បើទោះបីការរៀបចំឱ្យមានផែនការសកម្មភាព និងរចនាសម្ព័ន្ធរឹងមាំគឺជាលក្ខខណ្ឌគ្រឹះសម្រាប់គ្រឹះស្ថានសាធារណៈក៏ដោយ ប្រសិទ្ធភាពនៃការអនុវត្តគឺជាលក្ខខណ្ឌមួយដែលមិនអាចខ្វះបាននៅក្នុងការសិក្សាវាយតម្លៃនានា ដោយហេតុប្រសិទ្ធភាពនៃសេវាសាធារណៈនេះគឺជាចំណុចមួយដែលបង្ហាញពីគុណភាពនៃការរៀបចំផែនការសកម្មភាពនានារបស់ស្ថាប័ននីមួយៗ។ យោងតាមការសិក្សាដែលបានលើកឡើងខាងលើ ប្រសិទ្ធភាពនៃការអនុវត្ត ឬការផ្តត់ផ្គង់សេវានានា អាចកំណត់បានដោយការពេញចិត្តរបស់អ្នក

[238] Erock Taptuk Emre. "Efficiency of public sector organizations: Perspectives from theories of Bureaucracy" *MPRA Paper*, No.49386, 2013.
[239] Tom Christensen, Per Laegreid, Paul G. Roness, &Kjell Arne Rovik. *Organization theory and the public sector: Instrument, culture and myth.* Routledge Taylor & Francis Group, 2007.

ទទួលសេវា ពីព្រោះកាលណាសេវាបានឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទទួលសេវា នោះការពេញចិត្តរបស់អ្នកទទួលសេវានឹងកើនឡើង។ បន្ថែមពីនេះ ករណីសិក្សារបស់ស្ថាប័នឯកជនក៏អាចបង្ហាញពីទំនាក់ទំនងនេះផងដែរ ដូចជាការសិក្សានៅប្រទេសឥណ្ឌាដែលបង្ហាញថា កត្តាសំខាន់មួយចំនួនដែលធ្វើឱ្យការពេញចិត្តរបស់អ្នកទទួលសេវាធ្លាក់ចុះគឺ ល្បឿននៃសេវា គណនេយ្យភាពបុគ្គលិក គុណភាពនៃផលិតផល ឬសេវា និងអាកប្បកិរិយារបស់អ្នកផ្តល់សេវា។[240] បើធៀបទៅនឹងការសិក្សាខាងលើ ទស្សនៈនេះអាចសន្និដ្ឋានបានថា ទំនាក់ទំនងរវាងអ្នកផ្គត់ផ្គង់ និងអ្នកទទួលសេវានៅក្នុងក្របខណ្ឌសាធារណៈរបស់រាជធានីភ្នំពេញពិតជាមានលក្ខណៈដូចគ្នានឹងការសិក្សានេះពិតមែន។ យោងទៅតាមលទ្ធផលនេះ សាលារាជធានីភ្នំពេញអាចសន្និដ្ឋានបានថា ស្ថិតនៅក្នុងចំណុចមធ្យមចំពោះការអនុវត្តសកម្មភាពរបស់ខ្លួន(៣.២/៥)។

ចំពោះចំណុចសំខាន់ចុងក្រោយនៃការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញវិញ គឺការគ្រប់គ្រងហានិភ័យ។ នៅក្នុងការសិក្សាស្រាវជ្រាវ នៅពេលដែលស្ថាប័នមួយបានដឹងពីបញ្ហាប្រឈមដែលខ្លួនអាចជួបប្រទះនៅក្នុងពេលខាងមុខ សកម្មភាព និងការប្រព្រឹត្តទៅរបស់ស្ថាប័ននោះនឹងមានភាពល្អប្រសើរជាងមុន ដោយហេតុថាស្ថាប័នទាំងនោះ អាចធ្វើការសិក្សាស៊ីជម្រៅទៅលើហានិភ័យទាំងនោះ និងស្វែងរកមធ្យោបាយនានា ដើម្បីកាត់បន្ថយកម្រិតនៃហានិភ័យ និងពង្រឹងគុណភាពនៃសេវាដែលខ្លួនផ្គត់ផ្គង់តាមរយៈការប្រើប្រាស់ធនធានឱ្យបានល្អ និងការប្រើប្រាស់បច្ចេកវិទ្យានានា។[241] ដោយយោងទៅតាមបទសម្ភាសជាមួយមន្ត្រីជំនាញនៃសាលារាជធានីភ្នំពេញធៀបទៅនឹងករណីសិក្សានៅក្នុងប្រទេសមួយចំនួនដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងស្ថានភាពប្រទេសកម្ពុជា ដូចជាប្រទេសអូស្ត្រាលី រដ្ឋបាលសាលារាជធានីភ្នំពេញបាននឹងកំពុងជួប និងអាចនឹងបន្តជួបប្រទះបញ្ហាប្រឈមសំខាន់ចំនួនពីរគឺ បញ្ហាធនធានមនុស្ស និងបញ្ហាការយល់ដឹងរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ បន្ទាប់ពីធ្វើការសិក្សានឹងវិភាគទៅលើបញ្ហានេះ យើងសង្កេតឃើញថា កត្តាទាំងពីរនេះពិតជាចំណុច ដែលគួរឱ្យយកចិត្តទុកដាក់ពិតប្រាកដមែន ដូចនេះយើងអាចសន្និដ្ឋានបាន ការគ្រប់គ្រងហានិភ័យរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ គឺស្ថិតនៅក្នុងចំណុចមួយល្អប្រសើរ(៥/៥)។ លទ្ធផលនេះមានន័យថា សាលារាជធានីភ្នំពេញនឹងមានឱកាស និងពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនប្រឈមនឹងបញ្ហាទាំងនោះ។

ផ្អែកទៅតាមបំណកស្រាយ និងការសិក្សាខាងលើនេះ សាលារាជធានីភ្នំពេញអាចសន្និដ្ឋានបានថា ជាស្ថាប័នមួយដែលលក្ខណៈល្អប្រសើរគិតត្រឹមក្នុងឆ្នាំ២០២៤នេះ ដែលនៅក្នុងនោះសាលារាជធានីភ្នំពេញមានភាពខ្លាំងចំនួនបីគឺ ការរៀបចំរចនាសម្ព័ន្ធ ការរៀបចំផែនការសកម្មភាព និងការគ្រប់គ្រងហានិភ័យ។ ក្រៅ

[240] Mohammed Wamique Hisam, Shouvik Sanyal, Moinuddin Ahmad. "The Impact of Service Quality on Customer Satisfaction: A Study on Selected Retail Stores in India" *International Review of Management and Marketing, 6*(4),2016, 851-856.
[241] Emily R. Johnson. "The Significance of Challenge Awareness in Organizational Change" *Journal of Management Studies, Vol.5*, No.2, 2019, pp. 15-34.

ពីនេះ សាលារាជធានីភ្នំពេញមានកន្លែង ដែលគួរបំពេញបន្ថែមមួយ គឺការពង្រឹងការអនុវត្តរបស់ខ្លួន ដោយហេតុលក្ខណៈសម្បត្តិនេះស្ថិតនៅក្នុងកម្រិតមធ្យមនៅឡើយ។ កម្រិតនៃការអនុវត្តនេះអាចទទួលរងឥទ្ធពលពីតួរអង្គពាក់ព័ន្ធមានអ្នកផ្តល់សេវា និងអ្នកទទួលសេវា ហេតុនេះនៅក្នុងការពង្រឹងលក្ខណៈសម្បត្តិមួយនេះ ការគិតគូរ និងសិក្សាស៊ីជម្រៅឱ្យបានច្បាស់ចំពោះស្ថានភាព និងករណីនីមួយៗគឺចាំបាច់ណាស់។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃអស់រយៈពេល២ទសវត្សរ៍ជាងមក ប្រទេសកម្ពុជាទីបំផុតទទួលបានឯករាជ្យពេញលេញនៅក្នុងសម័យកាលព្រះរាជាណាចក្រកម្ពុជាទី២ ដែលចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៣ រហូតមកដល់ពេលបច្ចុប្បន្ន។ បើទោះបីជាប្រទេសនេះទទួលបានឯករាជ្យពេញលេញហើយក្តី ការដឹកនាំគ្រប់គ្រងប្រទេសកម្ពុជាឱ្យមានភាពល្អមិនមែនជារឿងងាយស្រួលនោះទេ ពោលប្រទេសនេះត្រូវដោះស្រាយបញ្ហាដ៏ស្មុគស្មាញជាច្រើននៅគ្រប់វិស័យទាំងអស់ ដែលបញ្ហាទាំងនេះគឺជាស្នាដៃ ដែលសម័យកាលមុនៗបន្សល់ទុកមក ជាពិសេសគឺសម័យកាលកម្ពុជាប្រជាធិបតេយ្យ(សម័យប៉ុល ពត) ដែលជាសម័យកាលដ៏ខ្មៅងងឹតមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា។

នៅក្នុងការដោះស្រាយបញ្ហាដ៏ស្មុគស្មាញទាំងនេះ រដ្ឋបាលសាធារណៈត្រូវបានកំណត់សម្គាល់ថាជាកូនសោមួយ ដែលមិនអាចខ្វះ។ សិក្សាទៅលើករណីសិក្សា និងបទពិសោធន៍នៅតាមបណ្តាប្រទេសនានាទូរទាំងពិភពលោក យើងសង្កេតឃើញថាកិច្ចការគ្រប់គ្រងរដ្ឋបាលសាធារណៈនេះ មានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងប្រទេសនីមួយៗ មិនថាជាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍។ រដ្ឋបាលសាធារណៈត្រូវបានកំណត់បែងចែកចេញជាច្រើនសណ្ឋានថ្នាក់ ដែលនៅក្នុងនោះយើងខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅទៅលើប្រព័ន្ធមួយនេះ ការសិក្សាស្រាវជ្រាវអំពី "ការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០២៣-២០២៤" គឺជាប្រធានបទមួយដែលសាកសមបំផុតសម្រាប់ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន។ នៅក្នុងការសិក្សានេះ ចំណុចសំខាន់ចំនួនបួនត្រូវកំណត់ ដែលចំណុចសំខាន់ទាំងបួនត្រូវបានបែងចែកជាជំពូក ដើម្បីភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ។ ជំពូកទាំងបួនមានគោលបំណងឆ្លុះបញ្ចាំងអំពី (១)បម្រែបម្រួលនៃការគ្រប់គ្រងរដ្ឋបាលពីមួយសម័យកាលទៅមួយសម័យកាល និងប្រព័ន្ធដែលមានប្រើប្រាស់នៅក្នុងបរិបទប្រទេសកម្ពុជា (២)ការរៀបចំគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ-ទិដ្ឋភាពទូទៅ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច (៣)លទ្ធផលនៃការគ្រប់គ្រងតាមប្រព័ន្ធរដ្ឋបាលបច្ចុប្បន្នតាមរយៈសមិទ្ធផលដែលសម្រេចបាន និង(៤)ស្ថានភាពរបស់សង្គម ដែលឆ្លុះបញ្ចាំងពីកម្រិតនៃការយល់ដឹង និងការឆ្លើយតបរវាងប្រជាពលរដ្ឋនឹងមន្ត្រីមូលដ្ឋាន រួមទាំងភាពខ្លាំងនិងខ្វះខាតនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនេះ។

ប្រព័ន្ធរដ្ឋបាលរបស់ប្រទេសកម្ពុជាមានការប្រែប្រួលខ្លាំងចំនួនបីដង ដែលវាត្រូវបានបែងចែកជា៣ដំណាក់កាលនៃការប្រែប្រួលគឺ មុនសម័យបារាំង នៅសម័យបារាំង និងក្រោយសម័យបារាំង។ នៅក្នុងនោះ យើងសង្កេតឃើញថា ការប្រែប្រួលនៅក្រោយសម័យបារាំងបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើដំណើរការនៃកិច្ច

គ្រប់គ្រងរដ្ឋបាលនៅក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធរដ្ឋបាលបីដែលមានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជារួមមាន ប្រព័ន្ធមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ ដែលបច្ចុប្បន្នប្រព័ន្ធមជ្ឈការលែងត្រូវបានប្រើប្រាស់ហើយ។ ផ្ទុយទៅវិញសហត្ថិភាពរវាងវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានប្រើប្រាស់យ៉ាងសកម្មនៅក្នុងពេលបច្ចុប្បន្ន ជាពិសេសនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាថ្នាក់មួយក្នុងចំណោមថ្នាក់ទាំងពីរនៃប្រព័ន្ធរបស់ប្រទេសកម្ពុជា។

នៅក្នុងកិច្ចគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ ដែលជារាជធានីតែមួយគត់របស់ប្រទេសកម្ពុជា ការគ្រប់គ្រងរៀបចំចាំបាច់ត្រូវតែពិចារណាទៅលើកត្តាធំៗមួយចំនួនដូចជា ភូមិសាស្ត្រ អាកាសធាតុ ប្រជាសាស្ត្រ និងសេដ្ឋកិច្ច ដើម្បីឱ្យការគ្រប់គ្រងដឹកនាំធ្វើឡើងប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងតំបន់រដ្ឋបាលដ៏សំខាន់មួយនេះត្រូវបានកំណត់បែងចែកជាខណ្ឌនិងសង្កាត់ ដែលខណ្ឌនិងសង្កាត់នេះត្រូវបានដឹកនាំដោយរដ្ឋបាលសាលារាជធានីភ្នំពេញ ក្រោមគំរូប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ។ ការដឹកនាំសាលារាជធានីភ្នំពេញត្រូវបានកំណត់បែងចែកជាតួនាទី ភារកិច្ច និងខ្សែគណនេយ្យភាពយ៉ាងច្បាស់លាស់ ដែលក្នុងនោះតួរអង្គសំខាន់ៗមាន ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ គណៈកម្មាធិការនានា និងនាយករដ្ឋបាល។ ចំពោះការរៀបចំក្រោមនាយករដ្ឋបាលនៃសាលារាជធានីភ្នំពេញរួមមានទីចាត់ការ និងការិយាល័យ ដែលខ្សែគណនេយ្យភាពនៅក្នុងនោះមានទម្រង់ពីក្រោមទៅលើ ឬពីថ្នាក់ទាបទៅថ្នាក់ខ្ពស់។

ការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញតាមបែបថ្មីនេះបានសម្រេចនូវសមិទ្ធផលជាច្រើន ដែលវាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ និងសុខុមាលភាពសង្គមនៃរាជធានីភ្នំពេញ។ នៅក្នុងសមិទ្ធផលធំៗមួយចំនួននៅក្នុងឆ្នាំ២០២៣-២០២៤ គួរឱ្យកត់សម្គាល់មានដូចជា ការផ្តត់ផ្គង់សេវារដ្ឋបាលទៅលើវិស័យទាំង១៤ ការអភិវឌ្ឍធនធានមនុស្ស(មន្ត្រីសាលារាជធានី) ការរក្សាសណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការរៀបចំរចនាសម្ព័ន្ធរាជធានីភ្នំពេញទៅតាមប្លង់គោល ការគិតគូរទៅលើវិស័យចរាចរណ៍ និងការពិចារណាចំពោះបញ្ហាប្រឈមដែលពាក់ព័ន្ធ។ លទ្ធផលនេះបានបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តរបស់សាលារាជធានីភ្នំពេញទៅតាមកំណែទម្រង់រដ្ឋបាលថ្មីនេះ។

ដើម្បីសិក្សាឱ្យកាន់តែស៊ីជម្រៅទៅលើកិច្ចការគ្រប់គ្រងមួយនេះ យើងបានធ្វើការសិក្សាស៊ីជម្រៅទៅលើទំនាក់ទំនងរវាងមន្ត្រីមូលដ្ឋាននឹងប្រជាពលរដ្ឋ នៅក្នុងគោលបំណងឈ្វេងយល់ពីកម្រិតនៃការយល់ដឹង និងការឆ្លើយតបចំពោះគ្នាទៅវិញទៅមក។ ជាលទ្ធផលយើងសង្កេតឃើញថា គម្លាតអន្តរកម្មរបស់សង្គមនៃរាជធានីភ្នំពេញគឺមិនមានលំនឹងនោះទេ ពោលគឺប្រជាពលរដ្ឋពុំសូវបានយល់ដឹងពីមន្ត្រី ឬកិច្ចការគ្រប់គ្រងរដ្ឋបាលឡើយ ដែលនេះអាចបង្កជាការលំបាកដល់មន្ត្រី និងប្រជាពលរដ្ឋសាមីក្នុងការប្រើប្រាស់សេវានានា។ បន្ថែមពីនេះ ឥទ្ធិពលនៃបញ្ហានេះអាចនឹងមានផលប៉ះពាល់ដល់ប្រសិទ្ធភាពនៃសេវាសាធារណៈផងដែរ នេះ

អាចជាផ្នែកមួយនៃមូលហេតុដែលប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញមានការពេញចិត្តកម្រិតមធ្យមចំពោះសេវាសាធារណៈ។ បន្ថែមពីនេះ យើងបានធ្វើការវាស់ស្ទង់ប្រសិទ្ធភាពរបស់សេវាសាធារណៈតាមមធ្យោបាយរបស់OECD គឺតាមរយៈការពេញចិត្តរបស់ប្រជាពលរដ្ឋ និងធ្វើការវាយតម្លៃទៅលើកិច្ចការគ្រប់គ្រងសាលារាជធានីភ្នំពេញតាមរយៈទស្សនៈ និងទ្រឹស្តីពាក់ព័ន្ធ។ ជាលទ្ធផល សាលរាជធានីភ្នំពេញមានចំណុចខ្លាំងច្រើនជាងចំណុចខ្សោយ បន្ទាប់ពីកំណែទម្រង់ និងការគ្រប់គ្រងដឹកនាំបែបថ្មីនេះ។

ការសិក្សាស្រាវជ្រាវមួយនេះបានបំភ្លឺយើងខ្ញុំទៅលើផ្នែក និងកិច្ចការជាច្រើននៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ មិនតែប៉ុណ្ណោះ វាបានផ្តល់នូវបទពិសោធន៍ និងចំណេះដឹងដ៏មានតម្លៃមួយផ្នែកធំដល់យើងខ្ញុំអំពីស្ថានភាពរបស់រាជធានីភ្នំពេញ រួមជាមួយនឹងដំណើរការគ្រប់គ្រងនានា។ ក្រៅពីនេះ យើងក៏បានយល់ដឹងអំពីកត្តាពាក់ព័ន្ធនានាដែលប៉ះពាល់ដំណើរគ្រប់គ្រងរដ្ឋបាល និងផ្នត់គំនិត ចំណេះដឹងរបស់ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញផងដែរ។ ការយល់ដឹងមួយនេះដើរតួរយ៉ាងសំខាន់ក្នុងការតម្រង់ទិសដល់ក្រុមយើងខ្ញុំនៅក្នុងពេលអនាគត។

# អនុសាសន៍

# អនុសាសន៍

ការសិក្សាស្រាវជ្រាវមួយនេះបានផ្តល់នូវផលប្រយោជន៍ជាច្រើនដល់យើងខ្ញុំ។ នៅក្នុងនោះ យើងខ្ញុំបានសង្កេតឃើញលទ្ធផលល្អជាច្រើន និងបញ្ហាប្រឈមមួយចំនួនដែលកំពុងកើតមាន និងអាចនឹងបន្តកើតមាននាពេលអនាគត។ ក្រុមយើងខ្ញុំ ក្នុងនាមជានិស្សិតស្រាវជ្រាវ សូមផ្តល់អនុសាសន៍មួយចំនួន ក្នុងគោលបំណងលើកស្ទួយវិស័យរដ្ឋបាលសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងសិស្សនិស្សិតដ៏ទៃទៀត ដែលចាប់អារម្មណ៍គិតគូរទៅលើកិច្ចការមួយនេះ។

## ក. ចំពោះរាជរដ្ឋាភិបាល

បន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចមក យើងសង្កេតឃើញថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាននិងតែងតែយកចិត្តទុកដាក់ទៅលើកិច្ចការងាររដ្ឋបាលសាធារណៈ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ នៅក្នុងនោះយើងខ្ញុំសង្កេតឃើញ ចំណុចមួយចំនួនដែលអាចបំពេញបន្ថែមឱ្យកាន់តែប្រសើរឡើងមានដូចជា៖

- បន្តពង្រឹងបន្ថែមនូវផែនការយុទ្ធសាស្ត្រនានាសម្រាប់ការកែទម្រង់រដ្ឋបាលសាធារណៈ
- លើកទឹកចិត្ត និងជំរុញការប្រើប្រាស់ធនធានបច្ចេកវិទ្យាឱ្យកាន់តែប្រសើរឡើង ដើម្បីកាត់បន្ថយការចំណាយ និងពង្រឹងគុណភាពសេវាសាធារណៈ
- ប្រើប្រាស់មធ្យោបាយអេឡិចត្រូនិច ដើម្បីផ្សព្វផ្សាយព័ត៌មានប្រកបដោយតម្លាភាព និងភាពឆាប់រហ័ស
- បន្តការរៀបចំផែនការអភិវឌ្ឍមន្ត្រី ដើម្បីធានានូវចីរភាពនៃភាពប្រសើរឡើង
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- ផ្តល់ឱកាសក្នុងការចូលរួមពីភ្នាក់ងារ ឬស្ថាប័នអន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍
- និងបន្តការគិតគូរប្រយោជន៍ជាតិជាធំ។

## ខ. ចំពោះមន្ត្រីរាជការ

នៅក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែប្រសើរឡើង និងរីកចម្រើនទៅមុខ ការចូលរួមពីសំណាក់មន្ត្រីមូលដ្ឋានគឺមិនអាចខ្វះបានឡើយ។ ក្នុងនោះមន្ត្រីរាជការអាចចូលរួមពង្រឹងបន្ថែមទៅលើ៖

- បន្តការផ្តល់សេវា និងបម្រើប្រជាពលរដ្ឋប្រកបដោយភក្តីភាព និងគណនេយ្យភាព
- ប្តេជ្ញាគិតគូរប្រយោជន៍ជាតិជាធំ
- មានការយោគយល់អធ្យាស្រ័យខ្ពស់ ជាពិសេសចំពោះប្រជាពលរដ្ឋដែលមានការខ្វះខាត
- អនុវត្តសកម្មភាព និងភារកិច្ចនានារបស់ខ្លួនប្រកបដោយឧត្តមគតិ

- និងបន្តសហការយ៉ាងសកម្មជាមួយប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ដើម្បីប្រទេសជាតិ។

## គ. ចំពោះប្រជាពលរដ្ឋ

ប្រជាពលរដ្ឋមានតួនាទីសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា នៅក្នុងពេលអតីតកាល បច្ចុប្បន្ន និង អនាគត ហេតុនេះការចូលរួមរបស់ប្រជាពលរដ្ឋគឺ មិនអាចខ្វះបានឡើយ។ យើងខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា៖

- ប្រជាពលរដ្ឋគ្រប់រូបនឹងមានគំនិតស្នេហាជាតិពិតប្រាកដ
- ចូលរួមក្នុងសកម្មភាពនានារបស់រាជរដ្ឋាភិបាល ដើម្បីប្រយោជន៍រួម
- ទុកចិត្តចំពោះគ្នាទៅវិញទៅមក ដើម្បីសម្រេចគោលដៅ "ខ្មែរតែមួយ"
- បណ្ដុះគំនិតចង់ដឹង ចង់ចូលរួមក្នុងសកម្មភាព ដែលជាប្រយោជន៍ដល់សង្គម
- រស់នៅ និងដើរតួរជាគំរូដល់យុវជនជំនាន់ក្រោយ
- និងលុបបំបាត់ចិត្តគំនិត អំពើ និងសកម្មភាពអវិជ្ជមានទាំងឡាយចំពោះជាតិ។

## ឃ. ចំពោះនិស្សិត

ក្នុងនាមយើងខ្ញុំជានិស្សិតស្រាវជ្រាវ យើងខ្ញុំមានក្តីសង្ឃឹមថា និស្សិតផ្សេងទៀត ដែលបានសិក្សាទៅលើកិច្ចការមួយនេះ នឹងមានការពេញចិត្ត និងចង់រួមចំណែកនៅក្នុងការសិក្សាស្រាវជ្រាវ និងការចែករំលែកចំណេះដឹងនៅក្នុងវិស័យរដ្ឋបាលសាធារណៈនេះ។ និស្សិតបញ្ញវន្ត គឺជាគ្រឹះមួយដ៏សំខាន់ និងមិនអាចខ្វះបាននៅក្នុងការកសាងសង្គមជាតិ ក្នុងនោះនិស្សិតគ្រប់រូបអាចចូលរួមបានតាមសកម្មភាពដូចជា៖

- ចូលរួមសិក្សាទៅលើកិច្ចការនានាប្រកបដោយឧត្តមគតិ
- ចូលរួមចែករំលែកចំណេះដឹង ដែលខ្លួនមានដល់ប្រជាពលរដ្ឋដ៏ទៀត
- ប្រើប្រាស់ចំណេះដឹង ដែលខ្លួនមាន ដើម្បីជាប្រយោជន៍ដល់ជាតិ
- ជាពិសេស យើងខ្ញុំសូមលើកទឹកចិត្តឱ្យនិស្សិតជំនាន់ក្រោយ ចូលរួមសិក្សាស្រាវជ្រាវអំពី កិច្ចការនានា ដែលរួមចំណែកក្នុងការដឹកនាំប្រទេសជាតិឱ្យខិតទៅរកភាពរីកចម្រើន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើកិច្ចការមួយនេះ យើងខ្ញុំលើកទឹកចិត្តឱ្យមានការសិក្សាស៊ីជម្រៅបន្តទៀតទៅលើប្រធានបទមួយចំនួន ដែលបង្ហាញពីគម្លាតអន្តរកម្មសង្គម ហេតុផល និងបាតុភូតរបស់វា នៅក្នុងសង្គមកម្ពុជា។ ការសិក្សាផ្សេងទៀត ដូចជាបម្រែបម្រួលនៃការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ កំណើននៃតម្រូវការសេវាសាធារណៈ និងប្រធានបទពាក់ព័ន្ធនានា។ កិច្ចការទាំងនេះ នឹងមិនត្រឹមតែផ្តល់ជាចំណេះដឹងនោះទេ ប៉ុន្តែវានឹងជួយក្នុងការកែប្រែប្រទេសជាតិទាំងមូលនាពេលខាងមុខ។

# ឯកសារយោង

# ឯកសារយោង

## ក. ឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


១- រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, ១៩៨១.

២- រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា,១៩៨៩.

៣- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, ២០២៣.

៤- ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ, ១៩៩៦.

៥- ច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ, ១៩៩៦.

៦- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ, ២០០៨.

៧- ច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ, ២០០៩.

៨- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤.

៩- ច្បាប់ស្តីពីការរៀបចំអង្គការ.

១០- ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦៤ ចុះនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១.

១១- ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៣៨៣ ចុះនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨.

១២- ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៣៨៤ ចុះនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨.

១៣-ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៣៨៥ ចុះនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨.

១៤- ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤៥ ចុះនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣.

១៥- ព្រះរាជក្រឹត្យ នស/រកត/១០២០/១១០៨ ចុះនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០.

១៦- ព្រះរាជក្រឹត្យ នស/រកត/០២២១/១១៥ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១.

១៧- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌.

១៨- អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ.

១៩- អនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ.

២០- អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ.

២១- អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.

២២- អនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី ការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ.

២៣- អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ.

២៤- អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ.

២៥- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ.

២៦- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ.

២៧- ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.

២៨- ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ.

២៩- ប្រកាសលេខ ៣៨៧១ ប្រក ចុះថ្ងៃទ០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត.

៣០- ប្រកាសលេខ ៤៥១២ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តការអន្តរជាតិនៅក្នុងរចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ.

៣១- ប្រកាសលេខ ២៧៤៧ ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ.

៣២- ប្រកាសលេខ ៤៨០៧ ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៃរដ្ឋបាលរាជធានី រដ្ឋបានខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ.

៣៣- សេចក្តីសម្រេចលេខ ០៧៩ សសរ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌ៧មករា.

៣៤- សេចក្តីណែនាំលេខ ០១៥ ស.ណ.ន ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.

៣៥- សេចក្តីជូនដំណឹងលេខ ០៤៨/១៩ សជណ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រព័ន្ធតាមដានចលនាបម្លាស់ទីរថយន្តក្រុង (CITY BUS APP).

៣៦- សេចក្តីជូនដំណឹងលេខ ១៥៥ សជណ.រដស ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបើកប្រតិបត្តិការសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង(City Bus) រាជធានីភ្នំពេញ.

៣៧- សេចក្តីជូនដំណឹងលេខ ០០២/២៤ សជណ.ស ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញមកសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ(ស.ស.ភ)វិញ.

## ខ. ឯកសារមានលក្ខណៈជាគោលនយោបាយ


៣៨- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, *"គេហទំព័រអ៊ីនធឺណិត៖ ក្រសួងនិងស្ថាប័នរដ្ឋ"*, ដកស្រង់នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤.

៣៩- ក្រសួងការពារជាតិ, *"គេហទំព័រអ៊ីនធឺណិត៖ អង្គភាព ខ.ភ.ម"*, ដកស្រង់នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤.

៤០- ក្រសួងផែនការ, *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩*, វិទ្យាស្ថានជាតិស្ថិតិ, ២០១៩.

៤១- ក្រសួងព័ត៌មាន, *"រដ្ឋបាលរាជធានីភ្នំពេញ សម្ពោធដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងចរាចរណ៍ទំនើប"*, ២០១៩.

៤២- ក្រសួងមហាផ្ទៃ, *អភិបាលកិច្ចល្អ (បោះពុម្ពលើកទី២)*, ២០១០.

៤៣- ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ*, គ.ជ.អ.ប, ២០១១.

៤៤- ក្រសួងមហាផ្ទៃ, *សៀវភៅព័ត៌មានរាជធានី ខេត្ត, អគ្គនាយកដ្ឋានរដ្ឋបាល*, ២០២៤.

៤៥- ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ*, ២០១៩.

៤៦- ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំ ស្តីពី កិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*, អគ្គនាយកដ្ឋានរដ្ឋបាល, ២០១៥.

៤៧- ក្រសួងមហារផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលរាជធានីតាមបែបវិមជ្ឈការ(សម្រាប់ក្រុមប្រឹក្សារាជធានី)*, NSLA, ២០១៩.

៤៨- ក្រសួងមហាផ្ទៃ, *ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ ២០២៤-២០២៨*, ២០២៤.

៤៩- គ.ជ.អ.ប., *សៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ*, ២០០៩.

៥០- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, *តារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតនៃការជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧*, ២០២៣.

៥១- គណៈកម្មាធិការជាតិរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រោមជាតិ, *ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥ (បោះពុម្ពលើកទី១)*, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២០២១.

៥២- គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ, "*ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥*" ២០១៦.

៥៣- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស, *របាយការណ៍ ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញ ប្រចាំឆ្នាំ២០២៣*, សាលារាជធានីភ្នំពេញ, ២០២៣.

៥៤- ជា សុផារ៉ា, *រដ្ឋបាលរាជធានីភ្នំពេញ*, ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ, ១៩៩៨.

៥៥- ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា, "*គេហទំព័រអ៊ីនធឺណិត៖ ថ្នាក់ដឹកនាំ*", ដកស្រង់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤.

៥៦- រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី១*, ២០០៤.

៥៧- រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០*, ២០២១.

៥៨- រាជរដ្ឋាភិបាលកម្ពុជា, *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភាសម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨*, ២០២៣.

៥៩- រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដំណាក់កាលទី១*, ២០២៣.

៦០- សាលារាជធានីភ្នំពេញ, "*គេហទំព័រអ៊ីនធឺណិត៖ រាជធានីភ្នំពេញ*", ដកស្រង់នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤.

៦១- សាលារាជធានីភ្នំពេញ, "*ភ្នំពេញសម័យប៉ុលពត*", ដកស្រង់នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤.

៦២- អង្គភាពច្រកចេញចូលតែមួយ, *របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំឆ្នាំ២០២៣*, សាលារាជធានីភ្នំពេញ, ២០២៣.

៦៣- អង្គភាពច្រកចេញចូលតែមួយ, *របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំ ឆមាសទី១ ឆ្នាំ២០២៤*, សាលារាជធានីភ្នំពេញ, ២០២៤.

## គ. ឯកសារជាសៀវភៅ អត្ថបទ និងទិនានុប្បវត្តិ

៦៤- ងីម ហួរ និងច្រើនរូបទៀត, *អរិយធម៌ខ្មែរ (បោះពុម្ពលើកទី៦),* វិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ២០២០.

៦៥- ង៉ុយ ធឿន, *ប្រព័ន្ធរដ្ឋបាលកម្ពុជា,* សាលាភូមិន្ទរដ្ឋបាល, ២០១៨.

៦៦- ជី ឧត្តម &ថា ចាន់ធាន, *ការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការ,* ស.ភ.ន.វ.ស, ២០២០.

៦៧- ដេវីឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ (បោះពុម្ពលើកទី៣),* មជ្ឈមណ្ឌលខេមរសិក្សា, ២០០៩.

៦៨- ឌីខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) (បោះពុម្ពលើកទី២)*, មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០១១.

៦៩- ទឹម សុខហួយ, *ប្រវត្តិវិទ្យា (បោះពុម្ពលើកទី៣)*, ២០២៤.

៧០- វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី២*, Mou Seth, ២០០៨.

៧១- វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគទី៣*, Mou Seth, ២០១០.

៧២- ស៊ន សំណាង និងច្រើនរូបទៀត, *ប្រវត្តិវិទ្យា*, ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧.

៧៣- សាយ បូរី, *នីតិរដ្ឋបាលទូទៅ (បោះពុម្ពលើកទី៥),* Editions Angkor, ២០១២.

៧៤- សាយ បូរី, *វិទ្យាសាស្ត្ររដ្ឋបាល(បោះពុម្ពលើកទី២)*, Edition Angkor, ២០១៥.

៧៥- ស៊ាប សារុធ &លី វ៉ាម៉ាន, *កំណែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្ន (២០១៥-២០២០),* សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០២០.

៧៦- សុខ សុវត្ថិ, "ឈ្មោះសង្កាត់ទាំង១០៥ ក្នុងខណ្ឌទាំង១៤នៃរាជធានីភ្នំពេញ", *ខ្លឹរ,* ០១ មេសា ២០១៩.

៧៧- សឿន សោភ័ណ, *សេចក្តីផ្តើមរដ្ឋបាលសាធារណៈ (បោះពុម្ពលើកទី១)*, ណៃ ដារ៉ា, ២០១៩.

៧៨- សំ សារ៉ាក់, *នីតិរដ្ឋបាលស្តីពីចំណេះដឹងការងាររដ្ឋបាលកិច្ចការលេខាធិការ និងបណ្ណសារដ្ឋាន,* ២០១១.

៧៩- សៅ ឡាយ, *សេចក្តីផ្តើមរដ្ឋបាលសាធារណៈ (បោះពុម្ពលើកទី២)*, ២០០៨.

៨០- ហែម ឡាច, *ការវិវត្តនៃរដ្ឋបាលដែនដីខ្មែរ(តាំងពីសម័យមុនអង្គរ រហូតដល់ឆ្នាំ១៩៩៣)*, ២០២២.

៨១- ឥន ឃៀន, *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា(បោះពុម្ពលើកទី៤)*, សម្ងួហាកម្ម ឥន ឃៀន, ២០២៤.

## ឃ. ឯកសារបរទេសជាសៀវភៅ អត្ថបទ និងទិនានុប្បវត្តិ

៨២- Baredes Barbara. "Serving citizens: Measuring the performance of services for a better user experience" *OECD Working papers on Public Governance*, No.52, 2022.

៨៣- Benjamin Bolaane, &Emmanuel Isaac. "Privatization of solid waste collection services: Lesson from Gaborone" *Waste Management*, Vol. 40, 2015, pp. 14-21.

៨៤- Cambodia communication, "Cambodia's per capita GDP to exceed 2000$ in 2024" *Japan-Cambodia Association*, No.23/80, 2024.

៨៥- Carmen Morosan. *The role of the local government in promoting social and economic development*. Johns Hopkins University, 1995.

៨៦- Chanda Chansa Thelma. "Civic education and citizen participation in local government: A case of Lusaka District, Zambia" *International Journal of Research Publication and Reviews, Vol. 5*(3), 2024, pp. 4628-4637.

៨៧- Chanda Chansa Thelma. "Effects of Civic Education on Learners' response to governance tenets: A case of selected secondary schools in Kitwe District of Copperbelt province, Zambia" *GSJ, Vol. 11*(7), 2023, pp. 2320-9186.

៨៨- Christine W. Letts, William P. Ryan, & Allen Grossman. *High performance nonprofit organizations (1st ed.).* John Wiley &Sons, Inc., 1999.

៨៩- David Chandler. *A History of Cambodia (3rd Edition).* Westview Press, 2009.

៩០- Dweck Carol Susan. *Mindset The new psychology of success.* Random House, 2006.

៩១- Emily R. Johnson. "The Significance of Challenge Awareness in Organizational Change" *Journal of Management Studies, Vol.5,* No.2, 2019, pp. 15-34.

៩២- Erock Taptuk Emre. "Efficiency of public sector organizations: Perspectives from theories of Bureaucracy" *MPRA Paper*, No.49386, 2013.

៩៣- Ishwor Thapa. "Local Government: Concept, Roles, and Importance for Contemporary Society." *Tribhuvan University*, 2020.

៩៤- JICA. *The Project for Comprehensive Urban Transport Plan in Phnom Penh Capital City.* 2014.

៩៥- Michael D.Coe. *The Khmer Empire: The Oxford World History of Empire.* Oxford University Press, 2021, pp 430-449.

៩៦- Mohammed Wamique Hisam, Shouvik Sanyal, Moinuddin Ahmad. "The Impact of Service Quality on Customer Satisfaction: A Study on Selected Retail Stores in India" *International Review of Management and Marketing, 6*(4),2016, 851-856.

៩៧- Mukandala Rwekaza. *Decentralization and Democratization in Tanzania (Barkan J. edition).* Five Monographs on Decentralization and Democratization in Sub-Saharan Africa, University of Iowa, 1998.

៩៨- OECD. *Building trust to reinforce democracy: Main findings from the 2021 OECD survey on drivers of trust in public institutions*. OECD Publishing, 2022.

៩៩- Ozturk Ilhan. "The role of education in economic development: a theoretical perspective" *Journal of Rural Development and Administration,* Vol.33, No.1, 2001, pp. 39-47.

១០០- Richard L. Daft. *Organizational Theory and Design (10th ed.).* Cengage Learning, 2010.

១០១- Robert H. Wilson. "Understanding local governance: An international perspective" *Revista de Administrcao de Empresas,* Vol.2, No.2, 2000, pp. 51-63.

១០២- Roderic Broadhurst et al. *Violence and the civilizing process in Cambodia*. Cambridge University Press, 2015, pp. 246-270.

១០៣- Ronald J. Burke, Amanda F. Allisey, &Andrew J. Noblet, "The importance of human resource management in the public sector, future challenges and the relevance of the current collection" *Human Resource Management in the Public Sector*, 2013, pp. 1-13.

១០៤- Steinar Halden. "Important of Public Administration in our Society" *Global Journal of Interdisciplinary Social Sciences*, Vol.11, No.2, 2022, p. 1.

១០៥- Tom Christensen, Per Laegreid, Paul G. Roness, &Kjell Arne Rovik. *Organization theory and the public sector: Instrument, culture and myth.* Routledge Taylor & Francis Group, 2007.

១០៦- UNDP. "*Retrieved from Webpage: Human Development Index"* 29, June. 2024.

១០៧- Woodrow Wilson. "The Study of Administration" *Political Science Quarterly,* Vol.2, No.2, 1887, pp. 197-222.

១០៨- World Bank Open Data, "*Retrieved from Webpage: GDP per capita growth (annual%) - Cambodia*", 2023.

១០៩- Zellatifanny Cut Medika, Rumata Vience Mutiara, &Sakinah Awit Muarwati. “The impact of public information awareness and service towards public engagement” *Jurnal Studi Kumunikasi*, Vol. 5, 2021, pp. 439-452.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- បញ្ជីរាយនាមឧបសម្ព័ន្ធ៖

**ឧបសម្ព័ន្ធទី១៖** ឯកសារ និងកម្រងរូបភាពនៃការសិក្សាស្រាវជ្រាវធ្វើបទសម្ភាសនៅសាលារាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី២៖** បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ *(តាមវិធីសាស្ត្រកំណត់ត្រា ដោយមានការពិនិត្យ និងឯកភាព)*

**ឧបសម្ព័ន្ធទី៣៖** បទសម្ភាសជាមួយមន្ត្រីជំនាញ អង្គភាពច្រកចេញចូលតែមួយ នៃសាលារាជធានីភ្នំពេញ *(តាមវិធីសាស្ត្រសម្រាយខ្សែអាត់សម្លេង ដោយមានការអនុញ្ញាតពីមន្ត្រីសាមី)*

**ឧបសម្ព័ន្ធទី៤៖** បទសម្ភាសជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ *(តាមវិធីសាស្ត្រខ្សែអាត់សម្លេង ដោយមានការអនុញ្ញាតពីប្រជាពលរដ្ឋសាមី)*

**ឧបសម្ព័ន្ធទី៥៖** លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤

**ឧបសម្ព័ន្ធទី៦៖** របាយការណ៍ ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញ ប្រចាំឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី៧៖** របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី៨៖** របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំ ឆមាសទី១ ឆ្នាំ២០២៤

**ឧបសម្ព័ន្ធទី៩៖** ផែនទីរដ្ឋបាលរាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី១០៖** ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥

**ឧបសម្ព័ន្ធទី១១៖** រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី១២៖** ព្រះរាជក្រឹត្យ នស/រកត/០២២១/១១៥ ចុះនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ (ស្តីពីការតែងតាំងអភិបាលរាជធានីភ្នំពេញ)

**ឧបសម្ព័ន្ធទី១៣៖** ប្រកាសលេខ ២៧៤៧ ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី១៤៖** ប្រព័ន្ធឌីជីថលសម្រាប់ផ្តល់ព័ត៌មានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

# ឧបសម្ព័ន្ធទី១៖
# ឯកសារ និងកម្រងរូបភាពនៃការសិក្សា
# ស្រាវជ្រាវធ្វើបទសម្ភាសនៅសាលារាជធានី
# ភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ

យើងខ្ញុំឈ្មោះ ទេព និនរស្មី និងវន់ វិបុល ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៧ ក្រុម P4B01 ឆ្នាំសិក្សា២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ**
**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

កម្មវត្ថុ៖ សំណើសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ ។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន ឯកឧត្តមបណ្ឌិត មេត្តាជ្រាបថា៖ បន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេរសារណា និងការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី«ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញ» ដោយត្រូវចុះស្រាវជ្រាវឯកសារនៅ សាលារាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមបណ្ឌិត មេត្តាអនុញ្ញាតឱ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមបណ្ឌិត មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ

ថ្ងៃអង្គារ ០៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤

ហត្ថលេខា

លេខទូរស័ព្ទទំនាក់ទំនង៖ ០៩៧ ៨៩០ ៨៥០០
០៩៣ ៨០៥ ៨៦៨

ទេព និនរស្មី　　វន់ វិបុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

លេខ ៨៧៣ ស.ភ.ន.វ.ស

រដ្ឋបាលរាជធានីភ្នំពេញ
ចូល លេខ: ១១៧៦
ថ្ងៃទី ១៧ ... ម៉ោង ...
បញ្ជូន ...

**សូមគោរពជូន**

**ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

ន. គ្រប់គ្រងធនធានមនុស្ស
ចូល ថ្ងៃទី ... បញ្ជូន ...

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន០២រូប ចុះស្រាវជ្រាវឯកសារ។

**យោង៖** សំណើរបស់សាមីនិស្សិតចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម អភិបាល នៃគណៈអភិបាល មេត្តាជ្រាបថា៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួន០២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី«ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញ» នៅសាលារាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤ ដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូម ឯកឧត្តម អភិបាល នៃគណៈអភិបាល មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឱ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ

ថ្ងៃ ... ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤

**ជ.សាកលវិទ្យាធិការ**

**សាកលវិទ្យាធិការរង**

**យិត សុខួច**

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855)23 214 953, E-mail: rector@rule.edu.kh,website: www.rule.edu.kh



រូបភាពនៃការចូលរួមធ្វើបទសម្ភាសរបស់មន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ



រូបភាពនៃការចូលរួមធ្វើបទសម្ភាសរបស់មន្ត្រីជំនាញ អង្គភាពច្រកចេញចូលតែមួយ នៃសាលារាជធានីភ្នំពេញ

# ឧបសម្ព័ន្ធទី២៖

# បទសម្ភាសជាមួយមន្ត្រីជំនាញ ទីចាត់ការ គ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានី ភ្នំពេញ

*(តាមវិធីសាស្ត្រកំណត់គ្រា ដោយមានការពិនិត្យ និងឯកភាព)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## បទសម្ភាស

## ជាមួយមន្ត្រីជំនាញ ទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ

យើងខ្ញុំ **ឆេព និនស្មើ** និង **ចន់ ទិបុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤ ជំនាន់ទី១៧ ជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំកំពុងធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលនូវទិន្នន័យព័ត៌មានមួយចំនួនដើម្បីចងក្រងជាឯកសារសារណា ក្រោមប្រធានបទស្តីពី "**ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញ ២០២៣-២០២៤**" ក្នុងគោលបំណងសិក្សាស្វែងយល់បន្ថែមពីដំណើរការនៃការបំពេញកិច្ចការងាររដ្ឋបាលទូទៅ ការផ្តល់សេវាសាធារណៈ កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការ និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍនៅក្នុងរាជធានីភ្នំពេញ ព្រមទាំងសមិទ្ធផលនានាដែលទទួលបានក្នុងពេលកន្លងមកផងដែរ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះមន្ត្រីជំនាញទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមផ្តល់ព័ត៌មានសម្រាប់កិច្ចការស្រាវជ្រាវមួយនេះ រួមមាន៖

១- លោក **នាង មុនីរត្ន** អនុប្រធានការិយាល័យកសាងសមត្ថភាព នៃទីចាត់ការគ្រប់គ្រងធនធានមនុស្ស សាលារាជធានីភ្នំពេញ

២- លោក **វណ្ណា សុទិទ្ធ** អនុប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក នៃទីចាត់ការគ្រប់គ្រងធនធានមនុស្ស សាលារាជធានីភ្នំពេញ

៣- លោក **ឡេង ប៊ុនហេង** មន្ត្រីការិយាល័យកសាងសមត្ថភាព នៃទីចាត់ការគ្រប់គ្រងធនធានមនុស្ស សាលារាជធានីភ្នំពេញ

### កំណត់ត្រានៃខ្លឹមសារសំខាន់ៗដែលទទួលបានពីបទសម្ភាស

### ១- អំពីសាលារាជធានីភ្នំពេញ

រាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ទេសចរណ៍ វប្បធម៌ និងការទូតដែលមានការអភិវឌ្ឍលើគ្រប់វិស័យ។ មានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា ត្រង់ទន្លេចតុមុខជាចំណុចប្រសព្វរវាងទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់។

រាជធានីភ្នំពេញមានមានប្រជាជនសរុបចំនួន ២.២៨១.៩៥១នាក់ (ស្ថិតិជំរឿនប្រជាជនឆ្នាំ២០១៩) ផ្ទៃដីសរុបចំនួន ៦៩៥,២១៨គម² ស្មើនឹង ០,៣៨% នៃផ្ទៃដីសរុបទូទាំងប្រទេស ដែលចែកចេញជា ១៤ខណ្ឌ ១០៥សង្កាត់ និង៩៥៣ភូមិ។

បច្ចុប្បន្នសាលារាជធានីភ្នំពេញ មានទីចាត់ការចំនួន៩ អង្គភាពចំនួន៣ និងមានមន្ត្រីរាជការបម្រើការចំនួន ២៧៧នាក់ ជាស្ត្រីចំនួន ១០១នាក់។ ចំពោះចំនួនមន្ត្រីនេះ សាលារាជធានីភ្នំពេញនៅមានតម្រូវការបន្ថែមទៀត ដោយសារកត្តាកំណើនប្រជាសាស្ត្រ គួបផ្សំវិសមភាពរវាងមន្ត្រីចូលនិវត្តន៍ និងមន្ត្រីចូលបម្រើការថ្មីប្រចាំឆ្នាំ។

បន្ថែមពីនេះទៀត សាលារាជធានីភ្នំពេញបាននឹងកំពុងអនុវត្តបរិវត្តកម្មឌីជីថល (Digitalization) ស្របតាមផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើនតម្លាភាព និងភាពងាយស្រួលជូនប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាននិងសេវាសាធារណៈប្រកបដោយប្រសិទ្ធិភាព។

## ២- អំពីការអភិវឌ្ឍសមត្ថភាពមន្ត្រីនៅសាលារាជធានីភ្នំពេញ

សាលារាជធានីភ្នំពេញបាននឹងកំពុងសិក្សាពីតម្រូវការរបស់មន្ត្រីក្នុងការអភិវឌ្ឍសមត្ថភាពរបស់គាត់ ដែលការសិក្សានេះត្រូវបានអនុវត្តដោយទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលារាជធានីភ្នំពេញ ដើម្បីពង្រឹងនិងកសាងសមត្ថភាពមន្ត្រីឱ្យបានខ្ពស់ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់បម្រើជាប្រយោជន៍ជូនអង្គភាព ស្ថាប័ន និងប្រជាពលរដ្ឋផងដែរ។ នៅក្នុងដំណើរការអភិវឌ្ឍសមត្ថភាពមន្ត្រីនេះ សាលារាជធានីភ្នំពេញប្រើប្រាស់វិធីសាស្ត្រ ពីរយ៉ាងសំខាន់ៗគឺៈ ការប្រមូលទិន្នន័យផ្ទាល់ និងការប្រមូលទិន្នន័យតាមរយៈប្រព័ន្ធឌីជីថល ដើម្បីប៉ាន់ប្រមាណតម្រូវការការបណ្តុះបណ្តាលសមត្ថភាពរបស់មន្ត្រី។

ចំពោះវគ្គបណ្តុះបណ្តាល សាលារាជធានីភ្នំពេញបានចេញនូវចំណាត់ការបណ្តុះបណ្តាលមន្ត្រីទៅតាមភាពចាំបាច់ និងតម្រូវការ ដើម្បីបម្រើប្រជាពលរដ្ឋ ទៅតាមស្ថាប័នបណ្តុះបណ្តាលមានដូចតទៅៈ

១- ការបណ្តុះបណ្តាលនៅសាលារាជធានីភ្នំពេញផ្ទាល់

២- ការបណ្តុះបណ្តាលនៅតាមអង្គការដៃគូអភិវឌ្ឍ

៣- ការបណ្តុះបណ្តាលនៅក្រៅក្រសួង ស្ថាប័ន អង្គភាព

៤- ការបណ្តុះបណ្តាលនៅក្រៅប្រទេស។

បន្ថែមពីនេះ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីឱ្យកាន់តែប្រសើរឡើងនាពេលអនាគត សាលារាជធានីភ្នំពេញនឹងបន្តសហការជាមួយនឹងស្ថាប័នជំនាញ ដើម្បីពង្រីកដៃគូរសហការបន្ថែមទៀតដូចជា សាកលវិទ្យាល័យ និងគ្រឹះស្ថានជំនាញផ្សេងៗ សម្រាប់ការអភិវឌ្ឍសមត្ថភាពនេះ។

## ៣- អំពីការគ្រប់គ្រងចរាចរណ៍

ស្ថានភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ ក្លាយជាបញ្ហាចោទក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ដោយសារតែការកើនឡើងនៃយានយន្តយ៉ាងឆាប់រហ័ស គួបផ្សំជាមួយនឹងកំណើនសេដ្ឋកិច្ចដ៏សំខាន់របស់ប្រទេសផងដែរ។ ដើម្បីដោះស្រាយស្ថានការណចរាចរណ៍ដ៏ស្មុគស្មាញនេះ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានរៀបចំ "ផែនការមេដឹកជញ្ជូនទីក្រុងនៅតំបន់ទីក្រុងភ្នំពេញ" (JICA 2001 MP) ជាមួយនឹងទិសដៅឆ្នាំ២០១៥។ ត្រូវបានអនុវត្តតាម "ការកែលម្អគម្រោងនៃការដឹកជញ្ជូនទីក្រុងនៅតំបន់ទីក្រុងភ្នំពេញ" (ខែមីនា ឆ្នាំ២០០៧-២០១០) ដែល JICA បានស្វែងរកការលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាសម្រាប់ការកែលម្អផ្លូវប្រសព្វ ការដំឡើងសញ្ញាចរាចរណ៍ និងសុវត្ថិភាពចរាចរណ៍ទៅកាន់ដៃគូគម្រោងនៅក្នុងរាជធានីភ្នំពេញ។ គួរបញ្ជាក់ថា ការសាងសង់ផ្លូវ ត្រូវបានបញ្ចប់លឿនជាងការគ្រោងទុកក្នុងសមាជ JICA ឆ្នាំ២០០១។

ទោះជាយ៉ាងនេះក្តី ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍បានបន្តកើនឡើង ដោយសារការកើនឡើងនៃចរាចរណ៍យានយន្តជាពិសេសចរាចរណ៍ទោចក្រយាន្ត និងកង្វះមធ្យោបាយធ្វើដំណើរសាធារណៈ។ ហេតុនេះទើបបានជារដ្ឋាភិបាលកម្ពុជា ស្នើទៅរដ្ឋាភិបាលជប៉ុន ដើម្បីអនុវត្តគម្រោងកែទម្រង់សមាជិកសភាឆ្នាំ២០០១ និងរៀបចំផែនការដឹកជញ្ជូនក្នុងទីក្រុងដ៏ធំទូលំទូលាយ រួមទាំងផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាដឹកជញ្ជូនផងដែរ។ ចំពោះការងារនេះ ក្រុមអ្នកសិក្សាវចនាលម្អិតសម្រាប់ "គម្រោងផែនការដឹកជញ្ជូនទីក្រុង ក្នុងក្រុងភ្នំពេញ" (PPTUMP) បានសិក្សាលម្អិតនៅខែតុលា ឆ្នាំ២០១១។

ដោយពិចារណាលើគម្រោងខាងលើដែលបានអនុវត្តរួចហើយ ក្រុមសិក្សាការរចនាលម្អិតរបស់ PPUTMP បានពិភាក្សាអំពីការបង្កើតផែនការមេដឹកជញ្ជូនក្នុងទីក្រុង និងការផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធជាមួយក្រុមសមភាគី។ ដោយផ្អែកលើធាតុ ដែលមាននៅក្នុងកំណត់ត្រានៃកិច្ចពិភាក្សា (R/D) ដែលបានចុះហត្ថលេខាដោយភាគីទាំងពីរ PPUTMP ហើយត្រូវបានអនុវត្តចាប់ពីខែមីនា ឆ្នាំ២០១២ រហូតដល់ខែធ្នូ ឆ្នាំ២០១៤។

**៤- អំពីឯកសារជំនួយស្មារតី**

ដើម្បីជួយសម្រួលដល់ការសិក្សាស្រាវជ្រាវមួយនេះ សាលារាជធានីភ្នំពេញក៏បានផ្តល់នូវឯកសារបន្ថែមមួយចំនួនទៀត ដែលទាក់ទងនឹងការអភិវឌ្ឍអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថិតិប្រជាជន ស្ថិតិមន្ត្រីរាជការ ការផ្តល់សេវាសាធារណៈ ។ល។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមផ្តល់ព័ត៌មានដ៏មានតម្លៃ និងប្រសិទ្ធិភាព។

រាជធានីភ្នំពេញ ថ្ងៃទី 12 ខែកក្កដា ឆ្នាំ២០២៤

**ហត្ថលេខានិស្សិតសម្ភាស**

**ឆេព និនស្មើ** **នន់ ទីបុល**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤

**ឡេង ម៉ុនហេង**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤

**នាង មុនីរត្ន**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤

**ចន្ទ្រា សុទិន្ទ**

# ឧបសម្ព័ន្ធទី៣៖
# បទសម្ភាសជាមួយមន្ត្រីជំនាញ អង្គភាពច្រក
# ចេញចូលតែមួយ នៃសាលារាជធានីភ្នំពេញ

*(តាមវិធីសាស្ត្រសម្រាយខ្សែអាត់សម្លេង ដោយមានការអនុញ្ញាតពីមន្ត្រីសាមី)*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# បទសម្ភាស

# ជាមួយមន្ត្រីជំនាញ អង្គភាពច្រកចេញចូលតែមួយ នៃសាលារាជធានីភ្នំពេញ

យើងខ្ញុំ **ទេព និនរស្មី** និង **ទន់ ទិបុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤ ជំនាន់ទី១៧ ជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរនាក់កំពុងតែធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលផ្ដុំព័ត៌មាន ដើម្បីចងក្រងជាឯកសារសារណាមួយនៅក្រោមប្រធានបទស្ដីអំពី "**ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញ ២០២៣-២០២៤**" ក្នុងគោលបំណងចង់សិក្សាស្វែងយល់បន្ថែមពីដំណើរការនៃការបំពេញកិច្ចការងាររដ្ឋបាលទូទៅ ការផ្ដល់សេវាសាធារណៈ កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការនិងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍនៅក្នុងរាជធានីភ្នំពេញ និងសមិទ្ធផលដែលទទួលបានក្នុងពេលកន្លងមក។

យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះការចូលរួមផ្ដល់ព័ត៌មានដ៏មានសារៈសំខាន់ពីសំណាក់លោកស្រីប្រធានអង្គភាពច្រកចេញចូលតែមួយនៃសាលារាជធានីភ្នំពេញ តាមរយៈការឆ្លើយនៅសំណួរខាងក្រោម៖

**បទសម្ភាសជាមួយ៖** លោកស្រី **មួក យុវល័ក្ខ** ប្រធានអង្គភាពច្រកចេញចូលតែមួយ

អត្ថបទនេះសម្រាយទៅតាមខ្សែអាត់សម្លេងនៃបទសម្ភាសដែលទទួលបានការអនុញ្ញាតពី លោកស្រីប្រធានអង្គភាពដោយផ្ទាល់ សម្រាប់ប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ។

## ១. អំពីការងាររបស់អង្គភាពច្រកចេញចូលតែមួយនៃសាលារាជធានីភ្នំពេញ

**សំណួរទី១៖** តើការិយាល័យច្រកចេញចូលតែមួយមានរៀបចំជាផែនការ ឬក៏វិធានការអ្វីខ្លះសម្រាប់អភិវឌ្ឍសេវាសាធារណៈនៅក្នុងឆ្នាំ២០២៤?

**ចម្លើយទី១៖** ដំបូងយើងធ្វើការញែកឱ្យច្បាស់រវាងសេវាសាធារណៈ និងសេវារដ្ឋបាល។ ការដាក់ពាក្យស្នើសុំការអនុញ្ញាត ឬធ្វើអ្វីផ្សេងៗដែលយើងជាប្រជាពលរដ្ឋ ជាអាជីវករ ជាពាណិជ្ជករ ធ្វើការស្នើសុំ គឺយើងស្នើសុំសេវារដ្ឋបាល។ សេវាសាធារណៈមានដូចជាបញ្ហាសុខភាពសាធារណៈ មានសាលារៀន មានការរៀបចំសន្តិសុខសណ្ដាប់ធ្នាប់ជាដើម ហៅថាសេវាសាធារណៈ។ ពាក់ព័ន្ធជាមួយនឹងសេវារដ្ឋបាល យើងផ្ដល់ទៅតាមយន្តការច្រកចេញចូលតែមួយ ហើយយន្តការច្រកចេញចូលតែមួយមានបីថ្នាក់គឺ អង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៅក្នុងសង្កាត់។ អញ្ចឹងការបែងចែកគឺជាថ្នាក់ៗ អង្គភាពគឺសម្រាប់តែនៅរដ្ឋបាលរាជធានី និងរដ្ឋបាលខេត្ត

ហើយសម្រាប់ការិយាល័យច្រកចេញចូលតែមួយគឺនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយនិងយន្តការច្រកចេញចូលតែមួយគឺនៅឃុំ សង្កាត់។ សម្រាប់រាជធានីភ្នំពេញមាន១០៥សង្កាត់ យើងមានយន្តការច្រកចេញចូលតែមួយទាំង១០៥សង្កាត់។ ចំពោះភាពខុសគ្នានៅតាមថ្នាក់នីមួយៗ យើងផ្អែកទៅតាមប្រកាសអន្តរក្រសួង ផ្អែកទៅតាមអនុក្រឹត្យលេខ១៨ ដែលអនុក្រឹត្យលេខ១៨បានកំណត់មុខសេវាដែលក្រសួង ស្ថាប័នថ្នាក់ជាតិត្រូវធ្វើប្រតិភូកម្មមុខសេវាណាខ្លះ មកឱ្យកម្រិតថ្នាក់អង្គភាពច្រកចេញចូលតែមួយ កម្រិតការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ ហើយនិងយន្តការឃុំ សង្កាត់។ សម្រាប់អង្គភាពច្រកចេញចូលតែមួយ យើងមានមុខសេវា(វិស័យ)មកពីក្រសួង ស្ថាប័នចំនួន១២ និងសេវា២ទៀតដែលជាសេវាផ្ទាល់របស់រដ្ឋបាលរាជធានីខេត្តដែលក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មមកឱ្យ ការងារនោះមានការងារនីត្យានុកូលកម្ម(ការបញ្ជាក់លិខិតចម្លង) និងការងាររដ្ឋបាលដូចជាការសុំជីកឆ្លងផ្លូវ ការសុំវិនិយោគទុនក្រោម២លានរៀល និងវិស័យពាក់ព័ន្ធចំនួន១២ដូចជាវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ វិស័យសាធារណការ វិស័យវប្បធម៌ (...)។ល។ ដែលមានផ្សព្វផ្សាយនៅក្នុងវេបសាយ (Website)ផងដែរ។ នៅក្នុងការធ្វើប្រតិភូកម្មនេះក្រសួងបានចេញប្រកាសអន្តរក្រសួងមួយរវាងក្រសួង ស្ថាប័នសមី ហើយនិងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ឧទាហរណ៍ក្រសួងបរិស្ថានគាត់មានប្រកាសអន្តរក្រសួងមួយ អន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន និយាយអំពីការកំណត់តម្លៃសេវា ហើយនិងថេរវេលានៃការផ្តល់សេវា អញ្ចឹងការអនុវត្តរបស់អង្គភាពច្រកចេញចូលតែមួយគឺផ្អែកទៅលើប្រកាសអន្តរក្រសួងទាំងនេះ ចំពោះតម្លៃសេវាយើងដាក់បង្ហាញនៅ អង្គភាពច្រកសម្រាប់រាជធានីភ្នំពេញយើងបង្ហាញនៅលើកញ្ចក់ទូរទស្សន៍ យើងមានដាក់នៅលើការបិទផ្លាកជាតារាងតម្លៃដែលរយៈពេលនៅទីនោះស្រាប់ សម្រាប់នៅពេលប្រជាជនមក គាត់អាចសួរមន្ត្រីផ្ទាល់ក៏បាន គាត់អាចសន្សំពេលវេលាដោយការមើលព័ត៌មាននៅតាមវិធីផ្សព្វផ្សាយក៏បាន។

**សំណួរទី២៖** នៅពេលដែលអង្គភាពច្រកចេញចូលតែមួយអនុវត្តការងារ តើគាត់បានជួបនឹងបញ្ហាប្រឈមអ្វីខ្លះដែរ?

**ចម្លើយទី២៖** បញ្ហាប្រឈមដូចជាមិនមាននោះទេ ព្រោះបើគិតថាជាបញ្ហាប្រឈមវាដូចជាធំពេក។ ប៉ុន្តែចំពោះបញ្ហាវិញយើងជួបបញ្ហាដូចជា ទីមួយបញ្ហាដែលប្រជាពលរដ្ឋលោកមកស្នើសុំសេវា គាត់យកពាក្យសុំទៅបំពេញ អ្នកខ្លះគាត់មិនបានបំពេញដោយខ្លួនឯងទេ គឺពួកគាត់ឱ្យគេបំពេញឱ្យ ហើយគាត់មិនបានពិនិត្យមើលព័ត៌មានអ្វីទាំងអស់ ហើយនៅពេលដែលយកមកដាក់ព័ត៌មានខ្លះខុស អញ្ចឹងធ្វើគាត់ត្រូវចំណាយពេលបំពេញឡើងវិញ ទីពីរពាក់ព័ន្ធជាមួយនឹងការស្នើសុំរបស់គាត់ ឧទាហរណ៍ថាគាត់ស្នើសុំអាជីវកម្មអ្វីមួយ គាត់ដាក់ពាក្យស្នើសុំមក យើងទទួលយកសំណើរបស់គាត់ ហើយយើងបញ្ជូនទៅឱ្យមន្ត្រីបច្ចេកទេសចុះទៅសិក្សា ហើយនៅពេលដែលគេចុះទៅសិក្សាទៅឃើញថាទីតាំងនោះមិនសមស្របទៅតាមបច្ចេកទេសដែលគួរអនុញ្ញាតឱ្យធ្វើអាជីវកម្ម អញ្ចឹងយើងត្រូវឆ្លើយតបទៅគាត់វិញថាមិនអាចធ្វើបានទេ ប៉ុន្តែបញ្ហានោះគឺ នៅពេលដែលគាត់មកដាក់ពាក្យគាត់ត្រូវបង់សេវា ហើយសេវានឹងគឺ

មិនអាចដកវិញបានទេ អញ្ចឹងដើម្បីកុំខាតបង់ដល់ប្រយោជន៍ប្រជាពលរដ្ឋ កន្លងមករៀងរាល់សេវាណា ដែលអង្គភាពច្រកតែចេញចូលតែមួយពិនិត្យឃើញថានឹងមានភាពស្មុគស្មាញ និងមិនមានភាព ច្បាស់លាស់ថាត្រឹមត្រូវនិងអាចអនុញ្ញាតឱ្យបានយើងមិនតម្រូវឱ្យពួកគាត់បង់ប្រាក់នោះទេ គឺយើង ចេញបង្កាន់ដៃបណ្ដោះអាសន្នជំនួស។ បង្កាន់ដៃបណ្ដោះអាសន្ននេះគឺ យើងទទួលយកពាក្យសុំមក ដោយពួកគាត់មិនចាំបាច់បង់ប្រាក់ទេ គឺយើងធ្វើការសិក្សាបច្ចេកទេសជាមុនសិន ប្រសិនបើសិក្សាទៅ មានភាពត្រឹមត្រូវហើយចាំយើងហៅគាត់មកបង់សេវា ដើម្បីកុំគាត់មានការខាតបង់។ ចំពោះបញ្ហាដីធ្លីគឺ មានបញ្ហាប្រឈមច្រើន និងមានភាពស្មុគស្មាញខ្លាំង ដោយសារនៅក្នុងសង្គមយើងបញ្ហាដីធ្លីភាគច្រើន កើតឡើងពីសិទ្ធិ ផលប្រយោជន៍ ពីសាច់ញាតិបងប្អូនជាដើម អញ្ចឹងបញ្ហាជួបនៅពេលណាដែលយើង បានទទួលឯកសារហើយ យើងធ្វើចន្តការទៅ នៅពេលដែលយើងប្រកាសផ្សព្វផ្សាយភ្លាមគឺមានអ្នក ប្រឆាំងតវ៉ា មានអ្នកជំទាស់មិនឱ្យក្រុមការងារចុះទៅវាស់វែងជាដើម ដែលបង្កការលំបាកនៅក្នុងការ ផ្ដល់សេវា។ ក្រៅពីនេះប្រជាជន លោកមិនបានយល់ដឹងពីការងារបច្ចេកទេសទាំងនេះដែលលោកគ្រាន់ តែដឹងថា នៅពេលដែលដាក់ពាក្យសុំហើយ ដឹងតែបានលទ្ធផល ប៉ុន្តែមិនដឹងពីការជួបប្រទះបែបនេះ នៅពេលអនុវត្ត អញ្ចឹងហើយប្រជាពលរដ្ឋខ្លះគាត់រំពឹងថា គាត់បានដាក់ពាក្យរួចហើយ គាត់ដឹងតែបាន ផលហើយ ប៉ុន្តែនៅពេលដែលយើងចុះទៅដល់គាត់មិនទាន់បានជម្រះបញ្ហាជាមួយអ្នកជិតខាងជា ឧទាហរណ៍ ឬក៏បញ្ហាជាមួយបងប្អូនគាត់ដែលមិនទាន់បានដោះស្រាយគ្នារួច និងខ្លះទៀតមានជាប់ បំណុល ដែលបញ្ហាទាំងនេះធ្វើឱ្យមានការរាំងស្ទះដល់នីតិវិធីរបស់យើង និងយើងមិនអាចបំពេញឱ្យ គាត់កើត។ អ្នកបច្ចេកទេស ឬអាជ្ញាធរមូលដ្ឋានគាត់ក៏បានយល់ និងមានមនោសញ្ចេតនាដោយ លោកមិនចង់បដិសេធសំណើប្រជាពលរដ្ឋភ្លាមៗនៅពេលដែលមានបញ្ហា លោកក៏បានអញ្ជើញ ម្ចាស់សំណើឱ្យទៅដោះស្រាយគ្នា ឬសម្របសម្រួលជាមួយភាគីពាក់ព័ន្ធសិន ប្រសិនជាអាចដោះ ស្រាយចេញយើងនឹងបន្តចន្តការទៅតែម្តង យើងមិនចាំបាច់ឆ្លើយតប។ អញ្ចឹងនៅពេលដែលសម្រប សម្រួលគ្នាហ្នឹងត្រូវប្រើប្រាស់ពេលវេលាច្រើន អញ្ចឹងអ្នកដែលដាក់ពាក្យស្នើសុំគាត់ពុំបានយល់នៅបញ្ហា នេះទេ ប៉ុន្តែគាត់បែជាចោទយើងថាធ្វើការយឺត មិនគោរពតាមពេលវេលាជាដើម។ សម្រាប់ការជួប ប្រទះនៅការមិនពេញចិត្តបែបនេះ គឺមានតែអាជ្ញាធរមូលដ្ឋានឆ្លើយតបប្រាប់គាត់វិញថាមិនអាច អនុញ្ញាតឱ្យធ្វើបាន។ នេះគឺជាបញ្ហាប្រឈមដែលយើងជួបប្រទះ។

**សំណួរទី៣៖** ទាក់ទងនៅនឹងការផ្ដល់សេវានៅសាលារាជធានីភ្នំពេញផ្ទាល់ ក្នុងករណីដែលប្រជាពលរដ្ឋគាត់មិនពេញ ចិត្ត ឬករណីមានវិវាទកើតឡើង តើមាននីតិវិធីអ្វីខ្លះសម្រាប់ដោះស្រាយ?

**ចម្លើយទី៣៖** នៅក្នុងករណីនេះ គាត់អាចទៅជួបការិយាល័យប្រជាពលរដ្ឋ ដើម្បីដាក់ពាក្យបណ្ដឹងអំពី បញ្ហាទាំងនោះ និងធ្វើការតវ៉ា(...) ប៉ុន្តែកន្លងមកនេះយើងដូចជាមិនដែលបានទទួលពាក្យបណ្ដឹងទាក់ទងនៅបញ្ហា ទាំងនេះទេ(...)។

**សំណួរទី៤៖** ដើម្បីធានានូវប្រសិទ្ធិភាពសេវាដែលផ្តល់ដោយសាលារាជធានីភ្នំពេញផ្ទាល់ និងត្រូវនឹងតម្រូវការរបស់ប្រជាពលរដ្ឋ តើខាងអង្គភាពច្រកចេញចូលតែមួយបានរៀបចំនៅផែនការអ្វីខ្លះ?

**ចម្លើយទី៤៖** សម្រាប់ឆ្លើយតបទៅនឹងតម្រូវការនិងតាមនីតិវិធី យើងមានយន្តការតាមដាន។ បើនិយាយអំពីវិធានការរបស់យើងនៅពេលដែលគាត់យកឯកសារមកដាក់យើងចេញបង្កាន់ដៃឱ្យគាត់ ហើយយើងមានប្រព័ន្ធតាមដានថាឯកសារនោះចរន្តការដល់ណា រួចរាល់នៅពេលណា និងមានបញ្ហាអ្វី យើងជម្រាបគាត់។ ក្នុងពេលដែលមានបញ្ហាមក ហើយយើងបានដឹងបញ្ហាមុនពេលដែលគាត់សួរ យើងទាក់ទងទៅជម្រាបគាត់តាមលេខទូរសព្ទដែលដាក់ក្នុងបង្កាន់ដៃដើម្បីឱ្យគាត់បានដឹងព័ត៌មាន ក្នុងករណីខ្លះដែលយើងមិនបានទាក់ទងទៅគាត់ ហើយគាត់ទាក់ទងមកសួរយើងវិញថាចរន្តការឯកសារគាត់ដល់ណាហើយ ចប់ហើយឬនៅ? យើងក៏មានប្រព័ន្ធតាមដាន និងមានមន្ត្រីសម្រាប់ពិនិត្យមើលថាលេខកូដឯកសារនេះបានចរន្តការដល់ណា ដំណាក់កាលបន្ទាប់ត្រូវទៅណា និងជួបបញ្ហាអ្វីខ្លះ? គឺយើងមានប្រព័ន្ធតាមដានបែបនេះ។

## ២. អំពីឯកសារជំនួយបន្ថែម

ដើម្បីជួយសម្រួលដល់ការសិក្សាស្រាវជ្រាវមួយនេះ អង្គភាពច្រកចេញចូលតែមួយនៃសាលារាជធានីភ្នំពេញបានផ្តល់នូវឯកសារសំខាន់ៗចំនួនពីរគឺ៖

១- របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំឆ្នាំ២០២៣ របស់អង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ

២- របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំ ឆមាសទី១ ឆ្នាំ២០២៤ របស់អង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមផ្តល់ព័ត៌មាន ដ៏មានតម្លៃ និងប្រសិទ្ធិភាព!

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

**ហត្ថលេខានិស្សិតសម្ភាស**

**ទេព និនរស្មី** **ចាន់ ចិប៉ុល**

# ឧបសម្ព័ន្ធទី៤៖
# បទសម្ភាសជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ

*(តាមវិធីសាស្ត្រខ្មែរអាត់សម្លេង ដោយមានការអនុញ្ញាតពីប្រជាពលរដ្ឋសាមី)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# បទសម្ភាស

# ជាមួយប្រជាពលរដ្ឋ នៃរាជធានីភ្នំពេញ

យើងខ្ញុំ **ទេព និនរស្មី** និង **ទន់ ទិមុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤ ជំនាន់ទី១៧ ជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំកំពុងធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលផ្តុំនូវព័ត៌មាន ដើម្បីចងក្រងជាឯកសារសារណា ក្រោមប្រធានបទស្តីអំពី "**ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញ ២០២៣-២០២៤**" ក្នុងគោលបំណងសិក្សាស្វែងយល់បន្ថែមពីដំណើរការនៃការបំពេញការងាររដ្ឋបាលទូទៅ ការផ្តល់សេវាសាធារណៈ កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការនិងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍនៅក្នុងរាជធានីភ្នំពេញ ព្រមទាំងសមិទ្ធផលនានាដែលទទួលបានក្នុងពេលកន្លងមក។ ដើម្បីជានាឱ្យបានថាព័ត៌មានដែលយើងទទួលបានមានភាពត្រឹមត្រូវ និងពុំមានភាពលម្អៀង ការសាកសួរព័ត៌មានពីប្រជាពលរដ្ឋមូលដ្ឋានផ្ទាល់មានសារៈសំខាន់ណាស់ នៅក្នុងបង្ហាញពីភាពត្រឹមត្រូវនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះប្រជាពលរដ្ឋទាំងពីររូបនៃរាជធានីភ្នំពេញ ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីរួមចំណែកនៅក្នុងកិច្ចការមួយនេះ។

១- កញ្ញា **ម៉ាត់ សុខជា** ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញ ធ្វើការក្នុងវិស័យអប់រំ

២- កញ្ញា **សឿម ចាន់រី** ប្រជាពលរដ្ឋនៃរាជធានីភ្នំពេញ ជានិស្សិតក្នុងវិស័យអប់រំ

អត្ថបទនេះសម្រាយទៅតាមខ្សែអាត់សម្លេងនៃបទសម្ភាសតាមប្រព័ន្ធអ៊ីនធឺណិត(Google Meet) ដែលទទួលបានការអនុញ្ញាតពីប្រជាពលរដ្ឋសមីដោយផ្ទាល់ សម្រាប់ប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ។

## ១- អំពីព័ត៌មានផ្ទាល់ខ្លួន

**សំណួរទី១៖** គិតមកដល់ពេលបច្ចុប្បន្ន តើអ្នករស់នៅរាជធានីភ្នំពេញបានប៉ុន្មានឆ្នាំ?

**ចម្លើយទី១៖**

**ក.** សម្រាប់រូបខ្ញុំ ខ្ញុំបានរស់នៅក្នុងរាជធានីភ្នំពេញរយៈពេលប្រាំបួន(០៩)ឆ្នាំមកហើយ គឺចាប់តាំងពីឆ្នាំ២០១៣មក។

**ខ.** ខ្ញុំរស់នៅក្នុងរាជធានីភ្នំពេញអស់រយៈពេលបួន(០៤)ឆ្នាំ គឺចាប់ពីឆ្នាំ២០២០ ដល់២០២៤។

**សំណួរទី២៖** តើអ្នកមានសង្កេតឃើញ ការអភិវឌ្ឍ ឬភាពប្រសើរឡើងនៅក្នុងសង្គមដែរ ឬទេ?

**ចម្លើយទី២៖**

**ក**. នៅក្នុងរស់នៅសព្វថ្ងៃ បើធៀបនឹងពេលដែលខ្ញុំមករស់នៅក្នុងភ្នំពេញដំបូង ខ្ញុំសង្កេតឃើញថាមានការអភិវឌ្ឍ និងសាងសង់ច្រើន ជាពិសេសទៅលើការសាងសង់ស្ពានអាកាស ផ្លូវថ្នល់ និងសំណង់អាគារខ្ពស់ៗដែលមានភាពប្រសើរឡើង។

**ខ**. ចំពោះរូបខ្ញុំ ខ្ញុំសង្កេតឃើញថា សង្គមយើងមានការអភិវឌ្ឍច្រើនដូចជាកំណើនការសាងសង់សំណង់អាគារ ការអភិវឌ្ឍនៃប្រព័ន្ធគ្រប់គ្រងដូចជាសេវារដ្ឋបាល ដែលវាមានភាពទំនើបបែបបច្ចេកវិទ្យា និងមានភាពល្អប្រសើរជាងពេល ដែលខ្ញុំទើបមករស់នៅក្នុងរាជធានីភ្នំពេញដំបូងៗ។

**សំណួរទី៣៖** តើអ្នកមានការចាប់អារម្មណ៍ដូចម្តេចចំពោះព័ត៌មាន និងសកម្មភាពនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ?

**ចម្លើយទី៣៖**

**ក**. ខ្ញុំចាប់អារម្មណ៍ចំពោះសកម្មភាពគ្រប់គ្រងរដ្ឋបាលសាធារណៈ ជាពិសេសការបញ្ជាក់លិខិតផ្សេងៗ ដែលខ្ញុំទៅទទួលសេវាដូចជាការបញ្ជាក់សញ្ញាបត្របញ្ចប់ការសិក្សា និងសំបុត្រកំណើត ដែលខ្ញុំមិនបញ្ជាក់នៅស្រុកកំណើត ហើយខ្ញុំមកទទួលសេវានេះនៅរាជធានីភ្នំពេញ ខ្ញុំសង្កេតឃើញថា ការរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាក្នុងការរង់ចាំ និងទទួលសេវា ការរៀបចំរបៀបរបបផ្សេងៗទៀតមានប្រសិទ្ធិភាពជាងមុន ដែលវាបានជួយសន្សំសំចៃពេលវេលារបស់ខ្ញុំនៅក្នុងការទទួលសេវាកម្មទាំងនេះ។

**ខ**. ដូចគ្នាដែរ ខ្ញុំចាប់អារម្មណ៍ចំពោះសេវារដ្ឋបាល ដែលវាមានភាពប្រសើរឡើង។ ឧទាហរណ៍ កាលពីមុនខ្ញុំចង់បញ្ជាក់សញ្ញាបត្រផ្សេងៗ ខ្ញុំត្រូវទៅបញ្ជាក់នៅខេត្ត ប៉ុន្តែបច្ចុប្បន្នយើងអាចបញ្ជាក់នៅច្រកចេញចូលតែមួយ មួយណាក៏បាន ដែលវាបានសម្រួលដល់តម្រូវការរបស់ខ្ញុំ។ បន្ថែមពីនេះ ការទទួលបានព័ត៌មានពីសេវាផ្សេងៗទៀតក៏មានភាពល្អប្រសើរ ដោយវាមានប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗជាជំនួយ អញ្ចឹងវាផ្តល់ភាពងាយស្រួលដល់ខ្ញុំក្នុងការទទួលបានព័ត៌មាន និងតម្រូវការនៃនីតិវិធី។ ដូចនេះខ្ញុំពុំចាំបាច់ធ្វើដំណើរច្រើនដង ដើម្បីទទួលសេវាផ្សេងៗ ដែលវាបានធ្វើឱ្យខ្ញុំពេញចិត្តចំពោះការអភិវឌ្ឍ និងកែប្រែទាំងនេះ។

## ២- អំពីសេវាសាធារណៈ

**សំណួរទី៤៖** តើអ្នកធ្លាប់ប្រើប្រាស់សេវាសាធារណៈដែរ ឬទេក្នុងពេលប្រាំមួយ(០៦)ខែចុងក្រោយនេះ? បើមានតើជាសេវាអ្វី?

**ចម្លើយទី៤៖**

**ក**. នៅក្នុងរយៈពេលប្រាំមួយ(០៦)ខែចុងក្រោយនេះ ខ្ញុំបានទទួលសេវាសាធារណៈមួយចំនួនទាក់ទងនឹងសេវារដ្ឋបាល គឺការបញ្ជាក់ព្រឹត្តិបត្រថ្កោលទោស និងការបញ្ជាក់សញ្ញាបត្ររបស់ខ្ញុំ។ នៅក្នុងនេះ ខ្ញុំសង្កេត

ឃើញមានភាពល្អប្រសើរទាំងអាកប្បកិរិយារបស់មន្ត្រី និងសេវាកម្មផ្ទាល់។ ក្រៅពីនេះ មន្ត្រីច្រកចេញចូលតែមួយក៏បានជួយសម្រួលដល់ខ្ញុំច្រើនផងដែរ នៅក្នុងការទទួលសេវានេះ។

**ខ**. ចំពោះខ្ញុំវិញ នៅក្នុងរយៈពេលប្រាំមួយ(០៦)ខែចុងក្រោយនេះ ខ្ញុំបានទទួលសេវាធ្វើលិខិតថ្កោលទោស (ព្រឹត្តិបត្រថ្កោលទោស) ដែលការអនុវត្តរបស់ខ្ញុំគឺធ្វើតាមវីដេអូណែនាំរបស់ក្រសួងស្ថាប័ន។ បើធៀបនឹងការទទួលសេវានេះរបស់ខ្ញុំនៅក្នុងឆ្នាំមុន ឆ្នាំនេះមានភាពងាយស្រួលជាងមុន ដោយខ្ញុំអាចធ្វើការបង់ប្រាក់តាមរយៈធនាគារជាមុន មុននឹងទៅដកព្រឹត្តិបត្រថ្កោលទោស។

**សំណួរទី៥៖** តើអ្នកមានការពេញចិត្តកម្រិតណាចំពោះសេវានោះ? ហេតុអ្វី?

**ចម្លើយទី៥៖**

**ក**. សម្រាប់ពិន្ទុពី១ដល់៥ ខ្ញុំសុំឱ្យ៤ ដោយសារឯកសាររបស់ខ្ញុំត្រូវបានកំណត់ពេលវេលាទទួលបាន បានច្បាស់លាស់ ដែលពេលខ្ញុំទៅយកគឺបានសម្រេចរួចរាល់ដូចការកំណត់មែន។

**ខ**. ចំពោះការពេញចិត្តនៃសេវាកម្មដែលខ្ញុំទទួល បើគិតពី១ដល់៥ ខ្ញុំគិតថាចម្លើយខ្ញុំគឺ៣។ មូលហេតុដែលខ្ញុំឱ្យ៣ គឺដោយសារកំណែទម្រង់ថ្មីតាមបរិបទឌីជីថលនេះ បានផ្តល់ភាពងាយស្រួលច្រើនដល់រូបខ្ញុំ ចំណែកឯ២ទៀតគឺដោយសារតែកាលខ្ញុំទទួលសេវានេះ ការទទួលខុសត្រូវ និងភាពត្រឹមត្រូវរបស់មន្ត្រីទទួលបន្ទុកនៅមានកម្រិត។ កាលនោះខ្ញុំ ត្រូវទៅពីរដង ដោយសារតែឯកសាររបស់ខ្ញុំមានព័ត៌មានមិនត្រឹមត្រូវដែលទាមទារឱ្យរងចាំសារជាថ្មី និងប្រើប្រាស់ពេលយូរ ក្រៅពីនេះមន្ត្រីដែលទទួលឯកសាររបស់ខ្ញុំមិននៅ អញ្ចឹងមានភាពលំបាកខ្លះ។

**សំណួរទី៦៖** តើអ្នកមានជួបបញ្ហាអ្វីដែរ ឬទេក្នុងការទទួលសេវានោះ? តើបញ្ហានោះជាបញ្ហាអ្វី?

**ចម្លើយទី៦៖**

**ក**. ចំពោះបញ្ហាដែលខ្ញុំជួបប្រទះគឺ ការចេញលេខបង្កាន់ដៃខុស ដោយគាត់មិនបានពិនិត្យឡើងវិញឱ្យបានច្បាស់លាស់។ ហើយបន្ទាប់ពីខ្ញុំត្រឡប់មកផ្ទះវិញ ទើបមានមន្ត្រីទាក់ទងមកឱ្យខ្ញុំយកបង្កាន់ដៃទៅប្តូរវិញ។ ដូចនេះខ្ញុំគិតថាបញ្ហានេះ ទោះបីជាកំហុសអចេតនាក្តី ខ្ញុំគិតថាការពិនិត្យឡើងវិញឱ្យបានច្បាស់លាស់គួរតែមាន។

**ខ**. ចំពោះបញ្ហាដែលខ្ញុំបានជួបគឺ ការរងចាំ ដោយសារតែពេលខ្ញុំទៅទទួលសេវាមានមនុស្សច្រើន ដែលធ្វើឱ្យខ្ញុំរងចាំយូរ។ ក្រៅពីនេះ ប្រព័ន្ធគ្រប់គ្រងនៅមានភាពយឺតនៅឡើយ រួមនឹងការមិនយោគយល់របស់មន្ត្រីធ្វើការពោលគឺនៅពេលដែលម៉ោង៥ ជាម៉ោងដែលឈប់ផ្តល់សេវា ទោះបីប្រជាពលរដ្ឋមករងចាំយូរហើយក្តី មន្ត្រីពុំមានការយោគយល់ទទួលឯកសាររបស់ខ្ញុំទេ។ ដូចនេះខ្ញុំគិតថាការរៀបចំឱ្យច្បាស់លាស់ពីចំនួនដែលអាចទទួលសេវាបានគឺចាំបាច់ ដើម្បីកុំដូចករណីខ្ញុំ ដែលបានចាប់លេខរៀងហើយ ប៉ុន្តែដល់ម៉ោងសម្រាកគឺមិនត្រូវបានផ្តល់សេវាជូន។

## ៣- អំពីការយល់ដឹង និងព័ត៌មាន

**សំណួរទី៧៖** តើអ្នកបានដឹងពីប្រព័ន្ធរដ្ឋបាលរបស់រាជធានីភ្នំពេញដែរឬទេ? តើវាជាប្រព័ន្ធអ្វី?

**ចម្លើយទី៧៖**

**ក**. ខ្ញុំបានដឹងតិចតួចចំពោះប្រព័ន្ធរដ្ឋបាល។ ខ្ញុំគិតថាប្រព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ គឺជាប្រព័ន្ធមួយដែលបង្កើតឡើង ដើម្បីភាពងាយស្រួលក្នុងការគ្រប់គ្រងប្រជាពលរដ្ឋ។ ឧទាហរណ៍. សេវាដឹកជញ្ជូនឡានក្រុងសាធារណៈជាដើម ដែលវាត្រូវមានប្រព័ន្ធណាមួយក្នុងការគ្រប់គ្រងដើម្បីឱ្យដំណើរការមានភាពងាយស្រួល។ នេះគឺជាការយល់ឃើញរបស់ខ្ញុំចំពោះប្រព័ន្ធរដ្ឋបាល។

**ខ**. ចំពោះខ្ញុំវិញ ខ្ញុំមិនសូវបានដឹងអំពីប្រព័ន្ធរដ្ឋបាលរាជធានីភ្នំពេញនោះទេ។ អ្វីដែលខ្ញុំដឹង គឺការរៀបចំនីតិវិធីប្រឡងដូចជា ការជ្រើសរើសគ្រូ ដែលមានការៀបចំពីមួយដំណាក់កាលទៅមួយដំណាក់កាល។

**សំណួរទី៨៖** តើអ្នកបានទទួលព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍដែរ ឬទេ? ហេតុអ្វី?

**ចម្លើយទី៨៖**

**ក**. ខ្ញុំមិនសូវបានទទួលព័ត៌មានគ្រប់គ្រាន់នោះទេ ដែលភាគច្រើនគឺខ្ញុំបានគេហទំព័រហ្វេសប៊ុក(Facebook)។ ចំពោះការទទួលបានព័ត៌មានទូលំទូលាយជាប្រចាំ គឺខ្ញុំមិនសូវទទួលបានគ្រប់គ្រាន់ដែរទេ។ មូលហេតុដែលខ្ញុំមិនមានព័ត៌មានគ្រប់គ្រាន់ចំពោះការអភិវឌ្ឍ ផែនការ ឬនីតិវិធីទាំងនេះគឺ កត្តាខ្លួនឯង និងភាពចាំបាច់។ ឧទាហរណ៍. ខ្ញុំអត់ត្រូវការប្រើប្រាស់សេវា ឬព័ត៌មានទាំងអស់នោះ អញ្ចឹងខ្ញុំគិតថាខ្ញុំមិនចាំបាច់ដឹងនោះទេ នៅពេលណាដែលខ្ញុំត្រូវការទើបខ្ញុំរកមើលបន្ថែម។

**ខ**. ខ្ញុំពុំសូវទទួលបានព័ត៌មានគ្រប់គ្រាន់នោះទេ។ ខ្ញុំគិតថានេះអាចមកពីកត្តាខ្លួនខ្ញុំផ្ទាល់ ដោយសារខ្ញុំពុំសូវចំណាយពេលតាមដាននោះទេ ចំពោះព័ត៌មានមួយផ្នែកដែលខ្ញុំទទួលបានគឺតាមរយៈបណ្ដាញសង្គមផ្សេងៗ ដូចជាហ្វេសប៊ុក(Facebook) និងតេឡេក្រាម(Telegram)ជាដើម។ ដូចនេះខ្ញុំមិនសូវមានព័ត៌មានទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍគ្រប់គ្រាន់នោះទេ។ បន្ថែមពីនេះ ខ្ញុំពុំសូវមានពេលវេលាគ្រប់គ្រាន់សម្រាប់ការតាមដានព័ត៌មានទាំងអស់នេះ។

**សំណួរទី៩៖** តើប្រភពព័ត៌មានណាខ្លះ ដែលអ្នកប្រើប្រាស់សម្រាប់ទទួលព័ត៌មានពីការគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ?

**ចម្លើយទី៩៖**

**ក**. សម្រាប់ខ្ញុំ ខ្ញុំប្រើប្រាស់ហ្វេសប៊ុក(Facebook) ដោយការចុចតាមដានផេក(Follow Page)របស់សាលារាជធានីភ្នំពេញ ហើយមួយទៀត ខ្ញុំប្រើប្រាស់តេឡេក្រាម(Telegram)ដូចជាការចូលទៅក្នុងឆានែល(Channel) របស់ក្រសួងមុខងារសាធារណៈ និងក្រសួងស្ថាប័នផ្សេងៗ។ ដូចនេះខ្ញុំបានទទួលព័ត៌មានពីប្រភពពីរនេះ។

ខ. ប្រភពព័ត៌មានដែលខ្ញុំទទួលបាន គឺដូច(ក)ដែរ គឺតាមគេហទំព័រហ្វេសប៊ុក(Facebook) និងតេឡេក្រាម (Telegram)។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមផ្តល់ព័ត៌មានដ៏មានតម្លៃ និងប្រសិទ្ធិភាព។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤

**ហត្ថលេខានិស្សិតសម្ភាស**



**ទេព និនរស្មី** **ចន់ វិបុល**

# ឧបសម្ព័ន្ធទី៥៖

# លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ អំពីការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

# លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ

# អំពី

# ការគ្រប់គ្រងរដ្ឋបាលនៅសាលារាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤


**រៀបចំដោយ**

**លោក ទេព និនស្មី**
**និស្សិតរដ្ឋបាលសាធារណៈជំនាន់ទី១៧ នៃថ្នាក់**P4B01

**លោក ចន់ វិបុល**
**និស្សិតរដ្ឋបាលសាធារណៈជំនាន់ទី១៧ នៃថ្នាក់**P4B01


(សម្រាប់ប្រើប្រាស់នៅក្នុងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រឆ្នាំ២០២៤)

**ខែមិថុនា ឆ្នាំ២០២៤**

## កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះគឺជា លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញផ្ទាល់ទាក់ទងនឹងការប្រើប្រាស់សេវាសាធារណៈ ការយល់ដឹង និងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងពេលបច្ចុប្បន្ននេះ(២០២៤)។ គោលបំណងរបស់របាយការណ៍នៃលទ្ធផលការសិក្សាស្រាវជ្រាវមួយនេះគឺដើម្បីជាឯកសារជំនួយដល់ការសិក្សាស្រាវជ្រាវ និងការចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ស្ដីអពី "**ការគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញ ឆ្នាំ២០២៣-២០២៤**" របស់ និស្សិតពីររូបគឺ លោក **ទេព និនរស្មី** និងលោក **វន់ វិបុល** ដែលជានិស្សិតរដ្ឋបាលសាធារណៈជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ព័ត៌មាននៅក្នុងឯកសារមួយនេះគឺទទួលបានពីការស្ទង់មតិតាមរយៈប្រព័ន្ធអេឡិចត្រូនិចដោយកម្មវិធី Google Form ដែលមានការចូលរួមដោយស្ម័គ្រចិត្តពីប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញផ្ទាល់។ ជាការគោរពដល់ឯកជនភាពរបស់អ្នកចូលរួម ព័ត៌មានផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋដូចជា ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាយុ និងអ៊ីម៉ែល មិនត្រូវបានប្រមូលនោះទេ។

## រចនាសម្ព័ន្ធ

រចនាសម្ព័ន្ធនៃកិច្ចការមួយនេះត្រូវបានកំណត់និងបែងចែកជា៦ផ្នែកដូចខាងក្រោម៖

### ផ្នែកទី១ គ្រោងនៃការស្ទង់មតិ

ផ្នែកនេះនឹងបង្ហាញអំពីចំនួនរបស់អ្នកដែលបានចូលរួម សំណួរដែលបានរៀបចំសម្រាប់ធ្វើការស្ទង់មតិ និងគោលបំណងនៃសំណួរ។

### ផ្នែកទី២ លទ្ធផលដែលទទួលបានគិតជាមធ្យម

ផ្នែកនេះនឹងបង្ហាញអំពីលទ្ធផលដែលទទួលបានពីអ្នកចូលរួមដោយគិតជាមធ្យម ទៅតាមសំណួរនីមួយៗ។ ព័ត៌មានកំណត់សម្គាល់ក្រុមអ្នកឆ្លើយ(ស្ថានភាពបច្ចុប្បន្ន វិស័យ/ជំនាញ) នឹងមិនបានបង្ហាញនៅក្នុងនេះឡើយ។

### ផ្នែកទី៣ លទ្ធផលដែលទទួលបានគិតតាមក្រុមអ្នកចូលរួម

ផ្នែកនេះនឹងបង្ហាញអំពីលទ្ធផលដែលទទួលបានទៅតាមសំណួរនីមួយៗ និងជាមធ្យមទៅតាមក្រុមអ្នកចូលរួមដែលកំណត់ដោយស្ថានភាពបច្ចុប្បន្ន និងវិស័យ/ជំនាញ។

### ផ្នែកទី៤ លទ្ធផលដែលទទួលបានគិតតាមបណ្ដុំប្រភេទសំណួរ

ផ្នែកនេះនឹងបង្ហាញអំពីលទ្ធផលដែលទទួលបានដោយផ្អែកទៅលើការឆ្លើយតបរបស់អ្នកចូលរួមម្នាក់ទៅលើប្រភេទកម្រងសំណួរ និងស្ថិតិរបស់អ្នកដែលមានចម្លើយប្រហាក់ប្រហែលនឹងគ្នា។

## ផ្នែកទី៥ លទ្ធផលនៃតម្រូវការរបស់អ្នកចូលរួម

ផ្នែកនេះនឹងបង្ហាញអំពីតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ ដោយផ្អែកតាមចម្លើយដែលទទួលបាន។ លទ្ធផលនឹងត្រូវកំណត់បែងចែកទៅតាមវិស័យ និងផ្តល់ព័ត៌មានលម្អិតតាមវិស័យនីមួយៗ។

## ផ្នែកទី៦ សេចក្តីសន្និដ្ឋានលទ្ធផលនៃការសិក្សា

ផ្នែកនេះនឹងធ្វើការសង្ខេបអំពីលទ្ធផលឡើងមកវិញ និងកំណត់យកលក្ខខណៈរួមនៃលទ្ធផលរួមរបស់ការស្ទង់មតិ។

# ផ្នែកទី១ គ្រោងនៃការស្ទង់មតិ

## ១.១. បរិមាណនៃអ្នកចូលរួម

ការសិក្សាស្រាវជ្រាវមួយត្រូវបានរៀបចំឡើង ដោយក្រុមយើងខ្ញុំផ្ទាល់ដែលមានគោលដៅស្ទង់មតិ និងព័ត៌មានមួយពីប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញផ្ទាល់។ នៅក្នុងដំណើរប្រមូលទិន្នន័យមួយនេះយើងបានរៀបចំ និងផ្សព្វផ្សាយតាមមធ្យោបាយអេឡិចត្រូនិច ដែលមាន រយៈពេល៥ថ្ងៃគឺ គិតចាប់តាំងពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ និងជាលទ្ធផលយើងទទួលបានការចូលរួមពីប្រជាពលរដ្ឋចំនួន ១៩០នាក់មកពីកន្លែងផ្សេងៗគ្នា។




## ១.២. កម្រងសំណួរដែលប្រើប្រាស់នៅក្នុងការស្ទង់មតិ

នៅក្នុងការសិក្សាមួយនេះ អ្នកចូលរួមទាំងអស់ត្រូវចូលរួមឆ្លើយសំណួរចំនួន១៥ និងការទទួលស្គាល់ពីភាពត្រឹមត្រូវនៃចម្លើយចំនួន១។ ចំពោះសំណួរទាំង១៥នេះ យើងធ្វើការបែងចែកវាជាពីរប្រភេទគឺ (១)សំណួរជ្រើសរើស(MCQ)ចំនួន ១៤សំណួរ និង(២)សំណួរអធិប្បាយចំនួន ១សំណួរ។ កម្រងសំណួរទាំងនេះត្រូវបានរៀបចំឡើងជាពីរភាសាគឺភាសាខ្មែរ និងភាសាអង់គ្លេស ដែលមានដូចតទៅ៖

***កំណត់សម្គាល់៖*** Q ជាអក្សរកាត់នៃសំណួរ លេខត្រូវតាងជាលេខរៀងនៃសំណួរ ឧទាហរណ៍. Q1 តាងសំណួរទី១

**សំណួរទី១ (Q1)៖** ស្ថានភាពបច្ចុប្បន្ន* Current Status

○ សិស្សនិស្សិត - Student

○ រកស៊ី/ធ្វើការ - Employed

○ សិស្សនិស្សិត + រកស៊ី/ធ្វើការ -Employed Student

**សំណួរទី២ (Q2)៖** វិស័យការងារ / ជំនាញ* Field / Major

កំណត់សំគាល់ Noted:

**វិទ្យាសាស្ត្រពិត**សំដៅដល់វិស័យទាក់ទងនឹង គណិតវិទ្យា, រូបវិទ្យា, ពេទ្យ, វិទ្យាសាស្ត្រកុំព្យូទ័រ, ។ល។
Science includes Math, Physic, Biology, Medicine, Doctor, Computer Science, etc.

**វិទ្យាសាស្ត្រសង្គម**សំដៅដល់ សិល្បៈ, អប់រំ, វិទ្យាសាស្ត្រនយោបាយ, សង្គមវិទ្យា, ទស្សនៈវិទ្យា, នីតិសាស្ត្រ, រដ្ឋបាលសាធារណៈ, ។ល។
Social Science includes Art, Education, Political Science, Sociology, Philosophy, Law, Public Administration, etc.

- ○ វិទ្យាសាស្ត្រពិត - Science
- ○ វិទ្យាសាស្ត្រសង្គម - Social Science
- ○ Other…

**សំណួរទី៣ (Q៣)៖** តើវិស័យ /ជំនាញរបស់អ្នកទាក់ទងនឹងរាជរដ្ឋាភិបាលកម្រិតណាដែរ?

Rate how related your field / major is to the government sector.

| | 1 | 2 | 3 | |
|---|---|---|---|---|
| មានទំនាក់ទំនងតិចតួច - Somewhat Related | ○ | ○ | ○ | មានទំនាក់ទំនងខ្លាំង - Closely Related |

**សំណួរទី៤ (Q4)៖** តើអ្នកមានបានប្រើប្រាស់សេវាកម្មរដ្ឋបាលរបស់រាជរដ្ឋាភិបាលដែរទេក្នុងកំឡុងពេល៦ខែចុងក្រោយនេះ?(សេវាកម្មរដ្ឋបាលដូចជាការបញ្ជាក់លិខិតផ្សេងៗ, សេវាសាធារណៈដូចជាឡានក្រុង សេវាកម្មសុខាភិបាល ។ល។)

Have you used any governmental services in the last 6 months?
(Administrative Service: Verification of documents; Public Service: Public Transport; Healthcare, etc.)

- ○ ខ្ញុំបានប្រើប្រាស់ - Yes, I have.
- ○ ខ្ញុំមិនបានប្រើប្រាស់ទេ - No, I have not.
- ○ ខ្ញុំចាំមិនច្បាស់ - Maybe

**សំណួរទី៥ (Q5)៖** បើបានប្រើប្រាស់ សូមវាយតម្លៃការពេញចិត្តរបស់អ្នកចំពោះសេវាកម្មនោះ។ (ដោយគិតទៅលើ អាកប្បកិរិយារបស់មន្ត្រី, ល្បឿននៃសេវាកម្ម, និងភាពច្បាស់លាស់នៃដំណើរការ)

If you have used it, please rate your satisfaction below. (Based on Public Official's Attitude, Speed of Service, Transparent Process)

| | 1 | 2 | 3 | 4 | 5 | |
|---|---|---|---|---|---|---|
| មានការមិនពេញចិត្តខ្លាំង - Very Unsatisfied | ○ | ○ | ○ | ○ | ○ | មានការពេញចិត្តខ្លាំង - Very Satisfied |

**សំណួរទី៦ (Q6)៖** តើអ្នកគិតថា ការយល់ដឹងពីប្រព័ន្ធរដ្ឋបាលរបស់រដ្ឋាភិបាល និងមូលដ្ឋានមានសារៈសំខាន់កម្រិតណា?

Rate how important you think the understanding of Government and Local Administrative systems is.

គ្មានសារៈសំខាន់ - Not Important At All 1 ○ 2 ○ 3 ○ 4 ○ 5 ○ សំខាន់ខ្លាំងណាស់ - Extremely Important

**សំណួរទី៧ (Q7)៖** តើអ្នកដឹងអំពីប្រព័ន្ធរដ្ឋបាលនៅកម្ពុជាបានកម្រិតណា?

Rate how much you know about Cambodian Administrative System.

ដឹងតិចតួចបំផុត - Not at All 1 ○ 2 ○ 3 ○ 4 ○ 5 ○ ដឹងច្បាស់ទាំងអស់ - Fully Understood

**សំណួរទី៨ (Q8)៖** តើអ្នកគិតថាអ្នកដឹងពីរចនាសម្ព័ន្ធរបស់សាលារាជធានីភ្នំពេញកម្រិតណា?

Rate how much you know about Phnom Penh Capital Hall's structure.

មិនដឹងសោះ - Absolutely No Idea 1 ○ 2 ○ 3 ○ 4 ○ 5 ○ ដឹងច្បាស់ទាំងអស់ - Fully Understood

**សំណួរទី៩ (Q9)៖** តើអ្នកដឹងថាសាលារាជធានីភ្នំពេញផ្តល់សេវាសាធារណៈអ្វីខ្លះដែរទេ?

Do you know what services Phnom Penh Capital Hall provides?

○ ខ្ញុំបានដឹង - I am aware of that.

○ ខ្ញុំមិនបានដឹងទេ - I am not aware of that.

○ ខ្ញុំដឹងខ្លះៗ - I somehow aware of that.

**សំណួរទី១០ (Q10)៖** តើអ្នកគិតថារដ្ឋបាលរាជធានីភ្នំពេញប្រើប្រាស់ប្រព័ន្ធរដ្ឋបាលអ្វី?

What do you think Phnom Penh's Administration System is?

○ ប្រព័ន្ធប្រជាធិបតេយ្យ - Democracy

○ ប្រព័ន្ធមជ្ឈការ - Centralization

○ ប្រព័ន្ធវិមជ្ឈការ - Decentralization

○ ប្រព័ន្ធវិសហមជ្ឈការ - Deconcentration

**សំណួរទី១១ (Q11)៖** ក្រុមប្រឹក្សារាជធានីភ្នំពេញ មិនមែនជាគណៈអភិបាលរាជធានីភ្នំពេញទេ។

Phnom Penh Capital Council is not the same as Governor of Phnom Penh Capital.

○ ត្រូវ - True

○ ខុស - False

**សំណួរទី១២ (Q12)៖** តើអ្នកដឹងពីភារកិច្ច តួនាទី និងសិទ្ធិអំណាចរបស់មន្ត្រីនៅសាលារាជធានីភ្នំពេញកម្រិតណា?

Rate how much you know about Phnom Penh's Capital Hall's entities' duties and authorities.

○ មិនដឹងសោះ - Absolutely No Idea

○ ដឹងច្បាស់ទាំងអស់ - Fully Understood

**សំណួរទី១៣ (Q13)៖** តើអ្នកបានដឹងពីផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រផ្សេងៗដែលសាលារាជធានីភ្នំពេញត្រូវអនុវត្តដែរទេ? (ដូចជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល, គោលនយោបាយ, និងលិខិតគតិយុត្តផ្សេងៗ)

Are you aware of the Phnom Penh Capital Hall's development plan and strategies? (Such as Government Development Strategies, Policies, and Legal Documents)

○ ខ្ញុំបានដឹង - I am aware of that.

○ ខ្ញុំមិនបានដឹង - I am not aware of that.

○ ខ្ញុំដឹងខ្លះៗ - I somehow aware of that.

**សំណួរទី១៤ (Q14)៖** តើអ្នកបានដឹងពីសមិទ្ធផលដែលសាលារាជធានីភ្នំពេញបានសម្រេចនៅក្នុងឆ្នាំ ២០២៣ និង២០២៤ដែរ ឬទេ?

Are you aware of Phnom Penh Capital Hall's achievements in 2023 and 2024?

○ ខ្ញុំបានដឹង - I am aware of that.

○ ខ្ញុំមិនបានដឹងទេ - I am not aware of that.

○ ខ្ញុំដឹងខ្លះៗ - I somehow aware of that.

**សំណួរទី១៥ (Q15)៖** តើមានអ្វីដែលអ្នកចង់ឃើញ ឬសំណូមពរទៅដល់សាលារាជធានីភ្នំពេញដែរឬទេ? (ទាក់ទងទៅនឹងការអភិវឌ្ឍន៍, ការរឹតបន្តឹងសន្តាប់ធ្នាប់, ល្បឿនសេវាសាធារណៈ ។ល។)

Are there anything you want to say or wish to see in the future plan of Phnom Penh Capital Hall? (Such as Development Plans, Security and Order, Processes of Services, etc.)

ប្រសិនបើគ្មានសូមដាក់ N/A

If you do not have anything to say, please input N/A.

______________________________________________

______________________________________________

______________________________________________

______________________________________________

**ការទទួលស្គាល់ពីភាពត្រឹមត្រូវ៖** ខ្ញុំទទួលស្គាល់ថាចម្លើយដែលយើងខ្ញុំឆ្លើយខាងលើគឺពិតជាត្រឹមត្រូវតាមការយល់ឃើញរបស់ខ្ញុំ និងឥតមានការបង្ខំឡើយ។

I acknowledged that all my answers above are truthful and not influenced by anyone.

○ បានឃើញ និងឯកភាព - Seen and Agreed

### ១.៣. គោលបំណងនៃសំណួរ

ការរៀបចំកម្រងសំណួរខាងលើនេះមានគោលបំណងសំខាន់ៗបួនយ៉ាង សម្រាប់ប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវគឺ៖

**គោលបំណងទី១៖** កំណត់នៅអត្តសញ្ញាណសម្រាប់បែងចែកប្រភេទនៃក្រុមរបស់អ្នកចូលរួមតាមរយៈសំណួរចំនួនបីគឺ Q1 Q2 និងQ3។

**គោលបំណងទី២៖** ប្រមូលព័ត៌មានរបស់អ្នកចូលរួមទាក់ទងនឹងការប្រើប្រាស់សេវាសាធារណៈ ការពេញចិត្ត និងផ្តត់គំនិតរបស់ប្រជាពលរដ្ឋចំពោះការយល់ដឹងពីប្រព័ន្ធរដ្ឋបាលរបស់រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានតាមរយៈសំណួរបីគឺ Q4 Q5 និងQ6។

**គោលបំណងទី៣៖** ប្រមូលព័ត៌មានដើម្បីកំណត់ពីការយល់ដឹងរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលនៅសាលរាជធានីភ្នំពេញឆ្នាំ២០២៣-២០២៤ តាមរយៈសំណួរប្រាំបីគឺ Q7 Q8 Q9 Q10 Q11 Q12 Q13 និងQ14។

**គោលបំណងទី៤៖** ប្រមូលព័ត៌មាននិងស្វែងយល់អំពី តម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញនៅក្នុងឆ្នាំ២០២៤ តាមរយៈសំណួរអធិប្បាយ Q15។

## ផ្នែកទី២ លទ្ធផលដែលទទួលបានគិតជាមធ្យម

លទ្ធផលជាមធ្យមនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋចំនួន១៩០នាក់នេះ យើងទទួលបានលទ្ធផលដូចខាងក្រោម៖

តារាងស្ថិតិចម្លើយដែលទទួលបានពីសំណួរនីមួយៗ

| សំណួរ | Q1 | Q2 | Q3 | Q4 | Q5 | Q6 | Q7 | Q8 | Q9 | Q10 | Q11 | Q12 | Q13 | Q14 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនចម្លើយ | ១៩០ | ១៩០ | ១៩០ | ១៩០ | ១៧២ | ១៨៩ | ១៩០ | ១៩០ | ១៩០ | ១៩០ | ១៩០ | ១៩០ | ១៩០ | ១៩០ |

## ២.១. លទ្ធផលព័ត៌មានពីអត្តសញ្ញាណគិតជាមធ្យម (គិតជាភាគរយ%)










## ២.២. លទ្ធផលព័ត៌មានពីការប្រើប្រាស់សេវាគិតជាមធ្យម (គិតជាភាគរយ%)









## ២.៣. លទ្ធផលព័ត៌មានពីការយល់ដឹងពីប្រព័ន្ធរដ្ឋបាលគិតជាមធ្យម (គិតជាភាគរយ%)





Q8
1 មិនដឹងសោះ - Absolutely No Idea
2 ដឹងតិចតួច - Least Understood
3 ដឹងខ្លះៗ - Average Understood
4 ដឹងច្រើន - Well Understood
5 ដឹងច្បាស់ទាំងអស់ - Fully Understood
15.8
32.6
37.4
10.5
3.7
0 ៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០




Q9
ខ្ញុំបានដឹង - I am aware of that.
ខ្ញុំមិនបានដឹងទេ - I am not aware of that.
ខ្ញុំដឹងខ្លះៗ - I somehow aware of that.
15.3
20
64.7
0 ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០




Q10
ប្រព័ន្ធប្រជាធិបតេយ្យ - Democracy
ប្រព័ន្ធមជ្ឈការ - Centralization
ប្រព័ន្ធវិមជ្ឈការ - Decentralization
ប្រព័ន្ធវិសហមជ្ឈការ - Deconcentration
46.3
18.4
21.6
13.7
0 ១០ ២០ ៣០ ៤០ ៥០




Q11
ត្រូវ - True
ខុស - False
21.6
27.4
0 ៥ ១០ ១៥ ២០ ២៥ ៣០










# ផ្នែកទី៣ លទ្ធផលដែលទទួលបានគិតតាមក្រុមអ្នកចូលរួម

លទ្ធផលគិតទៅតាមប្រភេទក្រុមនេះនឹងត្រូវកំណត់បែងចែកជាបីក្រុមសំខាន់ៗគឺ ក្រុមនិស្សិត ក្រុមអ្នកធ្វើការ/រកស៊ី និងក្រុមនិស្សិតមានការងារធ្វើ។

## ៣.១. លទ្ធផលក្រុមនិស្សិត (គិតជាចំនួននាក់)

ការសិក្សាទៅលើលទ្ធផលនេះនឹងកំណត់បែងចែកនិស្សិតជាបីក្រុមដូចខាងក្រោម៖

| ប្រភេទក្រុមនិស្សិត | និស្សិតជំនាញវិទ្យាសាស្ត្រសង្គម | និស្សិតជំនាញវិទ្យាសាស្ត្រពិត | និស្សិតជំនាញផ្សេងៗ |
|---|---|---|---|
| ចំនួន | ៦៦ | ៦៨ | ៣ |

## ៣.១.១. ក្រុមនិស្សិតជំនាញវិទ្យាសាស្ត្រសង្គម

### ៣.១.១.១. លទ្ធផលលើការប្រើប្រាស់សេវា (គិតជាចំនួននាក់)

| | Q4 | Q5 (មិនពេញចិត្តខ្លាំង) | Q3 (១) | Q3 (២&៣) |
|---|---|---|---|---|
| ចំនួនអ្នកបានប្រើ | ៤៣ | ៤ | ១ | ៣ |
| ចំនួនអ្នកមិនបានប្រើ | ២៣ | - | - | - |

***កំណត់សម្គាល់៖*** Q5 និងQ3 គិតតែអ្នកដែលមិនពេញចិត្តតែប៉ុណ្ណោះ។

### ៣.១.១.២. លទ្ធផលនៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល (គិតជាចំនួននាក់)

លទ្ធផលនិស្សិតវិទ្យាសាស្ត្រសង្គមដែលគិតថាការយល់ដឹងពីប្រព័ន្ធរដ្ឋបាលមានសារៈសំខាន់

| | គ្មានសារៈសំខាន់ | សំខាន់តិចតួច | សំខាន់ | សំខាន់ខ្លាំង | សំខាន់ខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួននិស្សិត (Q6) | ២ | ៣ | ១៦ | ១៧ | ២៨ |

លទ្ធផលការយល់ដឹងរបស់និស្សិតវិទ្យាសាស្ត្រសង្គម (យោងតាមចម្លើយត្រឹមត្រូវ)

| ចំនួនចម្លើយត្រឹមត្រូវ (Q10 &Q11) | ១ | ២ |
|---|---|---|
| ចំនួននិស្សិត | ៥៦ | ២០ |

***កំណត់សម្គាល់៖*** ចំនួនចម្លើយត្រឹមត្រូវ សំដៅដល់ចំនួនចម្លើយត្រឹមត្រូវយ៉ាងតិចដែលនិស្សិតម្នាក់ៗបានឆ្លើយ។

លទ្ធផលការយល់ដឹងរបស់និស្សិតវិទ្យាសាស្ត្រសង្គម (យោងតាមការវាយតម្លៃ)

| | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួននិស្សិត (Q7) | ៧ | ១៣ | ៣១ | ១៤ | ១ |
| ចំនួននិស្សិត (Q8) | ១១ | ១៥ | ២៧ | ១២ | ១ |
| ចំនួននិស្សិត (Q12) | ៩ | ១៩ | ២៧ | ១០ | ១ |
| ចំនួននិស្សិត ($Qn^1$) | ៤ | ២ | ១០ | ៥ | ១ |

***កំណត់សម្គាល់៖*** $Qn^1$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q7 Q8 និងQ12។ ដូចនេះចំនួននិស្សិត ($Qn^1$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

លទ្ធផលនៃចំនួននិស្សិតវិទ្យាសាស្ត្រសង្គមដែលមិនបានដឹងអ្វីសោះនិងដឹងទាំងអស់ពីប្រព័ន្ធរដ្ឋបាល

| | |
|---|---|
| ចំនួននិស្សិតដែលឆ្លើយខុស និងមិនដឹងសោះ | 0 |

| | |
|---|---|
| ចំនួននិស្សិតដែលឆ្លើយត្រូវ និងដឹងទាំងអស់ | 0 |

### ៣.១.១.៣. លទ្ធផលនៃការយល់ដឹងពីសេវាសាធារណៈ សមិទ្ធផល និងផែនការអភិវឌ្ឍ

| | បានដឹង | បានដឹងខ្លះៗ | មិនបានដឹងសោះ |
|---|---|---|---|
| ចំនួននិស្សិត (Q9) | ៩ | ៤៩ | ៨ |
| ចំនួននិស្សិត (Q13) | ៦ | ៤៥ | ១៥ |
| ចំនួននិស្សិត (Q14) | ៥ | ៣៩ | ២២ |
| ចំនួននិស្សិត ($Qn^2$) | ១ | ២៦ | ៦ |

***កំណត់សម្គាល់៖*** $Qn^2$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q9 Q13 និងQ14។ ដូចនេះចំនួននិស្សិត ($Qn^2$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

## ៣.១.២. ក្រុមនិស្សិតជំនាញវិទ្យាសាស្ត្រពិត

### ៣.១.២.១. លទ្ធផលលើការប្រើប្រាស់សេវា (គិតជាចំនួននាក់)

| | Q4 | Q5 (មិនពេញចិត្តខ្លាំង) | Q3 (១) | Q3 (២&៣) |
|---|---|---|---|---|
| ចំនួនអ្នកបានប្រើ | ៤២ | ៣ | ២ | ១ |
| ចំនួនអ្នកមិនបានប្រើ | ២៦ | - | - | - |

***កំណត់សម្គាល់៖*** Q5 និងQ3 គិតតែអ្នកដែលមិនពេញចិត្តតែប៉ុណ្ណោះ។

### ៣.១.២.២. លទ្ធផលនៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល (គិតជាចំនួននាក់)

លទ្ធផលនិស្សិតវិទ្យាសាស្ត្រពិតដែលគិតថាការយល់ដឹងពីប្រព័ន្ធរដ្ឋបាលមានសារៈសំខាន់

| | គ្មានសារៈសំខាន់ | សំខាន់តិចតួច | សំខាន់ | សំខាន់ខ្លាំង | សំខាន់ខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួននិស្សិត (Q6) | ២ | ៤ | ១៧ | ១៦ | ២៩ |

លទ្ធផលការយល់ដឹងរបស់និស្សិតវិទ្យាសាស្ត្រពិត (យោងតាមចម្លើយត្រឹមត្រូវ)

| ចំនួនចម្លើយត្រឹមត្រូវ (Q10 &Q11) | ១ | ២ |
|---|---|---|
| ចំនួននិស្សិត | ៤២ | ១០ |

***កំណត់សម្គាល់៖*** ចំនួនចម្លើយត្រឹមត្រូវ សំដៅដល់ចំនួនចម្លើយត្រឹមត្រូវយ៉ាងតិចដែលនិស្សិតម្នាក់ៗបានឆ្លើយ។

លទ្ធផលការយល់ដឹងរបស់និស្សិតវិទ្យាសាស្ត្រពិត (យោងតាមការវាយតម្លៃ)

| | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួននិស្សិត (Q7) | ៩ | ២០ | ៣៤ | ០ | ១ |
| ចំនួននិស្សិត (Q8) | ៩ | ២៥ | ២៩ | ៤ | ១ |
| ចំនួននិស្សិត (Q12) | ១៧ | ២៥ | ២១ | ៥ | ០ |
| ចំនួននិស្សិត ($Qn^1$) | ៥ | ៦ | ១៦ | ២ | ០ |

***កំណត់សម្គាល់៖*** $Qn^1$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q7 Q8 និងQ12។ ដូចនេះចំនួននិស្សិត ($Qn^1$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

លទ្ធផលនៃចំនួននិស្សិតវិទ្យាសាស្ត្រសង្គមដែលមិនបានដឹងអ្វីសោះ និងដឹងទាំងអស់ពីប្រព័ន្ធរដ្ឋបាល

| | |
|---|---|
| ចំនួននិស្សិតដែលឆ្លើយខុស និងមិនដឹងសោះ | ៣ |
| ចំនួននិស្សិតដែលឆ្លើយត្រូវ និងដឹងទាំងអស់ | ០ |

### ៣.១.២.៣. លទ្ធផលនៃការយល់ដឹងពីសេវាសាធារណៈ សមិទ្ធផល និងផែនការអភិវឌ្ឍ

| | បានដឹង | បានដឹងខ្លះៗ | មិនបានដឹងសោះ |
|---|---|---|---|
| ចំនួននិស្សិត (Q9) | ១៤ | ៣៦ | ១៨ |
| ចំនួននិស្សិត (Q13) | ៩ | ២៥ | ៣៤ |
| ចំនួននិស្សិត (Q14) | ៧ | ៣២ | ២៩ |
| ចំនួននិស្សិត ($Qn^2$) | ៣ | ១៣ | ១៣ |

***កំណត់សម្គាល់៖*** $Qn^2$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q9 Q13 និងQ14។ ដូចនេះចំនួននិស្សិត ($Qn^2$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

## ៣.២. លទ្ធផលក្រុមអ្នកធ្វើការ/រកស៊ី (គិតជាចំនួននាក់)

ការសិក្សាទៅលើលទ្ធផលនេះនឹងកំណត់បែងចែកក្រុមអ្នកធ្វើការ/រកស៊ីជាបីក្រុមដូចខាងក្រោម៖

| ប្រភេទក្រុមអ្នកមានមុខរបរ | ក្រុមជំនាញវិទ្យាសាស្ត្រសង្គម | ក្រុមជំនាញវិទ្យាសាស្ត្រពិត | ក្រុមជំនាញផ្សេងៗ |
|---|---|---|---|
| ចំនួន | ១៤ | ៩ | ០ |

## ៣.២.១. ក្រុមអ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គម

### ៣.២.១.១. លទ្ធផលលើការប្រើប្រាស់សេវា (គិតជាចំនួននាក់)

| | Q4 | Q5 (មិនពេញចិត្តខ្លាំង) | Q3 (១) | Q3 (២&៣) |
|---|---|---|---|---|
| ចំនួនអ្នកបានប្រើ | ៦ | 0 | 0 | 0 |
| ចំនួនអ្នកមិនបានប្រើ | ៨ | - | - | - |

***កំណត់សម្គាល់៖*** Q5 និងQ3 គិតតែអ្នកដែលមិនពេញចិត្តតែប៉ុណ្ណោះ។

### ៣.២.១.២. លទ្ធផលនៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល (គិតជាចំនួននាក់)

លទ្ធផលអ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គមដែលគិតថាការយល់ដឹងពីប្រព័ន្ធរដ្ឋបាលមានសារៈសំខាន់

| | គ្មានសារៈសំខាន់ | សំខាន់តិចតួច | សំខាន់ | សំខាន់ខ្លាំង | សំខាន់ខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q6) | 0 | ១ | ២ | ១ | ១០ |

លទ្ធផលការយល់ដឹងរបស់អ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គម (យោងតាមចម្លើយត្រឹមត្រូវ)

| ចំនួនចម្លើយត្រឹមត្រូវ (Q10 &Q11) | ១ | ២ |
|---|---|---|
| ចំនួនបុគ្គល | ១៣ | ៦ |

***កំណត់សម្គាល់៖*** ចំនួនចម្លើយត្រឹមត្រូវ សំដៅដល់ចំនួនចម្លើយត្រឹមត្រូវយ៉ាងតិចដែលបុគ្គលម្នាក់ៗបានឆ្លើយ។

លទ្ធផលការយល់ដឹងរបស់អ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គម (យោងតាមការវាយតម្លៃ)

| | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q7) | ៣ | ៥ | ៤ | ១ | ១ |
| ចំនួនបុគ្គល (Q8) | ៤ | ៥ | ៣ | ១ | ១ |
| ចំនួនបុគ្គល (Q12) | ៧ | ៣ | ២ | ១ | ១ |
| ចំនួនបុគ្គល ($Qn^1$) | ៣ | ១ | ១ | 0 | 0 |

***កំណត់សម្គាល់៖*** $Qn^1$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q7 Q8 និងQ12។ ដូចនេះចំនួនបុគ្គល ($Qn^1$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

លទ្ធផលនៃចំនួនអ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គមដែលមិនបានដឹងអ្វីសោះនិងដឹងទាំងអស់ពីប្រព័ន្ធរដ្ឋបាល

| | |
|---|---|
| ចំនួនបុគ្គលដែលឆ្លើយខុស និងមិនដឹងសោះ | 0 |

| | |
|---|---|
| ចំនួនបុគ្គលដែលឆ្លើយត្រូវ និងដឹងទាំងអស់ | 0 |

### ៣.២.១.៣. លទ្ធផលនៃការយល់ដឹងពីសេវាសាធារណៈ សមិទ្ធផល និងផែនការអភិវឌ្ឍ

| | បានដឹង | បានដឹងខ្លះៗ | មិនបានដឹងសោះ |
|---|---|---|---|
| ចំនួនបុគ្គល (Q9) | ៣ | ៦ | ៥ |
| ចំនួនបុគ្គល (Q13) | ២ | ៧ | ៥ |
| ចំនួនបុគ្គល (Q14) | ១ | ៦ | ៧ |
| ចំនួនបុគ្គល ($Qn^2$) | ១ | ៥ | ៥ |

***កំណត់សម្គាល់៖*** $Qn^2$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q9 Q13 និងQ14។ ដូចនេះចំនួនបុគ្គល ($Qn^2$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

## ៣.២.២. ក្រុមអ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិត

### ៣.២.២.១. លទ្ធផលលើការប្រើប្រាស់សេវា (គិតជាចំនួននាក់)

| | Q4 | Q5 (មិនពេញចិត្តខ្លាំង) | Q3 (១) | Q3 (២&៣) |
|---|---|---|---|---|
| ចំនួនអ្នកបានប្រើ | ៤ | ៣ | ២ | ១ |
| ចំនួនអ្នកមិនបានប្រើ | ៥ | - | - | - |

***កំណត់សម្គាល់៖*** Q5 និងQ3 គិតតែអ្នកដែលមិនពេញចិត្តតែប៉ុណ្ណោះ។

### ៣.២.២.២. លទ្ធផលនៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល (គិតជាចំនួននាក់)

លទ្ធផលអ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិតដែលគិតថាការយល់ដឹងពីប្រព័ន្ធរដ្ឋបាលមានសារៈសំខាន់

| | គ្មានសារៈសំខាន់ | សំខាន់តិចតួច | សំខាន់ | សំខាន់ខ្លាំង | សំខាន់ខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q6) | 0 | ១ | 0 | ១ | ៦ |

លទ្ធផលការយល់ដឹងរបស់អ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិត (យោងតាមចម្លើយត្រឹមត្រូវ)

| ចំនួនចម្លើយត្រឹមត្រូវ (Q10 &Q11) | ១ | ២ |
|---|---|---|
| ចំនួនបុគ្គល | ៦ | ១ |

***កំណត់សម្គាល់៖*** ចំនួនចម្លើយត្រឹមត្រូវ សំដៅដល់ចំនួនចម្លើយត្រឹមត្រូវយ៉ាងតិចដែលបុគ្គលម្នាក់ៗបានឆ្លើយ។

លទ្ធផលការយល់ដឹងរបស់អ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិត (យោងតាមការវាយតម្លៃ)

| | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q7) | ១ | ៤ | ២ | ១ | ១ |
| ចំនួនបុគ្គល (Q8) | ២ | ៤ | ២ | ០ | ១ |
| ចំនួនបុគ្គល (Q12) | ៣ | ៣ | ៣ | ០ | ០ |
| ចំនួនបុគ្គល ($Qn^1$) | ១ | ១ | ០ | ០ | ០ |

***កំណត់សម្គាល់៖*** $Qn^1$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q7 Q8 និងQ12។ ដូចនេះចំនួនបុគ្គល ($Qn^1$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

លទ្ធផលនៃចំនួនអ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គមដែលមិនបានដឹងអ្វីសោះ និងដឹងទាំងអស់ពីប្រព័ន្ធរដ្ឋបាល

| | |
|---|---|
| ចំនួនបុគ្គលដែលឆ្លើយខុស និងមិនដឹងសោះ | ០ |
| ចំនួនបុគ្គលដែលឆ្លើយត្រូវ និងដឹងទាំងអស់ | ០ |

#### ៣.២.២.៣. លទ្ធផលនៃការយល់ដឹងពីសេវាសាធារណៈ សមិទ្ធផល និងផែនការអភិវឌ្ឍ

| | បានដឹង | បានដឹងខ្លះៗ | មិនបានដឹងសោះ |
|---|---|---|---|
| ចំនួនបុគ្គល (Q9) | ០ | ៧ | ២ |
| ចំនួនបុគ្គល (Q13) | ២ | ៤ | ៣ |
| ចំនួនបុគ្គល (Q14) | ១ | ៥ | ៣ |
| ចំនួនបុគ្គល ($Qn^2$) | ០ | ៣ | ១ |

***កំណត់សម្គាល់៖*** $Qn^2$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q9 Q13 និងQ14។ ដូចនេះចំនួនបុគ្គល ($Qn^2$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

### ៣.៣. លទ្ធផលក្រុមនិស្សិតដែលធ្វើការ/រកស៊ី (គិតជាចំនួននាក់)

ការសិក្សានៃលទ្ធផលនេះនឹងកំណត់បែងចែកក្រុមនិស្សិតដែលធ្វើការ/រកស៊ីជាបីក្រុមដូចខាងក្រោម៖

| ប្រភេទក្រុមអ្នកមានមុខរបរ | ក្រុមជំនាញវិទ្យាសាស្ត្រសង្គម | ក្រុមជំនាញវិទ្យាសាស្ត្រពិត | ក្រុមជំនាញផ្សេងៗ |
|---|---|---|---|
| ចំនួន | ១៨ | ១០ | ២ |

## ៣.៣.១. ក្រុមនិស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គម

### ៣.៣.១.១. លទ្ធផលលើការប្រើប្រាស់សេវា (គិតជាចំនួននាក់)

| | Q4 | Q5 (មិនពេញចិត្តខ្លាំង) | Q3 (១) | Q3 (២&៣) |
|---|---|---|---|---|
| ចំនួនអ្នកបានប្រើ | ១២ | 0 | - | - |
| ចំនួនអ្នកមិនបានប្រើ | ៦ | - | - | - |

***កំណត់សម្គាល់៖*** Q5 និងQ3 គិតតែអ្នកដែលមិនពេញចិត្តតែប៉ុណ្ណោះ។

### ៣.៣.១.២. លទ្ធផលនៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល (គិតជាចំនួននាក់)

លទ្ធផលនិស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គមដែលគិតថាការយ់ដឹងពីប្រព័ន្ធរដ្ឋបាលមានសារៈសំខាន់

| | គ្មានសារៈសំខាន់ | សំខាន់តិចតួច | សំខាន់ | សំខាន់ខ្លាំង | សំខាន់ខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q6) | 0 | ២ | ៣ | ៤ | ៩ |

លទ្ធផលការយល់ដឹងរបស់និស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គម (យោងតាមចម្លើយត្រឹមត្រូវ)

| ចំនួនចម្លើយត្រឹមត្រូវ (Q10 &Q11) | ១ | ២ |
|---|---|---|
| ចំនួនបុគ្គល | ១៧ | ៧ |

***កំណត់សម្គាល់៖*** ចំនួនចម្លើយត្រឹមត្រូវ សំដៅដល់ចំនួនចម្លើយត្រឹមត្រូវយ៉ាងតិចដែលបុគ្គលម្នាក់ៗបានឆ្លើយ។

លទ្ធផលការយល់ដឹងរបស់និស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គម (យោងតាមការវាយតម្លៃ)

| | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q7) | ១ | ៥ | ៦ | ៥ | ១ |
| ចំនួនបុគ្គល (Q8) | ២ | ៦ | ៥ | ២ | ៣ |
| ចំនួនបុគ្គល (Q12) | ៣ | ៤ | ១០ | ១ | 0 |
| ចំនួនបុគ្គល ($Qn^1$) | 0 | ២ | ២ | 0 | 0 |

***កំណត់សម្គាល់៖*** $Qn^1$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q7 Q8 និងQ12។ ដូចនេះចំនួនបុគ្គល ($Qn^1$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

លទ្ធផលនៃចំនួនអ្នកធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គមដែលមិនបានដឹងអ្វីសោះនិងដឹងទាំងអស់ពីប្រព័ន្ធរដ្ឋបាល

| | |
|---|---|
| ចំនួនបុគ្គលដែលឆ្លើយខុស និងមិនដឹងសោះ | 0 |

| | |
|---|---|
| ចំនួនបុគ្គលដែលឆ្លើយត្រូវ និងដឹងទាំងអស់ | ០ |

### ៣.៣.១.៣. លទ្ធផលនៃការយល់ដឹងពីសេវាសាធារណៈ សមិទ្ធផល និងផែនការអភិវឌ្ឍ

| | បានដឹង | បានដឹងខ្លះៗ | មិនបានដឹងសោះ |
|---|---|---|---|
| ចំនួនបុគ្គល (Q9) | ៣ | ១៣ | ២ |
| ចំនួនបុគ្គល (Q13) | ០ | ១៣ | ៥ |
| ចំនួនបុគ្គល (Q14) | ១ | ៩ | ៨ |
| ចំនួនបុគ្គល ($Qn^2$) | ០ | ៧ | ០ |

***កំណត់សម្គាល់៖*** $Qn^2$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q9 Q13 និងQ14។ ដូចនេះចំនួនបុគ្គល ($Qn^2$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

## ៣.៣.២. ក្រុមនិស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិត

### ៣.៣.២.១. លទ្ធផលលើការប្រើប្រាស់សេវា (គិតជាចំនួននាក់)

| | Q4 | Q5 (មិនពេញចិត្តខ្លាំង) | Q3 (១) | Q3 (២&៣) |
|---|---|---|---|---|
| ចំនួនអ្នកបានប្រើ | ៥ | ០ | - | - |
| ចំនួនអ្នកមិនបានប្រើ | ៥ | - | - | - |

***កំណត់សម្គាល់៖*** Q5 និងQ3 គិតតែអ្នកដែលមិនពេញចិត្តតែប៉ុណ្ណោះ។

### ៣.៣.២.២. លទ្ធផលនៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល (គិតជាចំនួននាក់)

លទ្ធផលនិស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិតដែលគិតថាការយល់ដឹងពីប្រព័ន្ធរដ្ឋបាលមានសារៈសំខាន់

| | គ្មានសារៈសំខាន់ | សំខាន់តិចតួច | សំខាន់ | សំខាន់ខ្លាំង | សំខាន់ខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q6) | ០ | ២ | ១ | ៤ | ៣ |

លទ្ធផលការយល់ដឹងរបស់និស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិត (យោងតាមចម្លើយត្រឹមត្រូវ)

| ចំនួនចម្លើយត្រឹមត្រូវ (Q10 &Q11) | ១ | ២ |
|---|---|---|
| ចំនួនបុគ្គល | ៨ | ២ |

***កំណត់សម្គាល់៖*** ចំនួនចម្លើយត្រឹមត្រូវ សំដៅដល់ចំនួនចម្លើយត្រឹមត្រូវយ៉ាងតិចដែលបុគ្គលម្នាក់ៗបានឆ្លើយ។

លទ្ធផលការយល់ដឹងរបស់និស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រពិត (យោងតាមការវាយតម្លៃ)

| | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួនបុគ្គល (Q7) | ០ | ៣ | ៧ | ០ | ០ |
| ចំនួនបុគ្គល (Q8) | ១ | ៥ | ៣ | ១ | ០ |
| ចំនួនបុគ្គល (Q12) | ១ | ២ | ៦ | ១ | ០ |
| ចំនួនបុគ្គល ($Qn^1$) | ០ | ១ | ៣ | ០ | ០ |

***កំណត់សម្គាល់៖*** $Qn^1$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q7 Q8 និងQ12។ ដូចនេះចំនួនបុគ្គល ($Qn^1$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

លទ្ធផលនៃចំនួននិស្សិតដែលធ្វើការ/រកស៊ីវិស័យវិទ្យាសាស្ត្រសង្គមដែលមិនបានដឹងអ្វីសោះ និងដឹងទាំងអស់ពីប្រព័ន្ធរដ្ឋបាល

| | |
|---|---|
| ចំនួនបុគ្គលដែលឆ្លើយខុស និងមិនដឹងសោះ | 0 |
| ចំនួនបុគ្គលដែលឆ្លើយត្រូវ និងដឹងទាំងអស់ | 0 |

### ៣.៣.២.៣. លទ្ធផលនៃការយល់ដឹងពីសេវាសាធារណៈ សមិទ្ធផល និងផែនការអភិវឌ្ឍ

| | បានដឹង | បានដឹងខ្លះៗ | មិនបានដឹងសោះ |
|---|---|---|---|
| ចំនួនបុគ្គល (Q9) | ០ | ៨ | ២ |
| ចំនួនបុគ្គល (Q13) | ០ | ៧ | ៣ |
| ចំនួនបុគ្គល (Q14) | ០ | ៦ | ៤ |
| ចំនួនបុគ្គល ($Qn^2$) | ០ | ៤ | ០ |

***កំណត់សម្គាល់៖*** $Qn^2$ សំដៅទៅដល់សំណួរទាំងបីខាងលើគឺ Q9 Q13 និងQ14។ ដូចនេះចំនួនបុគ្គល ($Qn^2$) សំដៅដល់ចំនួនដែលផ្តល់ចម្លើយដូចគ្នាចំពោះសំណួរទាំងបី។

## ផ្នែកទី៤ លទ្ធផលដែលទទួលបានគិតតាមបណ្តុំប្រភេទសំណួរ

ផ្នែកនេះ លទ្ធផលនៃការស្ទង់មតិនឹងត្រូវរៀបចំបែងចែកជាបណ្តុំនៃប្រភេទសំណួរ ដើម្បីកំណត់បែងចែកលទ្ធផលទៅតាមគោលបំណងនៃសំណួរនីមួយៗ និងគូសគំនូសតាងនៃលទ្ធផលដែលទទួលបានទៅតាមប្រភេទរៀងៗខ្លួន។

## ៤.១. លទ្ធផលតាមបណ្តុំប្រភេទសំណួរ

លទ្ធផលដែលទទួលបានត្រូវបានកំណត់និងបែងចែកជាបួនផ្នែកសំខាន់ៗគឺ ការពេញចិត្ត(ពីការផ្តល់សេវា) ផ្នត់គំនិត(ពីសារៈសំខាន់) ការយល់ដឹង(ពីប្រព័ន្ធរដ្ឋបាល) និងការស្វែងយល់(ពីសេវា សមិទ្ធផល និងផែនការ)។

### ៤.១.១. លទ្ធផលនៃការពេញចិត្ត (ពីការផ្តល់សេវា)

លទ្ធផលនៃការពេញចិត្តរបស់អ្នកបានទទួលសេវាសាធារណៈត្រូវបានបែងចែកជាប្រាំថ្នាក់គឺ៖

| Q5 | មិនពេញចិត្ត | ពេញចិត្តតិចតួច | ពេញចិត្ត | ពេញចិត្តខ្លាំង | ពេញចិត្តខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួននាក់ (ភាគរយ) | ១០ (៥.៤%) | ១៩ (១៦%) | ៤៤ (៣៧%) | ២៩ (២៤.៤%) | ១៧ (១៤.២%) |

### ៤.១.២. លទ្ធផលនៃផ្នត់គំនិត (ពីសារៈសំខាន់)

លទ្ធផលនៃផ្នត់គំនិតរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញត្រូវបានបែងចែកជាប្រាំថ្នាក់គឺ៖

| Q6 | គ្មានសារៈសំខាន់ | សំខាន់តិចតួច | សំខាន់ | សំខាន់ខ្លាំង | សំខាន់ខ្លាំងណាស់ |
|---|---|---|---|---|---|
| ចំនួននាក់ (ភាគរយ) | ៥ (២.៦%) | ១៣ (៦.៩%) | ៤១ (២១.៧%) | ៤៣ (២៣.៣%) | ៨៦ (៤៥.៥%) |

### ៤.១.៣. លទ្ធផលនៃការយល់ដឹង (ពីប្រព័ន្ធរដ្ឋបាល)

លទ្ធផលនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញត្រូវបានបែងចែកជាពីរប្រភេទ ដើម្បីរកចំណុចរួមមួយ។ នៅក្នុងផ្នែកទីមួយ លទ្ធផលនឹងត្រូវបែងចែកជាបីផ្នែកផ្អែកតាមចំនួនចម្លើយត្រឹមត្រូវដែលបានឆ្លើយដូចខាងក្រោម៖

លទ្ធផលនៃផ្នែកទី១នៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល

| (Q10 &Q11) | 0 | ១ | ២ |
|---|---|---|---|
| ចំនួន (ភាគរយ) | ៣៣ (១៧.៤%) | ១០៩ (៥៧.៤%) | ៤៨ (២៥.២%) |

នៅក្នុងផ្នែកទីពីរ លទ្ធផលនឹងត្រូវបានកំណត់បែងចែកជាប្រាំថ្នាក់ និងដែលលទ្ធផលនៃថ្នាក់នីមួយៗគឺបានពីការគណនារកតម្លៃមធ្យមនៃចម្លើយរបស់សំណួរទាំងបី(Q7, Q8, Q12)ដូចខាងក្រោម៖

លទ្ធផលនៃផ្នែកទី២នៃការយល់ដឹងពីប្រព័ន្ធរដ្ឋបាល

| Q7, Q8, Q12 | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួននាក់ (ភាគរយ) | ១៤ (៧.៤%) | ៧១ (៣៧.៤%) | ៨៧ (៤៥.៨%) | ១៧ (៨.៩%) | ១ (0.៥%) |

ដើម្បីគូសគំនូសតាងលទ្ធផលទាំងពីរនេះ យើងនឹងគណនារកភាគរយនៃថ្នាក់នីមួយៗ ដោយសន្និដ្ឋានថា ០(ផ្នែកទី១)=មិនដឹងសោះនិងដឹងតិចតួច(ផ្នែកទី២) ១(ផ្នែកទី១)=ដឹងខ្លះៗ(ផ្នែកទី២) និង៣(ផ្នែកទី១)=ដឹងច្រើននិងដឹងទាំងអស់(ផ្នែកទី២)។ ជាលទ្ធផលយើងបាន៖

- មធ្យម(%)នៃថ្នាក់១គឺ៖ $\frac{៧.៤+(១៧.៤/២)}{២}$ = ៨.១%
- មធ្យម(%)នៃថ្នាក់២គឺ៖ $\frac{៣៧.៤+(១៧.៤/២)}{២}$ = ២៣.១%
- មធ្យម(%)នៃថ្នាក់៣គឺ៖ $\frac{៥៧.៤+៤៥.៨}{២}$ = ៥១.៦%
- មធ្យម(%)នៃថ្នាក់៤គឺ៖ $\frac{៨.៩+(២៥.២/២)}{២}$ = ១០.៧%
- មធ្យម(%)នៃថ្នាក់៥គឺ៖ $\frac{០.៥+(២៥.២/២)}{២}$ = ៦.៥%។

### ៤.១.៤. លទ្ធផលនៃការស្វែងយល់ (ពីសេវា សមិទ្ធផល និងផែនការ)

លទ្ធផលនៃការស្វែងយល់(ពីសេវា សមិទ្ធផល និងផែនការ)របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញនឹងត្រូវកំណត់បែងចែកជាបីថ្នាក់ដូចខាងក្រោម៖

| Q9, Q13, Q14 | មិនដឹងសោះ | ដឹងតិចតួច | ដឹងខ្លះៗ | ដឹងច្រើន | ដឹងទាំងអស់ |
|---|---|---|---|---|---|
| ចំនួននាក់ (ភាគរយ) | ២៦ (១៣.៧%) | ៦០ (៣១.៦%) | ៧២ (៣៧.៩%) | ២៧ (១៤.២%) | ៥ (២.៦%) |

## ៤.២. គំនូសតាងនៃលទ្ធផលតាមបណ្តុំប្រភេទសំណួរ

### ៤.២.១. គំនូសតាងលទ្ធផលតាមបណ្តុំប្រភេទសំណួរ






តម្លៃនៅក្នុងគំនូសតាងនេះមានន័យថាៈ ១-ខ្សោយណាស់ ២-ខ្សោយ ៣-មធ្យម ៤-ល្អ ៥-ល្អណាស់។

## ៤.៣.២. គំនូសប្រៀបធៀបលទ្ធផលរវាងចំណុចទាបបំផុត និងខ្ពស់បំផុត

គំនូសនេះបង្ហាញពីចំនួនប្រជាជនដែលស្ថិតនៅក្នុង២ថ្នាក់ដំបូង(កម្រិតខ្សោយ) និងពីរថ្នាក់ចុងក្រោយ (កម្រិតល្អ)ទៅតាមបណ្តុំប្រភេទសំណួរ។



# ផ្នែកទី៥ លទ្ធផលនៃតម្រូវការរបស់អ្នកចូលរួម

ដើម្បីកំណត់ឱ្យបានច្បាស់ពីតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ លទ្ធផលដែលទទួលបាននឹងត្រូវបានកំណត់នឹងបែងចែកទៅតាមវិស័យដូចលទ្ធផលខាងក្រោមដូចខាងក្រោម៖

| | |
|---|---|
| **ចំនួនលទ្ធផលដែលទទួលបាន** | ៥៩ |

លទ្ធផលដែលទទួលបានទៅតាមភាពពាក់ព័ន្ធនៃតម្រូវការ

| **ប្រភេទចម្លើយ** | **ចំនួនលទ្ធផលដែលទទួលបាន** |
|---|---|
| សេវារដ្ឋបាល | ១២ |
| រៀបចំក្រុង | ១០ |
| គ្រប់គ្រងសំណល់ និងបរិស្ថាន | ៧ |
| សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង | ៧ |
| កិច្ចការច្បាប់ និងសិទ្ធិមនុស្ស | ៥ |
| សន្តិសុខ សណ្តាប់ធ្នាប់សង្គម | ១២ |
| សាធារណការ និងដឹកជញ្ជូន (ចរាចរណ៍) | ៧ |
| ផ្សេងៗ | ៥ |

## ៥.១. តម្រូវការទាក់ទងនឹងសេវារដ្ឋបាល

ផ្អែកតាមការស្ទង់មតិនិងលទ្ធផលដែលទទួលបាន ក្នុងនោះមានចម្លើយចំនួន១២ដែលទាក់ទងទៅនឹងតម្រូវការផ្នែកសេវារដ្ឋបាល។ ខ្លឹមសារនៃតម្រូវការ និងបញ្ហាសំខាន់ៗនៅក្នុងនោះទាក់ទងនឹងចំណុចធំៗពីរគឺ៖ ល្បឿននៃសេវាសាធារណៈ និងដំណើរការនៃសេវាសាធារណៈ។

ល្បឿននៃសេវាសាធារណៈគឺជាបញ្ហាចោទ និងតម្រូវការចម្បងមួយដែលប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញត្រូវការ។ នៅក្នុងសេវាមួយចំនួនដូចជា ការងារនីត្យានុកូលកម្ម និងការងាររដ្ឋបាល ប្រើប្រាស់ពេលវេលាច្រើនដើម្បីសម្រេចដែលវាបានបង្អាក់ដល់ដំណើរការនៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ក្រៅពីការប្រើប្រាស់ពេលវេលាយូរប្រជាពលរដ្ឋក៏មានតម្រូវការទាក់ទងនឹងដំណើរការនៃសេវាសាធារណៈដែរ ដែលទាមទារឱ្យមានកំណែរទម្រង់បន្ថែមទាក់ទងនឹងនីតិវិធី។ ការកែប្រែសំបុត្រកំណើតជាឧទាហរណ៍ ដែលទាមទារឱ្យមានការឆ្លងកាត់ច្រើនដំណាក់កាល និងប្រើប្រាស់ពេលវេលាច្រើន។

## ៥.២. តម្រូវការទាក់ទងនឹងការរៀបចំក្រុង

ការរៀបចំគ្រប់គ្រងទីក្រុងគឺជាតម្រូវការមួយដែលគួរឱ្យកត់សម្គាល់ផងដែរ។ នៅក្នុងលទ្ធផលទាំង ១០នេះ តម្រូវការដែលមានគឺទាក់ទងទៅនឹងការប្រើប្រាស់ និងគ្រប់គ្រងដីសាធារណៈ។ សំណូមពរមួយចំនួនធំមានដូចជា ការគ្រប់គ្រងជញ្ជើមផ្លូវដើម្បីកុំឱ្យមានការលក់ដូរបែបអាណាធិបតេយ្យ ការរៀបចំដាំដើមឈើនៅតាមដងផ្លូវ និងការគ្រប់គ្រងប្រព័ន្ធទឹក។

## ៥.៣. តម្រូវការទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង និងបរិស្ថាន

តម្រូវការទាក់ទងនឹងការគ្រប់គ្រងកាកសំណល់ និងបរិស្ថានបានក្លាយជាតម្រូវការមួយដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ។ យោងតាមលទ្ធផលដែលទទួលបានប្រជាពលរដ្ឋភាគច្រើនសំណូមពរឱ្យមានការចាត់វិធានការនិងរឹតបន្តឹងការគ្រប់គ្រងសម្រាមដូចជាថង់ប្លាស្ទិច ការរៀបចំពេលវេលាក្នុងការប្រមូលសម្រាម និងការបែងចែកប្រភេទសម្រាមឱ្យបានច្បាស់លាស់។ នៅក្នុងការអនុវត្ត និងអភិវឌ្ឍនេះប្រជាពលរដ្ឋបានសំណូមពរឱ្យបានការផ្សព្វផ្សាយពីនីតិវិធី និងគោលនយោបាយផ្សេងៗឱ្យបានកាន់តែច្រើននិងប្រសើរឡើង ដើម្បីជម្រុញឱ្យមានការចូលរួមទាំងអស់គ្នា។

## ៥.៤. តម្រូវការសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង

សេវាដឹកជញ្ជូនសាធារណៈដែលជាតម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានបែងចែកជាពីរ ដែលមួយផ្នែកធំទាក់ទងនឹងសេវាឡានក្រុង និងមួយផ្នែកទៀតទាក់ទងនឹងការអភិវឌ្ឍមធ្យោបាយផ្សេងទៀតដូចជារថភ្លើងក្នុងជាដើម។ តម្រូវការមួយនេះ គឺទាក់ទងនឹងការបង្កើនខ្សែរបណ្តាញរថយន្តក្រុងឱ្យកាន់តែមានភាពទូលំទូលាយ និងមានកាលវិភាគល្អប្រសើរជាងមុន។ បន្ថែមពីនេះ សំណូមពរទាំងនេះបានក្លាយជាតម្រូវការ និងក្តីរំពឹងមួយដ៏ធំពីសំណាក់សិស្សានុសិស្សដែលរស់នៅក្នុងរាជធានីភ្នំពេញ ព្រោះការពង្រឹងផ្នែកសេវាដឹកជញ្ជូនសាធារណៈនេះអាចជួយកាត់បន្ថយការចំណាយលើការធ្វើដំណើររបស់ប្រជាពលរដ្ឋជាពិសេសសិស្សានុសិស្ស និងរួមចំណែកក្នុងការកាត់បន្ថយការកកស្ទះផងដែរ។

## ៥.៥. តម្រូវការផ្នែកច្បាប់ និងសិទ្ធិមនុស្ស

ប្រជាពលរដ្ឋប្រាំរូបក្នុងចំណោមប្រជាពលរដ្ឋ៥៩រូប ដែលរស់នៅក្នុងរាជធានីភ្នំពេញបានធ្វើការស្នើសុំការយកចិត្តទុកដាក់ទាក់ទងនឹងការអនុវត្តច្បាប់ឱ្យមានភាពប្រសើរឡើង ក្នុងនោះមានការរឹតបន្តឹងការអនុវត្តរបស់មន្ត្រីរាជការ ការពិនិត្យមើលទៅលើសណ្តាប់ធ្នាប់ និងរបៀបរៀបរយនានានៅរាជធានីភ្នំពេញ។

ក្រៅពីការរឹតបន្តឹងនិងការត្រួតពិនិត្យកិច្ចការច្បាប់នានា ប្រជាពលរដ្ឋក៏សង្ឃឹមថា ការចូលរួមរវាងគ្រឹះស្ថានឯកជន និងស្ថាប័នរដ្ឋកាន់តែមានការកើនឡើង ដើម្បីជម្រុញការអភិវឌ្ឍនៅក្នុងរាជធានីភ្នំពេញ។

## ៥.៦. តម្រូវការផ្នែកសណ្តាប់ធ្នាប់ និងសន្តិសុខសង្គម

នៅក្នុងពេលមួយរយៈចុងក្រោយនេះ ប្រជាពលរដ្ឋចំនួន១២រូបក្នុងចំណោម៥៩រូបបានធ្វើការស្នើសុំឱ្យមានការយកចិត្តទុកដាក់ឡើងវិញឱ្យកាន់តែខ្លាំងទាក់ទងនឹងការគ្រប់គ្រងសណ្តាប់ធ្នាប់ និងសន្តិសុខសង្គមនេះ។ នៅក្នុងនោះមានប្រជាពលរដ្ឋមួយផ្នែកធំបានអះអាងថា ការលេចឡើងនៃក្មេងទំនើងជាពិសេសនៅពេលយប់បានបង្កភាពអសន្តិសុខ និងសេចក្តីព្រួយបារម្ភដល់ពួកគេក្នុងការធ្វើដំណើរ។ ក្រៅពីនេះ ការប្រើប្រាស់គ្រឿងញៀន និងបារីអគ្គិសនីក៏ជាផ្នែកមួយដែលបង្កជារូបភាពមិនសមរម្យដល់សង្គមផងដែរ។ ដើម្បីដោះស្រាយនៅបញ្ហាទាំងនេះ ប្រជាពលរដ្ឋមួយចំនួនស្នើសុំការចាត់វិធានការផ្សេងៗ និងការពង្រឹងការអនុវត្តឡើងវិញដូចជាគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលជាគោលនយោបាយមួយដ៏មានប្រសិទ្ធិភាពក្នុងពេលកន្លងមក។

## ៥.៧. តម្រូវការផ្នែកចរាចរណ៍

ការធ្វើដំណើរគឺជាសកម្មភាពប្រចាំថ្ងៃមួយដែលប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញត្រូវការជាចាំបាច់ដែលបានក្លាយជាតម្រូវការមួយដែលគួរឱ្យយកចិត្តទុកដាក់ផងដែរ។ នៅក្នុងនោះប្រជាពលរដ្ឋសំណូមការចាត់វិធានការ និងនីតិវិធីផ្សេងៗដើម្បីកាត់បន្ថយការកកស្ទះនៅក្នុងម៉ោងប្រញាប់(Rush Hour) ដូចជានៅពេលព្រឹក និងល្ងាចជាដើម ដែលជាម៉ោងសិស្សានុសិស្ស និងប្រជាពលរដ្ឋចេញពីធ្វើការ។ នៅក្នុងនោះការចាត់វិធានការដែលប្រជាពលរដ្ឋគិតថាមានប្រសិទ្ធិភាពរួមមាន ការដាក់មន្ត្រីចរាចរណ៍នៅតាមផ្លូវដែលមានការកកស្ទះខ្លាំង ការបង្កើតផ្លូវឯកទិស និងការបង្កើនសេវាដឹកជញ្ជូនសាធារណៈ។ ក្រៅពីការតម្រូវការទាក់ទងនឹងការកកស្ទះចរាចរណ៍ ប្រជាពលរដ្ឋមួយផ្នែកទៀតបានសំណូមពរទាក់ទង នឹងការពិនិត្យទៅលើផ្លាកសញ្ញាចរាចរណ៍និងភ្លើងសញ្ញាចរាចរណ៍ ការដាក់កាំមេរ៉ាសម្រាប់ផាកពិន័យ និងផ្សព្វផ្សាយច្បាប់ចរាចរណ៍ឱ្យកាន់តែប្រសើរឡើង ដើម្បីលុបបំបាត់ការបើកបរក្នុងពេលស្រវឹង និងការបើកបរហួសល្បឿនកំណត់។

# ផ្នែកទី៦ សេចក្តីសន្និដ្ឋានលទ្ធផលនៃការសិក្សា

ជាចុងក្រោយ បន្ទាប់ពីបានសិក្សាទៅលើលទ្ធផលដែលទទួលបានមក យើងសង្កេតឃើញចំណុចសំខាន់ៗមួយចំនួនដែលយើងទទួលបាន។ ជាលទ្ធផលទៅតាមគោលដៅទាំងបួននៃការរៀបចំការសិក្សានេះឡើងគឺ ការកំណត់អត្តសញ្ញាណ ចម្លើយទៅតាមអត្តសញ្ញាណ ចម្លើយជារួម និងតម្រូវការជារួម យើងសង្កេតឃើញចំណុចគួរឱ្យកត់សម្គាល់ចំនួនបីគឺ ភាពខុសគ្នារវាងការយល់ដឹងរបស់អ្នកមានការងារធ្វើ និងនិស្សិតទូទៅ កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ និងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ។

នៅក្នុងនោះយើងសង្កេតឃើញថាការយល់ដឹង និងការពេញចិត្តរបស់អ្នកមានការងារធ្វើរួមទាំងនិស្សិតដែលមានការងារធ្វើគឺមានលទ្ធផលល្អប្រសើរជាងនិស្សិតមិនមានការងារធ្វើ ពោលគឺស្ទើតែគ្មានអ្នកដែលមិនពេញចិត្តសោះចំពោះសេវាដែលទទួលបាន។ ក្រៅពីនេះ លទ្ធផលនៃផ្ដត់គំនិតរបស់ប្រជាពលរដ្ឋនិងនិស្សិតដែលមានការងារធ្វើក៏មានលក្ខណៈល្អប្រសើរជាងដែរ។ ចំពោះលទ្ធផលនៃការយល់ដឹងនិងការស្វែងយល់បានបង្ហាញថាប្រជាពលរដ្ឋដែលសិក្សា ឬ/និងធ្វើការទាក់ទងនឹងវិទ្យាសាស្ត្រសង្គមមានលទ្ធផលនៃការយល់ដឹងទាក់ទងនឹងការងាររដ្ឋបាលបានល្អប្រសើរជាង។

ចំពោះការយល់ដឹងជារួមវិញប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញមានការយល់ដឹង និងការស្វែងយល់ស្ថិតនៅក្នុងចំណុចមធ្យម ប៉ុន្តែមានទំនោរទៅកម្រិតខ្សោយដោយលទ្ធផលបង្ហាញថាប្រជាពលរដ្ឋដែលពុំសូវមានការយល់ដឹងមានបរិមាណច្រើនជាងប្រជាពលរដ្ឋដែលមានការយល់ដឹងច្រើន។ យ៉ាងណាមិញ ប្រជាពលរដ្ឋប្រមាណជា៤៥%មានផ្ដត់គំនិត និងយល់ថាការស្វែងយល់ពីការងាររដ្ឋបាលរបស់អាជ្ញាធរមូលដ្ឋានមានសារៈសំខាន់ណាស់ និងលើសពី៩០% ដែលគិតថាការយល់ដឹងមួយនេះមានសារៈសំខាន់។ ដូច្នេះប្រជាពលរដ្ឋមិនដល់១០%នោះទេ ដែលគិតថាការយល់ដឹងពីកិច្ចការងាររដ្ឋបាលមិនមានសារៈសំខាន់។ លទ្ធផលនេះមានបង្ហាញពីការចាប់អារម្មណ៍និងការយល់ដឹងទូទៅមួយចំនួនរបស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ។

ចំពោះតម្រូវការជារួមវិញ លទ្ធផលបានបង្ហាញថាប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញភាគច្រើនមានតម្រូវការជាចាំបាច់ចំពោះផ្នែកសំខាន់បី និងផ្នែកបន្ទាប់បន្សំប្រាំទៀត។ ផ្នែកដែលទទួលបានការចាប់អារម្មណ៍ និងមានតម្រូវការខ្ពស់ទាំងនោះរួមមានសេវារដ្ឋបាល កិច្ចការងារសណ្ដាប់ធ្នាប់និងសន្តិសុខសង្គម និងតម្រូវការទាក់ទងនឹងការរៀបចំក្រុង។ យោងតាមលទ្ធផលដែលទទួលបាន ការអនុវត្តសព្វថ្ងៃមានលក្ខណៈល្អប្រសើរហើយ ប៉ុន្តែវិស័យមួយចំនួននេះគឺជាផ្នែកមួយដែលមានតម្រូវការខ្ពស់ដូច្នេះការកែប្រែ និងការអភិវឌ្ឍឱ្យកាន់តែល្អប្រសើរឡើងនឹងរួមចំណែកក្នុងការកសាងសង្គមជាតិឱ្យឈានទៅមុខកាន់តែឆាប់រហ័ស។

## ប្រភពទិន្នន័យ

- Link ទិន្នន័យដើម៖ https://docs.google.com/spreadsheets/d/14Qd-4FAIvrc2Q6fiKVlA1FLgYtgqC5xJKeMIBkcGnYM/edit?usp=sharing

# ឧបសម្ព័ន្ធទី៦៖

# របាយការណ៍ ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញ ប្រចាំឆ្នាំ២០២៣

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ ស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលរាជធានីភ្នំពេញ ប្រចាំឆ្នាំ២០២៣

១- សកម្មភាពអភិវឌ្ឍន៍សមត្ថភាពតាមការកំណត់របស់ថ្នាក់ជាតិ៖

- មាន ៣ប្រធានបទ (បែងចែកជា ១៣វគ្គ)
- ចំនួនអ្នកចូលរួមសរុប ១.៤៤៨នាក់ (ស្រី ១.០៨៧នាក់)

២- សកម្មភាពអភិវឌ្ឍន៍សមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលរាជធានី ខេត្ត៖

- មាន ១៥ប្រធានបទ (បែងចែកជា ៦១វគ្គ)
- ចំនួនអ្នកចូលរួមសរុប ៧.៤៣៥នាក់ (ស្រី ២.៧៥៧នាក់)

៣- សកម្មភាពអភិវឌ្ឍន៍សមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ៖

- មាន ៤ប្រធានបទ (បែងចែកជា ៨វគ្គ)
- ចំនួនអ្នកចូលរួមសរុប ១.៣៦៥នាក់ (ស្រី ៧៧១នាក់)

៤- សកម្មភាពអភិវឌ្ឍន៍សមត្ថភាពតាមតម្រូវការរបស់រដ្ឋបាលឃុំ សង្កាត់៖

- មាន ១ប្រធានបទ (បែងចែកជា ២វគ្គ)
- ចំនួនអ្នកចូលរួមសរុប ៣៧៨នាក់ (ស្រី ៨៧នាក់)

❖ សរុបជារួម៖ ៨៤វគ្គ

ចំនួនអ្នកចូលរួមសរុប ១០.៦២៦នាក់ (ស្រី ៤.៧០២នាក់)។

# ឧបសម្ព័ន្ធទី៧៖

# របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា

# និងចំណូលប្រចាំឆ្នាំ២០២៣

សាលារាជធានីភ្នំពេញ
អង្គភាពច្រកចេញចូលតែមួយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំឆ្នាំ២០២៣
## អង្គភាពច្រកចេញចូលតែមួយរាជធានី ភ្នំពេញ

| ល.រ | វិស័យ | ត្រីមាសទី១ ឆ្នាំ២០២៣ | | | ត្រីមាសទី២ ឆ្នាំ២០២៣ | | | ត្រីមាសទី៣ ឆ្នាំ២០២៣ | | | ត្រីមាសទី៤ ឆ្នាំ២០២៣ | | | ប្រចាំឆ្នាំ២០២៣ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សេវា | ស្ត្រី | ចំណូល | សេវា | ស្ត្រី | ចំណូល | សេវា | ស្ត្រី | ចំណូល | សេវា | ស្ត្រី | ចំណូល | សេវា | ស្ត្រី | ចំណូល |
| 1 | នីត្យានុកូលកម្ម | 4,107 | 1,909 | 121,109,000 | 3,339 | 1,394 | 111,205,000 | 2,906 | 1,328 | 91,120,000 | 2,589 | 1,174 | 74,821,000 | 12,941 | 5,805 | 398,255,000 |
| 2 | ការងាររដ្ឋបាល | 6 | - | 30,100,000 | 5 | - | 28,500,000 | 6 | - | 42,000,000 | 6 | - | 30,000,000 | 23 | - | 130,600,000 |
| 3 | សុខាភិបាល | 302 | 50 | 116,650,000 | 326 | 48 | 140,930,000 | 314 | 52 | 114,770,000 | 316 | 55 | 116,380,000 | 1,258 | 205 | 488,730,000 |
| 4 | ទេសចរណ៍ | 226 | 63 | 144,758,500 | 141 | 42 | 77,575,000 | 179 | 52 | 104,908,000 | 230 | 59 | 172,335,000 | 776 | 216 | 499,576,500 |
| 5 | សាធារណការ និងដឹកជញ្ជូន | 27 | 8 | 2,046,500 | 26 | 11 | 3,518,000 | 30 | 18 | 4,153,500 | 16 | 6 | 2,880,000 | 99 | 43 | 12,598,000 |
| 6 | វប្បធម៌ និងវិចិត្រសិល្បៈ | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 7 | ព័ត៌មាន | 90 | 50 | 5,160,000 | 62 | 40 | 4,170,000 | 53 | 20 | 2,620,000 | 124 | 37 | 8,570,000 | 329 | 147 | 20,520,000 |
| 8 | បរិស្ថាន | 26 | 9 | 2,900,000 | 28 | 13 | 4,900,000 | 30 | 18 | 3,700,000 | 28 | 17 | 3,100,000 | 112 | 57 | 14,600,000 |
| 9 | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 120 | 27 | 30,800,000 | 112 | 41 | 24,070,000 | 83 | 38 | 29,170,000 | 325 | 54 | 67,965,000 | 640 | 160 | 152,005,000 |
| 10 | រ៉ែ និងថាមពល | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| 11 | ពាណិជ្ជកម្ម | 1 | - | 200,000 | - | - | - | 1 | - | 200,000 | - | - | - | 2 | - | 400,000 |
| 12 | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក)+(ខ) | 9,121 | 1,295 | 3,296,703,700 | 8,512 | 1,207 | 8,553,846,000 | 8,821 | 1,249 | 8,624,538,600 | 8,275 | 1,286 | 4,720,768,100 | 34,729 | 5,037 | 25,195,856,400 |
| | (ក) សំណង់ | 69 | 39 | 170,559,500 | 77 | 41 | 223,756,000 | 88 | 46 | 199,599,700 | 61 | 427 | 173,401,000 | 295 | 553 | 767,316,200 |
| | (ខ) សុរិយោដី | 9,052 | 1,256 | 3,126,144,200 | 8,435 | 1,166 | 8,330,090,000 | 8,733 | 1,203 | 8,424,938,900 | 8,214 | 859 | 4,547,367,100 | 34,434 | 4,484 | 24,428,540,200 |
| 13 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 4,491 | 177 | 120,629,500 | 4,366 | 168 | 115,082,000 | 4,230 | 169 | 106,661,000 | 3,441 | 177 | 88,358,500 | 16,528 | 691 | 430,731,000 |
| 14 | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 29 | 19 | 2,720,000 | 26 | 9 | 2,380,000 | 24 | 3 | 2,240,000 | 24 | 5 | 1,960,000 | 103 | 36 | 9,300,000 |
| | សរុប | 18,546 | 3,607 | 3,873,777,200 | 16,943 | 2,973 | 9,066,176,000 | 16,677 | 2,947 | 9,126,081,100 | 15,374 | 2,870 | 5,287,137,600 | 67,540 | 12,397 | 27,353,171,900 |

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០២៣
[illegible] អភិបាលរាជធានីភ្នំពេញ

ឃួង ស្រេង

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃចន្ទ ១៤កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣
ប្រធានអង្គភាពច្រកចេញចូលតែមួយ

មួក យុទ្ធល័ក្ខ

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣
មន្ត្រីទទួលបន្ទុកបញ្ជា

ហ៊ុ សុផានី

# ឧបសម្ព័ន្ធទី៨៖

# របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំ ឆមាសទី១ ឆ្នាំ២០២៤

សាលារាជធានីភ្នំពេញ
អង្គភាពច្រកចេញចូលតែមួយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបសង្ខេបពីចំនួនសេវា និងចំណូលប្រចាំ ឆមាសទី១ ឆ្នាំ២០២៤
## អង្គភាពច្រកចេញចូលតែមួយរាជធានី ភ្នំពេញ

| ល.រ | វិស័យ | ត្រីមាសទី១ | | | ត្រីមាសទី២ | | | សរុបឆមាសទី១ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សេវា | ស្ត្រី | ចំណូល | សេវា | ស្ត្រី | ចំណូល | សេវា | ស្ត្រី | ចំណូល |
| 1 | នីត្យានុកូលកម្ម | 3,076 | 1,178 | 108,018,000.00 | 2,815 | 661 | 84,918,000 | 5,891 | 1,839 | 192,936,000 |
| 2 | ការងាររដ្ឋបាល | 7 | - | 49,000,000.00 | 17 | 1 | 35,500,000 | 24 | 1 | 84,500,000 |
| 3 | សុខាភិបាល | 336 | 43 | 125,520,000.00 | 288 | 120 | 107,690,000 | 624 | 163 | 233,210,000 |
| 4 | ទេសចរណ៍ | 222 | 70 | 150,564,500.00 | 260 | 74 | 135,700,000 | 482 | 144 | 286,264,500 |
| 5 | សាធារណការ និងដឹកជញ្ជូន | 55 | - | 5,967,000.00 | 37 | 5 | 2,672,000 | 92 | 5 | 8,639,000 |
| 6 | វប្បធម៌ និងវិចិត្រសិល្បៈ | - | - | - | - | - | - | - | - | - |
| 7 | ព័ត៌មាន | 119 | 71 | 7,890,000.00 | 57 | 23 | 3,670,000 | 176 | 94 | 11,560,000 |
| 8 | បរិស្ថាន | 38 | - | 4,800,000.00 | 44 | 4 | 6,600,000 | 82 | 4 | 11,400,000 |
| 9 | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 131 | 53 | 39,590,000.00 | 72 | 31 | 28,830,000 | 203 | 84 | 68,420,000 |
| 10 | រ៉ែ និងថាមពល | 16 | - | 32,000,000.00 | 17 | - | 34,000,000 | 33 | - | 66,000,000 |
| 11 | ពាណិជ្ជកម្ម | 1 | - | 200,000.00 | - | - | - | 1 | - | 200,000 |
| 12 | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក)+(ខ) | 16,756 | 1,546 | 8,525,553,600 | 21,309 | 3,296 | 11,863,195,950 | 38,065 | 4,842 | 20,388,749,550 |
| | (ក) សំណង់ | 83 | 26 | 241,782,900.00 | 67 | 13 | 251,620,700 | 150 | 39 | 493,403,600 |
| | (ខ) សុរិយោដី | 16,673 | 1,520 | 8,283,770,700.00 | 21,242 | 3,283 | 11,611,575,250 | 37,915 | 4,803 | 19,895,345,950 |
| 13 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 3,566 | 175 | 92,419,000.00 | 4,013 | 579 | 88,077,000 | 7,579 | 754 | 180,496,000 |
| 14 | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 7 | - | 560,000.00 | 5 | - | 400,000 | 12 | - | 960,000 |
| សរុបរួម | | 24,330 | 3,136 | 9,142,082,100 | 28,934 | 4,794 | 12,391,252,950 | 53,264 | 7,930 | 21,533,335,050 |

**បានឃើញ និងឯកភាព**
ថ្ងៃសុក្រ ១៤កើតខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២៤
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**បានឃើញ និងពិនិត្យត្រឹមត្រូវ**
ថ្ងៃចន្ទ ១០រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤
**ប្រធានអង្គភាពច្រកចេញចូលតែមួយ**

**ម្ចូក យុទលំក្វ**

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤
មន្ត្រីទទួលបន្ទុកបេឡា

**ហ៊ី សុផានី**

# ឧបសម្ព័ន្ធទី៩៖
# ផែនទីរដ្ឋបាលរាជធានីភ្នំពេញ


ផែនទីរដ្ឋបាលរាជធានីភ្នំពេញ
ព្រំប្រទល់រាជធានីភ្នំពេញ
ព្រំប្រទល់ខណ្ឌ
ព្រំប្រទល់សង្កាត់
Source: Esri, Maxar, GeoEye, Earthstar Geographics, CNES/Airbus DS, USDA, USGS, AeroGRID, IGN, and the GIS User Community

# ឧបសម្ព័ន្ធទី១០៖

# ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ

# ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥
# Land Use Master Plan of Phnom Penh City 2035

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ









## មាត្រដ្ឋានផែនទី

មាត្រដ្ឋាន ១:៥០០០០

0 1,500 3,000 6,000 Meters

មួយសង់ទីម៉ែត្រស្មើនឹង៥០០ម៉ែត្រ
1centimetre equal 500meters

**សន្លឹកប្លង់: ០១**

| | |
|---|---|
| សិក្សាដោយ | : គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ |
| គាំទ្របច្ចេកទេសដោយ | : ទីចាត់ការរៀបចំក្រុង សាលារាជធានីភ្នំពេញ<br>មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ |

យោងស្មារតីអង្គប្រជុំក្រុមប្រឹក្សារាជធានីភ្នំពេញ ចុះថ្ងៃ ១៣ កក្កដា ២០១៦
បានឃើញ និងឯកភាព

ប៉ា សុជាតិវង្ស

អ៊ឹម ឈុនលឹម

# ឧបសម្ព័ន្ធទី១១៖

# រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ

ឯកសារដើម




ឯកសារកែសម្រួល(តាមលំនាំដើមទាំងស្រុង)



ឧបសម្ព័ន្ធទី១២៖

ព្រះរាជក្រឹត្យ នស/រកត/០២២១/១១៥

ចុះនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

( ស្តីពីការតែងតាំងអភិបាលរាជធានីភ្នំពេញ )

# ព្រះរាជក្រឹត្យ

នស/រកត/០២២១/១២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៣៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ឃួង ស្រេង** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ ជាអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចារ.ស.០២២១.១២៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១

# ឧបសម្ព័ន្ធទី១៣៖

# ប្រកាសលេខ ២៧៤៧ ប្រក

# ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១

# ស្តីពី

# ការទទួលស្គាល់សមាសភាពសមាជិក

# ក្រុមប្រឹក្សារាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៦៣៧ ប្រក

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៧៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការកំណត់ការទទួលស្គាល់ និងការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៩/៧៥៥ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងសេចក្តីណែនាំលេខ ០២២ សណន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងសម្រេចលេខ ៣០៣ គ.ជ.ប ស.សរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការទទួលស្គាល់បញ្ជីបេក្ខជនបម្រុងបន្ថែមជួរការសម្រាប់ក្រុមប្រឹក្សារាជធានីភ្នំពេញ

# សម្រេច

**ប្រការ ១.-**

ទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ចំនួន ២៧រូប ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១- ឯកឧត្តម **ម៉ប់ សារិន** | ជាប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២- ឯកឧត្តម **ជួប ខុន** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ៣- លោកជំទាវ **ម៉ុំ ក្រសាល** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ៤- ឯកឧត្តម **ខ៊ែត ចន្ថាឆី** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ៥- ឯកឧត្តម **នុត ជា** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ៦- លោកជំទាវ **យូន គីមនី** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ៧- ឯកឧត្តម **ប៊ី ប្រេម** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ៨- ឯកឧត្តម **ម៉ម យុទ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ៩- ឯកឧត្តម **ឈាភ តាឈាខុន** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១០- ឯកឧត្តម **ម៉ាំ ថាយ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១១- លោកជំទាវ **ជា សុគន្ធ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១២- លោកជំទាវ **កែម រ័ត្នតារា** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១៣- លោកជំទាវ **ចាន់ នីឡា** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១៤- លោកជំទាវ **ម៉ម សុធី** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១៥- ឯកឧត្តម **សេង គួនណា** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១៦- ឯកឧត្តម **សេង រតនៈ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១៧- ឯកឧត្តម **នុយ សុខន** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១៨- ឯកឧត្តម **អ៊ិង ស៊ីផាន** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ១៩- ឯកឧត្តម **តូច ម៉ាល័យ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២០- ឯកឧត្តម **ឡឿក សាមាន** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២១- ឯកឧត្តម **គីម សាខុម** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២២- ឯកឧត្តម **ឈី សុភាព** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២៣- ឯកឧត្តម **ខុន សុភៈ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២៤- ឯកឧត្តម **ស្រ៊ី គីមយុ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២៥- ឯកឧត្តម **កែ ម៉ិនឡេង** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២៦- ឯកឧត្តម **ផន ជាទី** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ |
| ២៧- ឯកឧត្តម **សរ សុខ** | ជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ។ |

**ប្រការ ២.-**

សមាសភាពសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ដូចមានក្នុងប្រការ១ ខាងលើនេះ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**ប្រការ ៣ .-**

រយៈពេលនៃការបំពេញការងាររបស់សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ដូចមានចែងក្នុងប្រការ១ខាងលើ ស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាអាណត្តិទី៣ លើកលែងតែសាមីខ្លួនបាត់បង់សមាជិកភាពពីក្រុមប្រឹក្សាតាមច្បាប់កំណត់។

**ប្រការ ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ .-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ៧ រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អង្គភាពប្រឆាំងអំពើពុករលួយ*
  *(ដើម្បីជូនជ្រាប )*
- *សាមីខ្លួន*
- *ដូចប្រការ ៥*
- *រាជកិច្ច*
- *ឯកសារ - កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី១៤៖

# ប្រព័ន្ធឱីឌីថលសម្រាប់ផ្តល់ព័ត៌មាន

# របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

MOI Mobile App




OWSM Cambodia




គេហទំព័រហ្វេសប៊ុក (Facebok Page)

